Public Disclosure Authorized
Public Disclosure Authorized
Public Disclosure Authorized
Public Disclosure Authorized

34475

# កម្ពុជា

## ការសិក្សាវាយតំលៃផលប៉ះពាល់ជាសក្តានុពលនៃសម្បទានដីសង្គមកិច្ច



ខែធ្នូ ឆ្នាំ២០០៥

ធនាគារពិភពលោក

**EASRD**

RURAL DEVELOPMENT & NATURAL RESOURCES EAST ASIA & PACIFIC REGION



# ប្រទេសកម្ពុជា

# ការសិក្សាវាយតំលៃផលប៉ះពាល់ជាសក្តានុពលនៃសម្បទានដីសង្គមកិច្ច

## របាយការណ៍ចុងក្រោយ

ខែធ្នូ ឆ្នាំ២០០៤


តំបន់អាស៊ីខាងកើត និងប៉ាស៊ីភិច

ធនាគារពិភពលោក

៨១៨ H ផ្លូវ NW

វ៉ាស៊ីតោន DC ២០៤៣៣


ឯកសារនេះត្រូវបានរៀបចំឡើងសំរាប់ធនាគារពិភពលោក ដោយសហប្រតិបត្តិការជាមួយរាជរដ្ឋាភិបាលកម្ពុជា អង្គការGTZ និង អង្គការOxfam GB

## អារម្ភកថា

ឯកសារនេះត្រូវបានរៀបរៀងឡើងដោយ ផ្អែកលើឯកសារការងារដែលរៀបចំដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អង្គការ Oxfam GB និងវិទ្យាស្ថានកសិ-អាជីវកម្មកម្ពុជា (ABiC) ។ ខ្លឹមសារ និងដំណើរការវិភាគផលប៉ះពាល់ភាពក្រីក្រ និងសង្គម (PSIA) បានត្រូវចាត់ចែងរួមគ្នា ដោយដៃគូទាំងអស់ ។ ការគាំទ្រហិរញ្ញវត្ថុសំរាប់ឯកសារការងារផ្សេងៗ ទទួលបានពីធនាគារពិភពលោក អង្គការ GTZ អង្គការ Oxfam GB និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

កិច្ចការនេះគឺធ្វើឡើងដោយយោងតាមកំណត់បង្ហាញស្តីពីគោលគំនិត (Concept Note) មួយ ដែលរៀបចំដោយ **Andreas Groetschel** ហើយដែលបានទទួលអនុលោមភាពពីលោក **Ian Porter** នាយកធនាគារពិភពលោកប្រចាំកម្ពុជា នាពេលកិច្ចប្រជុំស្តីពីការពិនិត្យឡើងវិញលើកំណត់បង្ហាញស្តីពីគោលគំនិត នាថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៣ ។ ក្រុមជំនាញដែលបានពិនិត្យឡើងវិញលើកំណត់បង្ហាញស្តីពីគោលគំនិត រួមមាន **Klaus Deininger** (DECRG) **Gilian Brown** (EASES) និង **Shaun Williams** (ទីប្រឹក្សាគោលនយោបាយដីធ្លី) ។ បន្ថែមលើនេះទៀត មានអ្នកចាប់អារម្មណ៍ និងពាក់ព័ន្ធផ្សេងទៀត ដែលរួមមាន **Kazi Matin** (EACTF) **Guo Li** (EASRD) **William Magrath** (EASRD) **Steven Schonberger** (EASRD) **Il Houng Lee** (IMF) បានផ្ញើចំណាប់អារម្មណ៍ និងយោបល់ជាលាយល័ក្ខណ៍អក្សររបស់គេ មកក្រុមការងារ ។

កិច្ចការនេះត្រូវបានចាត់ចែងភារកិច្ចដោយ **Wael Zakout** (EASRD) ។ ក្រុមគាំទ្រភារកិច្ច រួមមាន **Lars Lund** (EASES) **Chorching Goh** (EASPR) **Marianne Grosclaude** (EASRD) **Malcolm Childress** (ទីប្រឹក្សា EASRD) និង **Aline Coudouel** (PRMPR) ។ ថ្វីត្បិតតែយ៉ាងនេះក្តី និងបន្ថែមលើកិច្ចគាំទ្ររបស់សហការីដែលបានរៀបរាប់ខាងលើ កិច្ចការនេះបានទទួលផលយ៉ាងច្រើនពីតាមរយៈការផ្តល់យោបល់តិទៀនជាប្រចាំ និងការទំនាក់ទំនងយ៉ាងជិតស្និតពីអ្នកពាក់ព័ន្ធ ដែលមានការចាប់អារម្មណ៍ច្រើនរាប់មិនអស់ ពីទីក្រុងវ៉ាស៊ីនតោន និងនៅកម្ពុជា ដែលរួមទាំងពី **Stephen Mink** (EASRD) **Stefano Paternostro** (PRMPR) **Nisha Agrawal** (EASRD) **Mia Hyun** (ទីប្រឹក្សា) ។

ក្រុមការងារដឹងគុណជាពិសេសចំពោះការគាំទ្រ និងការរួមចំណែកដែលទទួលបានពីក្រសួងរៀបដែនដី នគរូបនីយកម្ម និងសំណង់ ដែលមានលោក **សរ សុវណ្ណ** (នាយកគំរោង LAMP) **ឌុច វនទីតូ** អគ្គនាយកទទួលបន្ទុកសម្បទានដីសង្គមកិច្ច អង្គការ GTZ ដែលមាន **Willi Zimmermann** (ទីប្រឹក្សាបច្ចេកទេស GTZ-LMAP) និងអង្គការ Oxfam GB រួមមាន **យន ឌីរ៉ាវី សុង វ៉ាន់ស៊ីន** និង **Mike Bird** ។ ថ្នាក់ដឹកនាំ អ្នកសិក្សាស្រាវជ្រាវ និងបុគ្គលិកនៅមូលដ្ឋានរបស់ស្ថាប័នខាងលើ បានផ្តល់ការគាំទ្រយ៉ាងថ្លៃថ្លា រហូតដល់ចប់ដំណើរការ ។ ជាចុងក្រោយ តែមិនមែនតិចតួចទេ ក្រុមការងារបានធ្វើការវាយតំលៃខ្ពស់ និងសោមនស្សរីករាយជាមួយនឹងភាពស្និតស្នាល បើកចំហ និងភាពទទួលរាក់ទាក់ ដែលយើងបានជួបប្រទះនៅថ្នាក់ភូមិ ស្រុក ខេត្ត និងជាតិ ។ ក្រុមការងារសូមថ្លែងអំណរគុណចំពោះការអត់ធ្មត់ក្នុងការផ្តល់ព័ត៌មានទាំងអស់ ។

ការរួមចំណែកដ៏មានតំលៃពីសំណាក់អ្នកពាក់ព័ន្ធទាំងអស់ ត្រូវបានកត់ត្រាទុកដោយការដឹងគុណ ។

ក្នុងពេលដែលកំពុងបញ្ចប់របាយការណ៍នេះ កិច្ចដំណើរការអនុវត្តកម្មវិធីជីសម្បទានសង្គមកិច្ច បានបោះមួយជំហានទៅមុខយ៉ាងសំខាន់ ។ រាជរដ្ឋាភិបាលកម្ពុជា បានចាប់ផ្តើមរៀបចំគំរោងមួយឈ្មោះ "ការបែងចែកដីធ្លីសំរាប់កិច្ចអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម" (LASED) ។ ក្រុមរៀបចំគំរោង (LASED) ប្រើប្រាស់បណ្តាគំហើញនិងអនុសាសន៏របស់ការវិភាគផលប៉ះពាល់ភាពក្រីក្រ និងសង្គម (PSIA) យ៉ាងល្អិតល្អន់ និងបន្តដំណើរការដែលប្រកបដោយមានតំលាភាព និងការចូលរួម ដែលបានចាប់ផ្តើមឡើងដោយក្រុមវិភាគផលប៉ះពាល់ភាពក្រីក្រ និងសង្គម (PSIA) ។

អត្ថបទការវិភាគផលប៉ះពាល់ភាពក្រីក្រ និងសង្គម (PSIA) លើកដំបូង មានគោលបំណងធំធេងលើសលុបដែលមួយចំនួនមិនអាចសំរេចបានឡើយ ។ បណ្តាការខ្វះខាតចំណេះដឹងទាំងឡាយដែលសេសសល់បន្ទាប់ពីអត្ថបទការវិភាគផលប៉ះពាល់ភាពក្រីក្រ និងសង្គម (PSIA) លើកដំបូង ត្រូវបានបំពេញបន្ថែមដោយបណ្តាការសិក្សាដែលធ្វើឡើងជាផ្នែកមួយនៃកិច្ចរៀបចំគំរោង ។ ក្នុងពេលដែលអត្ថបទការវិភាគផលប៉ះពាល់ភាពក្រីក្រ និងសង្គម (PSIA) ផ្តល់នូវព័ត៌មានយ៉ាងបរិបូណ៏អំពីឧបស័គ្គនៃការអនុវត្តបណ្តាការសិក្សាបន្ថែមនានា នឹងផ្តល់ចំលើយល្អិតល្អន់លើសំណួរ ដូចជា ទំហំដីអប្បបរមា ទិដ្ឋភាពសេដ្ឋកិច្ចនៃអ្នកដែលកំពុង ឬមានសក្តានុពលកាន់កាប់ដីកសិកម្មតូចតាចជាគំរូ យន្តការជាជំរើសនានា និងតំលៃរំពឹងទុកលើការផ្តល់សេវាកម្ម និង ហេដ្ឋារចនាសម្ព័ន្ធអប្បបរមា ជាដើម ។

ការវិភាគផលប៉ះពាល់ភាពក្រីក្រ និងសង្គម (PSIA) ចាំបាច់ត្រូវបានយល់ថាជាល្បាយនៃផលិតផលផង (នោះគឺជារបាយការណ៍នេះ) និងជាដំណើរការមួយផងដែរ ។ ដូច្នេះ ការវិភាគផលប៉ះពាល់ភាពក្រីក្រ និងសង្គម (PSIA) ប្លែកគ្នានឹងការសិក្សាស្តង់ដារនានា ។ ព័ត៌មានត្រូវបានប្រមូល និងចែករំលែក តាមវិធីសាស្ត្រប្រកបដោយមានការចូលរួម និងតំលាភាព ។ ក្នុងន័យនេះ ស្នាដៃដ៏ធំបំផុតរបស់ការវិភាគផលប៉ះពាល់ភាពក្រីក្រ និងសង្គម (PSIA) គឺការផ្តួចផ្តើមកិច្ចពិភាក្សាមួយដ៏បើកចំហ រវាងអ្នកពាក់ព័ន្ធទាំងអស់អំពីកម្មវិធីសម្បទានដីសង្គមកិច្ចដែលបានគ្រោងឡើង ។ ការចងសម្ព័ន្ធភាពដ៏ទូលាយមួយរវាងអ្នកពាក់ព័ន្ធផ្សេងៗ បានត្រូវបង្កើតឡើង ក្នុងអំឡុងកិច្ចប្រជុំ និងសិក្ខាសាលានានា ។ ការយល់ឃើញរួមគ្នារវាងរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងបណ្តាម្ចាស់ជំនួយ លើបញ្ហា សក្តានុពល និងសកម្មភាពដែលទាមទារអោយធ្វើ បានកើតឡើង ។

ដំណើរការដ៏បើកចំហនេះ ត្រូវបានរំពឹងថានឹងបន្តរហូតដល់ការរៀបចំ និងអនុវត្តគំរោង ។ ភាពជាដៃគូថ្មីនេះនឹងសំរបសំរួលការបន្សុទ្ធគោលនយោបាយ និងការចងក្រង និងអនុវត្តគំរោងការបែងចែកដីធ្លីមួយ ដែលដោះស្រាយតំរូវការរបស់អ្នកក្រីក្រនៅជនបទ និងគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជា ក្នុងកិច្ចខិតខំប្រឹងប្រែងកាត់បន្ថយភាពក្រីក្រ និងភាពរីកចំរើនរបស់ខ្លួន ។

ភ្នំពេញ

ខែវិច្ឆិកា ឆ្នាំ២០០៤

# អក្សរកាត់

| អក្សរកាត់ | ជាភាសាអង់គ្លេស | ជាភាសាខ្មែរ |
|---|---|---|
| **ABiC** | Agribusiness Institute Cambodia | វិទ្យាស្ថានកសិ-អាជីវកម្មកម្ពុជា |
| **ADB** | Asian Development Bank | ធនាគារអភិវឌ្ឍន៍អាស៊ី |
| **CDRI** | Cambodian Development Research Institute | វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវ ដើម្បីអភិវឌ្ឍន៍កម្ពុជា |
| **DWG** | District Working Group | ក្រុមការងារថ្នាក់ស្រុក ខណ្ឌ |
| **EIC** | Economic Institute of Cambodia | វិទ្យាស្ថានសេដ្ឋកិច្ចនៃកម្ពុជា |
| **FA** | Farmers Association | សមាគមកសិករ |
| **FELCRA** | Federal Land Consolidation and Rehabilitation Authority | អាជ្ញាធរសហព័ន្ធសំរាប់ការបង្រួបបង្រួម និងការស្តារដីធ្លីឡើងវិញ |
| **FELDA** | Federal Land Development Authority | អាជ្ញាធរសហព័ន្ធសំរាប់អភិវឌ្ឍន៍ដីធ្លី |
| **FGD** | Focus group discussion | ក្រុមគោលដៅសំរាប់ការពិភាក្សា |
| **GTZ** | Deutsche Gesellschaft fuer technische Zusamenarbeit | អង្គការ **GTZ** |
| **HHS** | Household survey | ការអង្កេតតាមគ្រួសារ |
| **IMF** | International Monetary Fund | មូលនិធិរូបិយវត្ថុអន្តរជាតិ |
| **LADIT** | Landlessness and Development Information Tool | ការប្រមូលព័ត៌មានអំពីភាពគ្មានដីធ្លី និងការអភិវឌ្ឍ |
| **LMAP** | Land Management and Administration Project | គំរោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី |
| **MAFF** | Ministry of Agriculture, Forestry and Fisheries | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| **MAG** | Mine Advisory Group | អង្គការ ម៉ែក |
| **MLMUPC** | Ministry of Land Management Urban Planning and Construction | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| **NGO** | Non-governmental organization | អង្គការមិនមែនរដ្ឋាភិបាល |
| **NRM** | Natural resource management | ការគ្រប់គ្រងធនធានធម្មជាតិ |
| **NTFESSD** | Norwegian Trust Fund in the Environmentally and Socially Sustainable Development Department | មូលនិធិស្ថិតក្នុងនាយកដ្ឋានអភិវឌ្ឍន៍សង្គម និងបរិស្ថានប្រកបដោយ ចីរភាពនៃប្រទេសណ័រវេស |
| **NTFP** | Non-timber forest product | អនុផលព្រៃឈើ |
| **PC** | Pagoda Committee | គណៈកម្មការវត្ត |
| **PLUAC** | Provincial Land Use and | គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង |

| អក្សរកាត់ | ជាភាសាអង់គ្លេស | ជាភាសាខ្មែរ |
|---|---|---|
| | Allocation Committee | |
| **PLUP** | Participatory Land Use Planning | ការកសាងផែនការប្រើប្រាស់ដីធ្លីដោយមានការចូលរួម |
| **PRA** | Participatory rural appraisal | ការសិក្សាវាយតំលៃជនបទដោយមានការចូលរួម |
| **PRK/SOC** | Peoples Republic of Kampuchea/State of Cambodia | សាធារណរដ្ឋប្រជាមានិតកម្ពុជា ឬរដ្ឋកម្ពុជា |
| **PRSP** | Poverty Reduction Strategy Paper | ឯកសារយុទ្ធសាស្ត្រកាត់បន្ថយភ ាពក្រីក្រ |
| **PSIA** | Poverty and Social Impact Analysis | ការ វិភាគផលប៉ះពាល់ភាពក្រីក្រ និងសង្គម |
| **RGC** | Royal Government of Cambodia | រាជរដ្ឋាភិបាលកម្ពុជា |
| **RWSS** | Rural Water Supply and Sanitation | ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យនៅជនបទ |
| **SC** | Social Land Concession | សម្បទានដីសង្គមកិច្ច |
| **SLCP** | Social Land Concession Program | កម្មវិធីសម្បទានដីសង្គមកិច្ច |
| **SSLC** | Sub-decree on Social Land Concessions | អនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច |
| **TSU** | Technical Support Unit | អង្គភាពគាំទ្របច្ចេកទេស |
| **UNTAC** | United Nations Transitional Administration for Cambodia | រដ្ឋបាលបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា |
| **VDC** | Village Development Committee | គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ |
| **WB** | World Bank | ធនាគារពិភពលោក |

# មាតិកាអត្ថបទ


អារម្ភកថា ii

អក្សរកាត់ iv

មាតិកាអត្ថបទ vi

របាយការណ៍សង្ខេប ix

**១. សេចក្តីផ្តើម ១**

១.១. គោលនយោបាយដីធ្លី និងការកែទំរង់ដីធ្លីនៅកម្ពុជា ១

១.២. សម្បទានដីសង្គមកិច្ច ៣

១.៣. ការសាកល្បង និងការវាយតំលៃកម្មវិធីសម្បទានសង្គមកិច្ចដែលបានស្នើឡើង ៥

**២. វិធីសាស្ត្រ និងដំណើរការវិភាគផលប៉ះពាល់ភាពក្រីក្រ និងសង្គម ៦**

២.១. ប្រភពដើមនៃសំណើ ៦

២.២. គ្រោងការស្រាវជ្រាវ និងដៃគូ ៦

២.២.១. កំណត់សំគាល់ទស្សនទាន ៦

២.២.២. ក្រុមស្រាវជ្រាវ និងភារកិច្ច ៧

២.៣. វិធីសាស្ត្រ ៨

២.៣.១. ឧបករណ៍ស្រាវជ្រាវ ៩

២.៣.២. ការជ្រើសរើសសំណាក ១០

២.៣.៣. វិធីសាស្ត្រសំរាប់វាយតំលៃភាពគ្មានដីធ្លី (ការប្រមូលព័ត៌មានអំពីភាពគ្មានដីធ្លី និងការអភិវឌ្ឍរបស់អង្គការអុកស្វាមអង់គ្លេស) ១១

២.៣.៤. ការពិគ្រោះយោបល់ និងសិក្ខាសាលានៅក្នុងប្រទេស ១៣

**៣. ការរកឃើញនៃការសិក្សាស្រាវជ្រាវ ១៤**

៣.១. សក្តានុពលនៃភាពក្រីក្រ និងផលប៉ះពាល់សង្គម ១៤

៣.១.១. មុខសញ្ញាទទួលដី-សក្តានុពលនៃអ្នកឈ្នះ និងអ្នកចាញ់ ១៤

៣.១.២. ផលប៉ះពាល់សង្គម ១៨

៣.១.៣. ផលប៉ះពាល់សេដ្ឋកិច្ច ១៨

៣.២. បញ្ហាស្ថាប័ន និងគោលនយោបាយ : ការរៀបចំ និងការអនុវត្តសម្បទានដីសង្គមកិច្ច ១៩

៣.២.១. សមត្ថភាពរបស់ស្ថាប័នដែលមានស្រាប់នៅក្នុងការអនុវត្តកំណែទំរង់ ១៩

៣.២.២. បញ្ហាតម្លាភាព និងគណនេយ្យភាព (សង្គម និងច្បាប់) ២៤

៣.២.៣. យន្តការដោះស្រាយទំនាស់ ២៦

៣.៣. បញ្ហាច្បាប់ ២៨
៣.៤. ភាពអាចរកបាននូវសេវាកម្មគាំទ្រនានា និងហេដ្ឋារចនាសម្ព័ន្ធ ២៩
៣.៤.១. ហេដ្ឋារចនាសម្ព័ន្ធ និងសេវាអប់រំ ៣២
៣.៤.២. ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មថែទាំសុខភាព ៣២
៣.៤.៣. ការផ្គត់ផ្គង់ទឹក ៣៣
៣.៤.៤. ភ្លើងបំភ្លឺ ៣៣
៣.៤.៥ ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មទីផ្សារ និងផ្លូវថ្នល់ ៣៤
៣.៤.៦. ឥណទាន ៣៥
៣.៥. អ្នកផ្តល់សេវាកម្មផ្សេងៗទៀត ៣៥
៣.៥.១. ក្រុមសាសនា ៣៥
៣.៥.២. អង្គការមិនមែនរដ្ឋាភិបាល ៣៦
៣.៥.៣. សមាគមន៍កសិករ ៣៧
៣.៥.៤. គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ ៣៧
**៤. ប្រជាពលរដ្ឋ និងដីធ្លី : ភាពគ្មានដីធ្លី និងដីដែលមានសក្តានុពលសំរាប់ធ្វើការបែងចែក ៣៨**
៤.១. វិសាលភាពនៃភាពគ្មានដីធ្លី ៣៨
៤.១.១. កម្មសិទ្ធិលើដីលំនៅដ្ឋាន ៣៩
៤.១.២. មូលហេតុដែលបណ្តាលអោយមានភាពគ្មានដីធ្លី ៣៩
៤.១.៣. មូលហេតុដែលនាំអោយបាត់បង់ដីធ្លី ៤០
៤.២. ភាពក្រខ្សត់ដីធ្លី ៤០
៤.២.១. មូលហេតុដែលនាំអោយមានភាពខ្វះខាតដីធ្លី ៤១
៤.៣. សក្តានុពលដីសំរាប់សម្បទានសង្គមកិច្ច ៤១
៤.៤. ភាពខុសៗគ្នានៅក្នុងជីវភាពរស់នៅនៃអ្នកដែលខ្វះដីធ្លី និងគ្មានដីធ្លី ៤៣
៤.៥. បញ្ហាទាក់ទងទៅនឹងការគ្មានដីធ្លី ដែលជាលក្ខណៈវិនិច្ឆ័យចំបង ៤៥
**៥. ការវាយតំលៃដំបូងលើការសាកល្បងកម្មវិធីសម្បទានដីសង្គមកិច្ច ៤៧**
**៦. សេចក្តីសន្និដ្ឋាន និងអនុសាសន៍សំរាប់កម្មវិធីសម្បទានដីសង្គមកិច្ច ៤៩**
៦.១. បុរេតំរូវការ និងល័ក្ខខ័ណ្ឌចាំបាច់នានាសំរាប់សម្បទានដីសង្គមកិច្ច ៤៩
៦.២. ទំនាក់ទំនងរវាងសម្បទានដីសង្គមកិច្ច សម្បទានសេដ្ឋកិច្ច និងការធ្វើចំណាត់ថ្នាក់ និងការគ្រប់គ្រងដីរដ្ឋ ៥០

៦.២.១. ការធ្វើចំណាត់ថ្នាក់ និងការគ្រប់គ្រងជីវរដ្ឋ ៥០

៦.២.២. សម្បទានសេដ្ឋកិច្ច ៥០

៦.២.៣. ការគ្រប់គ្រងសហគមន៍ព្រៃឈើ ៥១

៦.៣. ការជាប់ទាក់ទងទៅនឹងបញ្ហា ឬកម្មវិធីដីធ្លីផ្សេងៗទៀត ៥២

៦.៤. ភាពគ្មានដី និងដីដែលអាចមាន ៥៣

៦.៤.១. ការកំណត់អាទិភាព (តំបន់) ៥៣

៦.៤.២. ការតាំងទីលំនៅឡើងវិញ ៥៣

៦.៤.៣. សម្បទានដីសង្គមកិច្ច និងសិទ្ធិដីធ្លីរបស់ប្រជាពលរដ្ឋជនជាតិដើមភាគតិច ៥៤

៦.៥. ការផ្តល់ការគាំទ្រសេវាកម្ម និងហេដ្ឋារចនាសម្ព័ន្ធ ៥៤

៦.៦. បញ្ហាស្ថាប័ន និងការអនុវត្ត ៥៥

៦.៦.១. ថ្នាក់ជាតិ ៥៦

៦.៦.២. ថ្នាក់ខេត្ត ក្រុង ៥៦

៦.៦.៣. ថ្នាក់ស្រុក ខណ្ឌ ៥៦

៦.៦.៤. ថ្នាក់ឃុំ សង្កាត់ និងភូមិ ៥៦

៦.៦.៥. ទិដ្ឋភាពបច្ចេកទេស ៥៧

៦.៦.៦. តួនាទីរបស់រដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ៥៧

៦.៦.៧. ការចូលរួម និងការសំរបសំរួលពីអ្នកផ្តល់ជំនួយ ៥៨

៦.៧. តំរូវការស្រាវជ្រាវបន្ថែម ៥៨

៦.៨. សំណើរនានាសំរាប់ជំហានបន្ទាប់ ៥៩

**ឯកសារយោង** **៦១**

**សេចក្តីបន្ថែម** **៦៥**

សេចក្តីបន្ថែមទី១ : ទិន្នន័យអំពីភាពគ្មានដីធ្លី ៦៦

សេចក្តីបន្ថែមទី២ : ការសិក្សាវាយតំលៃទៅលើសក្តានុពលដីធ្លីដែលអាចរកបាន ៧៦

សេចក្តីបន្ថែមទី៣ : ការយល់ដឹងរបស់អ្នកភូមិ ៨៨

# របាយការណ៍សង្ខេប

## ប្រវត្តិដើម

ការវិភាគផលប៉ះពាល់ភាពក្រីក្រ និងសង្គម (PSIA) នៃកម្មវិធីសម្បទានដីសង្គមកិច្ចកម្ពុជា បានចាប់ផ្តើមក្នុងឆ្នាំសារពើពន្ធ២០០៣ ជាមួយនឹងសំណើរគំរោងសំរាប់ថវិកាក្រោមមូលនិធិស្ថិតក្នុងនាយកដ្ឋានអភិវឌ្ឍន៍សង្គម និង បរិស្ថានប្រកបដោយចីរភាពនៃប្រទេសណ័រវេស (NTFESSD) ។ យោងតាមការពិភាក្សាលើប្រធានបទកែទំរង់គោលនយោបាយ ជាមួយការិយាល័យប្រចាំនៅប្រទេសកម្ពុជា សមាជិករបស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ប្រចាំនៅកម្ពុជា អង្គការ GTZ ក្រុមអង្កេតលើការវិភាគផលប៉ះពាល់ភាពក្រីក្រ និងសង្គម (PSIA) និងជាមួយនឹងក្រុមស្នូលរបស់ធនាគារពិភពលោក ដើម្បីការវិភាគផលប៉ះពាល់ភាពក្រីក្រ និងសង្គម (PSIA) ការសិក្សាស្រាវជ្រាវអំពីសក្តានុពលផលប៉ះពាល់នៃសំណើគំរោងកម្មវិធីបែងចែកដីធ្លី ត្រូវបានសំរេចឡើង ។ បណ្តាកិច្ចកំណែទំរង់នៃគោលនយោបាយដែលបញ្ញត្តិលើលទ្ធភាពប្រើប្រាស់ និងគ្រប់គ្រងធនធានធម្មជាតិ ជាពិសេសអំពីដីសំរាប់កសិកម្មត្រូវបានរំពឹងថា នឹងធ្វើអោយមានការកើនឡើង នូវសក្តានុពល សំរាប់ភាពរីកចំរើនដែលអនុគ្រោះដល់អ្នកក្រីក្រ រួមបញ្ចូលទាំងលទ្ធភាពសំរាប់លើកស្ទួយតំលៃ តាមរយៈការកែច្នៃ ទីផ្សារ និងនាំចេញ ។ ប្រសិនបើអនុវត្តបានស៊ីចង្វាក់ និងស៊ីជំរៅ បណ្តាកំណែរទំរង់ទាំងអស់នោះ ត្រូវបានរំពឹងថា នឹងទទួលបានផលប៉ះពាល់ពីការបែងចែកជាវិជ្ជមាន និងមានឥទ្ធិពលទៅលើការកាត់បន្ថយភាពក្រីក្រយ៉ាងសំខាន់ ។

ក្នុងការគាំទ្រកិច្ចខិតខំរបស់រាជរដ្ឋាភិបាល ដើម្បីកាត់បន្ថយភាពក្រីក្រតាមរយៈធ្វើអោយប្រសើរឡើង នូវលទ្ធភាពប្រើប្រាស់ដីធ្លី ធនាគារពិភពលោក បានចាប់អារម្មណ៍លើការរៀបចំកិច្ចប្រតិបត្តិការវិនិយោគ[១] មួយ ដើម្បីសំរបសំរួលការអនុវត្តពេញលេញនៃកម្មវិធីសម្បទានដីសង្គមកិច្ច ។ ការវាយតំលៃអំពីសក្តានុពលផលប៉ះពាល់នៃបណ្តាសម្បទានដីសង្គមកិច្ច បានបង្កើតជាផ្នែកមួយសំខាន់នៃយុទ្ធសាស្ត្រគាំទ្រយូរអង្វែងរបស់ធនាគារពិភពលោក ដើម្បីកាត់បន្ថយភាពក្រីក្រក្នុងប្រទេសកម្ពុជា ។

## គោលបំណងនៃការសិក្សាស្រាវជ្រាវ

ការវិភាគផលប៉ះពាល់ភាពក្រីក្រ និងសង្គម (PSIA) ផ្តោតអារម្មណ៍លើការយល់ដឹងអំពីផលប៉ះពាល់នៃជំរើសវិធានការណ៍គោលនយោបាយ ដែលអភិបាលលទ្ធភាពប្រើប្រាស់ និងការប្រើប្រាស់ដីធ្លី ។ បណ្តាគោលបំណងជាក់លាក់នៃការសិក្សានេះ គឺដើម្បីកំណត់ភាពក្រីក្រ និងផលប៉ះពាល់សង្គមពីកំណែទំរង់ដីធ្លី ដែលជាការអនុវត្តអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច ភាពដែលអាចសំរេចលទ្ធផលបានពេញលេញ និងការប្តេជ្ញា ដើម្បីអោយការអនុវត្តទទួលបានជោគជ័យ ។

---

[១] ពេលកំពុងសរសេររបាយការណ៍នេះ (ខែតុលា ឆ្នាំ២០០៤) កិច្ចរៀបចំគំរោង "វិភាជន៍ដីធ្លីសំរាប់កិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម" កំពុងតែដំណើរការ ។

## យុទ្ធវិធីសិក្សាស្រាវជ្រាវ (Research Approach)

ការវិភាគផលប៉ះពាល់ភាពក្រីក្រ និងសង្គមនៃកម្មវិធីសម្បទានដីសង្គមកិច្ចកម្ពុជា (SC) ដែលបានគ្រោងឡើង បានដំណើរការនៅចន្លោះខែឧសភា ឆ្នាំ២០០៣ ដល់ខែឧសភា ឆ្នាំ២០០៤ ។ នេះជាកិច្ចអនុវត្តរួមគ្នារវាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អង្គការ GTZ, Oxfam GB វិទ្យាស្ថានកសិ-អាជីវកម្មកម្ពុជា (ABiC) និងធនាគារពិភពលោក ។

### ការរៀបចំកំណត់បង្ហាញស្តីពីគោលគំនិត (Concept Note)

កំណត់បង្ហាញពីគោលគំនិតមួយសំរាប់ការវិភាគផលប៉ះពាល់ភាពក្រីក្រ និងសង្គម (PSIA) ត្រូវបានរៀបចំឡើងក្នុងអំឡុងខែឧសភា ដល់ខែសីហា២០០៣ ។ កំណត់បង្ហាញនោះបានពន្យល់អំពីវិធីសាស្ត្រ ការវិភាគផលប៉ះពាល់ភាពក្រីក្រ និងសង្គម (PSIA) សំរាប់វិភាគកម្មវិធីបែងចែកដីធ្លីដែលបានគ្រោងឡើងនោះ និងគូសវាសអំពីដំណើរការសិក្សាស្រាវជ្រាវប្រកបដោយតំលាភាព មានការចូលរួម និងមានច្រើនវិធីសាស្ត្រ ។ នាថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៣ កំណត់បង្ហាញស្តីពីគោលគំនិត ត្រូវបានពិនិត្យឡើងវិញដោយក្រុមជំនាញ និងទទួលបានអនុលោមភាពពីនាយកធនាគារប្រចាំប្រទេសកម្ពុជា ។

### វិធីសាស្ត្រ

ដើម្បីធានាអោយមានតំណាងពីអ្នកពាក់ព័ន្ធផ្សេងៗគ្នាក្នុងការសិក្សាស្រាវជ្រាវ ក្រុមការងារបានរៀបចំឡើងដោយមានដៃគូការងារមកពីស្ថាប័នផ្សេងៗគ្នា ទទួលយកផ្នែកស្រាវជ្រាវខុសៗគ្នា ដោយយោងតាមបទពិសោធន៍ និងគុណសម្បត្តិមានព្រៀបរបស់ពួកគេ ក្នុងការចូលរួមវាយតំលៃស៊ីជំរៅនៃកម្មវិធីសម្បទានដីសង្គមកិច្ច ។ ការស្រាវជ្រាវនេះបែងចែកជាផ្នែកផ្សេងៗគ្នា ដើម្បីរំលេចឡើងនូវបញ្ហាសំខាន់ៗនៃកម្មវិធីសម្បទានដីសង្គមកិច្ច ។ ការវិភាគត្រូវបានគ្រោង ដើម្បីពិនិត្យមើលលើបញ្ហាសំខាន់ៗចំនួនបួន :

១. សក្តានុពលផលប៉ះពាល់សេដ្ឋកិច្ច និងសង្គមកិច្ច
   - ដោយផ្អែកលើយន្តការអនុវត្តដែលបានស្នើឡើងទាំងនេះ តើនរណានឹងទទួលបានផលពីកម្មវិធីនេះ? តើនរណាជាអ្នកឈ្នះ និងនរណាជាអ្នកចាញ់ ?
   - តើអាចរំពឹងថាមានផលប៉ះពាល់អ្វីលើការកាត់បន្ថយភាពក្រីក្រ? តើផលប៉ះពាល់ទាំងនោះ មានទំហំឬសារៈសំខាន់យ៉ាងដូចម្តេច?

២. ការរៀបចំគំរោងការ និងអនុវត្ត
   - តើមាន ឬគួរមានស្ថាប័នផ្លូវការ មិនផ្លូវការណាខ្លះ ចូលរួមក្នុងការរៀបចំគំរោងការ និងអនុវត្តកំណែទំរង់នេះ ?
   - តើមានស្ថាប័នដ៏ទៃណាទៀតខ្លះ និងថាតើស្ថាប័នទាំងនោះមានការពាក់ព័ន្ធដល់កំណែទំរង់នេះយ៉ាងដូចម្តេច?
   - តើស្ថាប័នទាំងនោះ ធ្វើការមានប្រសិទ្ធភាព និងតម្លាភាពដែរឬទេ ?

៣. ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មបន្ថែមដែលចាំបាច់អោយមាន

- ឈរលើគោលការណ៍មាននិរន្តរភាព សំរាប់ជនក្រីក្រ តើអ្វីដែលចាំបាច់ត្រូវធ្វើ ដើម្បីធានាផលប្រយោជន៍អតិបរមាដែលត្រូវបានទទួលពីកម្មវិធីបែងចែកដីធ្លីនេះ ?
- តើស្ថានភាពហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មបច្ចុប្បន្នយ៉ាងដូចម្តេច ?
- តើមានសេវាកម្មអ្វីផ្សេងទៀត ដែលសំខាន់សំរាប់និរន្តរភាពយូរអង្វែងនៃផលប៉ះពាល់ពីកំណែទំរង់នេះ? តើហេដ្ឋារចនាសម្ព័ន្ធសង្គម មានសារៈសំខាន់អ្វីខ្លះ សំរាប់កម្មវិធី ?

៤. ភាពគ្មានដីធ្លី និងសក្តានុពលដីធ្លីនៅទំនេរ

- តើដីដែលមានសំរាប់ធ្វើការបែងចែកមានប៉ុន្មាន (ពីដីសម្បទានសេដ្ឋកិច្ច ឬកសិកម្ម ដីមិនបានប្រើប្រាស់ ដីដែលស្ថិតក្រោមការកាន់កាប់ដោយកងទ័ព ដីដែលបាន និងកំពុងដោះមីន ដីព្រៃនិងព្រៃដែលរិចរឹល ។ល។) ? តើដីទាំងនេះនៅទំនេរឬ? តើអ្វីទៅដែលជាសក្តានុពលកសិកម្មនៃដីទាំងនោះ? តើមានអ្វីជាទំនាក់ទំនងនៃសំណាកគំរូក្នុងតំបន់ ?
- តើទំហំនៃភាពគ្មានដីមានប៉ុណ្ណា? តើតំរូវការនៃការបែងចែកដីមានប៉ុណ្ណា? តើមានអ្វីជាសំណាកគំរូ ក្នុងតំបន់?
- តើទំហំដីដែលមានទំនេរ ស៊ីសងគ្នានឹងតំរូវការដូចម្តេចដែរ ?

ដំណើរការស្រាវជ្រាវ បានរួមបញ្ចូលជាផ្នែកសំខាន់មួយ គឺការប្រឹក្សាយោបល់ជាដំណាក់កាល១ជាមួយស្ថាប័នរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងម្ចាស់ជំនួយក្នុងជំហានផ្សេង១គ្នានៃការងារអង្កេតលើការវិភាគផលប៉ះពាល់ភាពក្រីក្រ និងសង្គម (PSIA) ។ ប្រធានបទសិក្សាស្រាវជ្រាវ និងវិធីសាស្ត្រ បានត្រូវពិភាក្សាក្នុងសិក្ខាសាលា មុនពេលបញ្ចប់ការធ្វើគំរោងការស្រាវជ្រាវ និងការងារចុះសិក្សានៅមូលដ្ឋាន ។ ក្រុមសិក្សាស្រាវជ្រាវទទួលបានផលប្រយោជន៍ពីការចូលរួមយ៉ាងផុលផុស ពីសំណាក់ស្ថាប័ន កម្ពុជា និងដៃគូអភិវឌ្ឍន៍នានា ។

បន្ថែមទៅលើការវិភាគផ្ទាល់ ឬបឋម របាយការណ៍នេះក៏លើកឡើងនូវទិន្នន័យទីពីរ មានន័យថា ទិន្នន័យវិភាគដែលមានស្រាប់ ឬកំពុងតែដំណើរការទាក់ទងទៅនឹងជីវភាពជនបទ និងដែលពឹងផ្អែកទៅលើដីធ្លី ។ ដៃគូសិក្សាស្រាវជ្រាវ បានផលិតឡើងនូវរបាយការណ៍ផ្ទាល់ខ្លួនដែលក្រោយមក បានបូកបញ្ចូលរួមគ្នាជារបាយការណ៍អង្កេតលើការវិភាគផលប៉ះពាល់ភាពក្រីក្រ និងសង្គម (PSIA) បច្ចុប្បន្ន តាមការចង្អុលបង្ហាញរបស់ទីប្រឹក្សាធនាគារពិភពលោក ។

ដើម្បីអោយបានលទ្ធផលដែលតំណាងអោយកំរិតថ្នាក់ជាតិ ការសិក្សានេះបានអនុវត្តក្នុងតំបន់កសិ្សត្រ-បរិស្ថានទាំងបួន ដែលកំនត់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងឆ្នាំ១៩៨៦ ដោយដំណើរការអង្កេត នៅក្នុងពីរខេត្តដែលជ្រើសរើសឡើងដោយចៃដន្យ ក្នុងតំបន់កសិ្សត្រ-បរិស្ថាននីមួយ១ ។ ការធ្វើការជ្រើសរើសឡើងដោយចៃដន្យ ត្រូវបានប្រើប្រាស់ផងដែរក្នុងការជ្រើសរើសឃុំ ភូមិ និងក្រុមគ្រួសារ ។ ក្នុងខេត្តនីមួយ១ មានឃុំចំនួន៥

ត្រូវបានជ្រើសរើស និងជ្រើសរើសភូមិចំនួន១៥ ក្នុងឃុំនីមួយៗ ។ ក្នុងខេត្តមួយចំនួន ទីណាដែលមានឃុំតូច ការសិក្សាបានធ្វើឡើងនៅគ្រប់ភូមិ ដោយមិនមានការធ្វើការជ្រើសរើសឡើងដោយចៃដន្យឡើយ ហើយភូមិផ្សេងទៀត ត្រូវបានជ្រើសរើសពីឃុំផ្សេងក្នុងខេត្តដដែលទៀតតាមវិធីសាស្ត្រចៃដន្យ ។ ករណីនេះបានធ្វើនៅខេត្តកោះកុង និង ស្ទឹងត្រែង ។ ចុងក្រោយ គ្រួសារចំនួន១០ ក្នុងភូមិនីមួយៗត្រូវបានជ្រើសរើស ដើម្បីធ្វើការអង្កេត ។

ការវិភាគផលប៉ះពាល់ភាពក្រីក្រ និងសង្គម (PSIA) មិនអាចផលិតបាននូវព័ត៌មានដែលគ្រោងទាំងអស់ ដូចដែលបានគូសវាសក្នុងកំណត់បង្ហាញស្តីពីគោលគំនិតឡើយ ។ មិនមានគ្រប់ព័ត៌មាន និងទិន្នន័យដែលបានរំពឹងទុក សំរាប់ការវិភាគទាំងអស់ អាចរកបាន ឬប្រមូលទាន់ពេលវេលានោះទេ ។ ការវិភាគមានកង្វះខាត ក្នុងការធ្វើ បរិមាណភាពលើផលប្រយោជន៍ និងតំលៃ[២] ។ ព័ត៌មានដ៏សំខាន់នេះ នឹងជាលទ្ធផលនៃការសិក្សាដែលបានចាប់ផ្តើម ជាផ្លូវការ ក្នុងក្របខ័ណ្ឌរៀបចំគំរោង "វិភាជន៍ដីធ្លីសំរាប់កិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម" (LASED) ។ ដំណើរការ ដែលមានការកោតសរសើរថា មានតម្លាភាព និងការចូលរួមយ៉ាងជ្រាវជ្រៅ ដែលចាប់ផ្តើម ជាមួយការវិភាគ ផលប៉ះពាល់ភាពក្រីក្រ និងសង្គម (PSIA) នេះ ត្រូវបានរំពឹងថានឹងមានរហូតក្នុងតំណាក់កាលក្រោយៗទៀតនៃ ការរៀបចំ និងអនុវត្តគំរោង ។

## ការរកឃើញចំបងៗ

### ផលប៉ះពាល់ជាសក្តានុពលទៅលើភាពក្រីក្រ និងសង្គម

### ទំហំផលប៉ះពាល់ផ្នែកសង្គម

ជាង៨០ភាគរយនៃប្រជាជនកម្ពុជា រស់នៅក្នុងតំបន់ជនបទ និងពឹងផ្អែកលើកសិកម្ម ។ ក្នុងការអង្កេតលើ ការវិភាគផលប៉ះពាល់ភាពក្រីក្រ និងសង្គម (PSIA) ៨២.៥% នៃអ្នកចូលរួមក្នុងក្រុមគោលដៅសំរាប់ការពិភាក្សា បានរាយការណ៍ពីការពឹងផ្អែករបស់ពួកគេលើផលិតកម្មស្រូវ (និងដំណាំផ្សេងទៀត) ជាសកម្មភាពជីវភាពរស់នៅ បឋម ។ ភាពក្រីក្រសំរាប់គ្រួសារនៅជនបទ ត្រូវបានអោយនិយមន័យ ដោយពួកគាត់ថា គឺគ្មានអ្វីហូបគ្រប់គ្រាន់ សំរាប់រយៈពេលខ្លះៗ ក្នុងមួយឆ្នាំ ។ យោងតាមការអោយនិយមន័យរបស់ពួកគាត់ ការបែងចែកកំរិតនៃភាព ក្រីក្រ មានទ្រង់ទ្រាយប្រហាក់ប្រហែលនឹងភាពគ្មានដីធ្លីផងដែរ ។ ការមានកម្មសិទ្ធិដីមួយដុំ មិនគ្រាន់តែជាកត្តា សន្តិសុខស្បៀងដ៏សំខាន់មួយនោះទេ តែក៏ជាការចូលរួមក្នុងការផ្តល់ដល់គ្រួសារនូវឋានៈសង្គម (ភាពក្រីក្រ) ក្នុង សហគមន៍មួយផងដែរ ។ ស្ថិតនៅក្នុងល័ក្ខខ័ណ្ឌក្របខ័ណ្ឌសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជាបច្ចុប្បន្ន លទ្ធភាពប្រើប្រាស់ដីធ្លី គឺជាសំណាញ់សុវត្ថិភាពសង្គម ដ៏សំខាន់បំផុត នៅតំបន់ជនបទ ។

[២] របាយការណ៍របស់ ភីលីប ឌីហ្វ្រិត (ឆ្នាំ២០០៣) ផ្តល់នូវសក្តានុពលផលប្រយោជន៍ និងយុទ្ធសាស្ត្រជំរើស ។ ទោះយ៉ាងនេះក្តី អ្នកស្រាវជ្រាវមូលដ្ឋាន បានចោទជាសំនួរលើគុណភាពនៃមូលដ្ឋានទិន្នន័យរបស់ការវិភាគរបស់គាត់ ។

មានអ្នកផ្តល់ចំលើយតិចតួចណាស់ដែលមិនឯកភាពជាមួយនឹងលក្ខណៈវិនិច្ឆ័យ[៣] ដែលគ្រោងឡើង សំរាប់ទទួលបានសិទ្ធិជាអ្នកចូលរួមក្នុងកម្មវិធីសម្បទានដីសង្គម ។ ទោះជាយ៉ាងនេះក្តី អ្នកផ្តល់ចំលើយបានដឹងថា លក្ខណៈវិនិច្ឆ័យដែលដាក់មកនេះ នឹងអាចផាត់ចោលក្រុមគ្រួសារក្រីក្រមួយចំនួន ហើយអ្នកចូលរួមខ្លះបានស្នើអោយធ្វើការបើកទូលាយ ឬកែសំរួលការជ្រើសរើសដែលបានគ្រោងនោះ ។ យោងតាមក្រុមគោលដៅសំរាប់ការពិភាក្សា ក្នុងភូមិនានា ប្រជាជនកម្ពុជាមានដើមកំណើតគ្រប់ពូជសាសន៍ ដែលបានដាក់បញ្ចូលក្នុងសហគមន៍ត្រឹមត្រូវហើយ គួរតែផ្តល់លទ្ធភាពអោយចូលរួមក្នុងកម្មវិធី ។ លក្ខណៈវិនិច្ឆ័យនៅក្នុងការជ្រើសរើស ក៏ហាក់ដូចជាមានការរើសអើងប្រឆាំងនឹងគ្រួសារដែលមានមនុស្សតែម្នាក់ផងដែរ ដោយមិនដាក់បញ្ចូលដូចជា "កសិករ" វ័យក្មេងដែលមិនទាន់រៀបការ និងអ្នកភូមិចាស់ៗដែលរស់នៅតែម្នាក់ឯង ។

អ្នកផ្តល់ចំលើយមួយចំនួន មានការព្រួយបារម្ភអំពីការទន្ទ្រានយកដី នៅក្នុងរយៈពេល៥ឆ្នាំ មុនពេលមានសិទ្ធិកាន់កាប់ ។ ការមិនមានលទ្ធភាពជួល ឬបញ្ចាំដីនៅក្នុងរយៈពេលប្រាំឆ្នាំដំបូង ក៏ត្រូវបានមើលឃើញថា ជាបញ្ហាផងដែរ ជាពិសេស នៅពេលមានតំរូវការសាច់ប្រាក់ជាបន្ទាន់ ។ ការចំណាយទាក់ទងនឹងជំងឺ ត្រូវបានលើកឡើងថាជាបញ្ហាចំបង ។ បទពិសោធន៍ដែលបានលើកឡើងដោយ Oxfam បង្ហាញថា ទីផ្សារងងឹត/ក្រៅផ្លូវការសំរាប់ដីសម្បទានសង្គមកិច្ច នឹងអភិវឌ្ឍឡើងយ៉ាងរហ័ស ។ នេះគឺជាបញ្ហាយ៉ាងសំខាន់ ដោយសារការអង្កេត បានរកឃើញថា ក្នុងចំណោម**អ្នកដែលមានសក្តានុពលនឹងទទួលផលពីការបែងចែកដី ចំនួន៩៧ភាគរយ បានជំពាក់បំណុលគេរួចទៅហើយ** ដោយជាមធ្យមបំណុលនេះមានចំនួន ១១៧ ដុល្លារអាមេរិក ។

## ផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុ និងសង្គម

ការសិក្សា និងឯកសារស្រាវជ្រាវដែលមាន បង្ហាញថា ជាមួយនឹងដីដែលអាចប្រើប្រាស់បានសំរាប់ធ្វើស្រែចិញ្ចឹមជីវិត ប្រាក់ចំណូលដែលអាចទទួលបាននៅក្នុងក្របខ័ណ្ឌស្ថាប័ន និងការផ្តល់សេវានៅសព្វថ្ងៃនេះ ស្ថិតនៅចន្លោះមិនលើសពី១០០ ទៅ២០០ដុល្លារអាមេរិក ក្នុងមួយហិកតា[៤] ។ ទិន្នផលស្រូវជាមធ្យម ជិត២តោន ក្នុងមួយហិកតា ដោយកសិករក្រីក្រជាច្រើនទទួលផលស្រូវតែ ១.០០០គ.ក្រ ប៉ុណ្ណោះ ក្នុងមួយហិកតា ចំពោះស្រែដែលមានទឹកស្រោចស្រពអាចទទួលបានរហូតដល់៥តោន ។ កសិករដែលមានផ្ទៃដីតូច ទទួលផលតិចជាងកសិករដែលមានផ្ទៃដីមធ្យម ហើយកសិករដែលមានផ្ទៃដីមធ្យម ក៏ទទួលផលច្រើនជាងកសិករដែលមានផ្ទៃដីធំផងដែរ ។ ក្រៅពីការខ្វះខាតជាទូទៅលើសម្ភារកសិកម្មទំនើប កសិករដែលមានផ្ទៃដីតូច ប្រឈមនឹងបញ្ហាដោយគាត់ត្រូវបង្ខំ

---

[៣] ក).ជាជនជាតិកម្ពុជា និងជារូបវន្តបុគ្គល ។ ខ).ជាមេគ្រួសារដែលមានសមាជិកជាប់ខ្សែលោហិតចាប់ពីពីរនាក់ឡើងទៅ ឬក៏បានរៀបការ ហើយរស់នៅជាមួយគ្នា ។ គ).បំពេញបានលក្ខខ័ណ្ឌហិរញ្ញវត្ថុដែលបង្កើតដោយប្រកាសរបស់ក្រសួងសង្គមកិច្ច ។ ឃ).មិនជាម្ចាស់ដីដែលមានទំហំស្មើ ឬធំជាងដីដែលនឹងផ្តល់ដោយកម្មវិធីសម្បទានដីសង្គមកិច្ច ដែលមានបញ្ជាក់ក្នុងអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច ។ ង).បានត្រៀមខ្លួន មានការប្តេជ្ញា និងអាចចូលរួមក្នុងកម្មវិធីបាន ។

[៤] មធ្យមភាគលំអៀងសរុបសំរាប់ទុនសម្ភារទាប ការផលិតស្រូវរបស់អ្នកមានផ្ទៃដីតូច ។

ចិត្តលក់កំលាំងពលកម្មប្រចាំថ្ងៃ ដើម្បីបំពេញបន្ថែមប្រាក់ចំណូលពីកសិកម្ម ។ ឱកាសលក់កំលាំងពលកម្មនេះ មានលក្ខណៈប្រសើរបំផុតនៅក្នុងរដូវដែលគាត់ត្រូវចំណាយ កំលាំងពលកម្មលើដីស្រែចំការរបស់គាត់ ។ មានវដ្ដដ៏អាក្រក់ដែលធ្វើឱ្យកសិករតូចតាចស្ថិតនៅក្នុងសភាពក្រតោកយ៉ាក ។ ប្រការនេះ មានទំនាក់ទំនងយ៉ាងសំខាន់ជាមួយនឹងទំហំផ្ទៃដីដែលត្រូវបែងចែកក្នុងមួយគ្រួសារ ផ្អែកតាមកម្មវិធីសម្បទានដីសង្គមកិច្ច ។ ផ្ទៃដីត្រូវមានទំហំគ្រប់គ្រាន់សំរាប់ធានាដល់សន្តិសុខស្បៀងនៅក្នុងគ្រួសារ ។ ទំហំដីដែលត្រូវការ អាស្រ័យជាចំបងលើភាពសមស្រប និងផលិតភាពរបស់ដី ប៉ុន្តែមានការបញ្ជាក់ ជាទូទៅថា ផ្ទៃដីដែលបានប្រមើលទុកពី២ ទៅ៤ហិកតា ក្នុងមួយគ្រួសារ មានទំហំមិនគ្រប់គ្រាន់ទេសំរាប់ករណីភាគច្រើនបំផុត ។

**បញ្ហាស្ថាប័ន និងគោលនយោបាយ**

គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង (PLUAC) ត្រូវបានបង្កើតឡើងរួចហើយ នៅក្នុងខេត្តភាគច្រើន។ ស្វ័យវាយតំលៃ បង្ហាញពីទំនុកចិត្តរបស់គណៈកម្មាធិការនេះ ក្នុងការមានលទ្ធភាពបំពេញតួនាទីរបស់ខ្លួននៅក្នុងការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច ។ គណៈកម្មាធិការនេះ មានទំនុកចិត្តតិចតួចទាក់ទងនឹងសមត្ថភាពរបស់ក្រុមគាំទ្របច្ចេកទេស (TSU) ។ **មានតំរូវការជាច្រើនឱ្យមានការបណ្ដុះបណ្ដាល និងការកសាងសមត្ថភាព** ។ ករណីដូចគ្នានេះ ក៏កើតមានឡើងនៅក្នុងក្រុមការងារថ្នាក់ស្រុក ខណ្ឌ (DWG) ផងដែរ ដោយក្រុមការងារនេះ មានចំណេះដឹងដ៏មានកំរិតទាក់ទងនឹងគោលការណ៍ណែនាំ និងនីតិវិធីសំរាប់អនុវត្តសម្បទានដីសង្គមកិច្ច ។ ចំពោះបុគ្គលិកវិញ ក៏មានអតុល្យភាពផ្នែកយែនឌ័រជាដុំកំភួនផងដែរ ។ ជាមធ្យម មានស្ត្រីម្នាក់ នៅក្នុងក្រុមការងារថ្នាក់ស្រុក ខណ្ឌ ដែលចំនួននេះ គឺតិចជាងនៅក្នុងគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុងទៅទៀត ។

ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបានបោះឆ្នោតជ្រើសរើសឡើង (បង្កើតឡើង) នៅខែកុម្ភៈ ឆ្នាំ២០០២ ។ ក្នុងខណៈដែលក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបានប្រមើលមើលថា ជាអ្នកផ្ដួចផ្ដើមកម្មវិធីសម្បទានដីសង្គមកិច្ចនៅថ្នាក់មូលដ្ឋាន ប្រជាជននៅក្នុងភូមិមិនដល់ពាក់កណ្ដាលទេ ដែលបានដឹងពីតួនាទី និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។ ជាមធ្យមមានសមាជិកក្រុមប្រឹក្សាចំនួន៦នាក់ នៅក្នុងក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗ ប៉ុន្តែគ្មានក្រុមប្រឹក្សាឃុំ សង្កាត់ណាដែលមានសមាជិកជាស្ត្រីច្រើនជាងមួយនាក់ឡើយ ។ ក្នុងខណៈដែលសមត្ថភាពរបស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់មានកំរិតនោះ ក្រុមប្រឹក្សាឃុំ សង្កាត់ មានការងារផ្សេងៗទៀត គឺមិនគ្រាន់តែរ៉ាប់រងការទទួលខុសត្រូវ ជាច្រើនរបស់ខ្លួននៅពេលសព្វថ្ងៃនេះប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងត្រូវបំពេញកាតព្វកិច្ចនៅក្នុងគ្រួសាររបស់គាត់ និងការងារផ្សេងទៀតជាមួយភ្នាក់ងារ និងគំរោងនៅមូលដ្ឋាន ។ ជាមួយនឹងបញ្ហាប្រឈមទាំងនេះ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់តិចជាងពាក់កណ្ដាល មានជំនឿថា គាត់អាចបំពេញការងារទាំងអស់ ដែលនឹងត្រូវប្រគល់ឱ្យគាត់ អនុលោមតាមកម្មវិធីសម្បទានសង្គម ។ **ឧបសគ្គធំបំផុតចំពោះការ**

ចូលរួមចំណែកប្រកបដោយអត្ថន័យ ពីសំណាក់ក្រុមប្រឹក្សាឃុំនៅក្នុងវិស័យគ្រប់គ្រងធនធានធម្មជាតិជាពិសេសនៅក្នុងការកសាងផែនការ និងការអនុវត្តសម្បទានដីសង្គមកិច្ច គឺការខ្វះសមត្ថភាពនៅថ្នាក់ឃុំ ការមានច្បាប់ និងបទបញ្ញាមិនពេញលេញ និងកិច្ចសហប្រតិបត្តិការទន់ខ្សោយនៅក្នុងចំណោមស្ថាប័នរដ្ឋាភិបាល ។

ការពិភាក្សានៅតាមថ្នាក់នានានៅក្នុងអំឡុងពេលនៃការសិក្សាវិភាគផលប៉ះពាល់ភាពក្រីក្រ និងសង្គម (PSIA) បានបង្ហាញថា អ្នកចូលរួមនៅក្នុងការសិក្សាភាគច្រើនបំផុត (ជាង៩០ភាគរយ) បាននិយាយថា ការរួមចំណែកពីសំណាក់ក្រុមក្រៅផ្លូវការនៅមូលដ្ឋាន គឺជាការចាំបាច់ ដើម្បីធានាឱ្យមានប្រសិទ្ធិភាព ភាពត្រឹមត្រូវ ភាពដែលអាចទទួលយកបាន តម្លាភាព និងគណនេយ្យភាពនៃកម្មវិធី ។ ក្រុមក្រៅផ្លូវការដែល គួររួមចំណែកនៅក្នុងដំណើរការ និងការអនុវត្តសម្បទានដីសង្គមកិច្ច ដូចដែលអ្នកចូលរួមនៅក្នុងការសិក្សា បានលើកឡើងរួមមាន គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (VDC) (ii).អង្គការមិនមែនរដ្ឋាភិបាល (NGO) (iii).សមាគមកសិករនៅមូលដ្ឋាន (FA) (iv).គណៈកម្មការវត្ត (PC) (v).គណៈកម្មការសាសនា និង (vi).គណៈកម្មការសាលារៀន/មាតាបិតាសិស្ស ។ មានការសង្កេតឃើញថា អ្នកផ្តល់ព័ត៌មានជាច្រើននៅក្នុងគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីធ្លីខេត្ត ក្រុង (PLUAC) ក្រុមការងារថ្នាក់ស្រុក ខណ្ឌ (DWG) ក្រុមគោលដៅសំរាប់ការពិភាក្សា (FGD) និងការអង្កេតតាមគ្រួសារ (HHS) ហាក់ដូចជាគាំទ្រការចូលរួមឱ្យបានកាន់តែច្រើនពីសំណាក់ គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ និងអង្គការមិនមែនរដ្ឋាភិបាល នៅក្នុងការងារភាគច្រើនបំផុតដែលទាក់ទងនឹងក្រុមផ្សេងទៀត ។

គេអាចសង្កេតឃើញនិន្នាការជាទូទៅថា រដ្ឋបាលថ្នាក់លើ វាយតំលៃខ្ពស់ហួសលើសមត្ថភាពរបស់ថ្នាក់វិមជ្ឈការ ។ ជារួម បទបញ្ជាដែលមានបំណងគ្រប់គ្រងកម្មវិធីសម្បទានសង្គម ស្របជាមួយនឹងច្បាប់វិមជ្ឈការ និងការប្រគល់ភារកិច្ចដល់ស្ថាប័នរដ្ឋាភិបាលបែបវិមជ្ឈការ ។ ទោះជាយ៉ាងណាក៏ដោយ ល័ក្ខខ័ណ្ឌដំបូងសំរាប់ជំរុញកម្មវិធី ឱ្យអនុវត្តហួសពីកន្លែងសាកល្បងនោះ គឺការមានបទបញ្ញត្តិច្បាប់ច្បាស់លាស់ និងការអនុវត្តបទបញ្ញត្តិនេះ ។ មានតំរូវការជាបន្ទាន់ឱ្យមានអនុក្រឹត្យស្តីពីការធ្វើសារពើភ័ណ្ឌ និងការគ្រប់គ្រងដីរដ្ឋ ការអនុវត្តសម្បទានសេដ្ឋកិច្ចដែលមិនបានប្រើប្រាស់ ការយកពន្ធលើដីដែលគាំទ្រជនក្រីក្រ និង បទបញ្ជាដែលអាចអនុវត្តបានសំរាប់ស្តារដីរដ្ឋ (ច្បាប់ភូមិបាលឆ្នាំ២០០១ មាត្រា១៨) ។

### សេវាគាំទ្រ និងហេដ្ឋារចនាសម្ព័ន្ធ

ការបែងចែកដីនេះផ្ទាល់ ហាក់ដូចជាមិនមានផលប៉ះពាល់ជាដុំកំភួនលើការកាត់បន្ថយភាពក្រីក្រនៅតំបន់ជនបទនៅកម្ពុជាឡើយ ។ ទោះជាយ៉ាងណាក៏ដោយ ការបែងចែកដីនៅក្រោមកម្មវិធីសម្បទានសង្គម ត្រូវបានរំពឹងថា នឹងមានអម ហើយបំពេញបន្ថែមដោយការផ្តល់សេវាគាំទ្រ និងហេដ្ឋារចនាសម្ព័ន្ធក្នុងកំរិតអប្បបរមា ។ ដោយពិនិត្យមើលជាពិសេសទៅលើការកែលំអការផលិតស្រូវ លទ្ធផលអង្កេត និងប្រភពព័ត៌មានទីពីរ លើកឡើងថា កត្តាកំណត់ចំបង គឺលទ្ធភាពទទួលបានទុន និងការផ្សព្វផ្សាយកសិកម្ម ។ លទ្ធភាពទទួល និងប្រើប្រាស់

ផ្តល់ផលប្រយោជន៍មិនត្រឹមតែដល់អ្នកចូលរួមនៅក្នុងសម្បទានដីសង្គមកិច្ចប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដល់ប្រជាជននៅជនបទយ៉ាងទូលំទូលាយ ។

អ្នកចូលរួមនៅក្នុងការវិភាគផលប៉ះពាល់ភាពក្រីក្រ និងសង្គម (PSIA) ភាគច្រើន (៧០-៩០ ភាគរយ) បានចាត់ទុកថា សាលារៀន និងការអប់រំ ទឹកនិងអនាម័យ មណ្ឌលសុខភាពនិងការថែទាំសុខភាព ផ្លូវថ្នល់ ទីផ្សារ/ទំនាក់ទំនង និងមជ្ឈមណ្ឌល/សេវាសាសនា មានសារៈសំខាន់ក្នុងការធ្វើឱ្យកម្មវិធី មានលក្ខណៈទាក់ទាញ ផលប៉ះពាល់របស់កម្មវិធីមាននិរន្តរភាព ហើយការកាត់បន្ថយភាពក្រីក្រអាចសំរេចទៅបាន ។ **សារៈសំខាន់នៃសេវាសុខភាព ត្រូវការឱ្យមានការយកចិត្តទុកដាក់ពិសេសនៅក្នុងបរិបទភាពគ្មានដីធ្លី** ។ ក្រៅពីនេះជនក្រីក្រ និងអ្នកគ្មានដីធ្លី ត្រូវមានលទ្ធភាពទទួលបានបច្ចេកវិទ្យា ការផ្សព្វផ្សាយ ឧករណ៍កសិកម្ម និងទុនផ្សេងទៀតដែលអាចមានរូបភាពជាកញ្ចប់ជំនួយបឋម ។ អ្នកឆ្លើយសំណួរភាគច្រើនបំផុត បានសំដែងពីការមិនពេញចិត្ត ចំពោះលទ្ធភាពប្រើប្រាស់ និង/ឬ គុណភាពនៃសេវា និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រផ្នែកសង្គម និងផលិតកម្មដែលមានស្រាប់ ។ ការវាយតំលៃនៅថ្នាក់ភូមិលើការគ្របដណ្តប់ និងគុណភាពមានកំរិតទាប ហាក់ដូចជាមានសភាពធ្ងន់ធ្ងរ បើប្រៀបធៀបនឹងការយល់ឃើញរបស់បុគ្គលិកខេត្ត ក្រុង ឬស្រុក ខណ្ឌ ។

មានការសង្កេតឃើញគួរឱ្យចាប់អារម្មណ៍ទាក់ទងនឹង**សេវាឥណទាន** ។ ក្នុងខណៈដែលត្រូវកំណត់ដោយការសិក្សាមួយចំនួនថា ជាចំណុចគន្លឹះចំពោះការកែលំអផលិតភាព តាមរយៈលទ្ធភាពទទួលបានទុន **អ្នកភូមិមួយចំនួន បានលើកឡើងពីកង្វល់ថា បំណុលជាបន្តបន្ទាប់ក្នុងករណីដំណាំមិនបានផល នឹងជំរុញឱ្យមានការបាត់បង់ដីធ្លី** ។ លទ្ធភាពប្រើប្រាស់សេវាឥណទានផ្លូវការ និងក្រៅផ្លូវការ ត្រូវបានរាយការណ៍ថា មានចំនួន ៥៨ និង៥០ភាគរយ ។ អត្រាការប្រាក់ ត្រូវបានរាយការណ៍ថា នៅក្នុងឥណទានក្រៅផ្លូវការ (១១ភាគរយ) មានកំរិតខ្ពស់ជាងឥណទានផ្លូវការ (៤ភាគរយ) ។

នៅក្នុងភូមិភាគច្រើន សេវាការងារអភិវឌ្ឍន៍ ត្រូវបានគាំទ្រតាមរយៈគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ សមាគមសាសនា (គណៈកម្មការវត្ត) និងអង្គការមិនមែនរដ្ឋាភិបាល ។ ក្នុងចំណោមភូមិនៅក្នុងការសិក្សាវិភាគផលប៉ះពាល់ភាពក្រីក្រ និងសង្គម (PSIA) មានភូមិចំនួន៨០ភាគរយ បានរាយការណ៍ថា មានអង្គការមិនមែនរដ្ឋាភិបាលយ៉ាងតិចមួយ កំពុងដំណើរការនៅក្នុងភូមិរបស់ខ្លួន ។ ជាមធ្យមមានអង្គការមិនមែនរដ្ឋាភិបាលចំនួន ១,៨ កំពុងដំណើរការនៅក្នុងភូមិមួយ ។ ការចូលរួមជាចំបងរបស់អង្គការមិនមែនរដ្ឋាភិបាលទាំងនេះ គឺនៅក្នុងសេវាសង្គម និងប្រតិបត្តិការឥណទាន ។

### វិសាលភាពនៃភាពគ្មានដី

សំរាប់គោលបំណងនៃរបាយការណ៍នេះ "ភាពគ្មានដីធ្លី" ត្រូវបានកំណត់ថាជាការមិនមានដីកសិកម្ម និងការមិនមានមធ្យោបាយសំរាប់ទិញដីនេះ ។ ភាពក្រីក្រដី ត្រូវបានកំណត់ថា ជាការមិនមានដីគ្រប់គ្រាន់ ។ ការប៉ាន់ប្រមាណដីទំហំមួយភាគប្រាំមួយហិកតាក្នុងសមាជិកគ្រួសារម្នាក់ ត្រូវបានប្រើប្រាស់ ហើយកែតំរូវទៅតាម

គុណភាពដីកសិកម្មនៅក្នុងភូមិនីមួយៗ ។

ការអង្កេតរបស់ Oxfam បានបង្ហាញថា ក្នុងចំណោមគ្រួសារទាំង ២២.១៩៣ នៅក្នុងតំបន់គំរូ **គ្រួសារចំនួន ១១,៦ភាគរយ គ្មានដី** ។ ក្នុងចំណោមគ្រួសារទាំង ៣.៩៧៣ ដែលមានស្ត្រីជាមេគ្រួសារនៅ ក្នុងគំរូគ្រួសារចំនួន ១៨,៩ ភាគរយ ត្រូវបានរកឃើញថា គ្មានដី ។ គ្រួសារចំនួន ៤.៦ ភាគរយ ត្រូវបានរកឃើញថាក្រដី ។ នៅក្នុងគំរូទាំងមូល ភាពគ្មានដី មានលក្ខណៈទូទៅជាងភាពក្រដី ។ ក្នុងចំណោមគ្រួសារគ្មានដីទាំង ២.៦៤១ នៅក្នុងគំរូគ្រួសារចំនួន៣២ភាគរយ មានដីលំនៅឋាន រីឯ ៦៨ ភាគរយទៀត មិនមានទេ ។ លទ្ធផលពីការអង្កេតរបស់វិទ្យាស្ថានកសិ-អាជីវកម្មកម្ពុជា (ABiC) បង្ហាញពីអត្រាភាពគ្មានដីក្នុងកំរិតខ្ពស់ជាងតែបន្តិច គឺ ១៤,៦ភាគរយ ។ អត្រាខ្ពស់បំផុត ត្រូវបានរកឃើញនៅតំបន់ទន្លេសាប ។ **អត្រាភាពគ្មានដី មានការប្រែប្រួលយ៉ាង ខ្លាំងនៅក្នុងចំណោមភូមិ** ដោយការប្រែប្រួលខ្ពស់បំផុត ត្រូវបានរកឃើញនៅតំបន់ឆ្នេរសមុទ្រ ។ ភាពគ្មានដីនៅក្នុងកំរិតទាំងនេះ មានលក្ខណៈស្របទៅនឹងព័ត៌មានដែលឃើញមាននៅក្នុងមូលដ្ឋានទិន្នន័យ និងគំរោងស្រាវជ្រាវសំខាន់ៗផ្សេងទៀត ។

ក្នុងចំណោមប្រជាជនដែលគ្មានដីទាំងអស់ ប្រជាជនចំនួន៨០ភាគរយ មិនធ្លាប់មានដីនៅក្នុងភូមិរបស់ខ្លួនឡើយ ហើយប្រជាជន២០ភាគរយទៀត ធ្លាប់មានដីពីមុនមក ប៉ុន្តែបានបាត់បង់ដីនេះ ។ មនុស្សពីរប្រភេទ នៅក្នុងចំណោមអ្នកដែលមិនធ្លាប់មានដីសោះ គឺប្តីប្រពន្ធដែលមិនបានទទួលការបែងចែកដី នៅពេលគាត់រៀបការ (៣៣,៥ភាគរយ) និងគ្រួសារដែលបំលាស់ទីចូលមកក្នុងភូមិរបស់ខ្លួន (៣៣,៤ភាគរយ) ។ ក្នុងចំណោមគ្រួសារដែលបាត់បង់ដីរបស់ខ្លួន **គ្រួសារភាគច្រើន (៦០ភាគរយ) បានរាយការណ៍ពីការចំណាយលើសុខភាពដោយសារជំងឺនៅក្នុងគ្រួសារថាជាបុព្វហេតុចំបងដែលធ្វើឱ្យគាត់បាត់បង់ដីរបស់ខ្លួន ។**

និន្នការប្រជាសាស្ត្រ បង្ហាញថា ភាពគ្មានដី នឹងបន្តកើនឡើង ។ ការព្យាករណ៍ដោយផ្អែកលើក្រុមគោលដៅសំរាប់ការពិភាក្សា បង្ហាញអត្រា១៦ភាគរយ នៅឆ្នាំ២០០៥ ។ ក្រៅពីនេះ គ្រួសារដែលបាត់បង់ដីរបស់ខ្លួនទាំងនេះ អ្នកដែលទទួលរងខ្លាំងក្លាបំផុតដោយនិន្នាការប្រជាសាស្ត្រ គឺទំនងជាគូស្រករវ័យក្មេងដែលទើបតែរៀបការរួចហើយ មិនអាចមានដីចែកឱ្យគាត់ ។

### ដីទំនេរ

នៅក្នុងក្រុមគោលដៅសំរាប់ការពិភាក្សា និងការអង្កេតតាមគ្រួសារ មាន**ភូមិតែ៣៣ភាគរយប៉ុណ្ណោះដែលរាយការណ៍ថា គាត់មានដីទំនេរ ដែលជាតំបន់ព្រៃឈើរេចរិលមិនបានប្រើប្រាស់ និង/ឬដីដាំដំណាំដែលមិនបានប្រើប្រាស់** ។ ភូមិចំនួន៥៣ភាយរយ បានរាយការណ៍ថា តំបន់ព្រៃឈើមាននៅក្នុងសហគមន៍របស់គាត់ ។ ទំហំដីទំនេរ និងដីព្រៃ មានការប្រែប្រួលពីភូមិមួយទៅភូមិមួយទៀត ។ តួលេខដែលបានបញ្ជាក់ មានចាប់ពី ០ ទៅជាង៤០០០ហិកតា នៅក្នុងឃុំនីមួយៗ ។ នៅតំបន់ទន្លេមេគង្គ គ្មានភូមិណាមួយដែលរាយការណ៍ពីការមានដីទនេរ ឬដីព្រៃនៅក្នុងភូមិរបស់ខ្លួនឡើយ ។ ដីមានទំហំធំ ហើយត្រូវបានរាយការណ៍ថានៅទំនេរ គឺនៅតំបន់

ឥសាន្ត និងតំបន់ឆ្នេរ ។ គេគួរកត់សំគាល់ថា យន្តការតាមផ្លូវច្បាប់ក្នុងការបំប្លែងទ្រព្យសម្បត្តិរដ្ឋដែល "នៅទំនេរ" ទាំងនេះ នៅមិនទាន់បានបង្កើតឡើងពេញលេញនៅឡើយ ។ ព័ត៌មាននេះ ស្ថិតនៅក្នុងវិធីសាស្ត្រទីមួយដែលបានប្រមូលនៅក្នុងក្រុមគោលដៅសំរាប់ការពិភាក្សា នៅថ្នាក់ភូមិ ហើយនៅមិនទាន់បានផ្ទៀងផ្ទាត់នៅឡើយ ។

ទោះបីមានដីទំនេរត្រូវបានរាយការណ៍នៅក្នុងភូមិមួយចំនួនក្តី ក៏មិនមានប្រជាជនគ្រប់រូប បានយល់ព្រមថា ដីទាំងនេះអាច/គួរបំប្លែងឡើយ ។ ក្នុងខណៈដែលការសំភាសន៍ជាមួយគ្រួសារនីមួយៗ គេកំរនឹងលើកឡើងពីបញ្ហាដែលគ្រួសារភាគច្រើននៅក្នុងក្រុមគោលដៅសំរាប់ការពិភាក្សា បានសំដែងកង្វល់ថា ការបំប្លែងដីទំនេរនៅក្នុងភូមិរបស់ខ្លួន នឹងនាំឱ្យមានផលបះពាល់ជាអវិជ្ជមានលើការប្រកបរបរចិញ្ចឹមជីវិតរបស់គាត់ និងបរិស្ថាននៅមូលដ្ឋាន ។ ប្រភេទ និងទំហំនៃផលប៉ះពាល់ មានការប្រែប្រួលពីភូមិមួយទៅភូមិមួយទៀត ។ មានការលើកឡើងពីកង្វល់ទាក់ទងនឹងការបំប្លែងដីព្រៃ (ផលប៉ះពាល់បរិស្ថាន ផលប៉ះពាល់លើការប្រមូលផល និងអនុផលព្រៃឈើ) និងការបំប្លែងតំបន់វាលស្មៅ (ធនធានទ្រព្យសម្បត្តិរួម) ។ អ្នកភូមិយល់ថា ការបំប្លែងតំបន់ទាំងនេះទៅជាការប្រើប្រាស់ឯកជន នឹងរារាំងលទ្ធភាពប្រើប្រាស់ធនធាន ដែលអ្នកក្រីក្រ (អ្នកគ្មានដីធ្លី) ភាគច្រើនបំផុតពឹងផ្អែក ។

អ្នកភូមិភាគច្រើន ដែលភូមិរបស់ខ្លួនមានដីទំនេរ ហើយដែលគាត់គិតថា អាចបំប្លែងបាន បានយល់ព្រមថា គាត់អាចទទួលយកអ្នកតាំងទីលំនៅថ្មី ។ ពួកគាត់ត្រៀមខ្លួនទទួលអ្នកគ្មានដីដែលនឹងតាំងទីលំនៅ នៅក្នុងក្របខ័ណ្ឌកម្មវិធីសម្បទានដីសង្គមកិច្ច ។ ទោះជាយ៉ាងណាក៏ដោយ ប្រជាជនខ្លះ មានការរារែក ដោយអះអាងថា អ្នកគ្មានដីនៅក្នុងមូលដ្ឋាន គួរទទួលបានការយកចិត្តទុកដាក់នៅក្នុងអំឡុងពេលបែងចែកដី ។ ជាត្រលប់ទៅវិញ **អ្នកគ្មានដីចំនួន៧០ភាគរយ នៅកន្លែងផ្សេងៗ មានបំណង និងបានត្រៀមខ្លួនទៅរស់នៅកន្លែងណា ដែលគាត់អាចប្រកបរបរចិញ្ចឹមជីវិតបានប្រសើរដោយផ្អែកលើដី** ។ អ្នកគ្មានដីជិត៩០ភាគរយ នឹងទៅរស់នៅកន្លែងណាក៏បាននៅក្នុងប្រទេសកម្ពុជា ។ មានអ្នកគ្មានដីជាច្រើននាក់ហើយបាន ធ្វើដំណើរពាសពេញប្រទេស ដើម្បីស្វែងរកដី និងជំរើសនៅក្នុងការប្រកបរបរចិញ្ចឹមជីវិត ។

លទ្ធផលពីការសិក្សារបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្តីពីសក្តានុពលដីធ្លីនៅទំនេរ បានផ្តល់ពន្លឺជាច្រើន នៅក្នុងទស្សនៈអំពីដីដែលអាចប្រើប្រាស់បាន និងដីដែលអាចបំប្លែងបាន ។ ការអង្កេតរបស់ក្រសួងជាមួយមេឃុំ និងមនុស្សចាស់ៗ នៅក្នុងភូមិ បានបង្ហាញតែដីតិចតួច ទាក់ទងនឹងទំហំ និងគុណភាពដែលបានត្រៀមទុកសំរាប់ធ្វើការបែងចែកក្រោមកម្មវិធីសម្បទានដីសង្គមកិច្ច ។ ដីដែលបានកំណត់ មានលើកឡើងពីមូលហេតុនានា ជាពិសេសគឺមានលក្ខណៈមិនសមស្របសំរាប់ការប្រកបកសិកម្ម ទ្រង់ទ្រាយតូចប្រកបដោយចិរភាព ។

## អនុសាសន៍សំរាប់កម្មវិធីសម្បទានដីសង្គមកិច្ច

កម្មវិធីសម្បទានដីសង្គមកិច្ចដែលផ្តោតលើភាពក្រីក្រ នឹងត្រូវដោះស្រាយបញ្ហាចំនួនបីជុំវិញការផ្តល់លទ្ធភាពអោយជនក្រីក្រក្នុងការទទួលបានដីធ្លី គឺ (១).**មានគ្រួសារក្រីក្រដែលគ្មានដី** (២).**មានគ្រួសារក្រីក្រដែលបាត់បង់ដីរបស់ខ្លួន** និង (៣).**មានដីដែលគ្មានមនុស្ស** ។ ក្នុងករណីមានសេវាគាំទ្រដែលត្រូវការ ការធ្វើអោយធនធានដីដែលមិនបានប្រើប្រាស់/ប្រើប្រាស់តិចតួចទៅជាដីសំរាប់ផលិតកម្មឡើងវិញ និងការផ្តល់លទ្ធភាពអោយក្រុមជនក្រីក្របានចូលរួមនៅក្នុងផលប្រយោជន៍ជាអ្នកម្ចាស់ដី នឹងរួមចំណែកដល់កំណើនកសិកម្មដែលគាំទ្រជនក្រីក្រ ។

## ភាពគ្មានដី និងដីទំនេរ

### ការកំណត់អាទិភាព (នៅក្នុងតំបន់)

នៅពេលអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចយ៉ាងពេញលេញ ធនធានដ៏មានកំរិតដែលអាចប្រើប្រាស់ នឹងត្រូវចំណាយអនុលោមទៅតាមអាទិភាពដែលផ្អែកលើលក្ខណៈវិនិច្ឆ័យដែលបានឯកភាពរួមគ្នា ។ នៅពេលដំបូង ការអនុវត្តអាចផ្តោតទៅលើតំបន់ដែលភាពគ្មានដីមានកំរិតខ្ពស់ ហើយមានប្រាក់កំរៃដ៏មានកំរិត ។ ដោយសារការប្រកួតប្រជែងយកដី មានសភាពខ្លាំងក្លាបំផុត ការគាំទ្រចំពោះអ្នកគ្មានដី គឺជាការចាំបាច់បំផុត ។ ជំរើសមួយទៀតអាចបន្តបែងចែកជាទ្រង់ទ្រាយធំនៅក្នុងតំបន់ដែលមានដីទំនេរ ដោយគ្មានបញ្ហាធំដុំ ។ ការធ្វើបែបនេះ អាចពង្រីក និងកែលំអថែមទៀតនូវបទពិសោធន៍ផ្នែកស្ថាប័ននៅក្នុងការអនុវត្តកម្មវិធី ។ ជំរើសទីបី អាចជាការជ្រើសរើសតំបន់ដែលមានគំរោង/អ្នកផ្តល់ជំនួយកំពុងដំណើរការជំរុញការផ្តល់សេវា និងហេដ្ឋារចនាសម្ព័ន្ធនៅមូលដ្ឋាន ។ ការចំណាយសំរាប់អនុវត្តន៍ (របស់រាជរដ្ឋាភិបាល) ប្រហែលជាមានកំរិតទាបបំផុតនៅក្នុងតំបន់ភូមិសាស្ត្របែបនេះ ។ ទោះជាប្រើប្រាស់យុទ្ធសាស្ត្រតែមួយ ឬយុទ្ធសាស្ត្ររួមគ្នាក្តី ក៏ការព្រមព្រៀងពីអ្នកពាក់ព័ន្ធទាំងអស់ នឹងមានសារៈសំខាន់ក្រៃលែង ។

### ការតាំងទីលំនៅឡើងវិញ

លទ្ធផលពីការអង្កេត បានបង្ហាញថា អ្នកដែលមានសក្តានុពលនឹងទទួលដី មានបំណងធ្វើដំណើរទៅកាន់ទីឆ្ងាយ នៅក្នុងឃុំ និងនៅក្រៅឃុំ ប្រសិនបើសក្តានុពលភាពពីដីដែលគាត់ទទួលបាន អនុញ្ញាតឱ្យគាត់ធ្វើបែបនេះ ។ ការដើរហើរនៅក្នុងប្រទេសរបស់ប្រជាជន ដើម្បីស្វែងរកដីដាំដំណាំ បានកើតមានរួចហើយ ។ ទន្ទឹមនឹងនេះ ប្រជាជននៅមូលដ្ឋាននៅក្នុងតំបន់ដែលមិនខ្វះដីសំរាប់ធ្វើការបែងចែក មានបំណងផ្តល់ឱកាសដល់អ្នកចំណូលថ្មីដើម្បីធ្វើសមាហរណកម្មទៅក្នុងសហគមន៍របស់ខ្លួន ។ ទោះបីជាវិធីនេះ អាចមិនមែនជាការអះអាងសំរាប់ការតាំងទីលំនៅ នៅក្នុងក្របខ័ណ្ឌកម្មវិធីសម្បទានដីសង្គមកិច្ចក្តី ក៏ចលនារបស់គ្រួសារ ផ្តល់ឱកាសសំរាប់កម្មវិធីនៅក្នុង ប្រទេសទាំងមូល ។

## សហគមន៍របស់ជនជាតិដើមភាគតិច

ការអង្កេតមិនបានដាក់បញ្ចូលសហគមន៍ជនជាតិដើមភាគតិច ហើយក៏គ្មានកន្លែងសាកល្បងសម្បទានដីសង្គមកិច្ចណាមួយ បានលើកឡើងពីការដោះស្រាយនូវសក្តានុពលជំលោះដែលអាចមានឡើងនៅក្នុងភូមិប្រភេទនោះឡើយ ។ បណ្តាភូមិគំរូដើម្បីសិក្សានៅក្នុងខេត្តព្រះវិហារ មានជនជាតិព័រ និងគួយជាច្រើន នៅក្នុងចំណោមប្រជាជននៅក្នុងភូមិ ។ ជនជាតិទាំងនេះ ត្រូវបានធ្វើសមាហរណកម្មចូលទៅក្នុងសហគមន៍បានយ៉ាងប្រសើរ ។ សហគមន៍ជនជាតិដើមភាគតិច ត្រូវបានការពារដោយបទបញ្ញត្តិពិសេសនៅក្នុងច្បាប់ភូមិបាល ។ ការផ្តល់ដីសម្បទានសង្គមកិច្ចនៅក្នុងសហគមន៍ទាំងនេះ មិនអាចអនុវត្តបានទេ ។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើតំរូវការចំពោះការកាន់កាប់ជាលក្ខណៈឯកជន មានការកើនឡើង ការកែប្រែវិធីសាស្ត្រអាចជាការចាំបាច់ ។ ការប្រាស្រ័យទាក់ទងជាមួយសហគមន៍ដែលមានការចាប់អារម្មណ៍ និងការរៀបចំគ្រោងការគំរោងយ៉ាងប្រុងប្រយ័ត្ន គួរទទួលបានព័ត៌មានដែលត្រូវការ ដើម្បីឱ្យសហគមន៍ទាំងនេះ ទទួលបានផលប្រយោជន៍ពីការកែប្រែ នៅក្នុងចំណាត់ប្រភេទដី និង កម្មវិធីបែងចែកដីដែលមានសក្តានុពលភាព ។

## ការធ្វើឱ្យដីអាចប្រើប្រាស់បាន

រាជរដ្ឋាភិបាលកម្ពុជា ត្រូវប្រកាន់យកវិធានការយ៉ាងហ្មត់ចត់ឆ្ពោះទៅរកការអនុវត្តបទបញ្ជាដែលមានស្រាប់ ដែលដោះស្រាយបញ្ហាសម្បទានសេដ្ឋកិច្ចហួសពីការកំណត់ និងការទន្ទ្រានយកដីខុសច្បាប់ ។ សម្បទានសេដ្ឋកិច្ច អាចផ្តល់ដីរហូតដល់ ៥០០.០០០ហិកតា សំរាប់កម្មវិធីសម្បទានដីសង្គមកិច្ច ។ ការទន្ទ្រានយកដីខុសច្បាប់ អាចដោះស្រាយដោយគំនិតផ្តួចផ្តើមពង្រឹងការអនុវត្តច្បាប់ភូមិបាល ជាពិសេស "ការស្តារដីរដ្ឋឡើងវិញ" ផ្អែកលើមាត្រា១៨ នៃច្បាប់ភូមិបាល និងការអនុវត្តលទ្ធភាពស្តារតំបន់អះអាង ឬកាន់កាប់ដោយខុសច្បាប់ ។ ទោះបីជាវិសាលលំអិតនៃបញ្ហាទាំងនេះ នឹងអាស្រ័យលើឆន្ទៈនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាក្តី ក៏មានឱកាសជាច្រើន សំរាប់ធ្វើការបែងចែកដីឡើងវិញ ។

ទំហំដីកសិកម្ម ដែលនឹងត្រូវបែងចែកដល់អ្នកទទួលផល គួរតែកំណត់ ។ ទំហំ និងកំរិតអតិបរមានៃផ្ទៃដីកសិកម្ម គួរតែអាស្រ័យលើផលិតភាព (ជាសក្តានុពល) របស់ដី ហើយគួរមានការពិចារណាទៅលើទំហំគ្រួសាររបស់អ្នកទទួលផល ។ **ទំហំដីកសិកម្ម ត្រូវអនុញ្ញាតអោយមានការរស់នៅបានគ្រប់គ្រាន់ពីកសិកម្ម** ។ ការកាន់កាប់ដីទំហំតូចពេក នឹងផ្តល់នូវទិន្នផលតិចជាងសក្តានុពលភាពរបស់វា ក៏វិតផលប៉ះពាល់នៃការកាត់បន្ថយភាពក្រីក្រនៅក្នុងការបែងចែកដី ។ ការកំរិត ២-៤ហិកតា នៅក្នុងកន្លែងជាច្រើននៅក្នុងប្រទេស មានលក្ខណៈមិនគ្រប់គ្រាន់ឡើយ ។

**ចំណងទាក់ទងជាមួយកម្មវិធីដី/កម្មវិធីគ្រប់គ្រងធនធានធម្មជាតិផ្សេងទៀត**

ការបំពេញបន្ថែមកម្មវិធីសម្បទានដីសង្គមកិច្ច និងការគ្រប់គ្រងធនធានធម្មជាតិផ្សេងទៀត ព្រមទាំងគំរោង និងកម្មវិធីប្រកបរបរចិញ្ចឹមជីវិតដែលផ្អែកលើដី ត្រូវទាញយកផលប្រយោជន៍ឱ្យបានពេញលេញ ។ អ្នកពាក់ព័ន្ធទាំងអស់ រាជរដ្ឋាភិបាលកម្ពុជា អង្គការមិនមែនរដ្ឋាភិបាល អ្នកទទួលផលដែលមានសក្តានុពល មានការយល់ដឹងអំពីបញ្ហាប្រឈមផ្នែកសង្គម សេដ្ឋកិច្ច និងបរិស្ថាននៅក្នុងការបែងចែកដី ដូចដែលបានស្នើឡើងនៅក្នុងកម្មវិធីសម្បទានសង្គមកិច្ច ។ មានផលប្រយោជន៍ (និងតំរូវការ) នៅគ្រប់ថ្នាក់ ដើម្បីសំរបសំរួលតំរូវការផ្សេងគ្នា ហើយបំពេញការងាររួមគ្នាឆ្ពោះទៅរកការអភិវឌ្ឍដែលមានតុល្យភាព និងមាននិរន្តរភាព ។ **ដើម្បីទទួលបានផលប្រយោជន៍ពេញលេញនៅក្នុងការកាត់បន្ថយភាពក្រីក្រពីប្រព័ន្ធសម្បទានរបស់កម្ពុជា សម្បទានសេដ្ឋកិច្ច សម្បទានសង្គមកិច្ច សម្បទានព្រៃឈើ (ឬយ៉ាងហោចណាស់សម្បទាន និង/ឬ បទបញ្ញត្តិសំរាប់គំរោងព្រៃឈើសហគមន៍) ត្រូវរៀបចំគ្រោងការឡើងវិញ និង/ឬ ធ្វើឱ្យមានសុខដុមនីយកម្ម ។** ការកាត់បន្ថយភាពក្រីក្រ និងសក្តានុពលភាពកំណើននៅក្នុងផលិតផល ការកែច្នៃ និងការរកទីផ្សារកសិកម្ម នឹងសំរេចបានយ៉ាងប្រសើរបំផុតតាមរយៈការអភិវឌ្ឍ ព្រមគ្នានូវសម្បទានសេដ្ឋកិច្ចយ៉ាងសកម្ម និងមានបទញ្ញត្តិច្បាស់លាស់ ហើយផ្តល់ឱកាសកាន់តែប្រសើរដល់អ្នកគ្មានដីបានចូលរួម នៅក្នុងសកម្មភាពសេដ្ឋកិច្ចដែលពឹងផ្អែកលើដី ។

**ការធ្វើចំណាត់ប្រភេទ និង ការគ្រប់គ្រងដីរដ្ឋ**

អនុក្រឹត្យដែលនឹងកំណត់ដំណើរការធ្វើចំណាត់ប្រភេទ និងការគ្រប់គ្រងដីរដ្ឋ គឺជាជំហានចាំបាច់ ឆ្ពោះទៅរកកម្មវិធីសម្បទានដីសង្គមកិច្ចកាន់តែធំ ។ នៅពេលរៀបចំអនុក្រឹត្យស្តីពីការធ្វើចំណាច់ប្រភេទ និងការគ្រប់គ្រងដីរដ្ឋ គួរមានការពិចារណាលើបទពិសោធន៍ពីកន្លែងសាកល្បង ។ ជាមួយនឹងការដឹកនាំអន្តរក្រសួង ក្រុមប្រឹក្សាគោលនយោបាយដីធ្លី (CLP) សំរាប់ការប្រឹងប្រែងទាំងពីរនេះ ការសំរបសំរួលមិនគួរជាបញ្ហាចំបងឡើយ ។ ការដាក់ចេញ និងការអនុវត្ត (!) អនុក្រឹត្យអាចមើលឃើញថាជាជំហានយ៉ាងសំខាន់ដែលបង្ហាញពីការប្តេជ្ញាចិត្ត និងចេតនារបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីកែលំអអភិបាលកិច្ច ។ បញ្ហាចំបងមួយដែលត្រូវបំភ្លឺជាមួយអ្នកពាក់ព័ន្ធនឹងដីរដ្ឋទាំងអស់ ជាពិសេសរដ្ឋបាលព្រៃឈើ គឺ **លក្ខណៈវិនិច្ឆ័យដែលនឹងអនុញ្ញាតឱ្យមានការបំប្លែងដីពីវិស័យសាធារណៈ ឬវិស័យឯកជនរបស់រដ្ឋឱ្យទៅជាសម្បទានដីសង្គមកិច្ច ។** ក្នុងខណៈដែលបញ្ហា ភាពគ្មានដីធ្លីដ៏ស្រួចស្រាវ និង ភាពក្រីក្រនៅតែជាទិដ្ឋភាពយ៉ាងសំខាន់ លក្ខណៈវិនិច្ឆ័យ និងដំណើរការ នឹងត្រូវថ្លឹងថ្លែងជាមួយកង្វល់ផ្នែកសេដ្ឋកិច្ច សង្គមកិច្ច និងបរិស្ថាន ។ ប្រសិនបើគ្មានគោលការណ៍ណែនាំច្បាស់លាស់ នៅថ្នាក់ជាតិទេនោះ ការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចនៅថ្នាក់មូលដ្ឋាន នឹងមិនអាចប្រព្រឹត្តទៅបានឡើយ ។

## សម្បទានសេដ្ឋកិច្ច

ការរៀបចំគ្រោងការប្រព័ន្ធសម្បទានសេដ្ឋកិច្ចឡើងវិញ គឺជាជំហានគន្លឹះមួយទៀតឆ្ពោះទៅរកការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចប្រកបដោយជោគជ័យ ។ ការរឹតតាមច្បាប់លើសម្បទានសេដ្ឋកិច្ច និងការប្រមូលពន្ធលើដីមិនប្រើប្រាស់ត្រូវតែអនុវត្ត ។ នៅពេលនេះ ដីយ៉ាងច្រើនដែលមិនបានប្រើប្រាស់នៅក្នុងសម្បទានសេដ្ឋកិច្ចកំហិតការមានដីសំរាប់បែងចែកដល់អ្នកគ្មានដីដែលកំពុងត្រូវការ ។ ក្រៅពីនេះ សម្បទានសេដ្ឋកិច្ចជាច្រើន ប្រឈមនឹងទំនាស់ជាមួយអ្នកតាំងទីលំនៅដែលមានពីមុនមក ឬអ្នករស់នៅអនាធិបតេយ្យ នៅក្នុងព្រំដែនសម្បទានសេដ្ឋកិច្ច ។ ប្រព័ន្ធដែលបានពិនិត្យកែសំរួលឡើងវិញ អាចផ្តល់ផលប្រយោជន៍ដល់អ្នកកាន់កាប់សម្បទានសេដ្ឋកិច្ច និងអ្នកទទួលផលពីកម្មវិធីសម្បទានដីសង្គមកិច្ច ដោយផ្តល់លទ្ធភាពប្រើប្រាស់ដីធ្លីប្រកបដោយសុវត្ថិភាព ។ បទពិសោធន៍ពីប្រទេសជិតខាង ជាពិសេសម៉ាឡេស៊ី ថៃ បង្ហាញថា ការចាត់ចែងដែលផ្តល់ផលប្រយោជន៍ទៅវិញទៅមក អាចធ្វើទៅបាន ។ មុខងារសំខាន់នៅក្នុងវិស័យផ្តល់ទុន ការផ្តល់សេវា ការកែច្នៃ និង ការរកទីផ្សារផលិតផលកសិកម្ម អាចធ្វើឡើងដោយអ្នកកាន់កាប់សម្បទានសេដ្ឋកិច្ច ដូចជា តាមរយៈការចាត់ចែងដាំដំណាំ ដោយមានកិច្ចសន្យា ។ ការចាត់ចែងបែបនេះ មិនអាចធ្វើឡើងនៅកន្លែងផ្សេងទៀតឡើយ ។ ទោះជាយ៉ាងណាក៏ដោយ គំនិតផ្តួចផ្តើមផ្នែកឯកជន និងអង្គការមិនមែនរដ្ឋាភិបាលដែលមានស្រាប់ ដូចជានៅក្នុងការផលិតបន្លែ ឬការចិញ្ចឹមសត្វ បង្ហាញថា ប្រាក់ចំណូល និងផលិតផលដែលមានសក្តានុពលភាព សំរាប់កាត់បន្ថយភាពក្រីក្រ រួមទាំងផលិតផលដែលមិនមែនជាស្រូវ តាមរយៈការបង្កើនទិន្នផល ការកែលំអគុណភាព ការកែច្នៃ និងការរកទីផ្សារ មិនទាន់បានទាញយកផលឱ្យបានពេញលេញនៅឡើយ ។

## ការគ្រប់គ្រងព្រៃឈើសហគមន៍

ការគ្រប់គ្រងព្រៃឈើសហគមន៍ អាចបំពេញមុខងារយ៉ាងសំខាន់សំរាប់អ្នកគ្មានដីធ្លី និងអ្នកក្រខ្សត់ដីធ្លីដែលពឹងអាស្រ័យលើជំរើសជាច្រើនសំរាប់ការរស់នៅ និងភាពសុខសាន្តរបស់ខ្លួន ។ ជាពិសេសនៅក្នុងតំបន់ដែលមានព្រៃឈើក្រាស់ អ្នកភូមិដែលគ្មានដី ពឹងអាស្រ័យលើផលិតផលព្រៃឈើសំរាប់ការចិញ្ចឹមជីវិតរបស់ខ្លួន[៥] ។ តំបន់បែបនេះ ក៏ដើរតួនាទីយ៉ាងសំខាន់ផងដែរជាតំបន់ទ្រនាប់រវាងតំបន់កសិកម្មនៅក្នុងភូមិ រួមទាំងដីសម្បទានដីសង្គមកិច្ច ព្រៃបំរុងទុកជាអចិន្ត្រៃយ៍ ។ បញ្ហាប្រឈម គឺការធ្វើសុខដុមនីយកម្មសកម្មភាពព្រៃឈើដែលកើតមានឡើងនៅក្នុងឃុំ ។ អនុក្រឹត្យស្តីពីការគ្រប់គ្រងព្រៃឈើសហគមន៍ បញ្ជាក់ថា "ព្រៃឈើសហគមន៍ គឺជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ។ រដ្ឋបាលព្រៃឈើ មានសិទ្ធិផ្តល់ការទទួលស្គាល់ជាផ្លូវការដល់ការកំណត់ព្រំប្រទល់

---

[៥] ធនាគារអភិវឌ្ឍន៍អាស៊ី កំពុងស្ថិតនៅក្នុងដំណើរការអនុវត្តជាផ្លូវការការសិក្សាមួយ ដើម្បីកំណត់យុទ្ធសាស្ត្រក្នុងការបង្កើនសន្តិសុខស្បៀង និងការចិញ្ចឹមជីវិតរបស់គ្រួសារកសិករ និងសហគមន៍ដែលមានដីតិចតួចដែលកំពុងរស់នៅក្នុង ឬនៅជិតតំបន់ព្រៃឈើដាច់ស្រយាល និងដែលមិនអាចចូលទៅបាន ។ គេក៏មានគំរោងធ្វើការវាយតំលៃសក្តានុពលភាពនៃសហគមន៍ព្រៃឈើក្នុងការកាត់បន្ថយភាពក្រីក្រនៅសហគមន៍ខ្ពង់រាប និងស្វែងរកចំណងទាក់ទងជាមួយប្រតិបត្តិការព្រៃឈើបែបពាណិជ្ជកម្ម។

ព្រៃឈើសហគមន៍នីមួយៗ" ។ ការអនុវត្តបទបញ្ជា ( *ប្រកាស* ) អាស្រ័យលើការកំណត់និយមន័យ និងព្រំប្រទល់ច្បាស់លាស់លើដីរដ្ឋ ។ អនុក្រឹត្យដែលមាននៅពេលសព្វថ្ងៃនេះ អាចនឹងត្រូវពិនិត្យមើលឡើងវិញ នៅពេលអនុក្រឹត្យស្តីពីការធ្វើចំណាត់ប្រភេទនិងការគ្រប់គ្រងដីរដ្ឋ ត្រូវរៀបចំបញ្ចប់ ។ ប្រការនេះ មានសារៈសំខាន់ ជាពិសេសទាក់ទងនឹងសកម្មភាពព្រៃឈើដែលមានសក្តានុពលភាព ជាលក្ខណៈឯកជន ឬសហគមន៍ ដែលនឹងកើតមានឡើងនៅលើដីរដ្ឋសាធារណៈ និងឯកជន ដោយការទទួលខុសត្រូវលើការបែងចែក និង/ឬការគ្រប់គ្រងស្ថិតនៅលើក្រុមប្រឹក្សាឃុំ សង្កាត់ ។

ដូចគ្នានឹងកិច្ចសហប្រតិបត្តិការដោយមានសក្តានុពលភាពរវាងសម្បទានសេដ្ឋកិច្ច និងសម្បទានសង្គមកិច្ច (សហគមន៍) ព្រៃឈើនៅលើដីសម្បទានសង្គមកិច្ច និងសកម្មភាពព្រៃឈើ (ជាលក្ខណៈពាណិជ្ជកម្ម) អាចទទួលបានផលប្រយោជន៍ពីគ្នាទៅវិញទៅមក ។ ទោះជាយ៉ាងណាក៏ដោយ អនុក្រឹត្យដែលពាក់ព័ន្ធ ត្រូវធ្វើការកែសំរួលអោយបានសមស្រប ដើម្បីឱ្យអ្នកគ្មានដីធ្លី និងអ្នកខ្វះខាតដីធ្លី ទទួលបានផលប្រយោជន៍ប្រកបដោយសក្តានុពលដោយមិនបាច់បោះបង់ចោលគោលការណ៍និរន្តរភាព និងការពិចារណាផ្នែកបរិស្ថាន ។ មានការផ្តល់អនុសាសន៍ឱ្យ **ប្រើប្រាស់វេទិកាគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង (LUAC) មិនសំរាប់តែសម្បទានដីសង្គមកិច្ចប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសំរាប់ការកំណត់អាទិភាពឆ្ពោះទៅរកការប្រើប្រាស់ ប្រកបដោយនិរន្តរភាព និងមានលក្ខណៈសេដ្ឋកិច្ចលើដីរដ្ឋសំរាប់ប្រភេទព្រៃឈើសហគមន៍ សម្បទានសេដ្ឋកិច្ច និងការបំប្លែងព្រៃឈើនៅក្នុងការអភិវឌ្ឍខេត្ត និងយុទ្ធសាស្ត្រអភិវឌ្ឍ ។**

## ការផ្តល់សេវាគាំទ្រ និងហេដ្ឋារចនាសម្ព័ន្ធ

បញ្ជីសេវាជាអាទិភាព ដែលត្រូវមានសំរាប់ឱ្យសហគមន៍ទទួលបានផលប្រយោជន៍ពីកម្មវិធីសម្បទានដីសង្គមកិច្ច មានលក្ខណៈខុសប្លែកពីកម្មវិធីដែលផ្តោតតែទៅលើផលិតផលកសិកម្មសុទ្ធសាធ ។ សេវា និងហេដ្ឋារចនាសម្ព័ន្ធដែលត្រូវមាន នឹងត្រូវដោះស្រាយបញ្ហាចំនួនពី គឺ (១).**អ្នកទទួលគួរមានលទ្ធភាពប្រើប្រាស់ដីដោយមានផលិតភាពខ្ពស់បំផុត (រួមទាំងការបញ្ជូនផលិតផលរបស់គាត់ទៅកាន់ទីផ្សារ) និង (២).បញ្ហាលក់ដីដោយសារមានគ្រោះអាសន្ន ត្រូវដោះស្រាយ ។**

គេអាចសង្ឃឹមថា ការកែលំអធំបំផុតនៅក្នុងផលិតផលកសិកម្ម នឹងទទួលបានមកពីការណែនាំសមស្របលើទម្លាប់ដាំដំណាំដែលបានកែប្រែ និងមានការសាកល្បង ។ សេវាផ្សព្វផ្សាយកសិកម្ម ដោយមានការណែនាំជាក់លាក់សំរាប់កសិករតូចតាច នឹងមានផលប៉ះពាល់យ៉ាងប្រសើរនៅក្នុងរយៈពេលខ្លីជាងការផ្តល់ទុន សម្ភារ (ជាឥណទាន) ។ ដូចដែលបានបញ្ជាក់ដោយ **Auffret** (ឆ្នាំ២០០៣) វត្តមានរបស់បុគ្គលិកផ្សព្វផ្សាយកសិកម្ម ឬផ្សារជាអចិន្ត្រៃយ៍នៅក្នុងភូមិ បង្កើនប្រាក់ចំណូលរបស់គ្រួសារបានយ៉ាងច្រើន ។ ក្នុងខណៈដែលលទ្ធផលនៃការស្រាវជ្រាវរបស់គាត់ ក៏បញ្ជាក់ផងដែរថា "ដើម្បីឱ្យមានផលប៉ះពាល់ជាដុំកំភួនមកលើ ការកាត់បន្ថយភាពក្រីក្រនៅជនបទ គោលនយោបាយ ត្រូវផ្តោតទៅលើការធ្វើអន្តរាគមន៍ដែលបង្កើនការប្រើប្រាស់ទុននានាទៅតាមតំលៃដែល

មានការប្រកួតប្រជែងគ្នា ផ្តល់តំលៃដែលមានការប្រកួតប្រជែងសំរាប់ការលក់ផលិតផល និងកែលំអផលិតភាព ។ កង្វះលទ្ធភាពទទួលហិរញ្ញវត្ថុ រារាំងគ្រួសារមិនឱ្យទទួលបានទុនសំខាន់ៗ និងរារាំងគ្រួសារមិនឱ្យបែងចែកទុនទៅតាមរបៀបដែលនឹងទទួលបានផលជាអតិបរមា" ។ ទោះជាយ៉ាងណាក៏ដោយ លទ្ធផលពីការពិភាក្សាជាមួយក្រុមគោលដៅសំរាប់ការពិភាក្សា (FGD) បង្ហាញថា ជាញឹកញាប់ការទទួលយកឥណទានពីអ្នកផ្តល់ប្រាក់កម្ចីផ្លូវការ ឬក្រៅផ្លូវការ ជាបុព្វហេតុនៃការជំពាក់បំណុល និងការបាត់បង់ដីជាបន្តបន្ទាប់ ។

ការធ្វើអន្តរគមន៍ដ៏សំខាន់ គឺការផ្តល់សេវាសុខភាពដែលមានលទ្ធភាពទិញ និងដែលអាចជឿទុកចិត្តបាននៅក្នុងសហគមន៍ដែលជាអ្នកទទួលផល ។ ការចំណាយទាក់ទងនឹងជំងឺ ត្រូវបានលើកឡើងដូចគ្នាថា ជាមូលហេតុចំបងដែលធ្វើឱ្យគ្រួសារបាត់បង់ដីធ្លីរបស់ខ្លួន ។ មណ្ឌលសុខភាព និងការថែទាំសុខភាព ត្រូវបានលើកឡើងនៅក្នុងការអង្កេតតាមគ្រួសារ (HHS) និងក្រុមគោលដៅសំរាប់ការពិភាក្សា (FGD) ថា ជាសេវាអាទិភាពដែលត្រូវមានជាមួយកម្មវិធីសម្បទានដីសង្គមកិច្ច ។

ទំរង់មួយទៀតនៃសេវាគាំទ្រសង្គម អាចតំរូវឱ្យមាន ដើម្បីដោះស្រាយបញ្ហាបំណុលដែលមានរួចហើយ និងការតស៊ូជារៀងរាល់ថ្ងៃសំរាប់ការរស់រានមានជីវិតរបស់អ្នកគ្មានដីធ្លី ។ ប្រសិនបើមិនមានការផ្តល់ជាសាច់ប្រាក់ ឬជាសេវាដែលគ្របដណ្តប់លើការចំណាយវិនិយោគតូចតាចនៅក្នុងឧបករណ៍ចាំបាច់ ប៉ុន្តែមានសារៈសំខាន់ចំពោះជនក្រីក្រ ហើយដែលនឹងផ្តល់លទ្ធភាពអោយអ្នកទទួលដីកាត់បន្ថយរយៈពេលមុនពេលទទួលផលដំណាំជាលើកដំបូងទេនោះ សំពាធដែលនាំឱ្យមានការលក់ដី នឹងស្ថិតនៅដដែល ។ គេអាចរំពឹងថា បទបញ្ញត្តិមានស្រាប់ ដែលហាមឃាត់ការលក់ដីនៅក្នុងរយៈពេល៥ឆ្នាំដំបូង នឹងត្រូវរំលោភតាមរយៈការចាត់ចែងក្រៅផ្លូវការ ។

## បញ្ហាផ្នែកស្ថាប័ន និងការអនុវត្ត

តំរូវការឱ្យមានបទបញ្ញត្តិច្បាប់បន្ថែម ការកសាងផែនការបែបវិមជ្ឈការ និងរចនាសម្ព័ន្ធអនុវត្តន៍ ដែលបានប្រមើលមើល និងការសំរបសំរួល និងកិច្ចសហប្រតិបត្តិការចាំបាច់រវាងក្រសួងខ្សែបណ្តោយ និងភ្នាក់ងារផ្សេងៗរបស់រដ្ឋាភិបាល ផ្តល់តួនាទីលេចធ្លោដល់កម្មវិធីសម្បទានដីសង្គមកិច្ចក្នុងការបង្ហាញពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាចំពោះអភិបាលកិច្ចល្អ ។ **ជោគជ័យនៅក្នុងការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច អាស្រ័យលើការរីកចំរើន នៅក្នុងការងារអភិបាលកិច្ចដែលមានទំនាក់ទំនងដោយផ្ទាល់ ជាមួយនឹងជោគជ័យនៃការបែងចែកដីដោយមានភាពយុត្តិធម៌ និងមានភាពស្មើគ្នា** ។ កម្មវិធីសម្បទានដីសង្គមកិច្ច នឹងតំរូវឱ្យមានដូចគ្នានូវសមាសធាតុនៃការកែប្រែផ្នែកស្ថាប័ន/កម្មវិធីគាំទ្រអភិបាលកិច្ចល្អ និង គំរោងអភិវឌ្ឍន៍ជនបទ ។

### ថ្នាក់ជាតិ

ការសំរបសំរួល និងកិច្ចសហប្រតិបត្តិការនៅគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ហាក់ដូចជាដំណើរការដោយមានភាពរលូន ។ គណៈកម្មការ ដោយមានការគាំទ្រ និងការយល់ព្រមពី ក្រុមប្រឹក្សាគោលនយោ

បាយដីធ្លី (CLP) នឹងដាក់សំពាធមកលើអង្គភាពវិមជ្ឈការ នៅថ្នាក់ក្រោមឱ្យជំនះបាននូវការមិនជឿទុកចិត្ត និង ធានាឱ្យមានកិច្ចសហប្រតិបត្តិការ ។ ក៏ជាការសំខាន់ផងដែរក្នុងការបង្កើតឱ្យមានការយល់ដឹង យ៉ាងប្រាកដប្រជា អំពីការគាំទ្រផ្នែកបច្ចេកទេសអ្វីខ្លះដែលថ្នាក់លើត្រូវផ្តល់ឱ្យ ។ ដោយសាររដ្ឋបាលថ្នាក់លើ ហាក់ដូចជាវាយតំលៃ ហួសលើសក្តានុពលភាពរបស់អង្គភាពវិមជ្ឈការ មានគ្រោះថ្នាក់ចំពោះការមិនយកចិត្តទុកដាក់លើការវិនិយោគ កសាងសមត្ថភាពដែលត្រូវមាន ។

## ថ្នាក់ខេត្ត ក្រុង

គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង (PLUAC) ដែលត្រូវបង្កើតឡើងថ្មី នឹងបំពេញ ការងារយ៉ាងជិតស្និទ្ធជាមួយគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត ក្រុង ។ ដោយសារមានភាពត្រួតគ្នាជាច្រើន នៅក្នុងសមាជិកភាព ការសំរបសំរួលរវាងកម្មវិធីសម្បទានដីសង្គមកិច្ច និងកម្មវិធីអភិវឌ្ឍន៍ផ្សេងទៀត មិនគួរ ចោទជាបញ្ហាឡើយ ។ ទោះជាយ៉ាងណាក៏ដោយ មានតំរូវការឱ្យមានព័ត៌មាន ការបណ្តុះបណ្តាល និង យុទ្ធនាការ កសាងសមត្ថភាព ជាពិសេសការដោះស្រាយ ភាពទន់ខ្សោយនៅក្នុងអង្គភាពគាំទ្របច្ចេកទេសនៅថ្នាក់ខេត្ត ក្រុង (និងថ្នាក់វិមជ្ឈការបន្ថែមទៀត) ។

## ថ្នាក់ស្រុក ខណ្ឌ

ការសំរបសំរួល និងកិច្ចសហប្រតិបត្តិការរវាងភ្នាក់ងារនានារបស់រដ្ឋាភិបាល ហាក់ដូចជាធ្វើអោយចុះ ខ្សោយនៅក្នុងរចនាសម្ព័ន្ធបែបវិមជ្ឈការ ។ ការប្រើប្រាស់ធនធាន និង/ឬបញ្ហាបែងចែក អាចជាឧបសគ្គចំពោះ ការងារនៅមូលដ្ឋានដែលតំរូវដោយក្រុមការងារនៅថ្នាក់ស្រុក ខណ្ឌ ។ ថ្នាក់ស្រុក ខណ្ឌ អាចមានលក្ខណៈទន់ ខ្សោយបំផុត បើនិយាយពីសមត្ថភាព និងការប្រើប្រាស់ធនធាន បើប្រៀបធៀបជាមួយនឹងតួនាទីរបស់ពួកគេដែល បានរំពឹងទុកនៅក្នុងកម្មវិធី ។ ការណែនាំស្តីពីអាទិភាព និងការបែងចែកធនធាន រួមជាមួយនឹងការកសាង សមត្ថភាព នឹងតំរូវអោយមាន ។

## ថ្នាក់ឃុំ សង្កាត់ និងភូមិ

អ្នកភូមិមួយចំនួន មិនទាន់មានទំនុកចិត្តពេញលេញលើក្រុមប្រឹក្សាឃុំ សង្កាត់នៅឡើយ ។ អ្នកភូមិជា ច្រើន ចង់ឃើញមានស្ថាប័នឯករាជ្យជាផ្នែកមួយនៃការជ្រើសរើសអ្នកទទួលផល និងក្រុមអនុវត្តន៍សម្បទានដី សង្គមកិច្ច ។ អ្នកភូមិ ហាក់ដូចជាបើកចំហក្នុងការអនុញ្ញាតអោយប្រជាពលរដ្ឋមិនមែនជាខ្មែរបានចូលរួម នៅក្នុង កម្មវិធីសម្បទានដីសង្គមកិច្ច ។ អ្វីដែលអាចយល់បាននោះ គឺថា នៅក្នុងពេលដែលអ្នកភូមិចង់ឃើញការទាមទារ របស់ខ្លួនចំពោះដីធ្លី ត្រូវបានឆ្លើយតបជាមុន កម្មវិធីអាចជួបនឹងការប្រឆាំងនៅមូលដ្ឋានតិចតួច នៅពេលដាក់ បញ្ចូលជនជាតិភាគតិចមិនមែនជាខ្មែរដែលរស់នៅក្នុងព្រំប្រទល់របស់តំបន់ ។

### ទិដ្ឋភាពបច្ចេកទេស

មានទិដ្ឋភាពបច្ចេកទេសមួយចំនួននៅក្នុងកម្មវិធីសម្បទានដីសង្គមកិច្ច ដែលនឹងត្រូវមានការពិចារណាយ៉ាងប្រុងប្រយ័ត្ន និង/ឬ សិ៊រិតសំរាំង ។ ទិដ្ឋភាពចំបង គឺនិរន្តរភាពនៃការបែងចែកដីធ្លីសំរាប់ផលិតកម្មកសិកម្ម ត្រូវមានការធានា ។ ការពិចារណាផ្នែកបរិស្ថាន ត្រូវដឹកនាំការប្រែក្លាយតំបន់ព្រៃឈើដែលគ្មានគុណភាពអោយទៅជាដីកសិកម្ម ។ នីតិវិធីអនុវត្ត និងជ្រើសរើសអ្នកទទួលផល ត្រូវមានការពិចារណាលើល័ក្ខខ័ណ្ឌ/ទំនៀមទំលាប់នៅមូលដ្ឋាន ។ ការផ្តួចផ្តើមគំរោងសម្បទានដីសង្គមកិច្ច អាចត្រូវចំណាយពេលវែងជាងការរំពឹងទុក ។ ការបណ្តុះបណ្តាលកសាងផែនការ និងការអនុវត្តសម្បទានដីសង្គមកិច្ច ត្រូវតែជំរុញឡើង ។ អង្គការមិនមែនរដ្ឋាភិបាលនឹងដើរតួនាទីយ៉ាងសំខាន់នៅក្នុងការអនុវត្តនៅថ្នាក់ឃុំ សង្កាត់ ហើយអាស្រ័យហេតុនេះ គឺជាអតិថិជនចំបងសំរាប់ការបណ្តុះបណ្តាលទាក់ទងនឹងសម្បទានដីសង្គមកិច្ច ។

### តួនាទីរបស់រដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល

ការអង្កេត បានបង្ហាញថា ការរួមចំណែករបស់អង្គការមិនមែនរដ្ឋាភិបាល នៅក្នុងការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច នឹងមានលក្ខណៈសមស្របនៅគ្រប់ថ្នាក់ទាំងអស់ ។ ជាពិសេសនៅថ្នាក់ឃុំ សង្កាត់ និងភូមិ មានតួនាទីប្រកបដោយសក្តានុពលជាច្រើន សំរាប់អង្គការមិនមែនរដ្ឋាភិបាលដែលមានបទពិសោធន៍ នៅក្នុងការកៀងគរសហគមន៍ ការគ្រប់គ្រងធនធានធម្មជាតិ ហើយជាពិសេសនៅក្នុងការអភិវឌ្ឍកសិកម្ម/អ្នកកាប់កាប់ដីតិចតួច ។ ដោយសារគំរោងសម្បទានដីសង្គមកិច្ច នឹងត្រូវបញ្ចូលនៅក្នុងការកសាងផែនការប្រើប្រាស់ដីធ្លីដោយមានការចូលរួម (PLUP) នៅមូលដ្ឋាន ការពង្រីកការរួមចំណែករបស់អង្គការមិនមែនរដ្ឋាភិបាល នៅក្នុងការកសាងផែនការនៅថ្នាក់មូលដ្ឋាន ហាក់ដូចជាមានលក្ខណៈធម្មតា ។ ការធ្វើបែបនេះ ស្របទៅនឹងតំរូវការរបស់អ្នកភូមិដែលទាមទារឱ្យមានការគាំទ្រពីខាងក្រៅ (ការត្រួតពិនិត្យ) លើដំណើរការកសាងផែនការ និងអនុវត្តន៍សម្បទានដីសង្គមកិច្ច ។ ក្នុងខណៈដែលសិទ្ធិអំណាចធ្វើសេចក្តីសំរេចចិត្ត ស្ថិតនៅលើក្រុមប្រឹក្សាឃុំ សង្កាត់ ក្រុមប្រឹក្សានេះខ្លួនឯងផ្ទាល់បានសំដែងពីតំរូវការឱ្យមានការគាំទ្រលើទិដ្ឋភាពបច្ចេកទេសនៃកម្មវិធី ។ ទន្ទឹមនឹងនេះ អ្នកភូមិបានលើកឡើងពីតំរូវការឱ្យមានស្ថាប័នគាំទ្រ និង ត្រួតពិនិត្យនៅខាងក្រៅរចនាសម្ព័ន្ធជាផ្លូវការរបស់រដ្ឋាភិបាល ដើម្បីធានាអោយមានការអនុវត្តកម្មវិធី ដោយមានភាពយុត្តិធម៌ និងសមធម៌ ។

អង្គការមិនមែនរដ្ឋាភិបាលដែលបានទទួលការជឿទុកចិត្ត និងមានសមត្ថភាព អាចដើរតួនាទីចំបងនៅក្នុងកម្មវិធីសម្បទានដីសង្គមកិច្ចទ្រង់ទ្រាយធំ ជាបន្ថែមលើសមត្ថភាពរបស់ស្ថាប័នរដ្ឋាភិបាល ។ ដំណើរការពិនិត្យពិច័យ និងជ្រើសរើសយ៉ាងប្រុងប្រយ័ត្នលើអង្គការមិនមែនរដ្ឋាភិបាលដែលមានសក្តានុពលភាព នឹងត្រូវរៀបចំឡើង ។ បណ្តាញអង្គការមិនមែនរដ្ឋាភិបាលដែលមានស្រាប់ អាចដើរតួនាទីយ៉ាងសំខាន់នៅក្នុងដំណើរការនេះ ។ ក្នុងខណៈដែលអង្គការមិនមែនរដ្ឋាភិបាល រក្សាមុខងារសំរបសំរួល និងត្រួតពិនិត្យរបស់ខ្លួន ការអនុវត្តនៅថ្នាក់ភូមិ គួរផ្តល់ការជឿទុកចិត្តដល់អង្គការមិនមែនរដ្ឋាភិបាល ដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ។

## ការរួមចំណែក និងការសំរបសំរួលរបស់អ្នកផ្តល់ជំនួយ

នៅពេលនេះ អ្នកផ្តល់ជំនួយមួយចំនួន អនុវត្តគំរោង "សម្បទានដីសង្គមកិច្ច" របស់ខ្លួនផ្ទាល់ ។ ការបែងចែកដីដែលបានដោះមីនរួច ដីដែលបានទិញជាមួយនឹងមូលនិធិរបស់អ្នកផ្តល់ជំនួយ/គំរោង ។ល។ កើតមានឡើងនៅតាមឃុំ សង្កាត់នានានៅទូទាំងប្រទេស ។ ប្រការនេះ បង្កអោយមានបញ្ហា ដោយសារម៉្យាងការចាត់ចែងផ្នែកច្បាប់ ជានិច្ចកាល មិនមានភាពច្បាស់លាស់ ហើយម៉្យាងទៀត វាជាការបង្ហាញយ៉ាងច្បាស់ពីការចាប់អារម្មណ៍របស់អ្នកផ្តល់ជំនួយក្នុងការគាំទ្រចំពោះការបែងចែកដី ។ ការរៀនសូត្រពីបទពិសោធន៍លើគំនិតផ្តួចផ្តើមទាំងនេះ និងការកៀងគរអ្នកផ្តល់ជំនួយដែលមានការចាប់អារម្មណ៍ គឺជាផ្នែកមួយនៃមុខងារសំរបសំរួលរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (ឬស្ថាប័នសមស្របផ្សេងទៀត) ។

ការរួមចំណែករបស់អ្នកផ្តល់ជំនួយនៅក្នុងការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច អាចកើតមានឡើងទៅតាមវិធីពីរយ៉ាង ដែលមិនទៅដាច់ដោយឡែកពីគ្នា ប៉ុន្តែបំពេញបន្ថែមឱ្យគ្នាទៅវិញទៅមក ។ ដោយសារគំរោងសម្បទានដីសង្គមកិច្ច អាចមានទំនាក់ទំនងជាមួយសកម្មភាពរបស់អ្នកផ្តល់ជំនួយដែលមានស្រាប់នៅក្នុងភូមិពោលគឺនៅកន្លែងដែលសេវា និងហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ ត្រូវបានផ្តល់អោយឃុំ សង្កាត់ គំរោងសម្បទានដីសង្គមកិច្ច អាចពង្រីកផលប្រយោជន៍ ។ ជំរើសមួយទៀត គឺការគាំទ្រផ្នែកបច្ចេកទេសដល់ "មូលនិធិសម្បទានដីសង្គមកិច្ច" នៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (ឬស្ថាប័នសមស្របផ្សេងទៀត) ដែលតាមរយៈមូលនិធិនេះ សកម្មភាពនានា ទទួលបានមូលនិធិ និងការសំរបសំរួល ។ បទពិសោធន៍ពីប្រទេសផ្សេងទៀតនៅអាស៊ី បង្ហាញអំពីជំរើសស្ថាប័ន ឧទាហរណ៍ ការបង្កើតទីភ្នាក់ងារជំនាញ និងមានវិជ្ជាជីវៈខ្ពស់របស់រដ្ឋ ដូចជាអាជ្ញាធរសហព័ន្ធដើម្បីអភិវឌ្ឍន៍ដីធ្លី (FELDA) និងអាជ្ញាធរសហព័ន្ធដើម្បីបង្រួបបង្រួម និងស្តារដីធ្លីឡើងវិញ (FELCRA) នៅប្រទេស ម៉ាឡេស៊ី ដែលមានទំនាក់ទំនងជាមួយក្រសួងរដ្ឋ ។

# ១.  សេចក្តីផ្តើម

## ១.១.  គោលនយោបាយដីធ្លី និងការកែទម្រង់ដីធ្លីនៅកម្ពុជា

សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា កំពុងមានកំណើន ប៉ុន្តែអាត្រានៃភាពក្រីក្ររបស់ប្រជាជនរស់នៅជនបទភាគច្រើន នៅតែមានកំរិតខ្ពស់ ( ប្រជាជននៅជនបទចំនួន ៤០%មានប្រាក់ចំណូលតិចជាង ១ដុល្លារអាមេរិក ក្នុងមួយថ្ងៃ) ។ ការប្រកបរបរចិញ្ចឹមជីវិតនៅជនបទ មានលក្ខណៈមិនទៀងទាត់ ។ ការលូតលាស់វិស័យកសិកម្មមានភាពយឺតយ៉ាវ និងព្រៃឈើមិនអាចផ្តល់ផលប្រយោជន៍ទៅតាមលទ្ធភាពដែលវាអាចផ្តល់ ។ ប្រទេសកម្ពុជាជាប្រទេស ដែលសំបូរផលនេសាទទឹកសាប ក្នុងចំណោមប្រទេសទាំងឡាយលើពិភពលោក ។ ប៉ុន្តែបច្ចុប្បន្ននេះប្រទេសកម្ពុជាកំពុងជួបប្រទះការលំបាកដោយសារបញ្ហាជំលោះ និងការអនុវត្តច្បាប់ ដែលជាឧបស័គ្គរាំងលទ្ធភាពរបស់ប្រជាជនក្រីក្រក្នុងការទទួលបានផលនេសាទ ។

បញ្ហាដីធ្លី និងធនធានធម្មជាតិ ត្រូវបានលើកឡើងយ៉ាងច្បាស់លាស់ នៅក្នុងឯកសារយុទ្ធសាស្ត្រ ស្តីពីការកាត់បន្ថយភាពក្រីក្រ ។ ការកាត់បន្ថយភាពក្រីក្រ ក្នុងរយៈពេលខ្លី និងមធ្យម គឺអាស្រ័យទៅនឹងការបង្កើនប្រាក់ចំណូល និងការកាត់បន្ថយភាពងាយរកគ្រោះរបស់ប្រជាពលរដ្ឋ ដែលជីវភាពពឹងផ្អែកទៅលើដីធ្លី និងធនធានធម្មជាតិ និងការកាត់បន្ថយភាពងាយរងគ្រោះរបស់ប្រជាពលរដ្ឋ ដែលមានប្រាក់ចំណូលបានមកពីសកម្មភាពមិនមែនកសិកម្ម ហើយដែលប្រាក់ចំនូលទាំងនោះវាអាស្រ័យយ៉ាងខ្លាំងទៅនឹងដីធ្លី និងធនធានធម្មជាតិ ។ យោងតាមហេតុផលនេះ ភាពជាម្ចាស់ និងលទ្ធភាពប្រើប្រាស់ដីធ្លី និងធនធានធម្មជាតិ គឺជាមូលដ្ឋានគ្រឹះនៃការកាត់បន្ថយភាពក្រីក្រ ។ នេះជាបញ្ហាប្រឈមមុខដែលមានសភាពស្មុចស្មាញបំផុត ពីព្រោះនាពេលថ្មីៗនេះ បញ្ហាអភិបាលកិច្ច និងបញ្ហាសិទ្ធិមនុស្សនៃប្រទេសកម្ពុជា បានកើតមានឡើងដ៏ធ្ងន់ធ្ងរបំផុតនៅក្នុងវិស័យទាំងនេះ ។ ការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា គឺអាស្រ័យទៅលើលទ្ធភាព និងសុវត្ថិភាពពេញលេញរបស់ប្រជាជនក្រីក្រ ក្នុងការប្រើប្រាស់ដីធ្លី និងធនធានធម្មជាតិ ។ លទ្ធភាពប្រើប្រាស់ដីធ្លី និងធនធានធម្មជាតិទាំងនេះ អាស្រ័យលើអំណោយផលធម្មជាតិរបស់ប្រទេស ការបែងចែកធនធានដែលមានស្រាប់ និងអភិបាលកិច្ច ។

ច្បាប់ និងគោលនយោបាយថ្មីទាំងឡាយ មានបំណងធ្វើអោយមានសុវត្ថិភាព តម្លាភាព និងគណនេយ្យភាពកាន់តែច្រើននៅក្នុងការបែងចែក និងការរៀបចំឯកសារកម្មសិទ្ធិលើទ្រព្យសម្បត្តិ (រួមទាំងសិទ្ធិជាឯកជនក្នុងការទទួលបានដីធ្លី និងសិទ្ធិប្រើប្រាស់ព្រៃឈើ និងការនេសាទ) ។ ច្បាប់ និងគោលនយោបាយទាំងនេះ គូសបញ្ជាក់ពីដំណើរការផ្ទេររដ្ឋបាលសំរាប់ការគ្រប់គ្រងដីធ្លី និងធនធានធម្មជាតិ ហើយព្យាយាមកំណត់ក្របខ័ណ្ឌអភិបាលកិច្ចរបស់ថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ ។ រដ្ឋាភិបាលកំពុងរៀបចំដាក់អោយអនុវត្ត នូវគោលនយោបាយទាំងនេះតាមរយៈគំរោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី និង គំរោងគ្រប់គ្រងព្រៃសម្បទាន ។

មានដំណើរការជាច្រើន ទាក់ទងនឹងតួនាទីធនធានធម្មជាតិ ជាពិសេស ដីធ្លីនៅក្នុងកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច ដែលជាតម្រូវការចាំបាច់សំរាប់គាំទ្រប្រជាជនក្រីក្រ គឺ :

១). ផ្ទៃដីដាំដំណាំដែលប្រើប្រាស់ដោយគ្រួសារតូចៗ ត្រូវពង្រីង និងពង្រីក ប៉ុន្តែមិនបំផ្លាញព្រៃឈើដែលមានគុណភាពខ្ពស់ ។

២). យន្តការដើម្បីកែលំអការបែងចែកដីដល់អ្នកវិនិយោគកសិកម្ម ត្រូវបង្កើតឡើង ដើម្បីជំរុញសក្តានុពលភាពនៃការដាំដំណាំនានា និងកិច្ចសន្យាដាំដុះ ។

៣). លទ្ធភាពទទួលផលនេសាទ ត្រូវធ្វើអោយកាន់តែមានសមធម៌ និងអាចព្យាករណ៍បាន ហើយប្រព័ន្ធអេកូឡូស៊ីទន្លេសាបទាំងមូល ត្រូវដាក់អោយស្ថិតនៅក្រោមការគ្រប់គ្រងប្រកបដោយនិរន្តរភាព ពីព្រោះទន្លេសាបជាកន្លែងសម្បូរត្រីទឹកសាបបំផុតនៅលើពិភពលោក និង ជាលំនៅឋានរបស់ប្រជាជនជាងមួយលាននាក់ ។

៤). ព្រៃឈើដែលមិនទាន់កាប់ ត្រូវគ្រប់គ្រងប្រកបដោយចិរភាព ដោយមានការបែងចែកផលយ៉ាងទូលំទូលាយ តាមរយៈសេវារបស់រដ្ឋាភិបាលផ្អែកលើចំណូលពីព្រៃឈើ និងតាមរយៈលទ្ធភាពប្រើប្រាស់ផលិតផលព្រៃឈើពីរបស់អ្នកស្រុក ។

៥). សេចក្តីសំរេចអំពីរបៀបប្រើប្រាស់តំបន់ព្រៃរិចរិលសំរាប់ផលប្រយោជន៍សេដ្ឋកិច្ច ត្រូវធ្វើឡើង ដោយមានការថ្លឹងថ្លែងពីតំរូវការរបស់សហគមន៍នៅមូលដ្ឋាន និងបញ្ហាបរិស្ថាន ។

ការចុះបញ្ជី និងការផ្តល់កម្មសិទ្ធិដីធ្លី ត្រូវធ្វើឡើងនៅក្នុងតំបន់ណា ដែលមិនទាន់មានការចុះបញ្ជី ឬមិនទាន់មានផ្តល់កម្មសិទ្ធិដីធ្លី ។ ទន្ទឹមនឹងនេះ បញ្ហាទូទៅនៃការបែងចែក និងការផ្តល់ដីធ្លីដើម្បីបំរើអោយគោលបំណងច្រើនយ៉ាងសំរាប់កិច្ចអភិវឌ្ឍន៍ បាននឹងកំពុងតែចាប់ផ្តើមពិនិត្យមើលដោយរដ្ឋាភិបាល និងអ្នកផ្តល់ជំនួយ ។ ការសំរបសំរួលអន្តរក្រសួងដែលបានកែលំអ កំពុងតែអភិវឌ្ឍឡើងជាមួយក្រុមប្រឹក្សាគោលនយោបាយដីធ្លី ហើយតួនាទីដែលបានកំណត់កាន់តែច្បាស់សំរាប់អាជ្ញាធរមូលដ្ឋាន នៅក្នុងការធ្វើផែនការប្រើប្រាស់ដីធ្លី និងការបែងចែកដីធ្លីកំពុងតែកើតមានឡើង ។ គណៈកម្មាធិការអន្តរមន្ទីរស្តីពីការប្រើប្រាស់ និងការបែងចែកដីធ្លី ត្រូវបានបង្កើតឡើងនៅថ្នាក់ខេត្ត ក្រុង ដើម្បីបំពេញការខ្វះចន្លោះក្នុងការសំរបសំរួល និងកែលំអតម្លាភាពនៅក្នុងរដ្ឋាភិបាល ។ ការបែងចែកដីធ្លីដោយមិនស្មើភាព និងនិន្នាការនៅក្នុងទីផ្សារដីធ្លី គឺជាបញ្ហាកង្វល់ចំបង ។ ការផ្តល់សម្បទានដីសង្គមកិច្ច ការយកពន្ធលើដីធ្លី និងការរៀបចំអោយមានផែនការចែករំលែកដីធ្លី និងការកែលំអហិរញ្ញវត្ថុជនបទ គឺជាកត្តាសំខាន់ក្នុងការពង្រឹងលទ្ធភាពប្រើប្រាស់ដីធ្លី ពីសំណាក់ប្រជាជនក្រីក្រ ។ ដើម្បីធ្វើអោយអន្តរាគមន៍ផ្អែកគោលនយោបាយចំរុះទាំងនេះមានប្រសិទ្ធភាព ទាមទារអោយមានការសិក្សាស្រាវជ្រាវ និងការសិក្សាវាយតំលៃជាច្រើនថែមទៀត ។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងរយៈពេលវែង មានតែការកែលំអប្រាក់ចំណូលដែលមានប្រភពមកពីសកម្មភាពមិនមែន កសិកម្មប៉ុណ្ណោះ ទើបអាចឆ្លើយតបនឹងតំរូវការនៃការមានរកការងារធ្វើរបស់ប្រទេស ។ ឱកាសទាំងនេះ នៅមិនទាន់គ្រប់គ្រាន់នៅឡើយ នេះមានន័យថា លទ្ធភាពប្រើប្រាស់ដីធ្លីនៅតែជាបញ្ហា ជាពិសេសចំពោះជនដែលងាយរងគ្រោះបំផុត ។ កំណើនប្រជាជន នឹងដាក់សំពាធកាន់តែច្រើនមកលើទីក្រុង ក្នុងការរៀបចំ

ផែនការអភិវឌ្ឍន៍ ។ ការអភិវឌ្ឍន៍គោលនយោបាយតាំងលំនៅដ្ឋាន និងគំរោងសាកល្បងនៅក្នុងការកសាងផែនការ និងការកែលំអតារតាំងលំនៅដ្ឋាន ចង្អុលបង្ហាញពីរបៀបពង្រឹងការគ្រប់គ្រងដីធ្លីនៅទីប្រជុំជន ។

ទំនាស់ដីធ្លី និងភាពទន់ខ្សោយនៃប្រព័ន្ធតុលាការ នៅតែចោទជាបញ្ហា ។ គណៈកម្មការសុរិយោដីថ្មី មានបុគ្គលិក និងទទួលបានការបណ្ដុះបណ្ដាល ប៉ុន្តែទើបតែចាប់ផ្ដើមបំពេញការងាររបស់ខ្លួនប៉ុណ្ណោះ ។ ទោះជាយ៉ាងណាក៏ដោយ គណៈកម្មការនេះ តំណាងអោយការបោះជំហានឆ្ពោះទៅរកទំរង់ថ្មីនៃដំណោះស្រាយជំលោះដីធ្លីដោយមានលក្ខណៈសំរុះសំរួល ។ បញ្ហានៅក្នុងសេចក្ដីព្រាងក្រមស៊ីវិល ដែលគំរាមលើសុចរិតភាពនៃការចុះបញ្ជីទ្រព្យសម្បត្តិ ត្រូវតែដោះស្រាយដោយរដ្ឋាភិបាល ដោយមានជំនួយបច្ចេកទេសពីអ្នកផ្ដល់ជំនួយ មុនពេលសេចក្ដីព្រាងក្រមស៊ីវិលនេះ ក្លាយទៅជាច្បាប់ ។ ជាទូទៅ ក្របខ័ណ្ឌអភិបាលកិច្ចដីធ្លី ត្រូវផ្សព្វផ្សាយដោយមានតម្លាភាព និងមានតម្លាភាព នៅក្នុងរដ្ឋាភិបាល ដើម្បីអោយទំរង់ថ្មីនៃការគាំទ្រដល់ប្រជាជនក្រីក្រ ក្នុងការប្រើប្រាស់ដីធ្លីទទួលបានជោគជ័យ ។

ការឆ្លើយតបចំពោះបញ្ហាប្រឈមមុខទាំងនេះ ទាមទារអោយមានការចូលរួមចំណែកយ៉ាងខ្លាំងក្លា និងយូរអង្វែង ដែលនេះគឺជាមូលដ្ឋានសំខាន់នៃមូលដ្ឋានគ្រឹះក្នុងការបែងចែកទ្រព្យសម្បត្តិ ដើម្បីគាំទ្រកសិកម្មប្រពលវប្បកម្ម និងកសិកម្មចំរុះ ហើយកែលំអលទ្ធភាពប្រើប្រាស់ និងការគ្រប់គ្រងធនធានធម្មជាតិ និងទ្រព្យសម្បត្តិរួម ឬធនធានសាធារណៈ ។ ទោះបីជាការសិក្សាស្រាវជ្រាវ បានចាប់ផ្ដើមបំភ្លឺទិដ្ឋភាពជាច្រើនទៀត នៃទំនាក់ទំនងរវាងប្រព័ន្ធគ្រប់គ្រងដីធ្លី និងការកាត់បន្ថយភាពក្រីក្រក្ដី ក៏នៅតែមានការខ្វះចន្លោះចំបង់ៗមួយចំនួន ជាពិសេសគឺការខ្វះចន្លោះក្នុងផ្នែកវិភាគសមត្ថភាពដី ការយល់ដឹងអំពីទីផ្សារដីធ្លីអាចបំរើផលប្រយោជន៍អោយប្រជាជនក្រីក្រ និងការយល់ដឹងអំពីវិធីកែលំអឱកាសរកប្រាក់ចំណូលពីសកម្មភាព ឬការងារមិនមែនកសិកម្ម ។

## ១.២. សម្បទានដីសង្គមកិច្ច

ជាការច្បាស់ណាស់ថា ភាពគ្មានដីធ្លី និងភាពខ្វះដីធ្លី ជាកត្តាសំខាន់រួមចំណែកធ្វើអោយមានភាពក្រីក្រ និងភាពងាយរងគ្រោះសំរាប់ប្រជាជននៅជនបទនៃប្រទេសកម្ពុជា ។ ភាពគ្មានដីធ្លី និងភាពខ្វះដីធ្លី គឺជាផ្នែកមួយនៃការធ្វើអោយបាត់បង់ឱកាស និងគ្មានការងារធ្វើនៅតំបន់ជនបទ ។ គេត្រូវយល់អំពីទស្សនទាននៃការប្រកបរបរចិញ្ចឹមជីវិតចំរុះ ( ស្រូវ និង ត្រី ស្រូវ និងអ្វីផ្សេងទៀត ការបំរើការងារដើម្បីទទួលប្រាក់កំរៃបណ្ដោះអាសន្ន ការបំលាស់ទីទៅតាមរដូវ ។ល។) ។ បើពិចារណាអំពីបញ្ហាគ្មានដីធ្លីនៅក្នុងទស្សនទាននេះ នឹងបង្ហាញអោយឃើញពីបុព្វហេតុ និងរបាយនៃភាពគ្មានដីធ្លី ហើយនឹងបង្ហាញអោយឃើញថាភាពគ្មានដីធ្លី គឺជាបញ្ហាចំបងនៃការប្រកបរបរចិញ្ចឹមជីវិត ដែលជាផ្នែកមួយនៃបញ្ហាប្រឈមមុខយ៉ាងធំរបស់ប្រជាជននៅជនបទ ។ ទោះជាយ៉ាងណាក៏ដោយ ដីធ្លី ជាពិសេស ដីសំរាប់ការផលិតស្រូវ នៅតែជាផ្នែកមួយយ៉ាងសំខាន់នៃសន្តិសុខស្បៀង ។

សម្បទានដីសំរាប់គោលបំណងសង្គមកិច្ច គឺជាយន្តការស្របច្បាប់ក្នុងការផ្ទេរដីពីរដ្ឋ ដែលត្រូវកំណត់នៅក្នុងច្បាប់ភូមិបាលឆ្នាំ២០០១ ។ ការផ្ទេរដីតាមទំរង់នេះ ត្រូវបានដាក់បញ្ចូលនៅក្នុងច្បាប់ភូមិបាល ដើម្បី

អនុញ្ញាតអោយមានការផ្ទេរដីរដ្ឋយ៉ាងត្រឹមត្រូវដល់បុគ្គលជាឯកជន ឬជាក្រុមសំរាប់គោលបំណងសង្គមកិច្ច ។ អនុក្រឹត្យកំណត់ដំណើរការផ្ទេរ ត្រូវបានអនុម័តដោយទីស្ដីការគណៈរដ្ឋមន្ត្រីនៅខែមីនា ឆ្នាំ២០០៣ ។ ទោះជាយ៉ាងណាក៏ដោយ អនុក្រឹត្យនេះ មានសារៈសំខាន់ហួសពីសម្បទានសង្គមកិច្ច ពីព្រោះអនុក្រឹត្យនេះ បង្កើតធាតុសំខាន់ៗ ចំនួនពីរនៃវិធីសាស្ត្រតាមបែបវិមជ្ឈការ និងវិសហមជ្ឈការចំពោះការគ្រប់គ្រងដីធ្លី គឺ (i).អនុក្រឹត្យអនុញ្ញាតអោយការកសាងផែនការប្រើប្រាស់ដីធ្លី ត្រូវធ្វើឡើងនៅថ្នាក់មូលដ្ឋាន និង (ii).អនុក្រឹត្យបង្កើតអោយមានគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង ជារចនាសម្ព័ន្ធអន្តរមន្ទីរ ដោយមានសិទ្ធិអំណាចសំរេចយល់ព្រមផែនការសម្បទានសង្គមកិច្ច ដែលបានដាក់ជូនដោយក្រុមប្រឹក្សាឃុំ សង្កាត់ ។ និយាយម៉្យាងទៀតថា អនុក្រឹត្យនេះ បង្កើតអោយមានធាតុសំខាន់ៗ ចំនួនពីរនៃវិធីសាស្ត្រតាមបែបវិមជ្ឈការ និងវិសហមជ្ឈការចំពោះការគ្រប់គ្រងដីធ្លី ។

គោលបំណងនៃសម្បទានសង្គមកិច្ចនៅក្នុងអនុក្រឹត្យ គឺ :

- ផ្ដល់ដីដល់គ្រួសារក្រីក្រដែលគ្មានទីលំនៅសំរាប់សាងសង់លំនៅឋាន ។
- ផ្ដល់ដីដល់គ្រួសារក្រីក្រសំរាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារ ។
- ផ្ដល់ដីដល់គ្រួសារដែលត្រូវផ្លាស់ប្ដូរទីលំនៅបណ្ដាលមកពីការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈ សំរាប់តាំងលំនៅឋានថ្មី ។
- ផ្ដល់ដីដល់គ្រួសារដែលរងគ្រោះដោយគ្រោះធម្មជាតិ ។
- ជួយសម្រួលដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចនៅមូលដ្ឋាន ។
- ជួយសំរួលដល់សម្បទានដីសេដ្ឋកិច្ច ដោយផ្ដល់ដីឡូតិ៍ដល់កម្មករចំការធំៗ សំរាប់សង់លំនៅឋាន ឬសំរាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារ ។
- អភិវឌ្ឍតំបន់ដែលពុំទាន់ត្រូវបានប្រើប្រាស់នៅតំបន់ជនបទ ។
- ផ្ដល់ដីដល់គ្រួសារមាតុភូមិនិវត្តន៍ ។
- ផ្ដល់ដីដល់យោធិនរំសាយ ។
- ផ្ដល់ដីដល់មន្ត្រីរាជការ នៅពេលគាត់ចាកចេញពីសេវាសាធារណៈ ។

នៅក្នុងក្របខ័ណ្ឌការងារនេះ ដីរដ្ឋ ត្រូវតែបានកំណត់អត្តសញ្ញាណ ចែកជាចំណាត់ប្រភេទ ហើយត្រូវរៀបចំផែនការសំរាប់ប្រើប្រាស់ដីធ្លីទាំងនេះ (រួមមាន ព្រៃឈើ ផ្លូវទឹក ផ្លូវថ្នល់ និង ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនផ្សេងទៀត ឧទ្យាន តំបន់ការពារ រមនីយដ្ឋានវប្បធម៌ ទីកន្លែងសាធារណៈ និងតំបន់សំរាប់យោធាប្រើប្រាស់ ក៏ដូចជាតំបន់ ដែលមិនបានប្រើប្រាស់) ។ នេះជាគោលបំណងនៃការងារនៅក្នុងការធ្វើផែនទីដីរដ្ឋ ដែលកំពុងតែផ្ដួចផ្ដើមឡើងនៅពេលនេះ ហើយនឹងមាននៅក្នុងគំរោងសាកល្បង ។

ដើម្បីសំរេចយល់ព្រមផែនការសម្បទានសង្គមកិច្ច គណៈកម្មាធិការថ្មីមួយ ត្រូវបានបង្កើតឡើងនៅថ្នាក់ខេត្ត ក្រុង មានឈ្មោះថា គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង (PLUAC)។ គេត្រូវការ

គណៈកម្មាធិការដែលមានមន្ទីរជាច្រើន ពីព្រោះក្របខ័ណ្ឌទូទៅនៅក្នុងការគ្រប់គ្រងដីរដ្ឋ ពាក់ព័ន្ធនឹងវិស័យជាច្រើន ។ គណៈកម្មាធិការពហុវិស័យ ពិនិត្យពិចារណាដីនៅទីប្រជុំជន ដីកសិកម្ម ព្រៃឈើ ផ្លូវថ្នល់ ផ្លូវទឹក ទីកន្លែងរដ្ឋាភិបាល ឧទ្យាន និងតំបន់ការពារ រមនីយដ្ឋានវប្បធម៌ តំបន់យោធា និងកន្លែងផ្សេងទៀត ។ ទោះបីជាត្រូវបង្កើតឡើងនៅក្នុងអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ចក្តី គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង ត្រូវបានសង្ឃឹមថា នឹងមានការទទួលខុសត្រូវចំពោះការសំរេចយល់ព្រមលើការធ្វើចំណាត់ប្រភេទដី ការធ្វើផែនការប្រើប្រាស់ដី និងសេចក្តីសំរេចបែងចែកដីរដ្ឋ ទាំងអស់នៅក្នុងខេត្ត ក្រុង ។ គេសង្ឃឹមថា គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង នឹងទទួលសំណើផែនការប្រើប្រាស់ដីលំអិតពីក្រុមប្រឹក្សាឃុំ សង្កាត់ ដែលបង្កើតចេញពីផែនទីដីរបស់រដ្ឋ និងដំណើរការកសាងផែនការប្រើប្រាស់ដីដោយមានការចូលរួម ។ គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង នឹងសំរេចយល់ព្រម ឬ កែសំរួលផែនការទាំងនេះ ។

សម្បទានដីសំរាប់គោលបំណងសង្គមកិច្ច នឹងត្រូវផ្តួចផ្តើម និងអនុវត្តនៅថ្នាក់ឃុំ សង្កាត់សំរាប់ប្រជាពលរដ្ឋរបស់ឃុំ សង្កាត់ ការប្រើប្រាស់ដីទំនេរនៅក្នុងឃុំ សង្កាត់ ឬនៅតំបន់ជិតៗ ដែលស្ថិតនៅក្នុងស្រុក ខណ្ឌតែមួយ ។ បេសកកម្មរបស់រដ្ឋបាលនៅថ្នាក់មូលដ្ឋាន គឺត្រូវផ្តួចផ្តើម និងអនុវត្តផែនការសម្បទានដី ។ រដ្ឋបាលមូលដ្ឋាននឹងធ្វើការងារនេះ ដោយដាក់ពាក្យស្នើសុំរៀបចំផែនការប្រើប្រាស់ដី សំរាប់សម្បទានសង្គមកិច្ចជារៀងរាល់ឆ្នាំ និងអនុវត្តសម្បទានដីទាំងនោះ ។ ក្នុងន័យនេះ ស្ថាប័នដែលមានការទទួលខុសត្រូវចំពោះការអនុវត្តអនុក្រឹត្យនេះ ត្រូវធានាអោយបានថា សម្បទានដីសំរាប់កម្មវិធីសង្គមកិច្ច ត្រូវស្របជាមួយនឹងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ដោយអនុលោមតាមជំពូក៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមរបស់ជាតិ និងធានាថា សំណើប្រើប្រាស់ដីធ្លី ត្រឹមត្រូវតាមលក្ខណៈបច្ចេកទេសជាមួយនឹងដី ដែលបានកំណត់ ។ នីតិវិធី និងផែនការ ត្រូវបានដាក់បញ្ចូលទៅក្នុងដំណើរការកសាងផែនការ និងថវិកាអភិបាលកិច្ចមូលដ្ឋាន ។

## **១.៣. ការសាកល្បង និងការវាយតំលៃកម្មវិធីសម្បទានសង្គមកិច្ចដែលបានស្នើឡើង**

ដោយសារបទពិសោធន៍ដ៏មានកំរិតនៅក្នុងការផ្ទេរដីប្រភេទនេះ ដំណើរការរៀនសូត្រ និងការបង្កើតគំនិតថ្មី ដើម្បីធ្វើអោយការផ្ទេរនេះប្រព្រឹត្តទៅបាន គឺជាការចាំបាច់ ។ នៅក្នុងរយៈពេលខ្លី (ពី១ ទៅ ៣ឆ្នាំ) អាទិភាពទីមួយ នៅក្នុងការប្រើប្រាស់យន្តការសម្បទានដីសង្គមកិច្ច ដើម្បីកាត់បន្ថយភាពក្រីក្រ គឺការបង្កើតអោយមាននីតិវិធី ដែលអាចប្រើប្រាស់បានយូរអង្វែង និងមានតម្លាភាព ហើយអាចអនុវត្តនៅកន្លែងផ្សេងៗគ្នា និងនៅក្នុងបរិបទផ្សេងៗគ្នាបានផងដែរ ។ នៅខែតុលា ឆ្នាំ២០០៣ តំបន់ចំនួនបីរបស់គំរោងសាកល្បង ត្រូវបានជ្រើសរើសសំរាប់អនុវត្តន៍អនុក្រឹត្យ ។ ផ្អែកលើមូលដ្ឋាននៃការសាកល្បងនេះ សេចក្តីណែនាំស្តីពីការអនុវត្ត នឹងត្រូវរៀបចំព្រាងឡើង ហើយផ្សព្វផ្សាយដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។ របាយការណ៍ស្តីពីការវិភាគផលប៉ះពាល់ភាពក្រីក្រ និងសង្គមនេះ សិក្សាវិសាលភាពជាតិ នៃសម្បទានសង្គមទាក់ទងនឹងដីទំនេរ តំរូវការអោយមានសម្បទានសង្គម និងសេវាគាំទ្រសំរាប់អ្នកទទួលផលដែលមានសក្តានុពល ។

## ២. វិធីសាស្ត្រ និងដំណើរការវិភាគផលប៉ះពាល់ភាពក្រីក្រ និងសង្គម

### ២.១. ប្រភពដើមនៃសំណើ

ការវិភាគផលប៉ះពាល់ភាពក្រីក្រ និងសង្គមនៃកម្មវិធីសម្បទានដីសង្គមកិច្ចរបស់កម្ពុជា ត្រូវបានផ្តួចផ្តើមនៅឆ្នាំ២០០៣ ។ ផ្អែកលើការពិភាក្សាជាមួយក្រុមប្រចាំប្រទេសនៅកម្ពុជា សមាជិករបស់ក្រុមមូលនិធិរូបិយវត្ថុអន្តរជាតិ ប្រចាំប្រទេស ក្រុមវិភាគផលប៉ះពាល់ភាពក្រីក្រនិងសង្គមរបស់អង្គការ GTZ និងជាមួយសមាជិកក្រុមស្នូលវិភាគផលប៉ះពាល់ភាពក្រីក្រនិងសង្គមរបស់ធនាគារ ស្តីពីរបៀបវារៈកំណែទំរង់គោលនយោបាយរបស់កម្ពុជា គេសំរេចធ្វើការស្រាវជ្រាវផលប៉ះពាល់ដែលមានសក្តានុពលរបស់កម្មវិធីបែងចែកដីដែលបានស្នើឡើង ។ ការកែទំរង់គោលនយោបាយដែលកំណត់លើលទ្ធភាពប្រើប្រាស់ និងការគ្រប់គ្រងធនធានធម្មជាតិ ជាពិសេសដីសំរាប់កសិកម្ម ត្រូវបានសង្ឃឹមថា នឹងបង្កើនសក្តានុពលភាពកំណើនសេដ្ឋកិច្ច និងជីវភាពរបស់ប្រជាជនក្រីក្ររួមទាំងលទ្ធភាពបង្កើនតំលៃបន្ថែម តាមរយៈការកែច្នៃ ទីផ្សារ ការនាំចេញ និងការកែទំរង់ ។ ការកែទំរង់ ត្រូវបានសង្ឃឹមថា នឹងមានផលប៉ះពាល់នៅក្នុងការបែងចែកជាវិជ្ជមាន និងមានផលប៉ះពាល់នៅក្នុងការកាត់បន្ថយភាពក្រីក្រជាដុំកំភួន ។

នៅក្នុងការគាំទ្រកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាលើការកាត់បន្ថយភាពក្រីក្រ តាមរយៈការកែលំអលទ្ធភាពប្រើប្រាស់ដីធ្លី ធនាគារបានពិចារណាគាំទ្រលើប្រតិបត្តិការវិនិយោគ ដើម្បីជួយសំរួលដល់ការអនុវត្តយ៉ាងពេញលេញលើកម្មវិធីសម្បទានសង្គមកិច្ច ។ ផ្អែកលើការរកឃើញនៅក្នុងការវិភាគផលប៉ះពាល់ភាពក្រីក្រ និងសង្គម (PSIA) និងបទពិសោធន៍ពីកន្លែងសាកល្បង គេកំពុងរៀបចំសំណើនៅពេលនេះ ។ ដូច្នេះ ការវាយតំលៃលើផលប៉ះពាល់ជាសក្តានុពលនៃទំរង់សម្បទានសង្គមកិច្ច ជាផ្នែកមួយយ៉ាងសំខាន់នៃយុទ្ធសាស្ត្រគាំទ្ររយៈពេលវែងសំរាប់ការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ។

### ២.២. គ្រោងការស្រាវជ្រាវ និងដៃគូ

#### ២.២.១. កំណត់សំគាល់ទស្សនទាន

កំណត់សំគាល់ទស្សនទានសំរាប់ការវិភាគផលប៉ះពាល់ភាពក្រីក្រ និងសង្គម (PSIA) ត្រូវបានរៀបចំនៅរវាងខែឧសភា និង ខែសីហា ឆ្នាំ២០០៣ ។ កំណត់សំគាល់នេះ បានពន្យល់ពីវិធីសាស្ត្រវិភាគផលប៉ះពាល់ភាពក្រីក្រ និងសង្គម (PSIA) សំរាប់វិភាគសំណើកម្មវិធីបែងចែកដី និងបានគូសបញ្ជាក់វិធានទាំងឡាយ និងតម្លាភាពនៃដំណើការស្រាវជ្រាវដោយមានការចូលរួមដែលត្រូវបានលើកឡើង ។ នៅថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៣ ការប្រជុំពិនិត្យវាយតំលៃ ត្រូវបានធ្វើឡើង ដែលនៅក្នុងការប្រជុំនេះ ក៏ប្រមូលបាននូវមតិយោបល់ត្រលប់មកវិញដ៏មានតំលៃលើការស្រាវជ្រាវដែលបានស្នើឡើងផងដែរ ។

មតិយោបល់ពីអ្នកពិនិត្យវាយតំលៃ បានបញ្ជាក់ពីសារៈសំខាន់នៃការស្រាវជ្រាវដែលបានស្នើឡើងនេះ ។ គេបានលើកឡើងថា ទំនាក់ទំនងនៃការរកឃើញនៅក្នុងការស្រាវជ្រាវជាមួយនឹងការរៀបចំគោលនយោបាយ និង

កម្មវិធី និងជាមួយសកម្មភាពតាមដានត្រួតពិនិត្យ និងវាយតំលៃ នឹងត្រូវបានបញ្ជាក់យ៉ាងច្បាស់លាស់ ។ ការសិក្សាស្រាវជ្រាវ គួរពិនិត្យលើបញ្ហាសេដ្ឋកិច្ចនយោបាយដែលពាក់ព័ន្ធ ហើយគួរកំណត់ពីហានិភ័យដែលពាក់ព័ន្ធនឹងសំណើកំណែទំរង់នេះ ។ បញ្ហាដីទំនេរ និងជំរើសតាំងទីលំនៅ ត្រូវបានមើលឃើញ ថាជាប្រធានបទដ៏សំខាន់ផ្សេងទៀត សំរាប់ការសិក្សាស្រាវជ្រាវ ។ សកម្មភាពអង្កេត នឹងត្រូវរៀបចំឡើង ដើម្បីរកអោយឃើញនូវទិដ្ឋភាពរួមនៃបញ្ហា នៅទូទាំងក្នុងប្រទេស ។ វិធីសាស្ត្រស្រាវជ្រាវដោយមានការចូលរួមដែលបានស្នើឡើង ត្រូវបានវាយតំលៃខ្ពស់ ប៉ុន្តែក៏មានការលើកឡើងផងដែរថា ដៃគូស្រាវជ្រាវ គួរទទួលបានការណែនាំ ហើយគួរធានាអោយមានកិច្ចសហប្រតិបត្តិការ និងការសំរបសំរួលយ៉ាងជិតស្និទ្ធ ។

## ២.២.២. ក្រុមស្រាវជ្រាវ និងភារកិច្ច

ដើម្បីធានាអោយមានតំណាងមកពីអ្នកពាក់ព័ន្ធផ្សេងៗគ្នានៅក្នុងការស្រាវជ្រាវ ក្រុមសិក្សាស្រាវជ្រាវត្រូវបានរៀបចំអោយមានសមាសភាពមកពីដៃគូផ្សេងៗគ្នា និងធ្វើការសិក្សាស្រាវជ្រាវលើទិដ្ឋភាពផ្សេងៗ នៃការស្រាវជ្រាវ ដោយផ្អែកទៅតាមបទពិសោធន៍ និងចំណុចខ្លាំងរបស់ដៃគូទាំងនេះ ក្នុងការរួមចំណែកដល់ការវាយតំលៃយ៉ាងហ្មត់ចត់ លើកម្មវិធីសម្បទានសង្គមកិច្ច ។ ការសិក្សាស្រាវជ្រាវ ត្រូវបានបែងចែកជាផ្នែកផ្សេងៗ ដែលចង្អុលបង្ហាញពីទិដ្ឋភាពសំខាន់ៗនៃកម្មវិធីសម្បទានសង្គមកិច្ច ។ គេគិតថា ការវិភាគនឹងធ្វើឡើង ដើម្បីដោះស្រាយបញ្ហាចំបងចំនួន បួនគឺ :

### ១). សក្តានុពលផលប៉ះពាល់សេដ្ឋកិច្ច និងសង្គមកិច្ច

(១) អង្កេតភាពក្រីក្រ និងផលប៉ះពាល់ផ្នែកសង្គមនៃយន្តការបែងចែកដីដែលបានស្នើឡើង ។

(២) កំណត់ថាតើវិធានការដែលបានប្រមើលមើល អាចការពារជនក្រីក្រអោយចៀសផុតពីការទន្ទ្រានយកដី និងគាំទ្រ ជនក្រីក្រនៅក្នុងការដោះស្រាយទំនាស់ដីធ្លី ។

### ២). គ្រោងការ និងការអនុវត្ត

(៣) ផ្តោតជាពិសេសទៅលើលក្ខណៈវិនិច្ឆ័យដែលបានស្នើឡើងសំរាប់ការបែងចែកដីឡើងវិញ ដោយពិចារណាទៅលើភាពក្រីក្រ ការរួមបញ្ចូល (ជនជាតិដើមភាគតិច យេនឌ័រ) និងភាពងាយរងគ្រោះ ។

(៤) វាយតំលៃយន្តការតម្លាភាព និងគណនេយ្យភាព (ផ្នែកសង្គម និងច្បាប់) នៃដំណើរការបែងចែកដីធ្លី និងស្ថាប័នដែលពាក់ព័ន្ធ ។

### ៣). ហេដ្ឋារចនាសម្ព័ន្ធ និងសេវាដែលត្រូវការបន្ថែម

(៥) វាយតំលៃតំរូវការនៃវិធានការគាំទ្របន្ថែម ដើម្បីទទួលបានតំលៃបន្ថែមពីដីដែលបានបែងចែក ។

៤). ភាពគ្មានដីធ្លី និង ដីទំនេរដែលមានសក្តានុពល

(៦) វាយតំលៃដីទំនេរដែលមានសក្តានុពលសំរាប់បែងចែកនៅកន្លែងផ្សេងៗ នៅក្នុងប្រទេស និង

(៧) ប្រៀបធៀបតួលេខខាងលើជាមួយនឹងកំរិតនៃភាពគ្មានដីធ្លី និងអាទិភាពប្រចាំតំបន់ដែលទាមទារ និង ផលវិបាកដែលបានរំពឹងទុកសំរាប់កម្មវិធី ។

ការវិភាគផលប៉ះពាល់ភាពក្រីក្រ និងសង្គមលើកម្មវិធីសម្បទានដីសង្គមកិច្ចដែលបានគ្រោងឡើងនៅកម្ពុជា ត្រូវបានធ្វើឡើងនៅចន្លោះពីខែឧសភា ឆ្នាំ២០០៣ ដល់ខែឧសភា ឆ្នាំ២០០៤ ។ ការងារនេះ ត្រូវបានធ្វើឡើង រួមគ្នារវាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អង្គការGTZ អង្គការOxfam-GB វិទ្យាស្ថានកសិ-អាជីវកម្មកម្ពុជា (ABiC) និងធនាគារពិភពលោក ។ គេសង្ឃឹមថា ការវិភាគផលប៉ះពាល់ភាពក្រីក្រ និងសង្គម (PSIA) នឹងផ្តល់យោបល់ដ៏មានតំលៃលើសក្តានុពលភាព ការលំបាក និងអនុសាសន៍ជាក់ស្តែង សំរាប់ការរៀបចំកាត់តែង ការកែសំរួល និងការអនុវត្តគោលនយោបាយ ។ ដើម្បីចងក្រងជាឯកសារយ៉ាងល្អ អំពីការលំបាកនៅក្នុងការអនុវត្តយ៉ាងពេញលេញលើកម្មវិធីសម្បទានដីសង្គមកិច្ច រាជរដ្ឋាភិបាលកម្ពុជា នឹងអាចកៀងគរការគាំទ្រពីអ្នកផ្តល់ជំនួយសំរាប់កម្មវិធីដ៏ធំនេះ ។

## ២.៣. វិធីសាស្ត្រ

ប៉ារ៉ាម៉ែត្រជាមូលដ្ឋានសំរាប់ការស្រាវជ្រាវ ត្រូវបានបញ្ជាក់នៅក្នុងកំណត់សំគាល់ទស្សនទាន ហើយបានផ្តល់ជាមូលដ្ឋាន សំរាប់ការពិភាក្សានៅក្នុងប្រទេសលើវិធីសាស្ត្រស្រាវជ្រាវអោយមានលក្ខណៈសមស្រប និងជាក់ស្តែង ។ នៅមុនពេលរៀបចំគ្រោងការសិក្សាស្រាវជ្រាវនៅមូលដ្ឋានផ្ទាល់ មានការចងក្រង និងពិនិត្យមើលឯកសារ និងការងារដែលបានគ្រោងទុក និងការងារដែលកំពុងដំណើរការ ពាក់ព័ន្ធនឹងកំណែទំរង់ដីធ្លី ។ ការធ្វើបែបនេះ គឺដើម្បីធានាអោយមានភាពស្របគ្នានៅក្នុងការសិក្សា ជាមួយនឹងការអង្កេតដែលមានស្រាប់ និងដែលបានគ្រោងឡើង ទាក់ទងនឹងមាតិកានៃឯកសារ ។

គ្រោងការ និងឧបករណ៍សិក្សាស្រាវជ្រាវដែលបានរៀបចំឡើង ដោយសហការជាមួយដៃគូស្រាវជ្រាវសំខាន់ៗ ត្រូវបង្ហាញជូន និងពិភាក្សាជាមួយវិទ្យាស្ថានកសិ-អាជីវកម្មកម្ពុជា នៅក្នុងសិក្ខាសាលាបច្ចេកទេសនាទីក្រុងភ្នំពេញ ។ ការពិគ្រោះយោបល់ និងសិក្ខាសាលាមានបំណង : (ក).ធានាអោយមានគ្រោងការសមស្រប នៅក្នុងការសិក្សាស្រាវជ្រាវ (ខ).ផ្តល់សុពលភាពដល់វិធីសាស្ត្រ និងឧបករណ៍ដែលបានស្នើឡើង និង (គ).បង្កើតវេទិកាសំរាប់ការសហការ និងការចែករំលែកព័ត៌មានជាមួយស្ថាប័ន និងអ្នកសិក្សាស្រាវជ្រាវពាក់ព័ន្ធ ។ អ្នកពាក់ព័ន្ធនៅក្នុងដំណើរការរួមមាន វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវ ដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) អង្គការ Oxfam អង្គការ GTZ វិទ្យាស្ថានសេដ្ឋកិច្ចនៃកម្ពុជា (EIC) អង្គការ ADHOC ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិប្រទេសអូស្ត្រាលី (AusAID) គំរោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី/ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (LMAP/MLMUPC) ធនាគារអភិវឌ្ឍន៍អាស៊ី វេទិកាអង្គការមិនមែនរដ្ឋាភិបាល និងតំណាងគំរោងផ្សេងទៀត ។

ការវិភាគផលប៉ះពាល់ភាពក្រីក្រ និងសង្គម (PSIA) បានផ្តោតយ៉ាងខ្លាំងទៅលើដំណើការ ពោល គឺទៅលើការបង្កើតវេទិកាសំរាប់ការពិភាក្សាជាចំហ លើកំណែទំរង់គោលនយោបាយដែលបានស្នើឡើង ។ ការផ្តោតនេះត្រូវបានមើលឃើញថា ជាផ្នែកស្មើគ្នាមួយនៃការស្រាវជ្រាវ បន្ទាប់ពីការផ្តល់មាតិកាសំរាប់ឆ្លើយសំណួរស្រាវជ្រាវដែលបានតាក់តែង ។ ទីបំផុត ការវិភាគផលប៉ះពាល់ភាពក្រីក្រ និងសង្គម (PSIA) មិនអាចផ្តល់ចំលើយទាំងអស់ដល់ការងារស្រាវជ្រាវដែលបានពិពណ៌នានៅក្នុងផ្នែក ២.២.២ ឡើយ ។ ការកំណត់ទំហំផលប៉ះពាល់ជាសក្តានុពល និងការតំលៃនៃការចំណាយលើការអនុវត្តគំរោងជួបការលំបាក ដោយសារមិនមានទិន្នន័យ និងព័ត៌មានដែលពាក់ព័ន្ធសំរាប់ធ្វើការវិភាគ ។ វិធីសាស្ត្រដែលបានស្នើឡើង ត្រូវបានអនុវត្តដោយមានការយល់ខុសខ្លះអំពីទិន្នន័យ និងព័ត៌មានដែលមាន ហើយមិនមានការអនុញ្ញាតគ្រប់គ្រាន់ក្នុងការប្រមូលទិន្នន័យដំបូងលើប្រធានបទទាំងនេះ ។

ចំណុចខ្លាំងនៅក្នុងវិធីសាស្ត្រ គឺដំណើរការស្រាវជ្រាវប្រកបដោយការចូលរួម និងតម្លាភាព ដែលផ្តល់ឱកាសយ៉ាងទូលំទូលាយសំរាប់ការផ្លាស់ប្តូរមតិយោបល់ កង្វល់ និងការគាំទ្ររវាងរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងសហគមន៍អ្នកផ្តល់ជំនួយ ។ វិធីសាស្ត្រថ្មីនេះ ធ្វើអោយការវិភាគផលប៉ះពាល់ភាពក្រីក្រ និងសង្គម (PSIA) មានលក្ខណៈខុសប្លែកពីការសិក្សាធម្មតាផ្សេងទៀត ។ បរិយាកាសបំពេញការងារ ដែលបានបង្កើតឡើង បានជួយបញ្ចៀសការពិភាក្សាដែលមានលក្ខណៈប្រឈមមុខគ្នា ដែលជាញឹកញាប់គ្របដណ្តប់លើពិភាក្សាអំពីគោលនយោបាយគ្រប់គ្រងធនធានធម្មជាតិនៅកម្ពុជា ។

## ២.៣.១. ឧបករណ៍ស្រាវជ្រាវ

ការសិក្សាវាយតំលៃជនបទដោយមានការចូលរួម (PRA) ការពិភាក្សាតាមក្រុម និងការអង្កេតតាមគ្រួសារដែលបានជ្រើសរើស ត្រូវបានប្រើប្រាស់ដើម្បីប្រមូលទិន្នន័យបរិមាណ និងគុណភាពសំរាប់ការសិក្សា ។ ក៏រិតនៃការប្រើប្រាស់ឧបករណ៍ទាំងនេះ មានលក្ខណៈខុសៗគ្នា ។

ការសិក្សាវាយតំលៃជនបទដោយមានការចូលរួម (PRA) និងការពិភាក្សាតាមក្រុម ត្រូវបានធ្វើឡើងនៅថ្នាក់ឃុំ ស្រុក និងខេត្ត ជាមួយមន្ត្រីសំខាន់ៗ និងថ្នាក់ភូមិជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ និងអ្នកភូមិក្រីក្រ និងមិនក្រីក្រ ដើម្បីវាយតំលៃទស្សនៈរបស់គាត់អំពីកម្មវិធីបែងចែកដីដែលបានស្នើឡើង រីឯការអង្កេតតាមគ្រួសារ (HHS) ត្រូវបានប្រើប្រាស់នៅតាមគ្រួសារ ។ ក្រុមសិក្សាស្រាវជ្រាវ បានចំណាយពេលប្រហែល៣ថ្ងៃ នៅក្នុងឃុំគោលដៅនីមួយៗ ។

ការណែនាំយ៉ាងច្បាស់សំរាប់ឧបករណ៍សិក្សាវាយតំលៃជនបទដោយមានការចូលរួម ការពិភាក្សាតាមក្រុម និងការអង្កេតតាមគ្រួសារ ត្រូវបានរៀបចំតាក់តែងឡើង និងធ្វើការសាកល្បងជាមុននៅកន្លែងសាកល្បងរបស់កម្មវិធីសម្បទានដីសង្គមកិច្ចនៅខេត្តកំពង់ស្ពឺ ។ ការប្រើប្រាស់ស្របតាមលក្ខណៈបច្ចេកទេស និងមានលក្ខណៈគ្រប់គ្រាន់លើឧបករណ៍ទាំងនេះ ត្រូវបានធានាដោយបុគ្គលិកអង្កេត នៅតាមមូលដ្ឋានផ្ទាល់ដែលបានទទួលការបណ្តុះបណ្តាលច្បាស់លាស់ និងមានបទពិសោធន៍គ្រប់គ្រាន់ ។ នៅមុនពេលធ្វើការសាកល្បង និងការស្រាវជ្រាវ

នៅមូលដ្ឋាន ក្រុមបានទទួលការបណ្ដុះបណ្ដាលរំលឹកឡើងវិញរយៈពេលមួយសប្ដាហ៍ ។ ទស្សនទានដែលពាក់ព័ន្ធអំពីកម្មវិធីសម្បទានដីសង្គមកិច្ច ត្រូវបានពន្យល់ដល់ក្រុមសិក្សាស្រាវជ្រាវ ដោយមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលមានវត្តមាននៅក្នុងវគ្គបណ្ដុះបណ្ដាលរំលឹកឡើងវិញ គ្រប់ពេលទាំងអស់ ។

## ២.៣.២. ការជ្រើសរើសសំណាក

ដើម្បីទទួលបានលទ្ធផលដែលមានលក្ខណៈតំណាងអោយទូទាំងប្រទេស ការសិក្សាត្រូវបានធ្វើឡើង នៅក្នុងខេត្តពីរ ដែលបានជ្រើសរើសឡើងដោយចៃដន្យនៅក្នុងតំបន់កៀត្រ-បរិស្ថានចំនួនបួន ដែលបានកំណត់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅឆ្នាំ១៩៨៦ ។ ការជ្រើសរើសដោយចៃដន្យ ត្រូវបានអនុវត្តជាថ្មីទៀតសំរាប់ឃុំ ភូមិ និងគ្រួសារ ។ ឃុំចំនួនប្រាំមកពីខេត្តនីមួយៗ និងភូមិចំនួន១៥ មកពីឃុំនីមួយៗ ត្រូវបានជ្រើសរើសសំរាប់ការសិក្សាស្រាវជ្រាវ ។ ចំពោះខេត្តខ្លះ ដែលឃុំមានទំហំតូច ភូមិទាំងអស់ត្រូវបានដាក់បញ្ចូលដោយមិនបាច់ធ្វើការជ្រើសរើសដោយចៃដន្យ ហើយភូមិដែលនៅសល់ត្រូវជ្រើសរើសដោយចៃដន្យ ពីឃុំផ្សេងទៀតនៅក្នុងខេត្តជាមួយគ្នា ។ ករណីនេះ កើតមានឡើងនៅខេត្តកោះកុង និងខេត្តស្ទឹងត្រែង ។ ជាចុងក្រោយ គ្រួសារចំនួន១០ ត្រូវជ្រើសរើស ពីភូមិនីមួយៗសំរាប់ការអង្កេតតាមគ្រួសារ ។ តារាងទី១ បង្ហាញដោយសង្ខេបនូវព័ត៌មានអំពីចំនួនសំណាក សំរាប់ការសិក្សាស្រាវជ្រាវ សំរាប់ការផ្តោតនៅតាមកំរិតនៃការសិក្សាស្រាវជ្រាវផ្សេងៗគ្នា ។

**តារាងទី១ : ចំនួនសំណាក**

| | មេគង្គ | ទន្លេសាប | ឆ្នេរសមុទ្រ | ព្រៃសាន្ត | សរុប |
|---|---|---|---|---|---|
| ចំនួនខេត្តធ្វើការសិក្សាវាយតំលៃជនបទដោយមានការចូលរួម | ១ | ១ | ១ | ១ | ៤ |
| ចំនួនស្រុកធ្វើការសិក្សាវាយតំលៃជនបទដោយមានការចូលរួម | ២ | ២ | ២ | ២ | ៨ |
| ចំនួនឃុំធ្វើការសិក្សាវាយតំលៃជនបទដោយមានការចូលរួម | ១០ | ១០ | ១០ | ១០ | ៤០ |
| ចំនួនក្រុមគោលដៅសំរាប់ការពិភាក្សាតាមភូមិ | ៣០ | ៣០ | ៣០ | ៣០ | ១២០ |
| ចំនួនការអង្កេតតាមគ្រួសារ | ៣០០ | ៣០០ | ៣០០ | ៣០០ | ១.២០០ |

ផែនទី១ : តំបន់កសិ្សត្រ_បរិស្ថាននៅកម្ពុជា




គួរកត់សំគាល់ថា ចំនួនតំបន់ ឬសំណាកសំរាប់ការសិក្សាស្រាវជ្រាវនេះ ត្រូវបានអនុវត្តជាទូទៅ ដោយមិនគិតអំពីចំនួនប្រជាជននៅក្នុងតំបន់នីមួយៗ ។ ការធ្វើបែបនេះ មានបំណងទទួលបានព័ត៌មានពីទិដ្ឋភាពផ្សេងៗគ្នានៅក្នុងតំបន់ អោយបានច្រើនតាមដែលអាចធ្វើបាន ដូចជា ទំនៀមទំលាប់ វប្បធម៌ និងប្រពៃណីនៅក្នុងការប្រកបរបរចិញ្ចឹមជីវិត ។ ឧទាហរណ៍ នៅភូមិភាគឦសាន្ត មានសហគមន៍ជនជាតិដើមភាគតិចខុសៗគ្នាជាច្រើន ។ ក្នុងករណីនេះ សំណាកសមាមាត្រ ធៀបនឹងចំនួនសំណាក នឹងធ្វើអោយសំណាកដែលមានទំហំតូច អាចកាត់បន្ថយលទ្ធភាពជ្រើសរើសក្រុម ឬបុគ្គលផ្សេងគ្នា សំរាប់ការសិក្សាស្រាវជ្រាវ ។ អាស្រ័យហេតុនេះ គេមិនប្រើប្រាស់សំណាក់បែបនេះទេ ។ នៅក្នុងផ្នែកខាងក្រោម នឹងបង្ហាញជូនពីការរកឃើញរបស់ការសិក្សាស្រាវជ្រាវ ។

## ២.៣.៣. វិធីសាស្ត្រសំរាប់វាយតំលៃភាពគ្មានដីធ្លី (ការប្រមូលព័ត៌មានអំពីភាពគ្មានដីធ្លី និងការអភិវឌ្ឍរបស់អង្គការអុកស្វាមអង់គ្លេស)

ចំពោះការសិក្សាវាយតំលៃលំអិតអំពីភាពគ្មានដីធ្លី ភាពក្រីក្រដោយគ្មានដីធ្លី និងមូលហេតុ អង្គការអុកស្វាមប្រើប្រាស់ "ការប្រមូលព័ត៌មានអំពីភាពគ្មានដីធ្លី និងការអភិវឌ្ឍ (LADIT)" នៅក្នុងឃុំ និងភូមិដែលបានជ្រើសរើស [៦] ។

---

[៦] ការប្រមូលព័ត៌មានអំពីភាពគ្មានដីធ្លី និងការអភិវឌ្ឍ (LADIT) ត្រូវបានបង្កើតឡើង នៅឆ្នាំ១៩៩៩ ដោយអង្គការអុកស្វាមអង់គ្លេស ហើយត្រូវបានសាកល្បងនៅកន្លែងផ្ទាល់ ដោយសហការជាមួយអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក "អ្នកអភិវឌ្ឍន៍សហគមន៍" និង "សន្តិសេនា" ។ ការប្រមូលព័ត៌មានអំពីភាពគ្មានដីធ្លី និងការអភិវឌ្ឍ (LADIT) ត្រូវបានប្រើប្រាស់ដោយអង្គការអុកស្វាមអង់គ្លេស ក្រសួងអភិវឌ្ឍន៍ជនបទ និងអង្គការអភិវឌ្ឍន៍ចំនួន៤៥ នៅក្នុងការស្រាវជ្រាវពីភាពគ្មានដីធ្លី និងការអភិវឌ្ឍដែលមានសរសេរ នៅក្នុងរបាយការណ៍អង្គការអុកស្វាមអង់គ្លេស "ការធ្វើឱ្យគេមើលឃើញជនក្រីក្រកាន់តែច្បាស់ : តើដីទាំងអស់ទៅណា? ភាគ៤" ។

ការប្រមូលព័ត៌មានអំពីភាពគ្មានដីធ្លី និងការអភិវឌ្ឍ (LADIT) មានគោលបំណងចំនួនពីរគឺ :

- ដើម្បីប្រមូលព័ត៌មានអំពីវិសាលភាព និងបុព្វហេតុនៃភាពគ្មានដីនៅជនបទ និងផលប៉ះពាល់នៃសកម្មភាពអភិវឌ្ឍន៍មកលើភាពគ្មានដី ។ ជាងនេះទៀត គឺដើម្បីប្រមូលព័ត៌មានអំពីភាពខ្វះដី និងការប្រកបរបរចិញ្ចឹមជីវិតរបស់អ្នកគ្មានដីធ្លីនិង អ្នកខ្វះដី [៧] ។
- ដើម្បីបង្កើនការយល់ដឹងពីភាពគ្មានដី ជាពិសេសដោយបង្កើតដំណើរការសិក្សាស្រាវជ្រាវដែលពាក់ព័ន្ធនឹងការធ្វើអោយអ្នកស្រាវជ្រាវចុះទៅតាមភូមិ និងចំណាយពេលជួប និងស្តាប់ប្រជាជនដែលគ្មានដី និងខ្វះដី ។

ដើម្បីធ្វើការស្រាវជ្រាវ អ្នកស្រាវជ្រាវចុះទៅភូមិ ហើយសំរាកនៅទីនោះ ដើម្បីប្រមូលទិន្នន័យទីមួយ ។ នៅក្នុងអំឡុងពេលនោះ ភារកិច្ចខាងក្រោម ត្រូវបានអនុវត្ត :

- ការសំភាសន៍ជាមួយមេភូមិ ឬអ្នកដឹកនាំភូមិដែលមានការគោរពពីអ្នកភូមិ
- ការអង្កេតតាមគ្រួសារទាំងអស់ដែលគ្មានដី និងមានដីតិចតួច
- ក្រុមពិភាក្សាប្រមូលព័ត៌មានអំពីភាពគ្មានដីធ្លី និងការអភិវឌ្ឍ (LADIT) ដោយមានការចូលរួមពីអ្នកភូមិ១៦នាក់ គឺបុរស៨នាក់ និង នារី៨នាក់ ដោយមានមនុស្សចាស់៤នាក់ អ្នកដឹកនាំភូមិ៤នាក់ និងសមាជិកនៅក្នុងគ្រួសារចំនួន៤ ដែលមានដីតិចតួច និង គ្រួសារចំនួន៤ ដែលគ្មានដី ។

ចំណុចពិសេសនៃការ ប្រមូលព័ត៌មានអំពីភាពគ្មានដីធ្លី និងការអភិវឌ្ឍ (LADIT) ដែលលើកទឹកចិត្តដល់ការឆ្លុះបញ្ចាំងរបស់បុគ្គលិកអភិវឌ្ឍន៍ គឺ :

- គេតំរូវអោយអ្នកសំរបសំរួលការប្រមូលព័ត៌មានអំពីភាពគ្មានដីធ្លី និងការអភិវឌ្ឍ (LADIT) ចុះទៅជួបគ្រួសារដែលគ្មានដីនីមួយៗ នៅគេហដ្ឋានរបស់គាត់ផ្ទាល់ ដូច្នេះបានសង្កេតឃើញពីជីវិតលក្ខណះ និងស្ថានភាពរបស់អ្នកទាំងនេះ
- ក្រុមពិភាក្សាប្រមូលព័ត៌មានអំពីភាពគ្មានដីធ្លី និងការអភិវឌ្ឍ (LADIT) ធ្វើអោយបុគ្គលិកអភិវឌ្ឍន៍ (អ្នកសំរបសំរួលការ ប្រមូលព័ត៌មានអំពីភាពគ្មានដីធ្លី និងការអភិវឌ្ឍ (LADIT)) យល់ដឹងពីការវិនិច្ឆ័យរបស់អ្នកភូមិអំពីប្រសិទ្ធភាពនៃសកម្មភាពអភិវឌ្ឍន៍ទាក់ទងនឹងបញ្ហានៃភាពគ្មានដីធ្លី ។

---

[៧] ចំណុចខាងក្រោយនេះ ត្រូវបានកែសំរួល ដើម្បីអោយស្របទៅនឹងការប្រមូលព័ត៌មានអំពីភាពគ្មានដីធ្លី និងការអភិវឌ្ឍ (LADIT) សំរាប់ការស្រាវជ្រាវវិភាគផលប៉ះពាល់ភាពក្រីក្រ និងសង្គម (PSIA) ។

## ២.៣.៤. ការពិគ្រោះយោបល់ និងសិក្ខាសាលានៅក្នុងប្រទេស

តម្លាភាព និងការចូលរួម គឺជាទស្សនទានគន្លឹះនៅក្នុងដំណើរការសិក្សាស្រាវជ្រាវទាំងមូល ។ ការពិគ្រោះយោបល់របស់បុគ្គលម្នាក់ៗ និងសិក្ខាសាលាចែករំលែកព័ត៌មានដំបូង ត្រូវបានធ្វើឡើងនៅទីក្រុងភ្នំពេញ ក្នុងខែឧសភា ឆ្នាំ២០០៣ ដើម្បីផ្តល់ព័ត៌មានអំពីសំណើស្រាវជ្រាវវិភាគផលប៉ះពាល់ភាពក្រីក្រ និងសង្គម (PSIA) ដល់អ្នកពាក់ព័ន្ធដែលមានការចាប់អារម្មណ៍ ។ ទស្សនទាននៃការសិក្សាស្រាវជ្រាវ ត្រូវបានពិភាក្សានៅក្នុងអំឡុងពេលសិក្ខាសាលាដែលមានការចូលរួមយ៉ាងផុលផុស នៅទីក្រុងភ្នំពេញ ដើម្បីទទួលយោបល់ត្រលប់មកវិញ ដើម្បីរៀបចំវិធីសាស្ត្រអោយបានប្រសើរ ។ សិក្ខាសាលាដោយឡែក ត្រូវបានធ្វើឡើង ដើម្បីទទួលយោបល់ត្រលប់មកវិញ អំពីវិធីសាស្ត្រស្រាវជ្រាវដែលបានស្នើឡើង ។ លទ្ធផលស្រាវជ្រាវពីការសិក្សា "បន្ទាប់បន្សំ" ផ្សេងៗទៀត ត្រូវបានចែករំលែកនៅក្នុងចំណោមដៃគូ ដើម្បីអោយមានការផ្តល់មតិយោបល់ ហើយបន្ទាប់មកត្រូវបានផ្សព្វផ្សាយ សំរាប់ធ្វើការពិភាក្សាអោយកាន់តែទូលំទូលាយ ។

នៅខែឧសភា ឆ្នាំ២០០៤ សិក្ខាសាលារយៈពេលមួយថ្ងៃ ត្រូវបានធ្វើឡើង ដើម្បីចែករំលែកការរកឃើញ និងអនុសាសន៍ពីវិភាគផលប៉ះពាល់ភាពក្រីក្រ និងសង្គម (PSIA) ។ អ្នកចូលរួមនៅក្នុងសិក្ខាសាលាជិត១០០នាក់ មកពីស្ថាប័នរដ្ឋាភិបាលនៅថ្នាក់ជាតិ និងនៅមូលដ្ឋាន អ្នកផ្តល់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាល បានពិភាក្សាពីការរកឃើញ និងអនុសាសន៍នៃសំយោគការវិភាគផលប៉ះពាល់ភាពក្រីក្រ និងសង្គម (PSIA) ហើយផ្តល់មតិយោបល់ដ៏មានប្រយោជន៍សំរាប់ការរៀបចំសេចក្តីព្រាងរបាយការណ៍ ស្តីពីការវិភាគផលប៉ះពាល់ភាពក្រីក្រ និងសង្គម (PSIA) នេះ ។ សិក្ខាសាលាជាបន្តទៀត ត្រូវបានគ្រោងឡើង ដើម្បីផ្សព្វផ្សាយ និងពិភាក្សានៅក្នុងថ្នាក់ខេត្ត ។

## ៣. ការរកឃើញនៃការសិក្សាស្រាវជ្រាវ

### ៣.១. សក្ដានុពលនៃភាពក្រីក្រ និងផលប៉ះពាល់សង្គម

#### ៣.១.១. មុខសញ្ញាទទួលដី-សក្ដានុពលនៃអ្នកឈ្នះ និងអ្នកចាញ់

ក្រុមគោលដៅសំរាប់ការពិភាក្សា និងការអង្កេតតាមគ្រួសារ ដែលធ្វើឡើងដោយវិទ្យាស្ថានកសិ-អាជីវកម្មកម្ពុជាបានរកឃើញថា អ្នកចូលរួមនៅថ្នាក់ភូមិភាគច្រើន បានគាំទ្រយ៉ាងខ្លាំងលើលក្ខណៈវិនិច្ឆ័យ[៨] ដែលបានស្នើឡើង សំរាប់អ្នកជាមុខសញ្ញាទទួលដីពីកម្មវិធីសម្បទានដីសង្គមកិច្ច ។ លក្ខណៈវិនិច្ឆ័យដែលបានស្នើឡើង បានទទួលការគាំទ្រជាឯកច្ឆន្ទ សំរាប់អ្នកជាមុខសញ្ញាទទួលដី ដែលមានសញ្ជាតិកម្ពុជា និងជាអ្នកដែលមានដីមានទំហំមិនធំជាងទំហំដីដែលនឹងផ្ដល់ដោយកម្មវិធី (ទោះបីជាមិនបានទទួលការឯកភាពជាឆ្លុងមួយពីគ្រប់គ្រួសារទាំងអស់ដែលបានធ្វើការអង្កេតក៏ដោយ) ហើយជាអ្នកមានលទ្ធភាព[៩] និងមានឆន្ទៈក្នុងការចូលរួមនៅក្នុងកម្មវិធី ។ លក្ខណៈវិនិច្ឆ័យផ្សេងៗទៀតដែលចែងថា "ជាមេគ្រួសារដែលមានសមាជិកយ៉ាងតិចពីរនាក់ជាញាតិវង្ស" និងលក្ខណៈវិនិច្ឆ័យដែលចែងថា "អាចឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យហិរញ្ញវត្ថុ ដែលបានរៀបចំដោយក្រសួងសង្គមកិច្ច" មានការគាំទ្រយ៉ាងដោយសំលេងភាគច្រើន ទោះបីជាមិនទាំងស្រុងក៏ដោយ ជាពិសេសទៅលើលក្ខណៈវិនិច្ឆ័យដែលចែងពីសមាជិកគ្រួសារ ។ ការលើកឡើងរបស់អ្នកភូមិ ស្ដីពីលក្ខណៈវិនិច្ឆ័យមុខសញ្ញាទទួលដី មានបង្ហាញនៅក្នុងសេចក្ដីបន្ថែមទី៣ ។

---

[៨] អនុក្រឹត្យបានចែងថាអ្នកដែលមានមុខសញ្ញាទទួលដីត្រូវតែ : (ក).សាង់សង់លំនៅដ្ឋាន នៅលើផ្នែកមួយនៃដីដែលបានផ្ដល់អោយដោយកម្មវិធីបន្ទាប់ពីរយៈពេលបីខែក្រោយពីទទួលបានដី ហើយសមាជិកគ្រួសាររស់នៅទីនោះជាប្រចាំរយៈពេលច្រើនជាងប្រាំមួយខែក្នុងមួយឆ្នាំ (ខ).ធ្វើការដាំដុះនៅលើដីកសិកម្មដែលបានផ្ដល់អោយនៅក្នុងរយៈពេល១២ខែក្រោយពីទទួលបានដីនោះ និងបន្ដប្រើប្រាស់ដីនោះ (គ).អាចមានលទ្ធភាពដាក់ពាក្យសុំកាន់កាប់ដីធ្លី បន្ទាប់ពីបានឆ្លើយតបទៅនឹងល័ក្ខខ័ណ្ឌចាំបាច់របស់កម្មវិធីសម្បទានដីសង្គមកិច្ច (ឃ).ប្រសិនបើស្លាប់ ការផ្ទេរកម្មសិទ្ធទៅដល់អ្នកផ្សេង ត្រូវតែអនុលោមទៅតាមល័ក្ខខ័ណ្ឌនៅអំឡុងពេលប្រាំឆ្នាំនៃកម្មវិធីសម្បទានដីសង្គមកិច្ច និងអាចមានលទ្ធភាពទទួលបាននូវកម្មសិទ្ធសំរាប់កាន់កាប់លើដីនោះ (ង).មិនអនុញ្ញាតិអោយជួល ដោះដូរ អោយ ឬក៏លក់ទៅអោយអ្នកផ្សេង នៅក្នុងរយៈពេលប្រាំឆ្នាំដំបូង នូវដីដែលបានផ្ដល់អោយដោយកម្មវិធីសម្បទានដីសង្គមកិច្ចឡើយ ។

[៩] អនុក្រឹត្យបានចែងថាអ្នកដែលមានមុខសញ្ញាទទួលដីត្រូវតែ : (ក).សាង់សង់លំនៅដ្ឋាននៅលើផ្នែកមួយនៃដីដែលបានផ្ដល់អោយដោយកម្មវិធីបន្ទាប់ពីរយៈពេលបីខែក្រោយពីទទួលបានដី ហើយសមាជិកគ្រួសាររស់នៅទីនោះជាប្រចាំរយៈពេលច្រើនជាងប្រាំមួយខែក្នុងមួយឆ្នាំ (ខ).ធ្វើការដាំដុះនៅលើដីកសិកម្មដែលបានផ្ដល់អោយនៅក្នុងរយៈពេល១២ខែ ក្រោយពីទទួលបានដីនោះ និងបន្ដប្រើប្រាស់ដីនោះ (គ).អាចមានលទ្ធភាពដាក់ពាក្យសុំកាន់កាប់ដីធ្លី បន្ទាប់ពីបានឆ្លើយតបទៅនឹងល័ក្ខខ័ណ្ឌចាំបាច់របស់កម្មវិធីសម្បទានដីសង្គមកិច្ច (ឃ).ប្រសិនបើស្លាប់ ការផ្ទេរកម្មសិទ្ធទៅដល់អ្នកផ្សេង ត្រូវតែអនុលោមទៅតាមល័ក្ខខ័ណ្ឌក្នុងអំឡុងពេលប្រាំឆ្នាំនៃកម្មវិធីសម្បទានដីសង្គមកិច្ច និងអាចមានលទ្ធភាពទទួលបាននូវកម្មសិទ្ធិសំរាប់កាន់កាប់លើដីនោះ (ង).មិនអនុញ្ញាតិអោយជួល ដោះដូរ អោយ ឬក៏លក់ទៅអោយអ្នកផ្សេង នៅក្នុងរយៈពេលប្រាំឆ្នាំដំបូង នូវដីដែលបានផ្ដល់អោយដោយកម្មវិធីសម្បទានដីសង្គមកិច្ចឡើយ ។

ទោះជាយ៉ាងណាក៏ដោយ ក៏ក្រុមគោលដៅពិភាក្សាក៏បានបញ្ជាក់ផងដែរ ពីការចង់អោយមានវិធីសាស្រ្ត ដែលមានលក្ខណៈចំហ និងទូលំទូលាយជាងនេះ អំពីថាតើប្រជាពលរដ្ឋប្រភេទណាគួរត្រូវបានជ្រើសរើសជាមុខសញ្ញាទទួលដីពីកម្មវិធី ។ អ្នកចូលរួមនៅក្រុមគោលដៅពិភាក្សាមួយចំនួន ក៏បានផ្តល់មតិថា ប្រជាពលរដ្ឋដែលមិនមានសញ្ជាតិកម្ពុជា ក៏ត្រូវតែបានជ្រើសរើសជាមុខសញ្ញាទទួលដីពីកម្មវិធីផងដែរ ពីព្រោះពួកគេបានរស់នៅជាអចិន្ត្រៃយ៍ នៅក្នុងប្រទេសកម្ពុជា ដោយមិនគួរផ្អែកតែទៅលើលក្ខណៈវិនិច្ឆ័យដែលបានលើកស្នើឡើង ដោយផ្ទាក់ជាតិនោះឡើយ ។ អ្នកចូលរួមនៃក្រុមគោលដៅពិភាក្សានៅតាមតំបន់ស្ថានភាពភូមិសាស្រ្ត ដែលមានល្បាយប្រជាជនរាយប៉ាយដូចជា នៅខេត្តព្រៃវែងនៃតំបន់ជាប់ព្រំប្រទល់ជាមួយប្រទេសវៀតណាម និងខេត្តឧត្តរមានជ័យក្នុងតំបន់ដែលមានព្រំប្រទល់ជាប់ប្រទេសថៃ បានសំដែងនូវការទាមទារនេះ ។ ការផ្តល់ចំលើយឆ្លើយតបទាមទារបែបនេះ ប្រហែលជាការឆ្លុះបញ្ចាំងអោយឃើញពីស្ថានភាពនៃតំបន់ដែលមានទីតាំង ដែលស្ថិតនៅជាប់តំបន់ព្រំដែន ។ ទោះជាយ៉ាងនេះក៏ដោយ ការឆ្លើយតបជាក់ស្តែងពីអ្នកចូលរួមក្រុមគោលដៅសំរាប់ការពិភាក្សា ដូចដែលបានពិពណ៌នានៅក្នុងសេចក្តីបន្ថែមទី៣ ផ្តល់នូវអំណះអំណាងស្តីពីទាមទារទាំងនេះយ៉ាងច្បាស់លាស់ ។ កត្តានេះក៏បានគូសបញ្ជាក់ដែរថា ជនជាតិភាគតិចដែលរស់នៅក្នុងប្រទេសកម្ពុជា (រួមទាំងជនជាតិដើមភាគតិចនៅតំបន់ខ្ពង់រាប) ត្រូវតែដាក់បញ្ចូលទៅក្នុងកម្មវិធីផងដែរ ។ លទ្ធភាព និងឆន្ទៈក្នុងការចូលរួមបានបង្ហាញពីការឆ្លើយតបជាវិជ្ជមាន ក៏ប៉ុន្តែនៅក្នុងការអង្កេតតាមគ្រួសារ (ដូចដែលបានចងក្រងជា របាយការណ៍នៅក្នុងសេចក្តីបន្ថែមទី៣) ក៏មានគំនិតមិនយល់ស្របខ្លះទៅនឹងការចែងពីទំហំដីធំបំផុតដែលអាចមានសិទ្ធិកាន់កាប់បាន ដែលពួកគេបានពន្យល់ថា លក្ខណៈវិនិច្ឆ័យទាំងនេះ ចាំបាច់ត្រូវអោយមានលក្ខណៈបត់បែន ដើម្បីអោយស្របទៅតាមទំហំនៃសមាជិកគ្រួសារនីមួយៗ ។

ការជំទាស់ដ៏ធំ ត្រូវបានផ្តោតទៅលើបញ្ហាទំហំគ្រួសារ និងសមាជិកគ្រួសារបង្កើត ។ ជាពិសេស គឺការជំទាស់ពីប្រជាពលរដ្ឋដែលមានវ័យចំណាស់ ដែលបានប្រតិកម្មថា ជាការប្រកាន់ និងរើសអើងចំពោះពួកគេ មិនមែនជាសមាជិកនៃគ្រួសារទាំងនោះ។ ការសិក្សាក៏បានលើកយកឧទាហរណ៍មកបញ្ជាក់ផងដែរ ពីបញ្ហាក្មេងកំព្រា ដែលបានបញ្ចេញមតិថា ក្នុងនាមជាប្រជាពលរដ្ឋវ័យក្មេងម្នាក់ ពួកគេប្រហែលជាអាចមានលទ្ធភាពពឹងផ្អែកទៅលើការលក់កំលាំងពលកម្មប្រចាំថ្ងៃរបស់គេបាន ក៏ប៉ុន្តែវានឹងមិនអាចមានលទ្ធភាពឡើយ នៅពេលដែលពួកគេមានវ័យចាស់ជរាទៅ ។ សមាជិកគ្រួសារដែលមានស្ត្រីជាមេគ្រួសារ ជាពិសេសស្ត្រីដែលមានវ័យចំណាស់ ក៏មិនឯកភាពលើលក្ខណៈវិនិច្ឆ័យនេះដែរ ពីព្រោះពួកគាត់គិតថាវាមានការប្រកាន់រើសអើងនឹងពួកគាត់ ។ លក្ខណៈវិនិច្ឆ័យហិរញ្ញវត្ថុ (ភាពក្រីក្រ) របស់ក្រសួងសង្គមកិច្ច ត្រូវបានពិចារណាថា មានលក្ខណៈមិនសូវច្បាស់លាស់ ហើយបានស្នើឡើងថា សូម្បីតែនៅតាមកន្លែងដែលប្រជាពលរដ្ឋគ្មានដីធ្លី តែមិនមែនជាអ្នកក្រីក្រ ជាទូទៅពួកគេនឹងអាចធ្លាក់ខ្លួនក្របាន ។ ដោយហេតុនេះ សុវត្ថិភាពនៃលទ្ធភាពទទួលបានដីធ្លី នឹងជួយអោយជីវភាពរស់នៅរបស់ពួកគាត់មាននិរន្តរភាពបាន ។ ហេតុនេះ យោងទៅតាមការអះអាងរបស់អ្នកចូលរួមក្រុមគោលដៅសំរាប់ការពិភាក្សា កង្វះខាតខាងហិរញ្ញវត្ថុ

បច្ចុប្បន្ន គួរតែមិនមែនជាលក្ខណៈវិនិច្ឆ័យតែមួយប៉ុណ្ណោះទេ ។ ហេតុផលទាក់ទងទៅនឹងការមិនយល់ស្របទៅនឹងលក្ខណៈវិនិច្ឆ័យនេះ ដែលបានលើកឡើងតាមរយៈការធ្វើការអង្កេតតាមគ្រួសារមានដាក់បញ្ចូល នៅក្នុងរបាយការណ៍នៅក្នុងសេចក្តីបន្ថែមទី៣ ក៏ប៉ុន្តែរបាយការណ៍នេះគ្រាន់តែអាចធ្វើសេចក្តីសន្និដ្ឋានបណ្តោះអាសន្នប៉ុណ្ណោះ ដែលថា យេនឌ័រ ភាពក្រីក្រ ជនងាយរងគ្រោះ ទាក់ទងទៅនឹងបញ្ហាទាំងនេះ តំរូវអោយមានការសិក្សាវិភាគ ដោយប្រុងប្រយ័ត្នជាទីបំផុត ។

អ្នកផ្តល់ការសំភាសន៍ដែលបានចូលរួមនៅក្នុងក្រុមគោលដៅពិភាក្សា និងនៅក្នុងការធ្វើការអង្កេតតាមគ្រួសារ បានលើកស្នើឡើងនូវលក្ខណៈវិនិច្ឆ័យបន្ថែម ។ ចំនួនភាគច្រើន (៥៥ភាគរយ) នៃអ្នកចូលរួមនៅក្នុងក្រុមគោលដៅពិភាក្សា និងអ្នកដែលបានឆ្លើយតបទៅនឹងការអង្កេតតាមគ្រួសារ (៦៣,៩ភាគរយ) បានស្នើឡើងថា គ្រួសារដែលទើបតែមានគូរស្រករថ្មីថ្មោង គ្រួសារក្រីក្រគ្មានដី គ្រួសារក្រីក្រមានដីតិចតួច និងគ្រួសារដែលគ្មានការងារធ្វើ ត្រូវតែប្រើប្រាស់ជាលក្ខណៈវិនិច្ឆ័យបន្ថែមទៅលើលក្ខណៈវិនិច្ឆ័យដែលមានស្រាប់ ។ អ្នកចូលរួមនៅក្នុងក្រុមគោលដៅសំរាប់ពិភាក្សាមួយចំនួនតូច (៤៩,២ភាគរយ) បានអះអាងថា គ្រួសារដែលមានមេគ្រួសារតែម្នាក់ដែលរួមមានមេគ្រួសារជាស្ត្រីមេម៉ាយ បុរសពោះម៉ាយ និងជនពិការ គួរតែប្រើប្រាស់ជាលក្ខណៈវិនិច្ឆ័យបន្ថែមមួយផ្សេងទៀត ។ ដោយឡែក ចំលើយឆ្លើយតបពីការធ្វើការអង្កេតតាមគ្រួសារមានចំនួនតែ ២៤,៨ភាគរយ ដែលទាមទារបែបនេះ ។ បើយោងទៅតាមចំលើយឆ្លើយតបពីអ្នកចូលរួមនៅក្នុងក្រុមគោលដៅពិភាក្សា (១០,៨ភាគរយ) និងការអង្កេតតាមគ្រួសារ (១៤,២ភាគរយ) បានស្នើឡើងថា គ្រួសារដែលមានសមាជិកជាជនពិការគ្មានដី គួរតែប្រើប្រាស់ជាលក្ខណៈវិនិច្ឆ័យមួយផ្សេងទៀត ។ បើយោងទៅតាមចំលើយឆ្លើយតបពីអ្នកចូលរួមនៅក្នុងក្រុមគោលដៅពិភាក្សា (៧,៥ភាគរយ) និងពីការអង្កេតគ្រួសារ(៩,២ភាគរយ) គ្រួសារដែលមានសមាជិកជាក្មេងកំព្រា ឬមួយក៏គ្រួសារដែលមានជនរីយចំណាស់ទទួកបន្ទុកថែរក្សាផ្គត់ផ្គង់ក្មេងកំព្រា គួរតែប្រើប្រាស់ជាលក្ខណៈវិនិច្ឆ័យមួយផ្សេងទៀត ។ លក្ខណៈវិនិច្ឆ័យផ្សេងៗទៀតដូចជា : គ្រួសារក្រីក្រដែលដីធំ គ្រួសារក្រីក្រដែលមានសមាជិកច្រើន ហើយមានមេគ្រួសារជាស្ត្រី និងគ្រួសារក្រីក្រដែលមានមេគ្រួសារជាកងទ័ពរំសាយ ត្រូវបានគិតគូររួចហើយនៅក្នុងមាត្រា១១នៃអនុក្រឹត្យសម្បទានដីសង្គមកិច្ច ។ គ្រួសារដែលមានសមាជិកជាជនផ្លាស់ទីលំនៅដោយសារតែសង្គ្រាម ឬក៏គ្រួសារដែលមានសមាជិកជាជនមាតុភូមិនិវត្តន៍ពីជំរុំជនភៀសខ្លួនតាមព្រំដែន គឺជាលក្ខណៈវិនិច្ឆ័យដែលបានកំណត់ផងដែរ ដោយចំលើយពីអ្នកចូលរួមនៅក្នុងក្រុមគោលដៅពិភាក្សា (១,៧ភាគរយ) និងពីការអង្កេតគ្រួសារ (០,៩ភាគរយ) ។ ទោះជាយ៉ាងណាក៏ដោយ ក៏អ្នកចូលរួមនៃក្រុមគោលដៅពិភាក្សា (៣,៣ភាគរយ) និងពីការអង្កេតតាមគ្រួសារ (២,៩ភាគរយ) មួយចំនួនតូចទៀត បានទាមទារថា គ្រួសារដែលមិនជាក្រីក្រ តែមិនមានប្រភពការងារធ្វើច្បាស់លាស់ ឬដែលអាចទុកចិត្តបាន នោះក៏គួរតែមានសិទ្ធិទទួលបាននូវការបែងចែកដីពីកម្មវិធីសម្បទានដីសង្គមកិច្ចផងដែរ ។

អ្នកទទួលផលពីកម្មវិធីសម្បទានដីសង្គមកិច្ច នឹងរំពឹងថានឹងត្រូវគោរពយ៉ាងហោចណាស់លើល័ក្ខខ័ណ្ឌទាំង ៥យ៉ាងរបស់កម្មវិធី នេះបើយោងទៅតាមការលើកឡើងរបស់អ្នកចូលរួមនៃក្រុមគោលដៅពិភាក្សា និងពីការអង្កេតតាមគ្រួសារទាំងអស់ ។ ល័ក្ខខ័ណ្ឌទាំង៥នោះ គឺទាក់ទងទៅនឹងការសាងសង់លំនៅដ្ឋាននៅក្នុងរយៈពេល៣ខែ និងរស់នៅទីនោះជាប្រចាំយ៉ាងតិច៦ខែក្នុងមួយឆ្នាំ ការដាំដុះនៅក្នុងរយៈពេល១២ខែ បន្ទាប់ពីទទួលបានដី និងការបន្តប្រើប្រាស់ដីនោះ ការមានសិទ្ធិក្នុងការដាក់ពាក្យស្នើសុំប័ណ្ណកាន់កាប់ ក្រោយពីបានអនុវត្តរយៈពេល៥ឆ្នាំដំបូងតាមតំរូវការចាំបាច់របស់កម្មវិធីសម្បទានដីសង្គមកិច្ច ការមានសិទ្ធិផ្ទេរដីតាមរយៈការផ្ទេរមរតក និងការមិនអនុញ្ញាតអោយចាកចេញ ធ្វើការដោះដូរ ជួល ឬក៏លក់ដីទាំងនោះនៅក្នុងរយៈពេល៥ឆ្នាំដំបូង នៃកម្មវិធីសម្បទានដីសង្គមកិច្ចបានឡើយ ។

អ្នកចូលរួមដែលជាជនក្រីក្រនៅក្នុងក្រុមគោលដៅពិភាក្សា ក៏បានអះអាងបញ្ជាក់ពីការមិនឯកភាពទៅលើល័ក្ខខ័ណ្ឌដែលតំរូវអោយធ្វើការសាងសង់លំនៅដ្ឋានក្នុងរយៈពេល៣ខែ ដោយបានតវ៉ាថា ពួកគេមិនមានធនធានអាចធ្វើដូចនេះបានឡើយ ហើយដោយឡែកចំពោះតំរូវការនៅក្នុងការធ្វើការដាំដុះលើដីនេះ នៅក្នុងរយៈពេល ១២ខែវិញនោះ ក្រុមជនពិការក៏បានអះអាងថា ពួកគេពឹងផ្អែកទៅលើការលក់កំលាំងពលកម្មដើម្បីការរស់នៅពីមួយថ្ងៃទៅមួយថ្ងៃរបស់គេតែប៉ុណ្ណោះ ។ ដោយហេតុដូច្នេះ ទាំងក្រុមអ្នកក្រីក្រ និងក្រុមងាយទទួលរងគ្រោះសំណូមពរអោយមានការកែតំរូវល័ក្ខខ័ណ្ឌទាំងឡាយ ដែលតម្រូវអោយពួកគេអនុវត្តតាម ។

ក្រុមផ្សេងៗទៀត ក៏សុំអោយមានការកែសំរួលនូវល័ក្ខខ័ណ្ឌ ដែលតំរូវអោយអនុវត្តតាមផងដែរ ។ ក្នុងនោះរួមមាន ទាំងក្រុមជនជាតិភាគតិច និងជនជាតិដើមភាគតិចផងដែរ ។ ជនជាតិដើមភាគតិចនៅតំបន់ខ្ពង់រាបបានលើកឡើងថា ដោយសារពួកគាត់ប្រឈមនឹងបញ្ហានៃការទន្ទ្រានយកដីពីសំណាក់ពួកអ្នកមាន និងអ្នកមានអំណាច ដែលមកពីខាងក្រៅ (រួមបញ្ចូលទាំងមន្ត្រីយោធា និងមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់) ដូចនេះ រយៈពេល៥ឆ្នាំគឺជារយៈពេលដ៏យូរណាស់ក្នុងការរង់ចាំ ។ ពួកគាត់នឹងបាត់បង់ដីរបស់ពួកគាត់ ។ កត្តាទាំងនេះ គឺស្ថិតនៅក្នុងបរិបទនៃការប្រកបរបរចិញ្ចឹមជីវិត ដែលជនជាតិដើមភាគតិចទាំងនេះ ត្រូវបង្ខំចិត្តធ្វើការកាត់បន្ថយនូវការពឹងផ្អែកទៅលើកសិកម្មពនេចររបស់ពួកគាត់ដែលគេតែងតែអនុវត្តកន្លងមក ។ អ្នកចូលរួមនៃក្រុមគោលដៅពិភាក្សាដែលជាជនជាតិចាម ក៏បានលើកឡើងនូវចំណុចដូចគ្នា ដែលសិទ្ធិនៅក្នុងការទទួលបាននូវកម្មសិទ្ធដីធ្លី គួរតែធ្វើត្រូវឡើងបន្ទាប់ពីរយៈពេល៣ឆ្នាំ ដើម្បីជៀសវាងពីការទន្ទ្រានយកដីរបស់ពួកគេ ពីក្រុមមកពីខាងក្រៅ ។

ការព្រួយបារម្ភណ៏មួយចំនួនទៀត ក៏បានលើកឡើងផងដែរ ដោយប្រជាពលរដ្ឋមួយចំនួនតូចថា ប្រសិនបើពួកគេជ្រើសរើសអ្នកស្នងដំណែងមរតកជាអ្នកដែលមិនអាចទាមទារកាន់កាប់លើដធ្លីបាន នោះប្រជាពលរដ្ឋផ្សេងទៀត នឹងអាចទាមទារកាន់កាប់លើដីទាំងនេះ។ ក្រុមអ្នកចូលរួមនៃក្រុមគោលដៅពិភាក្សាផ្សេងទៀត បានអះអាងថាដីត្រូវតែអាចប្រើប្រាស់ជាលក្ខណៈរួមបាន នៅក្នុងពេលដែលជីវភាពរស់នៅ ជួបនឹងវិបត្តិជួបគ្រោះអាសន្ន (ឧទាហរណ៏ ការមានជំងឺឈឺស្កាត់ភ្លាមៗ ដែលមិនបានគ្រោងទុក) ។

ទន្ទឹមនឹងនោះក៏មានអ្នកចូលរួមនៃក្រុមគោលដៅពិភាក្សាច្រើនទៀត (ឧទាហរណ៍ ពីអតីតជំរុំកងទ័ពខ្មែរក្រហមមួយ) បានអះអាងថា គ្មានអ្នកណាម្នាក់ត្រូវបានអនុញ្ញាតអោយជួល លក់ ឬក៏ដោះដូរដីយ៉ាងតិចរយៈពេល១០ឆ្នាំដំបូង ។ ការអះអាងរបស់គេ ដោយយោងលើបញ្ហាដែលគ្រួសារខ្លះអាចលក់ដីធ្លី ហើយផ្លាស់ប្តូរទៅរស់នៅក្នុងភូមិមួយផ្សេងទៀត និងបន្ទាប់មកធ្វើការទាមទារដីធ្លីម្តងទៀត ក្នុងនាមជាអ្នកគ្មានដី ហើយតាមរយៈការធ្វើនេះ ពួកគេនឹងទទួលបានដីបន្ថែមទៀតពីកម្មវិធីសម្បទានដីសង្គមកិច្ច ។

### ៣.១.២. ផលប៉ះពាល់សង្គម

ជាង៨០ភាគរយនៃប្រជាពលរដ្ឋក្នុងប្រទេសកម្ពុជា ដែលរស់នៅតំបន់ជនបទ មានជីវភាពរស់នៅពឹងផ្អែកទៅលើកសិកម្ម ។ នៅក្នុងការអង្កេតលើការវិភាគផលប៉ះពាល់លើភាពក្រីក្រ និងសង្គម អ្នកចូលរួមចំនួន ៨២,៥ ភាគរយនៃក្រុមគោលដៅពិភាក្សាបានរាយការណ៍ថា ពួកគេពឹងផ្អែកទៅលើការដាំដំណាំស្រូវ (និងដំណាំផ្សេងទៀត) ដែលជាសកម្មភាពសំរាប់គាំទ្រជីវភាពរស់នៅសំខាន់របស់ពួកគេ ។ ភាពក្រីក្ររបស់គ្រួសារនានា នៅតំបន់ជនបទត្រូវបានកំណត់ដោយខ្លួនពួកគេផ្ទាល់ថា ជាអ្នកដែលមិនមានស្បៀងអាហារគ្រប់គ្រាន់សំរាប់ហូបនៅក្នុងមួយរយៈពេលណាមួយក្នុងមួយឆ្នាំ ។ ផ្អែកទៅតាមនិយមន័យដែលបានកំណត់ដោយពួកគាត់ របាយនៃអត្រាភាពក្រីក្រមានលក្ខណៈស្របទៅតាមបែបផែនដូចគ្នាទៅនឹងភាពគ្មានដីធ្លី ។ ភាពជាម្ចាស់នៅលើដីមួយកន្លែង មិនគ្រាន់តែផ្តល់នូវសុវត្ថិភាពស្បៀងអាហារសំខាន់ៗប៉ុណ្ណោះទេ តែថែមទាំងរួមចំណែកផងដែរទៅដល់ការលើកស្ទួយឋានៈសង្គម (ភាពក្រីក្រ) គ្រួសារផងដែរនៅក្នុងសហគមន៍ ។ ភាពក្រីក្រមានន័យបន្ថែមទៀតថា ជាការស្ថិតនៅកាន់តែដាច់ឆ្ងាយពីសង្គម ដោយក្លាយទៅជាអ្នកដែលត្រូវបានគេមិនអោយចូលរួមនៅក្នុងការធ្វើសេចក្តីសំរេចចិត្ត និងនៅក្នុងព្រឹត្តិការណ៍សង្គមនានានៅក្នុងភូមិ ។

ដីគឺជាធនធានសំខាន់បំផុត សំរាប់ធានាសុវត្ថិភាពនៃជីវភាពរស់នៅក្នុងតំបន់ជនបទ ។ ទោះបីជាមានផលិតផលទាប និងអវត្តមាននៃជំរើសក្នុងការធានារ៉ាប់រងផ្សេងៗទៀតក៏ដោយ ក៏ការមានលទ្ធភាពប្រើប្រាស់ដីធ្លីនៅតែជាការធានារ៉ាប់រង ក្នុងការទប់ទល់ទៅនឹងការបរាជ័យនៃចំណូលមកពីប្រភពផ្សេងៗទៀត ។

### ៣.១.៣ ផលប៉ះពាល់សេដ្ឋកិច្ច

របាយការណ៍ពីការសិក្សា និងការស្រាវជ្រាវផ្សេងទៀត បានបង្ហាញអោយឃើញថា ដីធ្លីទាំងឡាយដែលមានលក្ខណៈសមស្របក្នុងការធ្វើស្រែ គឺគ្រាន់តែគ្រប់គ្រាន់ល្មមសំរាប់តែចិញ្ចឹមជីវិតប៉ុណ្ណោះ ។ បើគិតជាប្រាក់ចំណូលនៅក្នុងក្របខ័ណ្ឌស្ថាប័ន និងការផ្តល់សេវាកម្មបច្ចុប្បន្ន នោះវាមិនអាចលើសពី ១០០-២០០ដុល្លារទេ ក្នុងមួយហិកតា[១០] ។ ជាទូទៅទិន្នផលស្រូវមានជាមធ្យម គឺប្រហែលជា២តោនក្នុងមួយហិកតា ។ ការប្រមូលផលស្រូវរបស់គ្រួសារក្រីក្រជាមធ្យមបានតែ ១.០០០គីឡូក្រាម ប៉ុណ្ណោះក្នុងមួយហិកតា ។ ប៉ុន្តែនៅកន្លែងខ្លះអាចមាន

---

[១០] មធ្យមភាគសំរាប់ការិតទុនផលិតកម្មស្រូវតិចរបស់កសិករខ្នាតតូច ។

សក្តានុពលភាពទទួលបាន៥តោន ក្នុង១ហិកតា ចំពោះតំបន់ដែលមានប្រព័ន្ធស្រោចស្រព្គគ្រប់គ្រាន់ ។ ការពិនិត្យទិន្នន័យឡើងវិញ ដោយធនាគារពិភពលោក (Auffret ឆ្នាំ២០០៣) បានបង្ហាញអោយឃើញថា សំរាប់កសិករខ្នាតតូច លទ្ធភាពផលិតកម្មហាក់បីដូចជាមានទិន្នផលទាបជាងកសិករខ្នាតមធ្យម ហើយដែលជាទូទៅ កសិករខ្នាតមធ្យមមានផលិតភាពខ្ពស់ជាង កសិករខ្នាតធំ[១១] ។

ក្រៅពីកង្វះខាតជាទូទៅនៃគ្រឿងផ្គត់ផ្គង់កសិកម្មទាន់សម័យ កសិករខ្នាតតូចជួបប្រទះនឹងបញ្ហា ដែលពួកគេត្រូវបានបង្ខំចិត្តអោយលក់កំលាំងពលកម្មប្រចាំថ្ងៃ ដើម្បីបំពេញបន្ថែមទៅលើចំណូលពីសកម្មភាពកសិកម្មរបស់ខ្លួន ។ ឱកាសនានាសំរាប់ការធ្វើបែបនេះ មានល្អបំផុតនៅក្នុងអំឡុងពេលនៃការចាប់ផ្តើមរៀបចំដី និងពេលដាំដុះ ហើយគឺជាពេលដែលពួកគេត្រូវតែត្រឡប់មកវិញ ដើម្បីបំពេញការងារស្រែចំការរបស់គេដែរ ។ មានវដ្តដ៏លំបាកមួយដែលនឹងបង្កធ្វើអោយកសិករខ្នាតតូចអាចបាត់បង់នូវអ្វីៗទាំងអស់ ។ យុទ្ធសាស្ត្រដែលកសិករភាគច្រើន ជ្រើសរើសដើម្បីប្រឈមទៅនឹងការលំបាកនេះ គឺការពឹងផ្អែកទាំងស្រុងទៅលើ (សុវត្ថិភាព) ចំណូលពីការលក់កំលាំងពលកម្មប្រចាំថ្ងៃ ប្រការនេះមានឥទ្ធិពលប៉ះពាល់សំខាន់ទៅលើការកំណត់ទំហំដី ដែលត្រូវធ្វើការបែងចែកក្នុងមួយគ្រួសារនៅក្នុងកម្មវិធីសម្បទានដីសង្គមកិច្ច ។ គឺជាទំហំដីដែលត្រូវការចាំបាច់គ្រប់គ្រាន់សំរាប់ធានានូវសុវត្ថិភាពស្បៀងអាហារសំរាប់គ្រួសារ ។ ហេតុនេះត្រូវការសិក្សាស្រាវជ្រាវបន្ថែមទៀត ដើម្បីអោយមានការយល់ដឹងច្បាស់លាស់ពីតំបន់ដែលអាចមានដីទំនេរ ដែលអាចធ្វើអោយកសិករផ្តោតការយកចិត្តទុកដាក់ទៅលើការដាំដុះរបស់ខ្លួនគេផ្ទាល់ ។

## ៣.២. បញ្ហាស្ថាប័ន និងគោលនយោបាយ : ការរៀបចំ និងការអនុវត្តសម្បទានដីសង្គមកិច្ច

### ៣.២.១. សមត្ថភាពរបស់ស្ថាប័នដែលមានស្រាប់នៅក្នុងការអនុវត្តកំណែទំរង់

សមត្ថភាពរបស់ស្ថាប័ននានា ដែលមានស្រាប់ដើម្បីអនុវត្តកំណែទំរង់ ត្រូវតែធ្វើការវាស់វែងដោយប្រៀបធៀបទៅនឹងឆន្ទៈរបស់ពួកគេនៅក្នុងការអនុវត្តកម្មវិធី ។ គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីធ្លីខេត្តបាត់ដំបង និងកោះកុង បដិសេធមិនព្រមជួបប្រជុំជាមួយនឹងក្រុមសិក្សាវិភាគពីផលប៉ះពាល់លើភាពក្រីក្រ និងសង្គម ទោះបីជាក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៅទីក្រុងភ្នំពេញ បានស្នើសុំអោយពួកគេ ជួបប្រជុំជាមួយក្រុមការងារក៏ដោយ ។ ខេត្តបាត់ដំបង គឺជាខេត្តធំមួយនៅតំបន់បឹងទន្លេសាប មានប្រវត្តិយូរអង្វែងនៅក្នុងការបង្កើត និងការតាំងទីលំនៅ ជាមួយនឹងបទពិសោធន៍ថ្មីៗនៅក្នុងការបែងចែកដីធ្លីនៅតំបន់ដីដោះមីនរួច ដល់ព្រជាពលរដ្ឋធ្វើមាតុភូមិនិវត្តន៍ អ្នកផ្លាស់ប្តូរទីលំនៅ និងអ្នកតាំងទីលំនៅថ្មី ព្រមទាំងអ្នកដែលមានទំនាស់ដីធ្លីនានា ។ ខេត្តកោះកុង ស្ថិតនៅតំបន់ឆ្នេរសមុទ្រ គឺជាខេត្តមួយមានទំហំដីធំធេង ដែលមានតំបន់មួយភាគធំ ត្រូវបានបែងចែកទុកជាតំបន់ឧទ្យានជាតិ តំបន់ការពារព្រៃឈើ និងដែនជំរកសត្វព្រៃ ហើយជាខេត្តដែលបានង្កើតគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីធ្លីរួចហើយ ។ នៅក្នុងចំណោមខេត្តបីផ្សេងទៀត ខេត្តកំពតកំពុងតែស្ថិតនៅក្នុងដំណើរការនៃការ

---

[១១] កសិករខ្នាតតូច គឺជាកសិករដែលស្ថិតនៅលំដាប់ក្រោមទី៣នៃទំហំដីដែលបានបែងចែក កសិករខ្នាតមធ្យម គឺជាកសិករដែលស្ថិតនៅលំដាប់ទីពីរនៃទំហំដីដែលបានបែងចែក និងកសិករខ្នាតធំ គឺជាកសិករដែលស្ថិតនៅក្នុងលំដាប់ខ្ពស់ទីបីនៃទំហំដីដែលបានបែងចែក ។

បង្កើតគណៈកម្មាធិការនេះឡើង ។

ជារួម មានសមាជិកនៃគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីធ្លីនៃខេត្តទាំងបួនចំនួន៣៣នាក់ បានចូលរួមនៅក្នុងការសិក្សាវាយតំលៃនៅក្រោមការសិក្សាស្រាវជ្រាវស្តីពីការវិភាគផលប៉ះពាល់លើភាពក្រីក្រ និងសង្គម ដែលក្នុងនោះ មានសមាជិកគណៈកម្មាធិការជាស្ត្រីបីនាក់ ។ គណៈកម្មាធិការនេះតំណាងអោយស្ថាប័នពាក់ព័ន្ធនានាដែលជាសមាជិកនៃគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង ។

សមាជិកគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្តក្រុង បានចូលរួមនៅក្នុងការសិក្សាវាយតំលៃលើសមត្ថភាពរបស់ខ្លួនគេផ្ទាល់ និងរបស់ក្រុមការងារស្រុក និងក្រុមប្រឹក្សាឃុំ សង្កាត់ នៅក្នុងកម្មវិធីសម្បទានដីសង្គមកិច្ច ដូចដែលមានចែងនៅក្នុងអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច ។ គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង មានសមាជិកជាមធ្យម១៣,៥នាក់ ដែលក្នុងនោះមាន១,៥នាក់ជាស្ត្រី ហើយអង្គភាពគាំទ្របច្ចេកទេសរបស់ខ្លួន មានបុគ្គលិកជាមធ្យម១,៥នាក់ រួមទាំងបុគ្គលិកជាស្ត្រី ។ ខេត្តកំពង់ចាម នៅមិនទាន់មានបុគ្គលិកអង្គភាពគាំទ្របច្ចេកទេសនៅឡើយទេ ។ គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុងមានសមាជិកច្រើន តែអង្គភាពគាំទ្របច្ចេកទេសរបស់ខ្លួន មានសមាជិកតិច ។

ភាគច្រើននៃគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង (៧៥ភាគរយ)មានជំនឿជឿជាក់ថាពួកគេអាចអនុវត្តនូវរាល់គ្រប់សកម្មភាពនៅក្នុងកម្មវិធីសម្បទានដីសង្គមកិច្ចបាន រួមទាំងការធ្វើចំណាត់ថ្នាក់ដី និងការរៀបចំផែនការប្រើប្រាស់ដី ដោយផ្ញើផែនការសម្បទានដីសង្គមកិច្ច និងផែនការដែលបានអនុម័តរួច ទៅគណៈកម្មាធិការថ្នាក់ជាតិដើម្បីពិនិត្យឡើងវិញ ។ សូម្បីតែសមាជិកគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីខេត្តកំពតដែលសមាជិករបស់ខ្លួននៅមិនទាន់បង្កើតឡើងជាផ្លូវការក៏ដោយ ក៏មានជំនឿជឿជាក់យ៉ាងមុតមាំថា ពួកគេអាចអនុវត្តរាល់សកម្មភាពទាំងអស់ ដូចដែលមានចែងនៅក្នុងអនុក្រឹត្យបាន ក៏ប៉ុន្តែ ក៏នៅតែបានបញ្ជាក់ផងដែរថាសមាជិកគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង ព្រមទាំងបុគ្គលិកអង្គភាពគាំទ្របច្ចេកទេសរបស់ខ្លួនត្រូវតែទទួលការបណ្តុះបណ្តាលស្តីពីទិដ្ឋភាពបច្ចេកទេស ដូចជាគោលការណ៍នៃការធ្វើចំណាត់ថ្នាក់ដី ការកំណត់ និងការបែងចែក ការជ្រើសរើសអ្នកដែលជាមុខសញ្ញាទទួលផលប្រយោជន៍ពីកម្មវិធី និងការអភិវឌ្ឍ ។

កំរិតអប់រំរបស់បុគ្គលិកអង្គភាពគាំទ្របច្ចេកទេសមិនខ្ពស់មែន ក៏ប៉ុន្តែមានកំរិតគ្រាន់បើជាងកំរិតអប់រំរបស់សមាជិកគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង ។ ទោះបីជាភាគច្រើននៃបុគ្គលិកទាំងនេះមានកំរិតអប់រំទាបជាង សាលាបណ្តុះបណ្តាលវិជ្ជាជីវៈក៏ដោយ ក៏ពួកគេភាគច្រើនបានបណ្តុះបណ្តាលនៅក្នុងកំរិតអប់រំខ្ពស់ជាងកំរិតបឋម ។

ភាគច្រើននៃគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុងបានវាយតំលៃថា ពួកគាត់ និងបុគ្គលិកអង្គភាពគាំទ្របច្ចេកទេសក្រោមឱវាទ អាចអនុវត្តបាននូវរាល់សកម្មភាពទាំងឡាយ ដែលបានប្រគល់អោយពួកគាត់ធ្វើ ក៏ប៉ុន្តែបានស្នើសុំថា ពួកគាត់នៅត្រូវការជំនួយគាំទ្រពីថ្នាក់ជាតិ ។ ជំនួយទាំងនេះមានផ្សេងៗគ្នាច្រើន

ក៏ប៉ុន្តែ ជំនួយសំខាន់ៗរួមមាន ថវិកា ការបណ្តុះបណ្តាលបច្ចេកទេស និងការផ្តល់នូវក្របខ័ណ្ឌច្បាប់គ្រប់គ្រាន់ដើម្បីជំរុញដល់ការអនុវត្តច្បាប់ និងអនុក្រឹត្យ ដូចជាប្រកាស គោលការណ៍ណែនាំ និងនីតិវិធីនានា ។

នៅថ្នាក់ស្រុក ខណ្ឌ ក្រុមការងារស្រុក ខណ្ឌបានបង្កើតឡើងជាផ្លូវការរួចហើយ នៅតាមបណ្តាខេត្ត ក្រុងមួយចំនួន ។ នៅខេត្តកំពត ឧត្តរមានជ័យ និងស្ទឹងត្រែង ក្រុមការងារនេះនៅមិនទាន់បានតែងតាំងនៅឡើយ ។ ក្រុមការងារថ្នាក់ស្រុក ខណ្ឌមួយចំនួន បានបង្កើតឡើងតែតាមរយៈដីការខេត្ត ក្រុងតែប៉ុណ្ណោះ ។ ក្រុមការងារថ្នាក់ស្រុក ខណ្ឌនីមួយៗ តម្រូវអោយសមាជិកមួយចំនួនជាបុគ្គលិក ។ យោងទៅតាមសេចក្តីរាយការណ៍របស់គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង ក្រុមការងារថ្នាក់ស្រុក ខណ្ឌនីមួយៗ មានចំនួនសមាជិកជាមធ្យម៩,៣ នាក់ ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏សមាជិកគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្តក្រុងមិនអាចវាយតំលៃពីសមត្ថភាពរបស់ក្រុមការងារថ្នាក់ស្រុក ខណ្ឌបានឡើយ ។ ជាទូទៅ សមាជិកគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុងមិនបានដឹងពីកំរិតអប់រំរបស់សមាជិកក្រុមការងារថ្នាក់ស្រុក ខណ្ឌឡើយ ។ ការសិក្សាបានរកឃើញថា ជាមធ្យមក្រុមការងារថ្នាក់ស្រុក ខណ្ឌ មានសមាជិកប្រហែល៨នាក់ ដែលចំនួននេះ តិចជាងចំនួនដែលបានរាយការណ៍ដោយគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង ហើយភាគច្រើននៃសមាជិកក្រុមការងារថ្នាក់ស្រុក ខណ្ឌមានកំរិតអប់រំទាបជាងកំរិតមធ្យមសិក្សាជាន់ខ្ពស់ ។ តែទោះជាយ៉ាងណាក៏ដោយ មានបុគ្គលិកក្រុមការងារថ្នាក់ស្រុក ខណ្ឌតែ១៣,៥ភាគរយប៉ុណ្ណោះដែលជាស្ត្រី ។

ទោះបីជាសមត្ថភាពរបស់ពួកគេនៅមានកំរិតទាបក៏ដោយ ក៏ជាងពាក់កណ្តាលនៃក្រុមការងារថ្នាក់ស្រុក ខណ្ឌបានប្រកាសថា ពួកគេអាចធ្វើសកម្មភាពទាំងឡាយទាក់ទងទៅនឹងសម្បទានដីសង្គមកិច្ចបាន ។ ក្រុមការងារថ្នាក់ស្រុក ខណ្ឌ ហាក់បីដូចជាមានជំនឿជឿជាក់ក្នុងការបំពេញការងារបីយ៉ាង រួមមាន : ការកំណត់ដី ការរៀបចំផែនការ និងការជ្រើសរើសអ្នកជាមុខសញ្ញាទទួលដី និងការអនុវត្តនូវផែនការសម្បទានដីសង្គមកិច្ច ដែលបានអនុម័តរួច ។ យោងទៅតាមការវាយតំលៃផ្ទាល់ខ្លួនរបស់ក្រុមការងារថ្នាក់ស្រុកខណ្ឌ សមាជិកគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្តក្រុង ហាក់បីដូចជាបានវាយតំលៃហួសពីសមត្ថភាពរបស់ក្រុមការងារថ្នាក់ស្រុក ខណ្ឌនៅក្នុងការបំពេញតួនាទីរបស់ពួកគេ ដូចដែលបានចែងនៅក្នុងអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច ជាពិសេស តួនាទីទាក់ទងទៅនឹងការកំណត់ និងការធ្វើចំណាត់ថ្នាក់ដី ការរៀបចំផែនការប្រើប្រាស់ដី និងការអនុវត្តការងារដែលមិនបានគ្រោងទុកមួយចំនួនផ្សេងទៀត ដែលនឹងប្រគល់អោយដោយគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្តក្រុង និងការធានានូវដំណើរការអនុវត្តប្រកបដោយប្រសិទ្ធភាព និងតម្លាភាពនៃកម្មវិធីសម្បទានដីសង្គមកិច្ច ។ ក្រុមការងារថ្នាក់ស្រុកខណ្ឌ ស្នើសុំអោយមានការជួយជ្រោមជ្រែង ពីគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្តក្រុង និងព្រមទាំងពីថ្នាក់ជាតិផងដែរ ។

អំណាចនៅក្នុងការរៀបចំ និងការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចនៅថ្នាក់មូលដ្ឋាន ត្រូវបានប្រគល់តួនាទីជូនទៅដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្រោមមាត្រា២៨ នៃអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច ។ ក្រុមប្រឹក្សា

ឃុំសង្កាត់ ត្រូវបានបោះឆ្នោតជ្រើសរើសឡើងនាខែកុម្ភៈ ឆ្នាំ២០០២ មានតួនាទីក្នុងការទទួលខុសត្រូវ និងអនុវត្តសកម្មភាពនានាមួយចំនួន ដូចមានចែងនៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។ យ៉ាងហោចណាស់ក្រុមប្រឹក្សាឃុំ សង្កាត់ ប្រហែលជាពាក់កណ្តាលដែលក្រុមសិក្សាបានជួប បានរាយការណ៍ថា ពួកគាត់បានចូលរួមអនុវត្តសកម្មភាពទាក់ទងទៅនឹងកម្មវិធីសម្បទានដីសង្គមកិច្ច ជាពិសេសទាក់ទងទៅនឹងការ ដោះស្រាយទំនាស់ផ្សេងៗនៅមូលដ្ឋាន (៦០ភាគរយ) ។ ពួកគាត់បានកៀងគរប្រជាពលរដ្ឋ ដើម្បីចូលរួមអនុវត្តសកម្មភាពនានាទាក់ទងទៅនឹងការអភិវឌ្ឍ (៦២ភាគរយ) និងបានផ្សព្វផ្សាយព័ត៌មានស្តីពីគោលនយោបាយ និងគោលការណ៍ណែនាំនានា ដែលបង្កើតឡើងដោយរាជរដ្ឋាភិបាល (៤៨ភាគរយ) ។

ផ្នែកមួយនៃការវិភាគផលប៉ះពាល់លើភាពក្រីក្រ និងសង្គម គឺដើម្បីពិភាក្សាជាមួយសហគមន៍ ក្នុងការស្វែងរកចំណេះដឹង និងគោលគំនិតរបស់ពួកគាត់ ស្តីពីការងារដែលបាន និងកំពុងអនុវត្តដោយក្រុមប្រឹក្សាឃុំ សង្កាត់ ។ អ្នកចូលរួមនៃក្រុមគោលដៅពិភាក្សា បានរាយការណ៍ពីសកម្មភាពនានា ដែលបានអនុវត្តដោយក្រុមប្រឹក្សាឃុំសង្កាត់ ប្រហាក់ប្រហែលគ្នាទៅនឹងអ្វី ដែលបានរាយការណ៍ដោយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ។ ទោះជាយ៉ាងណាក៏ដោយ ក៏គោលគំនិតនេះ គឺគ្រាន់តែចង់ដឹងពីថាតើក្រុមប្រឹក្សាឃុំ សង្កាត់មានភាពសកម្មយ៉ាងដូចម្តេចក្នុងសកម្មភាពដែលពួកគេបានរាយការណ៍ប្រាប់ ដោយប្រៀបធៀបទៅនឹងគំនិតយល់ឃើញរបស់អ្នកភូមិដែលបានចូលរួមនៅក្នុងក្រុមគោលដៅពិភាក្សាផ្សេងៗគ្នា ។ តិចជាងពាក់កណ្តាលនៃចំនួនអ្នកដែលបានចូលរួមនៅក្នុងក្រុមគោលដៅពិភាក្សា (៤០ភាគរយ) បានទទួលស្គាល់ថា ក្រុមប្រឹក្សាឃុំ សង្កាត់ បានធ្វើសកម្មភាពទាក់ទងទៅនឹងការដោះស្រាយទំនាស់នានានៅមូលដ្ឋាន ។ ១ភាគ៣នៃចំនួនអ្នកចូលរួមនេះ (៣៣ភាគរយ) បានយល់ឃើញថា ក្រុមប្រឹក្សាឃុំ សង្កាត់អនុវត្តសកម្មភាពទាក់ទងទៅនឹងការប្រមូលកៀងគរប្រជាពលរដ្ឋចូលរួមក្នុងការអនុវត្តសកម្មភាពអភិវឌ្ឍន៍ ហើយតិចជាង១ភាគ៤ (២៣ភាគរយ) បានយល់ឃើញថាក្រុមប្រឹក្សាឃុំ សង្កាត់ ធ្វើសកម្មភាពទាក់ទងទៅនឹងការផ្សព្វផ្សាយព័ត៌មានស្តីពីគោលនយោបាយ និងគោលការណ៍ណែនាំនានា ដែលបង្កើតឡើងដោយរដ្ឋាភិបាល ។ សូម្បីតែនៅក្នុងតំបន់ដែលតំរូវអោយមានការថែរក្សាសន្តិសុខនៅមូលដ្ឋាន ជាង៦០ភាគរយនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់គិតថា ពួកគាត់បានអនុវត្តតួនាទីដូចបានរៀបរាប់ខាងលើ ក៏ប៉ុន្តែ មានតែ១៥ភាគរយនៃចំនួនអ្នកចូលរួមនៃក្រុមគោលដៅពិភាក្សាប៉ុណ្ណោះទេ ដែលយល់ឃើញបែបនេះ ។

ក្រុមប្រឹក្សាឃុំសង្កាត់នៅតាមបណ្តាឃុំជ្រើសរើសមួយចំនួន មានសមាជិកជាមធ្យម៦នាក់ ។ ជាទូទៅឃុំទាំងនេះ ជាឃុំដែលមានចំនួនប្រជាពលរដ្ឋតិច ។ ក្រុមប្រឹក្សាឃុំ សង្កាត់មានកំរិតអប់រំទាបជាងសមាជិកគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្តក្រុង និងក្រុមការងារថ្នាក់ស្រុកខណ្ឌ ។ ជាង៧៥ភាគរយនៃក្រុមប្រឹក្សាឃុំ សង្កាត់ មិនបានទទួលការអប់រំកំរិតថ្នាក់មធ្យមសិក្សាទេ ។ ក្នុងចំណោមសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងនោះ មានសមាជិកតែ ៦ភាគរយប៉ុណ្ណោះជាស្ត្រី ។

ក្រុមប្រឹក្សាឃុំ សង្កាត់មានបុគ្គលិកគាំទ្រមួយចំនួនដូចជា ស្មៀនឃុំ សង្កាត់ និងមេភូមិ ។ នៅក្នុងករណីខ្លះ ឃុំ សង្កាត់មួយចំនួន មានគណៈកម្មាធិការ ឬគណៈកម្មការផ្លូវការមួយចំនួន ដូចជា គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ ឬគណៈកម្មការវត្ត ដើម្បីជួយបំពេញការងាររបស់ពួកគេ ។ ទោះជាយ៉ាងក៏ដោយ ក៏ចំនួននៃបុគ្គលិកគាំទ្រ មានតិចតួច ហើយសមត្ថភាពរបស់ពួកគេក៏មានកំរិត ។ ភាគច្រើននៃបុគ្គលិកគាំទ្រទាំងនេះ (៨៩ភាគរយ) បានបញ្ចប់ ឬរៀន ថ្នាក់បឋមសិក្សាតែប៉ុណ្ណោះ ។ មួយភាគតូចនៃបុគ្គលិកគាំទ្រទាំងនេះ (៣,៤ភាគរយ) បានបញ្ចប់ការសិក្សានៅកំរិតមធ្យមសិក្សា ។ មានតែ១៤ភាគរយនៃបុគ្គលិកគាំទ្រតែប៉ុណ្ណោះជាស្ត្រី ។ ដោយហេតុដូចនេះ សមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ នៅមានកំរិតទាបនៅឡើយ ទាំងធនធានមនុស្ស និងចំណេះដឹង ។ វាមិនមានអ្វីដែលគួរអោយភ្ញាក់ផ្អើលឡើយទាក់ទងទៅនឹងបញ្ហានេះ ។ ទោះជាយ៉ាងណាក៏ដោយ ក៏ភាគច្រើននៃពួកគាត់ (៨២,៥ ភាគរយ) បានបញ្ជាក់ ដោយមោទនភាពថា ពួកគាត់អាចអនុវត្តនូវរាល់សកម្មភាពទាំងឡាយណា ដែលបានរំពឹងដោយក្រុមប្រឹក្សាឃុំ សង្កាត់ ។ ពួកគាត់មិនមានការខ្វះខាតនូវជំនឿជឿជាក់លើខ្លួនឯងឡើយ ។

ជាអកុសល ក្នុងខណៈដែលសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់នៅមានកំរិត ដោយសារតែមូលហេតុនានាដូចបានរៀបរាប់ខាងលើ ការបំពេញការងាររបស់ពួកគាត់ ក៏រឹតតែមានកំរិតកំណត់ទៅទៀត ដោយសារតែត្រូវមានការទទួលខុសត្រូវច្រើនយ៉ាងរបស់ពួកគាត់ រួមទាំង ភារកិច្ចទទួលខុសត្រូវក្នុងការគាំទ្រដល់ជីវភាពរស់នៅរបស់គ្រួសារផ្ទាល់ខ្លួន និងភារកិច្ចក្នុងការចូលរួមនៅក្នុងការអនុវត្តសកម្មភាពនានា ជាមួយនឹងភ្នាក់ងារ និងជាមួយនឹងគំរោងផ្សេងៗទៀតនៅមូលដ្ឋាន និងកាតព្វកិច្ចរបស់ពួកគាត់ចំពោះគ្រួសារ និងចំពោះការងារផ្សេងៗទៀតជាមួយនឹងភ្នាក់ងារនានានៅមូលដ្ឋាន ។ ប្រការនេះមានន័យថា សមត្ថភាពស្រូបយករបស់ពួកគាត់នៅមានកំរិត ទោះបីជាជាង២ភាគ៣ (៧២,៥ភាគរយ) បានបញ្ជាក់ថា ពួកគាត់មានសមត្ថភាពនៅក្នុងការកំណត់ដីធ្លី ជាងពាក់កណ្តាល (៥៧,៥ភាគរយ) នៅក្នុងការធ្វើចំណាត់ថ្នាក់ដី ជិត២ភាគ៣ (៦២,៥ភាគរយ) នៅក្នុងការរៀបចំផែនការប្រើប្រាស់ដី និងជាង៣ភាគ៤ (៨០ភាគរយ) នៅក្នុងការធ្វើផែនការ និងការប្រើប្រាស់លក្ខណៈវិនិច្ឆ័យ ដើម្បីកំណត់អ្នកជាមុខសញ្ញាទទួលដីក៏ដោយ ។ តែទោះជាយ៉ាងនេះក្តី ក៏តិចជាងពាក់កណ្តាល (៤២,៥ភាគរយ) នៃក្រុមប្រឹក្សាឃុំ សង្កាត់ បានបញ្ជាក់ថា ពួកគាត់អាចអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចបាន ។

ក្រុមការងារថ្នាក់ស្រុកបានពិចារណាលើសមត្ថភាពស្រូបយករបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ខ្ពស់ជាងការយល់ឃើញរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។ ជាងពាក់កណ្តាល (៥៦,៣ភាគរយ) នៃចំលើយដែលផ្តល់ដោយក្រុមការងារថ្នាក់ស្រុកខណ្ឌ បានគិតថាក្រុមប្រឹក្សាឃុំ សង្កាត់ មានសមត្ថភាពនៅក្នុងការអនុវត្តសកម្មភាពនានា ដែលទាក់ទងទៅនឹងអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច ហើយជាង៣ភាគ៤ផ្សេងទៀត (៨១,៣ភាគរយ) គិតថាក្រុមប្រឹក្សាឃុំ សង្កាត់អាចអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចបាន ។

អ្នកចូលរួមនៃក្រុមគោលដៅពិភាក្សា និងការអង្កេតតាមគ្រួសារ មានសុទិដ្ឋិនិយមចំពោះសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច ។ ជាងពាក់កណ្តាលនៃចំនួនអ្នកចូលរួមក្នុង

ក្រុមគោលដៅពិភាក្សា (៦២,៥ភាគរយ) និងពីការអង្កេតតាមមគ្រួសារ (៦២,៧ភាគរយ) មានជំនឿជឿជាក់ថា ក្រុមប្រឹក្សាឃុំសង្កាត់ អាចអនុវត្តសកម្មភាពនានាមួយចំនួន ដែលបានរំពឹងទុកនៅក្នុងអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ចបាន ។ ភាពខុសគ្នានៃសមត្ថភាពរបស់ក្រុមសិក្សាវាយតំលៃជនបទដោយមានការចូលរួមនៅថ្នាក់ឃុំ ក្រុមពិភាក្សាគោលដៅនៅថ្នាក់ភូមិ និងក្រុមផ្តល់ព័តិមានអង្កេតតាមគ្រួសារ មានតិចតួចណាស់ បើគិតជាមធ្យមភាគក្នុងការអនុវត្តការងារដែលបានប្រគល់ជូនដល់ពួកគេ ។

ឆ្លើយតបទៅនឹងសមត្ថភាពស្រូបយកមានកំរិត របស់បុគ្គលិកជំនួយការក្រុមប្រឹក្សាឃុំ សង្កាត់ ពួកគេស្នើសុំអោយមានការបណ្តុះបណ្តាលបច្ចេកទេស (៨២,៥ភាគរយ) ជំនួយថវិកា (៧០ភាគរយ) សម្ភារបច្ចេកទេស និងការិយាល័យ (៥២,៥ភាគរយ) មធ្យោបាយធ្វើដំណើរ (៣២,៥ភាគរយ) គោលការណ៍ណែនាំគ្រប់គ្រាន់ សំរាប់គាំទ្រដល់ការអនុវត្តច្បាប់ និងបច្ចេកទេស (២៧,៥ភាគរយ) និងការបណ្តុះបណ្តាលច្បាប់ (២៧,៥ភាគរយ) ។ ជាង៩០ភាគរយនៃចំនួនបុគ្គលិកក្រុមការងារថ្នាក់ស្រុកខណ្ឌ និងអ្នកចូលរួមនៅក្នុងក្រុមគោលដៅពិភាក្សា បានអះអាងថា ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវការចាំបាច់នូវការបណ្តុះបណ្តាលបច្ចេកទេសនេះ ។ យើងអាចធ្វើការសន្និដ្ឋានបានថា គ្រប់ភាគីពាក់ព័ន្ធទាំងអស់ ទោះបីជាក្រុមការងារថ្នាក់ស្រុកខណ្ឌ អ្នកភូមិ ឬក៏ក្រុមប្រឹក្សាឃុំសង្កាត់នឹងមិនមានជំនឿជឿជាក់ពិតប្រាកដ នៅក្នុងដំណើរការកម្មវិធីសម្បទានដីសង្គមកិច្ចឡើយ ក្នុងខណៈដែលវគ្គបណ្តុះបណ្តាលបច្ចេកទេស ទាក់ទងទៅនឹងកម្មវិធីនេះ មិនត្រូវបានផ្តល់ដល់ពួកគាត់ ។

### ៣.២.២. បញ្ហាតម្លាភាព និងគណនេយ្យភាព (សង្គម និងច្បាប់)

គំរូនានាដែលមាននៅក្នុងក្របខ័ណ្ឌអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច ធានានូវប្រសិទ្ធភាព ភាពស្មើភាពគ្នា ភាពអាចទទួលយកបាន តម្លាភាព និងគណនេយ្យភាព ក្នុងការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច និង ជាពិសេសដើម្បីសំរេចបាននូវគោលដៅរួមនៃការកាត់បន្ថយភាពក្រីក្ររបស់គ្រួសារដែលគ្មានដី និងមានដីតិចតួច ដូចមានចែងនៅក្នុងក្របខ័ណ្ឌអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច ។ ការសិក្សាស្តីពីការវិភាគផលប៉ះពាល់លើភាពក្រីក្រ និងសង្គមបានពិភាក្សាពីបញ្ហាទាំងនេះ ជាមួយនឹងអ្នកចូលរួមនៃក្រុមគោលដៅពិភាក្សា និងពីការអង្កេតតាមគ្រួសារ ដើម្បីយល់ដឹងពីវិសាលភាពនៃជំនឿទុកចិត្ត ដែលពួកគេគិតថា កម្មវិធីនឹងមានលទ្ធភាពដោះស្រាយគ្រប់បញ្ហាទាំងនេះនៅក្នុងអំឡុងពេលនៃដំណើរការកម្មវិធីសម្បទានដីសង្គមកិច្ច ។

ការពិភាក្សានៅគ្រប់កំរិតថ្នាក់ ក្នុងរយៈពេលនៃការសិក្សាវិភាគផលប៉ះពាល់លើភាពក្រីក្រ និងសង្គមបានបង្ហាញថា ភាគច្រើននៃអ្នកដែលបានចូលរួមនៅក្នុងការសិក្សា (ជាង៩០ភាគរយ) បាននិយាយថា ការចូលរួមក្រៅផ្លូវការជាមួយក្រុមនានានៅមូលដ្ឋានមានសារៈសំខាន់ជាទីបំផុត ក្នុងការធានានូវប្រសិទ្ធភាព ភាពស្មើភាពគ្នាភាពអាចទទួលយកបាន តម្លាភាព និងគណនេយ្យភាពរបស់កម្មវិធី ។ ទោះជាយ៉ាងណាក៏ដោយ ក៏ការឆ្លើយតបពីការអង្កេតតាមគ្រួសារតិចជាង៦០ភាគរយបានគិតថា ទាំងគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ ឬទាំងអង្គការមិនមែនរដ្ឋាភិបាល ត្រូវតែចូលរួមនៅក្នុងការអនុវត្តកម្មវិធី ហើយសមាជិកគណៈកម្មាធិការប្រើប្រាស់និងបែងចែកដីថ្នាក់

ខេត្តក្រុង ក៏បានអះអាងដូចគ្នានេះដែរថា ក្រុមទាំងពីរត្រូវតែចូលរួម ។ អ្នកចូលរួមនៅក្នុងក្រុមគោលដៅពិភាក្សា មានមតិវិជ្ជមានជាងលើការចូលរួមពីក្រុមទាំងពីរ (ជាង៧០ភាគរយ) ហើយក្រុមប្រឹក្សាឃុំសង្កាត់ក៏មានមតិដូចគ្នា ទោះបីជាគេបានសិក្សាវាយតំលៃលើគណៈកម្មាធិការអភិវឌ្ឍន៍ភូមិថា មានលក្ខណៈជាអវិជ្ជមានក្នុងការចូលរួមជាង (៦៨ភាគរយ) និងអង្គការមិនមែនរដ្ឋាភិបាល (៨០ភាគរយ) ក៏ដោយ ។ ប្រការនេះ ប្រហែលជាបានឆ្លុះបញ្ចាំង ពីការមិនឯកភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ទៅនឹងក្រុមខ្សែទទឹងនានា នៅថ្នាក់ភូមិ និងការគាំទ្រដល់អង្គការ មិនមែនរដ្ឋាភិបាលដែលជាប្រភពឧបត្ថម្ភគាំទ្រ ។ អ្នកផ្តល់ចំលើយឆ្លើយតបនៅក្នុងការអង្កេតតាមគ្រួសារ មិនមាន ការចាប់អារម្មណ៍ប៉ុន្មានឡើយ ចំពោះវត្តមានរបស់អង្គការមិនមែនរដ្ឋាភិបាល ឬក៏គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ ចូលរួមនៅក្នុងការកំណត់ដីធ្លី (ទោះបីជាគណៈកម្មាធិការ បានទទួលការស្វាគមន៍ជាងអង្គការមិនមែនរដ្ឋាភិបាល) ការធ្វើចំណាត់ថ្នាក់ដី និងការរៀបចំផែនការប្រើប្រាស់ដី ក៏ប៉ុន្តែក្រុមទាំងពីរ ត្រូវបានទទួលការស្វាគមន៍ ក្នុងការជួយ រៀបចំផែនការ និងការជ្រើសរើសអ្នកជាមុខសញ្ញាទទួលដី និងការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច (អង្គការ មិនមែនរដ្ឋាភិបាល ត្រូវបានវាយតំលៃ ថាមានប្រសិទ្ធភាពជាង គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ) ។

អ្នកចូលរួមនៅក្នុងក្រុមគោលដៅពិភាក្សា មានមតិវិជ្ជមានជាងអ្នកឆ្លើយតបពីការអង្កេតតាមគ្រួសារ (ជាពិសេសលើការរៀបចំផែនការ និងការជ្រើសរើសអ្នកជាមុខសញ្ញាទទួលដី) ហើយក៏ដូចក្រុមប្រឹក្សាឃុំ សង្កាត់ដែរ ក៏ប៉ុន្តែ អ្វីដែលគួរអោយចាប់អារម្មណ៍នោះ គឺគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្តក្រុង គិតថា អង្គការមិនមែនរដ្ឋាភិបាល នឹងអាចចូលរួមអនុវត្តគ្រប់សកម្មភាពទាំងអស់មានប្រសិទ្ធភាពជាង ហើយដែលក្រុម ការងារថ្នាក់ស្រុកខណ្ឌ មានគំនិតមិនសូវជាវិជ្ជមានប៉ុន្មានឡើយចំពោះបញ្ហានេះ ។ តាមការពិត គណៈកម្មាធិការ ប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្តក្រុង ហាក់បីដូចជាមានជំនឿជឿទុកចិត្តតិចតួចណាស់ ឬក៏គ្មានទាល់តែសោះ ចំពោះក្រុមនៅថ្នាក់ភូមិនានា លើកលែងតែគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ ។ ប្រការនេះ ប្រហែលជាគណៈកម្មាធិការ ប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្តក្រុង គិតថាគណៈកម្មាធិការអភិវឌ្ឍន៍ភូមិត្រូវតែជា ឬក៏តំណាងអោយសំលេងភូមិ នៅក្នុងអំឡុងពេលអនុវត្តន៍ ហើយវានឹងបង្កអោយមានលក្ខណៈងាយស្រួលជាង នៅក្នុងការទាក់ទងជាមួយនឹងក្រុម តែមួយ ទោះបីជាគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្តក្រុហ មានគំនិតវិជ្ជមានចំពោះគណៈកម្មការវត្ត ដែលមានសំលេងគាំទ្រជាង៥០ភាគរយ ក្នុងការជឿជាក់ថា គណៈកម្មការវត្តនឹងធ្វើការងារ នេះបានល្អប្រសើរជាង ក៏ដោយ ។ ប្រសិនបើមានការឯកភាពព្រមព្រៀងគ្នាណាមួយ លើកលែងតែអ្នកឆ្លើយតប ពីការអង្កេតតាមគ្រួសារ យើងអាចពិនិត្យមើលឃើញថា ទាំងគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ និងអង្គការមិនមែនរដ្ឋាភិបាល នឹងមានជំនឿ ជឿជាក់មុតមាំ នៅក្នុងការចូលរួមអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច ។

អ្នកចូលរួមនៅក្នុងក្រុមគោលដៅពិភាក្សា និងការអង្កេតតាមគ្រួសារ បានលើកឡើងនូវសំណើមួយចំនួន ដើម្បីធានានូវតម្លាភាព គណនេយ្យភាព ភាពអាចទទួលយកបាន និងយុត្តិធម៌សំរាប់កម្មវិធី ។ ជាង៤០ភាគរយ នៃអ្នកចូលរួមនៅក្នុងក្រុមគោលដៅពិភាក្សា គិតថា ត្រូវតែមានប្រជាពលរដ្ឋចាស់ទុំ និងប្រជាពលរដ្ឋជិតខាង និង

អ្នកដែលគ្មានដី ចូលរួមនៅក្នុងកម្មវិធីសម្បទានដីសង្គមកិច្ច ដូចដែលពួកគេធ្លាប់បានធ្វើពាក់ព័ន្ធជាមួយនឹងអាជ្ញាធរនៅគ្រប់លំដាប់ថ្នាក់ និងគ្រប់គណៈបក្សនយោបាយនានាដែរ ។ ប្រហែលជា២០ភាគរយនៃអ្នកចូលរួមនៃក្រុមគោលដៅពិភាក្សាគិតថា បុព្វជិតត្រូវតែចូលរួមនៅក្នុងកម្មវិធី (មានអ្នកឆ្លើយតបពីការអង្កេតតាម គ្រួសារតែ១០ភាគរយប៉ុណ្ណោះដែលមានមតិដូចគ្នា) ក៏ប៉ុន្តែតិចជាង១០ភាគរយនៃអ្នកចូលរួមនៅក្នុងក្រុមគោលដៅពិភាក្សា និងជាង៥ភាគរយនៃចំនួនអ្នកឆ្លើយតបនៅក្នុងការអង្កេតតាមគ្រួសារគិតថា ប្រជាពលរដ្ឋគ្មានដី (ឬអ្នកជាមុខសញ្ញាទទួលដីផ្សេងទៀត) ត្រូវតែចូលរួមនៅពេលរៀបចំផែនការ និងការអនុវត្ត ។ ប្រការនេះ មិនមែនមានន័យថាចង់សម្តែងចេញនូវប្រផ្នូរល្អ នៃការចូលរួមយ៉ាងសកម្មពីគ្រប់ភាគីដែលទទួលផលប្រយោជន៍ ទាំងអស់នៅក្នុងកម្មវិធីសម្បទានដីសង្គមកិច្ចនោះទេ ក៏ប៉ុន្តែវាជាការសំខាន់ក្នុងការយោងទៅលើការដកស្រង់នូវមតិជាក់ស្តែងដែលបានធ្វើឡើងដោយអ្នកចូលរួមនៅក្នុងក្រុមគោលដៅពិភាក្សា (សូមមើលសេចក្តីបន្ថែមទី៣) ។

### ៣.២.៣. យន្តការដោះស្រាយទំនាស់

ការព្រមព្រៀងឯកភាពគ្នា ដែលកើតចេញពីការសិក្សាស្តីពីការវិភាគផលប៉ះពាល់លើភាពក្រីក្រ និងសង្គមបានបង្ហាញថា មានករណីទំនាស់ដីធ្លីខុសៗគ្នាជាច្រើនរួចមកហើយនៅក្នុងប្រទេសកម្ពុជា ដូច្នេះទំនាស់ទាក់ទងទៅនឹងកម្មវិធីសម្បទានដីសង្គមកិច្ច មិនមែនជារឿងរ៉ាវថ្មីឡើយ ។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងពេលជាមួយគ្នានេះដែរក៏មានការព្រមព្រៀងឯកភាពគ្នាថា វាមានសារៈសំខាន់ណាស់ក្នុងការព្យាយាមជៀសវាង ឬក៏កាត់បន្ថយទំនាស់ទាំងនេះ អោយបានកំរិតអតិប្បរមាតាមតែអាចធ្វើទៅបាន ។ ដោយហេតុដូចនេះ ក៏មានការមានការលើកស្នើឡើងថា វិធានការបន្ធូរបន្ថយត្រូវតែដាក់បញ្ចូលទៅក្នុងកម្មវិធីសម្បទានដីសង្គម ដើម្បីធានាអោយអាចទទួលបាននូវលទ្ធផលទាំងនេះ ។

ទំនាស់ដីធ្លីមានការកើនឡើង ចាប់តាំងពីទស្សវត្សឆ្នាំ១៩៨០ ។ ទំនាស់ទាំងនេះត្រូវបានចងក្រង និងវិភាគយ៉ាងល្អប្រសើរ ។ យោងទៅតាមការអង្កេតស្តីពីការពង្រីកគោលដៅសង្គ្រោះបន្ទាន់របស់កម្មវិធីស្បៀងអាហារអង្គការសហប្រជាជាតិឆ្នាំ១៩៩៨ វិទ្យាស្ថានបណ្តុះបណ្តាលនិងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) ឆ្នាំ២០០០បានសរសេរថា "ចាប់តាំងពីឆ្នាំ១៩៨៧មក ទំនាស់ដីធ្លីធំៗចំនួន២១៧ករណី ប៉ះពាល់ជាមធ្យមដល់៥០គ្រួសារ និងដី១២០ហិកតា ត្រូវបានកត់ត្រាទុក" ហើយនៅឆ្នាំ២០០១បានកត់ត្រាករណីទំនាស់ដីធ្លី៧ប្រភេទផ្សេងៗគ្នាទៀត ។ នៅក្នុងឯកសាររបស់វិទ្យាស្ថានបណ្តុះបណ្តាលនិងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) ដូចគ្នានេះដែរ បានរាយការណ៍ថា ករណីទំនាស់ដីធ្លីដែលកើតមានឡើងជាញឹកញាប់នោះ គឺ ជាទំនាស់ព្រំប្រទល់រវាងអ្នកជិតខាង ហើយភាគច្រើននៃទំនាស់ទាំងនេះកើតមានឡើងនៅដើមឆ្នាំ១៩៩០ ដោយសារតែមិនមានវិធានការសមស្របណាមួយបានធ្វើឡើងឡើយ នៅពេលធ្វើការបែងចែកដីនៅឆ្នាំ១៩៨៩ ។ ទោះបីជាមានការទទួលស្គាល់បែបនេះក៏ដោយ "នៅពាក់កណ្តាលឆ្នាំ១៩៩០ បរិបទនៃទំនាស់បានផ្លាស់ប្តូរ ដោយសារតែតំលៃដីធ្លីបានកើនឡើង ហើយប្រហែល

ជាទិដ្ឋភាពសំខាន់ៗនៃការផ្លាស់ប្តូរ ដូចនេះមានចំនួនករណីកើនឡើងទាក់ទងទៅនឹងការចាប់យកដីធ្លីខុសច្បាប់ ការផ្តល់សម្បទានកសិកម្ម ឬក៏ទំនាស់ទាក់ទងទៅនឹងការធានាអោយខ្ចីប្រាក់ ដែលជាមូលហេតុធ្វើអោយប្រជាពលរដ្ឋមូលដ្ឋាន ជាទូទៅបានចាប់ផ្តើមបាត់បង់ដីរបស់គេ ទៅដល់អ្នកដ៏ទៃ ឬក៏ស្ថាប័នផ្សេងៗពីក្រៅសហគមន៍" ។ ទំនាស់ដីធ្លី មិនដែលមានប្រយោជន៏ដល់ប្រជាពលរដ្ឋក្រីក្រទេ ។ ជាទូទៅទាក់ទងទៅនឹងការចាប់យកដីខុសច្បាប់ ឬប្រើអំណាចបង្ខំចាប់យកដី ។ យោងតាមលោក សនវីលៀម ដែលបានដកស្រង់នៅក្នុងរបាយការណ៏របស់វិទ្យាស្ថានបណ្តុះបណ្តាលនិងស្រាវជ្រាវដើម្បីអភិវឌ្ឍន៏កម្ពុជា (CDRI) (ឆ្នាំ២00១) "ការចាប់យកដីខុសច្បាប់ គឺមានទ្រង់ទ្រាយធំ និងធ្វើឡើងដោយអ្នកមានអំណាចជាងអ្នករងគ្រោះ" ។

ទោះបីជាករណីទំនាស់ដីធ្លី គឺជាបញ្ហាដ៏ស្រួចស្រាវច្រើនឆ្នាំកន្លងមកក៏ដោយ ក៏ភាគច្រើននៃអ្នកចូលរួមនៅក្នុងការសិក្សាការវិភាគផលប៉ះពាល់លើភាពក្រីក្រ និងសង្គមនៅថ្នាក់ភូមិ និងគ្រួសារ (៨0ភាគរយ) ហាក់បីដូចជាមានជំនឿថា មិនមានទំនាស់កើតឡើងទេ ។ ក្នុងពេលជាមួយគ្នានេះដែរ ប្រហែលជា៤0ភាគរយនៃក្រុមការងារថ្នាក់ស្រុកខណ្ឌ និងជាង៦0ភាគរយនៃក្រុមប្រឹក្សាឃុំ សង្កាត់បានអះអាងថា ទំនាស់នានានឹងកើតមានឡើង ។ សក្តានុពលទំនាស់ដែលបានប្រមើលមើល ដោយអ្នកចូលរួមនៅក្នុងការសិក្សាការវិភាគផលប៉ះពាល់លើភាពក្រីក្រ និងសង្គម បានដាក់បញ្ចូលទំនាស់ទាក់ទងទៅនឹងការច្រណែនឈ្នានីសគ្នា (២៧,៥ភាគរយនៃក្រុមប្រឹក្សាឃុំសង្កាត់ ១0ភាគរយក្រុមគោលដៅពិភាក្សា និង៨ភាគរយនៃការអង្កេតតាមគ្រួសារ) ការប្រកាសកាន់កាប់ដីខុសច្បាប់ (២២,៥ភាគរយនៃក្រុមប្រឹក្សាឃុំសង្កាត់ ៧ភាគរយក្រុមគោលដៅពិភាក្សា និង៤ភាគរយនៃការអង្កេតតាមគ្រួសារ) ។ ទំនាស់ផ្សេងៗទៀតដែលបានប្រមើលមើល អាចជាទំនាស់លើជីជាតិនៃដី និងចំងាយពីភូមិ ភាពអាចមានដីគ្រប់គ្រាន់ និងដីព្រៃ ។ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ មានការព្រួយបារម្ភណ៏ច្រើនជាង អំពីលទ្ធភាពនៃទំនាស់ដែលអាចកើតមានឡើងនៅថ្នាក់ភូមិ ។

ដើម្បីដោះស្រាយបញ្ហា និងទំនាស់នានា អ្នកចូលរួមនៅក្នុងការសិក្សាការវិភាគផលប៉ះពាល់លើភាពក្រីក្រ និងសង្គម បានលើកជាសំណើមួយចំនួន ។ ក្រុមប្រឹក្សាឃុំ សង្កាត់ជាច្រើនមានការជឿជាក់ថា អាជ្ញាធរស្រុក ខណ្ឌ រួមជាមួយនឹងក្រុមប្រឹក្សាឃុំ សង្កាត់ អាចនឹងមានលទ្ធភាពដោះស្រាយនូវរាល់ករណីទំនាស់នានា ។ នៅក្នុងចំណោមអ្នកចូលរួមនៅក្នុងក្រុមគោលដៅពិភាក្សា និងអ្នកផ្តល់ការសំភាសន៏នៅក្នុងការអង្កេតតាមគ្រួសារ បានលើកឡើងថា ក្រុមប្រឹក្សាឃុំ សង្កាត់ នឹងមានលទ្ធភាពដោះស្រាយករណីទំនាស់នានា បានប្រសើរជាងអាជ្ញាធរស្រុក ខណ្ឌ ។ ផ្ទុយទៅវិញ ក្រុមការងារថ្នាក់ស្រុក ខណ្ឌបានអះអាងថា បើមានករណីទំនាស់នានាដែលតម្រូវអោយមានការដោះស្រាយ នោះបញ្ហាទាំងនេះ ចាំបាច់ត្រូវតែដោះស្រាយនៅថ្នាក់ខេត្ត ក្រុង ឬមួយក៏ត្រូវផ្សះផ្សាស្រុះស្រួលគ្នារវាងភាគីពាក់ព័ន្ធនៅនឹងកន្លែងផ្ទាល់តែម្តង ។

## ៣.៣. បញ្ហាច្បាប់

អនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច បានផ្តល់តួនាទីសំខាន់ដល់ក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងការអនុវត្ត ។ នៅក្នុងពេលជាមួយគ្នានេះដែរ មិនទាន់មានភាពច្បាស់លាស់នៅឡើយទេលើគោលការណ៍នានា ដែលតំរូវអោយអនុវត្តតាម ។ អំណាចនៅក្នុងការធ្វើសេចក្តីសំរេចចិត្តរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ នៅមិនទាន់មានភាពច្បាស់លាស់នៅឡើយ ដោយសារតែពួកគេនៅមានការរំពឹងទុកពីការជួយជ្រោមជ្រែងយ៉ាងច្រើនពីអ្នកខាងក្រៅ ក្នុងការអនុវត្តកម្មវិធី ។ ក្រុមប្រឹក្សាឃុំ សង្កាត់ ជួនកាលនៅពឹងផ្អែកទៅលើការគាំទ្របច្ចេកទេស ដែលពួកគេនឹងទទួលបានពីអាជ្ញាធរស្រុក ខេត្ត និងតាមរយៈអង្គការមិនមែនរដ្ឋាភិបាល និងអ្នកផ្តល់ការគាំទ្រពីអ្នកផ្តល់ជំនួយផ្សេងៗទៀត ។ គោលការណ៍ណែនាំបន្ថែមនានា (ប្រកាស) នឹងត្រូវតែចែងអោយបានលំអិត អំពីការទទួលខុសត្រូវនៃថ្នាក់រដ្ឋបាលផ្សេងៗគ្នា ។

ដំណើរការសំរាប់គំរោងសម្បទានដីសង្គមកិច្ចដែលបានអនុម័តរួច មិនទាន់មានលក្ខណៈស៊ីសង្វាក់គ្នាពេញលេញជាមួយនឹងគោលការណ៍រៀបចំផែនការផ្សេងៗទៀតនៅឡើយ ។ នៅពេលធ្វើការបញ្ច្រាបគំរោងសម្បទានដីសង្គមកិច្ចទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ គឺជាជំហានសំខាន់ ។ ដំណើរការទាំងពីរនេះ អនុលោមទៅតាមដំណើរការអនុម័តពីរផ្សេងគ្នា ។ ប្រការនេះនឹងនាំទៅដល់ស្ថានភាពមួយ ដែលផែនការអភិវឌ្ឍន៍ឃុំ សង្កាត់អនុម័តដោយក្រុមប្រឹក្សាឃុំ សង្កាត់ ប្រសិនបើមិនមានការជំទាស់នៅក្នុងរយៈពេល៤៥ថ្ងៃពីអភិបាលខេត្ត ក៏ប៉ុន្តែបន្ទាប់ពីការអនុម័តនោះមក អាចមានការជំទាស់នៅពេលណាមួយដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ដែលជាអ្នកពិនិត្យលើផ្នែកសម្បទានដីសង្គមកិច្ច ។ ដំណើរការទាំងពីរត្រូវការចាំបាច់ ឬមួយក៏ធ្វើអោយមានសុខដុមនីយកម្ម ជាមួយគ្នា ឬមួយក៏ត្រូវបំបែកចេញពីគ្នា ។

ប្រការដែលចែងពីការបិទផ្សាយ និងជូនដំណឹងជាសាធារណៈ ក៏នៅមិនទាន់មានភាពច្បាស់លាស់ និងមិនផ្សាភ្ជាប់គ្នាល្អជាមួយនឹងគោលការណ៍នានា ដែលមានចែងនៅក្នុងអនុក្រឹត្យស្តីពីការធ្វើវិមជ្ឈការអំណាច តួនាទី និងភារកិច្ចទៅអោយក្រុមប្រឹក្សាឃុំ សង្កាត់ ។ ទីកន្លែង និងពេលវេលាសំរាប់ការផ្សព្វផ្សាយ និងការអាន ឬមើលឯកសារ ទិន្នន័យនានា ត្រូវការអោយមានការបញ្ជាក់បន្ថែមទៀតអោយបានច្បាស់លាស់ ។

បញ្ហាគន្លឹះ នៅក្នុងពេលឆាប់ៗខាងមុខនេះ គឺបញ្ហាទាក់ទងទៅនឹងឋានានុក្រមរបស់ច្បាប់ដីធ្លី ដែលត្រូវតែធ្វើយ៉ាងណារៀបចំអោយមានជាស្រេច សំរាប់ការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច ។ នៅតាមតំបន់ភាគច្រើននៅក្នុងប្រទេស នៅមិនទាន់មានការកំណត់ព្រំប្រទល់ដីរដ្ឋផ្លូវការនៅឡើយ ។ ការងារបច្ចុប្បន្នទាក់ទងទៅនឹងការរៀបចំអនុក្រឹត្យស្តីពីការកំណត់ដីរដ្ឋ និងការធ្វើផែនទី គឺជាផ្នែកមួយនៃច្បាប់ដ៏សំខាន់បំផុត សំរាប់ការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច ។ នៅពេលបច្ចុប្បន្ននេះ មិនទាន់មានមូលដ្ឋានច្បាប់ សំរាប់ការធ្វើការកំណត់ និងការកែប្រែដីសាធារណៈ ឬដីឯកជនរបស់រដ្ឋ សំរាប់ការប្រើប្រាស់ក្នុងគោលបំណងផ្សេងៗទៀតបាននៅឡើយ ។

## ៣.៤. ភាពអាចរកបាននូវសេវាកម្មគាំទ្រនានា និងហេដ្ឋារចនាសម្ព័ន្ធ

ប្រជាពលរដ្ឋដែលមានវ័យចំណាស់នៅកម្ពុជា អាចរំលឹកឡើងវិញបាន នៅអំឡុងពេលដែលមានការបែងចែកដីនៅក្នុងសម័យសម្តេចព្រះនរោត្តមសីហនុដឹកនាំប្រទេសកម្ពុជា ក្នុងអំឡុងទស្សវត្សឆ្នាំ១៩៦០ ។ បន្ថែមពីលើការធ្វើសេចក្តីសំរេចចិត្តបែងចែកដីដែលបានធ្វើឡើងក្នុងអំឡុងឆ្នាំ១៩៨០ នៅក្នុងសម័យសាធារណៈរដ្ឋប្រជាមានិតកម្ពុជា និងសម័យរដ្ឋកម្ពុជា វាមានសារៈសំខាន់បំផុត ដែលតំរូវអោយប្រជាពលរដ្ឋចូលរួមនៅក្នុងក្រុមសាមគ្គី (ក្រុមសហករ ឬក្រុមសាមគ្គីផលិតកម្ម) ។ នៅក្នុងឆ្នាំ១៩៩២-១៩៩៣ ជាផ្នែកមួយនៃដំណើរការមាតុភូមិនិវត្តន៍ ដីត្រូវបានធ្វើការបែងចែកទៅអោយប្រជាពលរដ្ឋ ដែលវិលត្រឡប់មកពីជំរុំភៀសខ្លួននានា តាមព្រំដែនថៃភាគពាយ័ព្យប្រទេស ជាពិសេសខេត្តបាត់ដំបង និងឧត្តរមានជ័យ ហើយដូចគ្នាដែរនៅតំបន់ជំរកងទ័ពខ្មែរក្រហម ។ ប្រជាពលរដ្ឋសុទ្ធតែបានដឹងថា តើការបែងចែកដី ដែលបានធ្វើឡើងនេះ មានប្រសិទ្ធភាព ឬគ្មាន ហើយដែលប្រការនេះពួកគាត់មានការឯកភាពជារួមថា ជាទូទៅមិនមានប្រសិទ្ធភាពឡើយ ដោយសារតែបញ្ហាយុត្តិធម៌ និងសមធម៌ ដែលជាទូទៅត្រូវបានលើកឡើង ។ ក៏ប៉ុន្តែមិនបានយកមកអនុវត្តជាក់ស្តែងឡើយ នៅតាមកន្លែងដែលមានការបែងចែកដី ហើយជានិច្ចកាលដំណើរការនៃការបែងចែកដីមិនមានតម្លាភាពឡើយ ។ ជាងនេះទៅទៀត ការបែងចែកដីទាំងនេះ បានផ្តល់អោយប្រទេសកម្ពុជានូវបទពិសោធន៍ដ៏ច្រើនលើសលុប សំរាប់ការរៀបចំផែនការកម្មវិធីសម្បទានដីសង្គមកិច្ច ។

ដូចដែលបានបង្ហាញតាមរយៈបទពិសោធន៍ខាងលើរួចមកហើយ ដីខ្លួនឯងនឹងមិនអាចធានាបានថា កម្មវិធីនឹងនាំអោយមានការចាប់អារម្មណ៍ ពីអ្នកជាមុខសញ្ញាទទួលដីដែលមានសក្តានុពលឡើយ ហើយថា តើវានឹងរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ ប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាពដែរឬទេ ។ មេយ័រ (Maijers) (១៩៩៤) បានដកស្រង់សំដី ដោយវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (២០០១) បានអះអាងថា ប្រជាពលរដ្ឋកម្ពុជាដែលកំពុងប្រកបរបរកសិកម្ម មិនមានស្ថានភាពល្អប្រសើរឡើយ ហើយសូម្បីតែនៅក្នុងការធ្វើជំរឿន ឆ្នាំ១៩៦២ (មិនមានការធ្វើជំរឿនត្រូវបានធ្វើឡើងទៀតឡើយ រហូតមកដល់ឆ្នាំ១៩៩៥) បានបង្ហាញថា ៨៤ភាគរយនៃគ្រួសារដែលប្រកបមុខរបរកសិកម្ម ក្នុងចំណោមចំនួន៨០០.០០០គ្រួសារ គឺគ្រាន់តែជាម្ចាស់ដីប៉ុណ្ណោះ តែមិនមែនជាអ្នកធ្វើកសិកម្មពិតប្រាកដឡើយ ។ ដោយហេតុដូចនេះ បញ្ហាចោទចំពោះការរៀបចំផែនការកម្មវិធីសម្បទានដីសង្គមកិច្ចនោះគឺ : (១).តើកម្មវិធីនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ? និង (២).តើមានអត្ថប្រយោជន៍ដែរឬទេ នៅក្នុងការរៀបចំអោយមានកម្មវិធីនេះ? ។ បញ្ហាបន្ថែមផ្សេងទៀតនោះគឺ តើត្រូវមានវិធានការចាំបាច់អ្វីខ្លះទៀត ដើម្បីអោយកម្មវិធីសម្បទានដីសង្គមកិច្ច អាចសំរេចបាននូវគោលបំណងរបស់ខ្លួន និងកាត់បន្ថយផលប៉ះពាល់លើភាពក្រីក្រ អោយបានដល់កំរិតអតិបរមាដែរឬទេ? ។

មានការឯកភាពជារួមថា បច្ចុប្បន្នការផ្តល់ហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច និងសង្គមនៅតាមតំបន់ជនបទនៅគ្រប់ទីកន្លែងទាំងអស់នៅមានលក្ខណៈទន់ខ្សោយ ហើយកាន់តែទន់ខ្សោយជាងនេះទៅទៀត នៅតាមបណ្តាឃុំ

និងភូមិដែលស្ថិតនៅដាច់ស្រយ៉ាល ។ ដើម្បីធានាអោយមានការចាប់អារម្មណ៍ពីសក្តានុពល និងពីបេក្ខជនដែលជាមុខសញ្ញាទទួលដីស្របច្បាប់នៅក្នុងកម្មវិធី អ្នកចូលរួមនៅក្នុងការសិក្សាលើការធ្វើការវិភាគផលប៉ះពាល់លើភាពក្រីក្រ និងសង្គម បានលើកស្នើឡើងថា សេវាកម្ម និងហេដ្ឋារចនាសម្ព័ន្ធជាក់លាក់មួយចំនួន ត្រូវតែរៀបចំអោយមាន និងអាចដំណើរការបានពេញលេញនៅនឹងកន្លែង មុនពេល ឬក៏ក្នុងពេលដំណាលគ្នាជាមួយនឹងការអនុវត្តកម្មវិធី ។ ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មនានាដែលបានចាត់អាទិភាពដោយអ្នកចូលរួម នៅក្នុងក្រុមគោលដៅពិភាក្សា និងអ្នកឆ្លើយតបនៅក្នុងការអង្កេតតាមគ្រួសាររៀបទៅតាមលំដាប់អាទិភាព រួមមាន : (១).ការកែលំអលទ្ធភាពទទួលបានសេវាអប់រំ (៩៦ភាគរយ) (២).ការកែលំអផ្លូវថ្នល់ (៩៥ភាគរយ) (៣).ការកែលំអលទ្ធភាពទទួលបានសេវាកម្មថែទាំសុខភាព (៩៤ភាគរយ) (៤).ការកែលំអលទ្ធភាពទទួលបានសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ (៩៥ភាគរយ) (៥).ការសាងសង់ទីផ្សារ (៧៥ភាគរយ) (៦).ការរៀបចំអោយមានវត្តអារាម និងព្រះសង្ឃនៅនឹងកន្លែង (៧៤ភាគរយ) (៧).ការរៀបចំអោយមានភ្លើងអគ្គិសនីនៅតាមតំបន់ជនបទ (២៨ភាគរយ) ការកែលំអលទ្ធភាពទទួលបានឥណទាន (២៤ភាគរយ) ការបណ្តុះបណ្តាលវិជ្ជាជីវៈ (១៣ភាគរយ) និងមជ្ឈមណ្ឌលសាសនា ក្រៅពីព្រះពុទ្ធសាសនា (វិហារឥស្លាម) ។

ទោះបីជាភាគច្រើននៃអ្នកចូលរួមនៅក្នុងក្រុមគោលដៅពិភាក្សា និងអ្នកឆ្លើយតបនៅក្នុងការតាមអង្កេតគ្រួសារបានធ្វើការពិចារណាទៅលើការផ្គត់ផ្គង់សេវាកម្ម និងហេដ្ឋារចនាសម្ព័ន្ធនានា ថាជាកត្តាចាំបាច់សំរាប់អោយការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច ប្រព្រឹត្តទៅបានប្រកបដោយប្រសិទ្ធភាពក៏ដោយ ក៏ពួកគាត់បានអះអាងថា វិធានការកាត់បន្ថយភាពក្រីក្រ គឺវាត្រូវរួមផ្សំនឹងអន្តរាគមន៍ទាំងនេះ វាមិនមែនមានតែកម្មវិធីសម្បទានដីសង្គមកិច្ចតែមួយមុខប៉ុណ្ណោះទេ ដែលផ្តល់នូវវិធានការគ្រប់គ្រាន់នៅក្នុងការកាត់បន្ថយភាពក្រីក្រ ។ តិចជាង៦០ភាគរយនៃអ្នកចូលរួមនៅក្នុងក្រុមគោលដៅពិភាក្សា និងអ្នកឆ្លើយតបនៅក្នុងការអង្កេតតាមគ្រួសារ ជឿជាក់ថា កម្មវិធីសម្បទានដីសង្គមកិច្ច ផ្សាភ្ជាប់ជាមួយនឹងអន្តរាគមន៍ទាំងនេះ នឹងរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ ។ ក្នុងចំណោមមូលហេតុ សំខាន់នានាទាក់ទងទៅនឹងការគិតបែបនេះមានចរិកលក្ខណៈអវិជ្ជមានចំពោះកម្មវិធីសម្បទានដីសង្គមកិច្ច គឺដោយសារតែបទពិសោធន៍កន្លងមកជាមួយនឹងកម្មវិធីបែងចែកដី និងបញ្ហានៃកំនើនប្រជាពលរដ្ឋ[១២] ។ ផ្ទុយទៅវិញ គ្រប់សមាជិកនៃគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ដែលក្រុមសិក្សាបានជួប មានជំនឿជឿជាក់យ៉ាងមុតមាំថា កម្មវិធីសម្បទានដីសង្គមកិច្ច នឹងរួមចំណែកទៅដល់ការកាត់បន្ថយភាពក្រីក្រជារួម និងជាពិសេស ប្រសិនបើកម្មវិធីដាក់រួមបញ្ចូលនូវអន្តរាគមន៍នានាទាក់ទងទៅនឹងការអភិវឌ្ឍ ។ ក្នុងចំណោមក្រុមការងារថ្នាក់ស្រុកប្រហែលជា៧៥ភាគរយ បានមើលឃើញនូវមូលហេតុទាក់ទងគ្នារវាងកត្តាទាំងពីរ ហើយដែលជាង៥០ភាគរយផ្សេងទៀតនៃក្រុមប្រឹក្សាឃុំ សង្កាត់ ដែលក្រុមសិក្សាបានជួប ក៏មានការយល់ដឹងប្រហាក់ប្រហែលគ្នានេះដែរ ។

[១២] របាយការណ៍ស្តីពីសេចក្តីថ្លែងការរបស់អ្នកភូមិទាំងនេះ សូមមើលសេចក្តីបន្ថែមទី៣ ផ្នែកសេវាកម្ម និងហេដ្ឋារចនាសម្ព័ន្ធ ។

ដើម្បីធ្វើអោយកម្មវិធីអាចរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រជារួមបាន អន្តរាគមន៍ជាក់លាក់មួយចំនួន គួរតែត្រូវបានចាត់អទិភាព ដើម្បីសំរេចបាននូវលទ្ធផល ដែលនឹងនាំឈានទៅដល់ការកាត់បន្ថយភាពក្រីក្រ ។ អ្នកចូលរួមភាគច្រើននៅថ្នាក់ឃុំសង្កាត់ ភូមិ និងគ្រួសារ បានលើកឡើង ពីប្រភេទនៃអន្តរាគមន៍ផ្សេងៗ ដែលពួកគេចង់ឃើញអោយមានការដាក់បញ្ចូលទៅក្នុងកម្មវិធី ។ ជាង២ភាគ៣នៃអ្នកចូលរួមនៅក្នុងក្រុមគោលដៅពិភាក្សា និង១ភាគ៣នៃអ្នកឆ្លើយតបនៅក្នុងការអង្កេតតាមគ្រួសារ បានលើកឡើងពីអន្តរាគមន៍នានាទាក់ទងទៅនឹងការចិញ្ចឹមសត្វ ។ អ្នកចូលរួមមួយភាគធំផ្សេងទៀត នៅក្នុងក្រុមគោលដៅពិភាក្សា (៣០,៨ភាគរយ) និងអ្នកឆ្លើយតបនៅក្នុងការអង្កេតតាមគ្រួសារ (១៣,៧ភាគរយ) បានលើកឡើងពីអន្តរាគមន៍ជំនួយស្បៀងអាហារ ទោះបីជាចំនួនអ្នកឆ្លើយតបនៅក្នុងការអង្កេតតាមគ្រួសារមានចំនួនច្រើនជាងបន្តិចក៏ដោយ (១៦,១ភាគរយ) ក៏ពួកគេ បានអោយអាទិភាពទៅលើការកែលំអឧបករណ៍កសិកម្ម និងការអនុវត្តកម្មវិធីជំនួយស្បៀងអាហារ ថាជាអន្តរាគមន៍ចាំបាច់ បើប្រៀបធៀបជាមួយនឹងអ្នកចូលរួមនៅក្នុងក្រុមគោលដៅពិភាក្សា (២៤,២ភាគរយ) ។ អន្តរាគមន៍ផ្សេងទៀត គឺទាក់ទងទៅនឹងការកែលំអផលិតកម្មកសិកម្ម និងការកែច្នៃផលិតផលកសិកម្ម ។ អ្នកចូលរួមមួយចំនួនតូចផ្សេងទៀត ក៏បានអះអាងបញ្ជាក់ដែរថា ការកែលំអមូលធនសង្គម (ការរៀបចំចងក្រងសង្គម និងបណ្តាញនានា) ក៏ត្រូវបានលើកឡើងផងដែរ ។ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក៏បានកំណត់នូវអន្តរាគមន៍នានាមួយចំនួនតូចផងដែរ ។

ឧទាហរណ៍ថា បើសិនជារាល់សេវាកម្ម និងហេដ្ឋារចនាសម្ព័ន្ធសង្គម និងអន្តរាគមន៍ពាក់ព័ន្ធនានា ដូចដែលបានលើកឡើងខាងលើ ត្រូវបានផ្តល់រួមគ្នាជាមួយនឹងកម្មវិធីសម្បទានដីសង្គមកិច្ច អ្នកចូលរួមនៅក្នុងការសិក្សាស្តីពីការវិភាគផលប៉ះពាល់លើភាពក្រីក្រ និងសង្គម ជឿជាក់ថា អន្តរាគមន៍ទាំងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រ ។ គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្តក្រុង (៧៥ភាគរយ) ក្រុមការងារថ្នាក់ស្រុកខណ្ឌ (៦៩ភាគរយ) និងក្រុមប្រឹក្សាឃុំសង្កាត់ (៦២ភាគរយ) ជឿជាក់ថា កម្មវិធីនេះ នឹងទប់ស្កាត់នូវការធ្វើចំណាកស្រុករបស់ប្រជាពលរដ្ឋ ដើម្បីស្វែងរកការងារធ្វើ ។ សមាជិកនៃក្រុមការងារថ្នាក់ស្រុកខណ្ឌ និងក្រុមប្រឹក្សាឃុំ សង្កាត់ចំនួនស្មើគ្នា (៦២ភាគរយ) ក៏ប៉ុន្តែចំនួននេះមិនមានអ្នកចូលរួមជាសមាជិកមកពីគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្តក្រុងទេ ជឿជាក់ថា ការមានលទ្ធភាពក្នុងការប្រើប្រាស់ដីកសិកម្ម និងលំនៅដ្ឋាន នឹងជួយដល់ការកែលំអជីវភាពរស់នៅ ។ គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្តក្រុង (៥០ភាគរយ) មានជំនឿជឿជាក់ថា នឹងអាចកាត់បន្ថយបទល្មើសសង្គមនានា ។ ក្រុមការងារថ្នាក់ស្រុកខណ្ឌមានចំនួនតិចជាងបន្តិច (៤៤ភាគរយ) ព្រមទាំងក្រុមប្រឹក្សាឃុំសង្កាត់តិចតួចបំផុត (១០ភាគរយ) ក៏បានទទួលឯកភាពលើការពន្យល់នេះ ។ មានតែអ្នកចូលរួមដែលជាសមាជិកគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្តក្រុង (៧៥ភាគរយ) ប៉ុណ្ណោះដែលមានជំនឿជឿជាក់ថា ការផ្តល់នូវសេវាកម្ម និងហេដ្ឋារចនាសម្ព័ន្ធសង្គមនានាដោយផ្សារភ្ជាប់ជាមួយនឹងកម្មវិធីសម្បទានដីសង្គមកិច្ច នឹងជួយសំរួលក្នុងការកាត់បន្ថយភាពក្រីក្រ ហើយដែលអ្នកចូលរួមដូចគ្នានេះចំនួនមួយភាគតូចប៉ុណ្ណោះ (២៥ភាគរយ) ជឿជាក់ទៅលើការផ្សារភ្ជាប់កម្មវិធីនេះទៅនឹងការកែលំអបច្ចេកទេសកសិកម្ម ។

### ៣.៤.១. ហេដ្ឋារចនាសម្ព័ន្ធ និងសេវាអប់រំ

នៅក្នុងសំណាកគំរូនៃការសិក្សាស្រាវជ្រាវស្តីពីការវិភាគផលប៉ះពាល់លើភាពក្រីក្រ និងសង្គម ចំនួនជាមធ្យមនៃសាលារៀននៅថ្នាក់ស្រុកមានចំនួន៣៧ និងនៅថ្នាក់ឃុំមានចំនួន៤ ។ នៅថ្នាក់ស្រុកគ្រូបង្រៀនមានចំនួន ៣៨០នាក់ បង្រៀនដល់សិក្សានុសិស្សចំនួន១៦.១៤៩នាក់ (គ្រូម្នាក់បង្រៀនសិស្ស៤២,៦នាក់) ។ តាមការប៉ាន់ស្មាន ៨ភាគរយនៃសិស្សដែលគ្រប់អាយុចូលរៀន ជាទូទៅមិនបានចូលរៀនទេ ។ ចំពោះទិន្នន័យនៃចំនួនសិក្សានុសិស្ស ដោយបែកចែកតាមភេទ (ប្រុស ស្រី) ក្រុមសិក្សាមិនអាចមានលទ្ធភាពរកបាននៅឡើយ សំរាប់ការសិក្សាស្តីពីការវិភាគផលប៉ះពាល់លើភាពក្រីក្រ និងសង្គម ក៏ប៉ុន្តែក្រុមយើងអាចធ្វើការប៉ាន់ប្រមាណបាន ដោយផ្អែកលើបញ្ជីវត្តមានសិស្សចូលរៀននៅទូទាំងប្រទេស ដែលបានបង្ហាញថា មានចំនួនស្រីដែលមិនបានចូលច្រើនជាងបុរស ។ ជាងនេះទៅទៀត វាមានការចាំបាច់ណាស់នៅក្នុងការញែកអោយដាច់ ពីភាពខុសគ្នារវាង សិស្សចូលរៀនជាប្រចាំ និងសិស្សចូលរៀនមិនទៀងទាត់ : ដោយសារតែសិស្សស្រី ត្រូវជួយបំពេញការងារជាអ្នកថែទាំ ដែលប្រការនេះប្រហែលជាមូលហេតុដែលធ្វើអោយពួកគេមិនបានចូលរៀនបានទៀងទាត់ ដូចសិស្សប្រុសឡើយ ។ បន្ថែមលើនេះទៅទៀត មិនមានទិន្នន័យណាដែលអាចរកបាន ដើម្បីពិនិត្យពីគុណភាពនៃការបង្រៀន ឬមួយក៏ថាតើគ្រប់គ្រូបង្រៀនទាំងអស់ បានមកបង្រៀនជាប្រចាំ ឬពេញមួយថ្ងៃដែរឬយ៉ាងណាទេ នៅក្នុងរដូវបវេសនៈកាល ។ បញ្ហាគុណភាពសិក្សានេះ ត្រូវបានអ្នកចូលរួមនៅក្នុងក្រុមពិភាក្សារាយការណ៍ថា នៅក្នុងភូមិរបស់ពួកគាត់ មិនមានសាលារៀននៅក្នុង ឬនៅក្បែរភូមិឡើយ (៣៧,៥ភាគរយ) មិនមានបន្ទប់រៀនគ្រប់គ្រាន់ (៥២,៥ភាគរយ) និងមិនមានគ្រូបង្រៀនគ្រប់គ្រាន់ (៤០,៨ភាគរយ) ។ ជាទូទៅ ឪពុកម្តាយរបស់សិក្សានុសិស្ស ធ្វើការវាយតំលៃពីប្រសិទ្ធភាពរបស់សាលារៀន ដោយធ្វើការវាយតំលៃ ថាតើកំរិតនៃការរីកចំរើនលើចំណេះដឹងភាសារខ្មែររបស់កូនពួកគាត់ល្អដែរឬក៏អត់។

### ៣.៤.២. ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មថែទាំសុខភាព

មណ្ឌលសុខភាព មាននៅគ្រប់ស្រុកដែលយើងបានចុះទៅទស្សនៈកិច្ចទាំងអស់ ។ តែទោះជាយ៉ាងណាក៏ដោយ ក៏មិនមានបុគ្គលិកដែលមានជំនាញពេទ្យគ្រប់គ្រាន់ឡើយ ។ ជាមធ្យមមានវេជ្ជបណ្ឌិតតែម្នាក់ និងគិលានុបដ្ឋាក គិលានុបដ្ឋាកយាការ ១៧នាក់ ប៉ុណ្ណោះនៅទូទាំងស្រុក ។ នៅថ្នាក់ឃុំ នៅតាមកន្លែងដែលមានមណ្ឌលសុខភាព អាចមានវេជ្ជបណ្ឌិត និងគិលានុបដ្ឋាក គិលានុបដ្ឋាកយាការមួយ ឬពីរនាក់ ប្រចាំការនៅទីនោះ ម្តងម្កាលតែប៉ុណ្ណោះ ។ ក្រៅពីនោះ ក៏មានប៉ុស្តិ៍សុខភាពផងដែរ នៅតាមបណ្តាឃុំមួយចំនួន ក៏ប៉ុន្តែមិនមានវិជ្ជបណ្ឌិត ឬគិលានុបដ្ឋាក គិលានុបដ្ឋាកយាការ ដែលបានទទួលការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈពេទ្យត្រឹមត្រូវ អាចប្រចាំការនៅទីនោះម្តងម្កាល់បានឡើយ ។ ជារួម ប្រជាពលរដ្ឋបានត្អូញត្អែរពីកង្វះខាតក្នុងការផ្គត់ផ្គង់ថ្នាំសង្កូវ និងសេវាកម្មនានា ។ ពួកគាត់ក៏បានត្អូញត្អែរផងដែរ ពីអាកប្បកិរិយាអវិជ្ជមានរបស់បុគ្គលិកថែទាំសុខភាព ។ នៅថ្នាក់ភូមិ ៨៨,៣ភាគរយនៃក្រុមគោលដៅពិភាក្សាបានរាយការណ៍ថា មិនមានមណ្ឌលសុខភាពនៅក្នុង ឬនៅក្បែរភូមិរបស់

ពួកគាត់ឡើយ ។ នៅក្នុងតំបន់ដែលមិនមានមណ្ឌលសុខភាព ប្រជាពលរដ្ឋអាចទទួលបានសេវាថែទាំសុខភាព តែតាមរយៈគ្រូពេទ្យបុរាណតែប៉ុណ្ណោះ ។ ចំពោះប្រជាពលរដ្ឋដែលអាចមានលទ្ធភាពទទួលបាន សេវាថែទាំសុខភាព នៅមណ្ឌលសុខភាព មានតែមួយផ្នែកតូចតែប៉ុណ្ណោះ (៥,៨ភាគរយ) ដែលបានរាយការណ៍ ពីកង្វះខាតបុគ្គលិកពេទ្យ និង (១០,០ភាគរយ) ការផ្គត់ផ្គង់ថ្នាំសង្កូវ ។

## ៣.៤.៣. ការផ្គត់ផ្គង់ទឹក

នៅតំបន់ជនបទនៃប្រទេសកម្ពុជា ប្រភពសំខាន់ៗនៃការផ្គត់ផ្គង់ទឹក សំរាប់ការប្រើប្រាស់ក្នុងគ្រួសារ និងការប្រើប្រាស់ជាទូទៅ គឺអណ្តូងទឹក ត្រពាំង ទន្លេ និងបឹង ។ ចំពោះអណ្តូងទឹក បើផ្អែកតាមនិយមន័យរបស់អ្នកចូលរួមនៃក្រុមគោលដៅពិភាក្សា គឺរួមមានអណ្តូងស្នប់ដៃ អណ្តូងលូ និងអណ្តូងចំហរ ។ នៅថ្នាក់ស្រុក អណ្តូងទឹកមានចំនួនជាមធ្យម ៣០២,១ អណ្តូង ហើយដែលនៅថ្នាក់ឃុំត្រូវបានរាយការណ៍ថា មានអណ្តូងទឹកចំនួនជាមធ្យម៧២,១អណ្តូង ។ ប្រហែលជា៨០ភាគរយនៃអណ្តូងទឹក អាចមានលទ្ធភាពប្រើប្រាស់បានពេញមួយឆ្នាំ ដោយសារតែសមត្ថភាពផ្គត់ផ្គង់នៃខ្សែទឹកក្រោមដីនៅក្នុងរដូវប្រាំងមានកំរិតទាប ។ ទោះជាយ៉ាងណាក៏ដោយក៏ត្រពាំង គឺជាប្រភពផ្គត់ផ្គង់ទឹកតែមួយគត់សំរាប់សហគមន៍ភាគច្រើននៅតំបន់ជនបទ ។ ជាមធ្យមមានត្រពាំងទឹកចំនួន១៥.១ និង២.៣ ត្រូវបានកត់ត្រាថាមាននៅថ្នាក់ស្រុក និងឃុំ ។ ក្នុងចំណោមចំនួនអណ្តូងទឹក ដែលមានទាំងអស់ មានអណ្តូងទឹកតែ៥៦,៦ និង២៨,៥ភាគរយ ដែលបានរាយការណ៍ថា អាចប្រើប្រាស់បានពេញមួយឆ្នាំ ។ ក្នុងចំណោមទន្លេទាំងអស់ មានតែ៩៥,០ភាគរយប៉ុណ្ណោះដែលអាចផ្គត់ផ្គង់ទឹកបានពេញមួយឆ្នាំបាន សំរាប់ការប្រើប្រាស់ ក្នុងគ្រួសារ និងការប្រើប្រាស់ទូទៅនៅថ្នាក់ស្រុកខណ្ឌ និងថ្នាក់ឃុំ សង្កាត់ ។ នៅថ្នាក់ស្រុកខណ្ឌ ក្រុមការងារថ្នាក់ស្រុក បានរាយការណ៍ថា ៥២,២ភាគរយនៃបឹងធម្មជាតិ អាចផ្តល់ការផ្គត់ផ្គង់ទឹកបានខួបប្រាំង ខួបវស្សា ដែលក្នុងពេល ជាមួយគ្នានេះដែរ នៅថ្នាក់ឃុំ ក្រុមប្រឹក្សាឃុំ សង្កាត់បានរាយការណ៍ថា មានបឹងចំនួនតែ ១៩ភាគរយប៉ុណ្ណោះ ដែលអាចផ្គត់ផ្គង់ទឹកប្រើប្រាស់បានពេញមួយឆ្នាំ ។ នៅថ្នាក់ភូមិក្រុមគោលដៅពិភាក្សាបានរាយការណ៍ថា ជាមធ្យមមាន អណ្តូងទឹកចំនួន២០ និងត្រពាំងតែមួយប៉ុណ្ណោះ ដែលជាប្រភពនៃការផ្គត់ផ្គង់ទឹកសំរាប់ការប្រើប្រាស់ក្នុងគ្រួសារ ។ ជាងពាក់កណ្តាល(៥៥ភាគរយ)នៃក្រុមគោលដៅពិភាក្សាបានរាយការណ៍ថា ពួកគាត់ពឹងផ្អែកទៅលើទឹកទន្លេ ហើយមួយចំនួនតូចទៀត (២០ភាគរយ) ពឹងផ្អែកទៅលើទឹកទន្លេ និងបឹង ជាប្រភពទឹកសំរាប់ប្រើប្រាស់ក្នុងគ្រួសារ ហើយ២០,៨ភាគរយផ្សេងទៀត ពឹងផ្អែកទៅលើទឹកទន្លេ និងបឹង ជាប្រភពផ្គត់ផ្គង់ទឹកសំរាប់ប្រើប្រាស់ក្នុងគ្រួសារដូចគ្នា ។

## ៣.៤.៤. ភ្លើងបំភ្លឺ

ប្រេងឥន្ធនៈ គឺជាប្រភពសំខាន់សំរាប់អុជបំភ្លឺរបស់គ្រួសារភាគច្រើន នៅតំបន់ជនបទនៃប្រទេសកម្ពុជា ។ អ្នកចូលរួមនៅក្នុងក្រុមគោលដៅពិភាក្សាបានរាយការណ៍ថា ការអុជបំភ្លឺដោយប្រើប្រាស់ប្រេងឥន្ធនៈ មានចំនួនរហូតដល់ទៅ ៦២,៧ភាគរយ ហើយការប្រើប្រាស់អាគុយសំរាប់គោលបំណងដូចគ្នានេះមានចំនួន៣១,៥ភាគរយ ។

ការមានលទ្ធភាពក្នុងការប្រើប្រាស់ភ្លើងអគ្គិសនី គឺមានកំរិតតិចតួចណាស់ ហើយអាចមានតែនៅតាមតំបន់ ដែលស្ថិតនៅជិតទីរួមស្រុក ឬក៏ប្រជុំជនតូចៗប៉ុណ្ណោះ ។ ភ្លើងអគ្គិសនីទាំងនេះ មានតែនៅក្នុងរយៈពេលមួយខ្លី នាពេលព្រលប់តែប៉ុណ្ណោះ ជាទូទៅក្នុងរយៈពេលពីរ៣ ទៅ៤ម៉ោង ចាប់ពីម៉ោង១៨:០០ល្ងាច ដល់ម៉ោង ២២:០០យប់ ។

## ៣.៤.៥. ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មទីផ្សារ និងផ្លូវថ្នល់

ជាមធ្យម មានផ្សារចំនួនប្រហែល៣នៅថ្នាក់ស្រុក ។ ក្នុងចំណោមចំនួនផ្សារនោះ មានផ្សារតែមួយកន្លែងតែប៉ុណ្ណោះ ដែលបើកដំណើរការលក់ដូរពេញមួយថ្ងៃ ។ កម្រមានផ្សារលក់ដូរនៅថ្នាក់ឃុំ និងភូមិណាស់ ក្នុងចំណោមភូមិដែលយើងបានទៅទស្សនកិច្ច មានភូមិចំនួនតែ ៨,៣ភាគរយប៉ុណ្ណោះ ដែលមានផ្សារ ហើយដែលក្នុងនោះមាន ២,៥ភាគរយ បើកដំណើរការលក់ដូរពេញមួយថ្ងៃ ។ អវត្តមាននៃទីផ្សារនៅក្នុងភូមិ ប្រហែលជាមិនមែនបញ្ហាអ្វីឡើយ ចំពោះអ្នកភូមិភាគច្រើន ដោយសារតែពួកគាត់មានជីវភាពក្រីក្រខ្លាំង ហើយប្រហែលជាមិនមានអ្វីសំរាប់ធ្វើការដោះដូរឡើយ ។ បញ្ហាប្រឈមមុខពិតប្រាកដរបស់អ្នកភូមិនោះ គឺលទ្ធភាពក្នុងការទៅកាន់ទីផ្សារ ដែលមានស្រាប់នៅថ្នាក់ស្រុក ឬថ្នាក់ខេត្ត ។ ចំងាយពីរភូមិទាំងនោះទៅទីរួមស្រុក មិនមានចំងាយ ឆ្ងាយប៉ុន្មានឡើយ ក៏ប៉ុន្តែស្ថានភាពផ្លូវថ្នល់ គឺជាបញ្ហាប្រឈមចំបង ដែលជាកត្តាធ្វើអោយមានបញ្ហាលំបាក ក្នុងលទ្ធភាពទៅកាន់ទីផ្សារ និងពិបាកក្នុងការផ្តល់សេវានៃមធ្យោបាយធ្វើដំណើរ ។ ចំងាយជាមធ្យមពីភូមិដែល យើងបានទៅទស្សនកិច្ចទៅកាន់ទីរួមស្រុក មានចំងាយប្រហែលតែ ១៩គីឡូម៉ែត្រតែប៉ុណ្ណោះ ។ ចំងាយជាមធ្យមពីទីរួមឃុំទៅកាន់ទីរួមស្រុក មានចំងាយ១៦,៤គីឡូម៉ែត្រ ហើយពីទីរួមស្រុកទៅកាន់ទីរួមខេត្ត មានចំងាយ៣៩គីឡូម៉ែត្រ ។ ទោះជាយ៉ាងណាក្តី លទ្ធភាពក្នុងការធ្វើដំណើរទៅកាន់ឃុំ និងភូមិមានកំរិតកំណត់ជាពិសេសនៅក្នុងរដូវវស្សា ។ អ្នកចូលរួមនៅក្នុងក្រុមគោលដៅពិភាក្សាបានរាយការណ៍ថា ៦០,៦០ភាគរយនៃផ្លូវនៅក្នុងភូមិរបស់ពួកគាត់ អាចធ្វើចរាចរទៅវិញទៅមកបានពេញមួយឆ្នាំ ដោយជិះម៉ូតូ ហើយនៅរដូវប្រាំងអាចធ្វើចរាចរដោយឡានដឹកទំនិញ ឡានភីកអាប់ និងឡានទេសចរណ៍ ។ អ្នកភូមិមានចំនួនតិចជាង១០ភាគរយ នៅក្នុងតំបន់ដែលយើងបានទៅសិក្សាស្រាវជ្រាវ អាចធ្វើដំណើរទៅបាន តែតាមរយៈការធ្វើដំណើរតាមទូកតែប៉ុណ្ណោះ ។

តំលៃសំរាប់សេវាកម្មធ្វើដំណើរ ដែលផ្តល់ដោយមធ្យោបាយដឹកជញ្ជូនផ្សេងៗគ្នា ជាមធ្យមមានតំលៃខ្ពស់ បើប្រៀបធៀបទៅនឹងកំរិតស្តង់ដារជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ។ នៅថ្នាក់ភូមិ ការធ្វើដំណើរទៅកាន់ទីរួមស្រុកតាមម៉ូតូមានតំលៃ៦.៨០៥,៧រៀល រឺម៉ក ២.៦០៩,៦រៀល ឡានភីកអាប់ ៣.០៩៣,៣រៀល និងតាមទូកមានតំលៃ៥.៦៦៣,៦រៀល ។ ការធ្វើដំណើរពីទីរួមឃុំទៅកាន់ទីរួមស្រុកដោយម៉ូតូមានតំលៃ៦.៥៦៩,៤រៀល រថសណ្តោងឬរឺម៉ក ១.៦៥៣,៨រៀល ឡានភីកអាប់ ឬទេសចរណ៍១២កៅអី ១.៩៧៨,៦រៀល ឬ៩៧៨,៦រៀល និងតាមរថយន្តតាក់ស៊ី ២.៥០០,០រៀល ។ ការធ្វើដំណើរពីទីរួមស្រុកទៅកាន់ទីរួមខេត្តតាមរយៈមធ្យោបាយធ្វើដំណើរ ដូចគ្នាមានតំលៃ១៥.៤៨៣,៣រៀល ២.១៦៦,៧រៀល ៥.៩៥០,០រៀល និង៨.៨៧៥,០រៀល ។ នៅក្នុងតំលៃនេះ យើងអាចប៉ាន់ស្មានបានយ៉ាងពិតប្រាកដថា ភាគច្រើននៃប្រជាពលរដ្ឋនៅថ្នាក់ភូមិ កម្រមានអ្នកមានលទ្ធភាពធ្វើដំណើរទៅកាន់ទីរួមខេត្តណាស់ ។

### ៣.៤.៦. ឥណទាន

តាមការរាយការណ៍ ពីសមាជិកក្រុមការងារថ្នាក់ស្រុក ឥណទានដែលមានទាំងតាមប្រព័ន្ធក្រៅផ្លូវការ និងផ្លូវការ មានអត្រាខ្ពស់រហូតដល់ទៅ៨១,៣ភាគរយ និង ៧៥,០ភាគរយ ។ ព័ត៌មានដែលផ្តល់អោយក្រុមប្រឹក្សាឃុំ សង្កាត់ ទាក់ទងទៅនឹងចំនួននេះ មានលក្ខណៈដូចគ្នា ។ ទោះជាយ៉ាងនេះក្តី ក៏នៅថ្នាក់ភូមិ សហគមន៍មួយចំនួនតូច បានរាយការណ៍ថា សេវាកម្មទាំងនេះមាននៅក្នុងភូមិរបស់ពួកគាត់ ។ ក្នុងចំណោមក្រុមគោលដៅពិភាក្សាទាំងអស់ ៥០,៨ភាគរយ និង៥៨,៣ភាគរយ បានរាយការណ៍ថា មានសេវាកម្មឥណទានទាំងតាមប្រព័ន្ធក្រៅផ្លូវការ និងផ្លូវការ ។ តែទោះបីជាមានឥណទានទាំងនោះក៏ដោយ ក៏មានប្រជាពលរដ្ឋដែលរស់នៅក្នុងភូមិតែពាក់កណ្តាលតែប៉ុណ្ណោះ ដែលអាចមានលទ្ធភាពទទួលបាននូវសេវាឥណទាននេះ ដោយសារតែពួកគេមានការខ្វះខាតនូវការចងក្រងជាក្រុម ឬសហគមន៍សមស្រប ឬគ្រាន់តែខ្ចីសំរាប់បំរើតែគោលបំណងគាំទ្រជីវភាពរស់នៅតែប៉ុណ្ណោះ (ដូចជា ព្យាបាលជំងឺសមាជិកក្នុងគ្រួសារ) ។ អត្រាការប្រាក់ឥណទានតាមប្រព័ន្ធក្រៅផ្លូវការ មានកំរិតខុសគ្នា ចាប់ពីជាង៦ភាគរយ ទៅ៣០ភាគរយក្នុងមួយខែ ហើយដែលតាមរយៈឥណទានក្នុងប្រព័ន្ធផ្លូវការ អត្រានេះមានចំនួយតែពីជាង ៣ភាគរយ ទៅ១៤ភាគរយប៉ុណ្ណោះក្នុងមួយខែ ។

## ៣.៥. អ្នកផ្តល់សេវាកម្មផ្សេងៗទៀត

បន្ថែមពីលើហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មដែលបានរៀបរាប់ខាងលើ អ្នកចូលរួមនៅក្នុងការសិក្សាការវិភាគផលប៉ះពាល់លើភាពក្រីក្រ និងសង្គម ក៏បានកំណត់ពីអ្នកផ្តល់សេវាកម្មផ្សេងទៀត ដែលមានសារៈសំខាន់សំរាប់ពួកគាត់ផងដែរ ។ អ្នកផ្តល់សេវាកម្មទាំងនេះរួមមាន សេវាកម្មដែលផ្តល់ដោយមជ្ឈមណ្ឌលសាសនា ដូចជា ទីវត្តអារាម វិហារគ្រិស្តសាសនា និងវិហារឥស្លាម អង្គការមិនមែនរដ្ឋាភិបាល ក្រុមកសិករ និង គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ ។

### ៣.៥.១. ក្រុមសាសនា

នៅគ្រប់ឃុំ សង្កាត់ទាំងអស់ មានវត្តអារាមយ៉ាងតិចចំនួនពីរ និងជាមធ្យមមានព្រះសង្ឃគង់នៅចំនួន ១១អង្គ និងដូនជី ព្រមទាំងគណៈកម្មការវត្តចំនួនបី ដែលមានសមាជិក ជាមធ្យមមានចំនួន១១នាក់ (ជាទូទៅជាបុរសមានវ័យចំណាស់) ។ មិនមែនសុទ្ធតែគ្រប់ភូមិទាំងអស់នោះទេ ដែលអាចមានលទ្ធភាពសាងសង់វត្តអារាម និងគាំទ្រដល់សាសនាគ្រប់ពេលវេលា ។ ប៉ុន្តែ នៅតាមកន្លែងដែលពួកគាត់អាចមានលទ្ធភាពធ្វើបែបនេះបាន គេតែងតែឃើញមានគណៈកម្មការវត្តត្រូវបានបង្កើតឡើងផងដែរ ។

មិនដូចគ្នានឹងទីវត្តអារាមរបស់ព្រះពុទ្ធសាសនា និងព្រះសង្ឃខ្មែរដែលស្ថិតនៅក្នុងសម័យការក្រោមការគ្រប់គ្រងរបស់បារាំងទេ ទីវត្តអារាមព្រះពុទ្ធសាសនា និងព្រះសង្ឃពេលបច្ចុប្បន្ន ជាទូទៅផ្តល់នូវសេវាកម្មសាសនា និងប្រពៃណី ។ ឧទាហរណ៍ការផ្តល់សេវាសំរាប់ពិធីការរៀបអាពាហ៍ពិពាហ៍ ពិធីបុណ្យសព ពិធីបុណ្យចូលឆ្នាំ និង

ពិធីបុណ្យប្រពៃណីផ្សេងៗទៀត ការផ្តល់ការបណ្តុះបណ្តាលព្រះពុទ្ធសាសនា និងការកៀងគរធនធានក្នុងមូលដ្ឋាន និងពីខាងក្រៅសំរាប់ការសាងសង់វិហារព្រះពុទ្ធសាសនា ផ្លូវថ្នល់ និងសាលារៀននៅមូលដ្ឋាន ។ នៅក្នុងអំឡុងពេលនៃអណានិគមបារាំង ទីវត្តអារាមព្រះពុទ្ធសាសនា គឺជាទីកន្លែងរក្សាវប្បធម៌របស់កម្ពុជា ផ្តល់ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងជាទីកន្លែងដែលអ្នកស្នេហាជាតិប្រឆាំងអនានិគមបារាំងត្រូវបានប្រមូលផ្តុំគ្នា ។ នៅពេលនោះព្រះសង្ឃក៏ជាសមាជិកក្រុមអ្នកស្នេហាជាតិផងដែរ ដែលបានតស៊ូប្រឆាំងដើម្បីអត្តសញ្ញាណជាតិ និងឯករាជ្យភាពនៅកម្ពុជា ។

តែទោះជាយ៉ាងណាក៏ដោយ ក៏ទីវត្តអារាមនាបច្ចុប្បន្ន មានលក្ខណៈខុសគ្នាពីមុន ។ ទីវត្តអារាមបច្ចុប្បន្នចូលរួមយ៉ាងសកម្មនៅក្នុងការផ្សព្វផ្សាយនូវតំលៃវប្បធម៌ខ្មែរ ជាទីកន្លែងផ្តល់នូវការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងការអប់រំនយោបាយ ហើយជាទីកន្លែងផ្តល់នូវពីធីបុណ្យព្រះពុទ្ធសាសនាគ្រប់បែបយ៉ាង ដែលជាតំលៃនៃវប្បធម៌កម្ពុជា ហើយបើតាមមតិរបស់អ្នកចូលរួមនៃក្រុមគោលដៅពិភាក្សាបានអោយដឹងថា ប្រហែលជាមួយភាគបីនៃទីវត្តអារាម ផ្តល់នូវការជួយគាំទ្រក្នុងសកម្មភាពកៀគរធនធានសំរាប់សង្គម រួមទាំងផ្តល់កំលាំងពលកម្ម ក្នុងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធយ៉ាងសស្រាក់សស្រាំទៀតផង ។

ជាទូទៅក្រុមជនជាតិភាគតិចខ្មែរឥស្លាម ដែលបានចាត់ទុកថាខ្លួនថាជាមូស្លីម តែងតែចាត់ទុកព្រះវិហារ គឺជាមជ្ឈមណ្ឌលនៃជីវិតវប្បធម៌ និងសាសនាភូមិរបស់ពួកគេ ។ នៅតាមបណ្តាភូមិនានាមួយចំនួន ព្រះវិហារ គឺប្រើប្រាស់សំរាប់តែការគោរពបូជា និងការផ្សព្វផ្សាយនូវគំនិតសាសនាផ្សេងៗ ក៏ប៉ុន្តែព្រះវិហារនៅតាមបណ្តាភូមិខ្លះទៀតក៏ដើរតួនាទីសង្គមសំខាន់ផងដែរ នៅក្នុងការជួយគាំទ្រដល់គ្រួសារក្រីក្រ និងងាយទទួលរងគ្រោះ ដោយផ្អែកទៅលើការរួមចំណែកពីអ្នកភូមិផ្សេងទៀត ដែលមានជីវភាពធូរធារជាង ។ លើសពីនេះទៅទៀតនៅតាមបណ្តាភូមិមួយចំនួន ដែលមានប្រជាពលរដ្ឋមួយចំនួនបានផ្លាស់ប្តូរទៅកាន់សាសនាគ្រីស្ត (តាមប្រវត្តិភាគច្រើននៃប្រជាពលរដ្ឋទាំងនេះ គឺជាជនជាតិវៀតណាម ក៏ប៉ុន្តែបច្ចុប្បន្នមានសកម្មភាពធំធេង ដោយអ្នកកាន់លិទ្ធិនិកាយប្រូតេសស្តង់នៅកម្ពុជា រួមបញ្ចូលទាំងនៅតំបន់ខ្ពង់រាបផងដែរ) មានព្រះវិហារមួយចំនួន មានការទាក់ទងតែជាមួយនឹងការអភិវឌ្ឍលើសតិបញ្ញា ក៏ប៉ុន្តែនៅតាមបណ្តាភូមិខ្លះទៀត ព្រះវិហារមានការពាក់ព័ន្ធទៅនឹងការជួយកែលំអជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ដែលមិនមានបំណងចង់ក្លាយជាអ្នកកាន់សាសនាគ្រីស្តផងដែរ ។

### ៣.៥.២. អង្គការមិនមែនរដ្ឋាភិបាល

អង្គការមិនមែនរដ្ឋាភិបាល មានសកម្មភាពសកម្មនៅក្នុងប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ១៩៧៩មក (មួយចំនួនមានមូលដ្ឋាននៅទីក្រុង មុនឆ្នាំ១៩៧៥) ក៏ប៉ុន្តែពួកគេបានរីកសាយចាប់តាំងពីដើមឆ្នាំ១៩៩០មក ។ នៅគ្រប់ភូមិទាំងអស់ មានអង្គការមិនមែនរដ្ឋាភិបាលយ៉ាងតិចមួយកំពុងប្រតិបត្តិការនាពេលបច្ចុប្បន្ន ។ អង្គការមិនមែនរដ្ឋាភិបាល ដែលមាននៅតាមបណ្តាភូមិទាំងនេះ មានមុខងារ និងគំរោងផ្សេងៗគ្នា ។ ភាគច្រើននៃអង្គការទាំងនេះធ្វើការសំរបសំរួលការផ្តល់សេវាកម្មសង្គមផ្សេងៗ ហើយភាគច្រើនផ្តោតទៅលើផ្នែកសុខុមាលភាព ក៏ប៉ុន្តែខ្លះទៀត

សំរបសំរួលអនុវត្តគំរោងអភិវឌ្ឍន៍នានា រួមបញ្ចូលទាំងគំរោងកសាងសមត្ថភាព ដើម្បីអោយការរៀបចំសហគមន៍មូលដ្ឋានអាចបង្កើតឡើងបាន ដែលរួមបញ្ចូលទាំងការព្រងឹងសិទ្ធិដល់ក្រុមអ្នកក្រីក្រ និងអ្នកងាយទទួលរងគ្រោះជាពិសេសក្រុមស្ត្រី ។ អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនទៀត ដូចជាអង្គការអុកស្វាម អង្គការស៊ីដសេ និងអង្គការប៉ាដិក បានចូលរួមយ៉ាងសកម្ម នៅក្នុងការដោះស្រាយបញ្ហាទំនាស់ដីធ្លី ក៏ប៉ុន្តែការពិត គឺគ្រប់អង្គការមិនមែនរដ្ឋាភិបាលដែលទើបបានបង្កើតឡើងថ្មីៗទាំងអស់ បាននិងកំពុងស្វែងរកការចូលរួមយ៉ាងសកម្មក្នុងការដោះស្រាយបញ្ហាអភិវឌ្ឍន៍នានា ដោយប្រើវិធីសាស្ត្រការកែលំអជីវភាពរស់នៅ ។

### ៣.៥.៣. សមាគមន៍កសិករ

មានភូមិចំនួនតិចតួចណាស់ដែលបានរាយការណ៍ថា មានសមាគមន៍ ឬក្រុមកសិករបានបង្កើតឡើង ។ នៅក្នុងចំណោមភូមិចំនួន១២០ភូមិ មានតែអ្នកចូលរួមនៅក្នុងក្រុមគោលដៅពិភាក្សាចំនួន១៣,៤ភាគរយប៉ុណ្ណោះដែលបានរាយការណ៍ថា មានក្រុមកសិករបានបង្កើតឡើង ។ ជាមធ្យម ចំនួនក្រុមកសិករនៅក្នុងភូមិ ដែលយើងបានធ្វើទស្សនកិច្ចមានចំនួនតែ០,១ភាគរយ តែប៉ុណ្ណោះ ។ ក្រុមកសិករទាំងនេះ មិនបានចូលរួមយ៉ាងសកម្មនៅក្នុងការកែលំអជីវភាពរស់នៅ តាមរយៈការគាំទ្រដល់ក្រុមផលិត ឬការផ្សព្វផ្សាយនូវចំណេះដឹងថ្មីៗអំពីការកែលំអបច្ចេកទេសដាំដុះទេ ។

### ៣.៥.៤. គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ

គណៈកម្មាធិការអភិវឌ្ឍន៍ភូមិត្រូវបានសំរបសំរួលបង្កើតឡើងជាលើកទីមួយ នៅក្នុងប្រទេសកម្ពុជានៅដើមឆ្នាំ១៩៩០ ដោយក្រសួងអភិវឌ្ឍន៍ជនបទ កម្មវិធីសិលារបស់រាជរដ្ឋាភិបាលកម្ពុជា និងដោយអង្គការមិនមែនរដ្ឋាភិបាលជាច្រើនទៀត ។ បើយោងទៅតាមអ្នកចូលរួមនៅក្នុងក្រុមគោលដៅពិភាក្សា តួនាទីសំខាន់របស់គណៈកម្មាធិការអភិវឌ្ឍន៍ភូមិទាំងនេះ គឺស្វែងរក និងសំរបសំរួលជំនួយនានាពីខាងក្រៅសំរាប់ជួយដល់ការអភិវឌ្ឍន៍ (២៨,៣ភាគរយ) កៀងគរប្រជាពលរដ្ឋអោយចូលរួមអនុវត្តសកម្មភាពអភិវឌ្ឍន៍នានា (២៤,២ភាគរយ) និងផ្សព្វផ្សាយព័ត៌មានអំពីកម្មវិធីថែទាំសុខភាព (១០ភាគរយ) ។ យ៉ាងហោចណាស់ក៏មានគណៈកម្មាធិការអភិវឌ្ឍន៍ភូមិមួយដែរ ក្នុងមួយភូមិ ។ ការសិក្សាវាយតំលៃ ថាតើគណៈកម្មាធិការទាំងនោះ បានបំពេញការងារមានប្រសិទ្ធភាព ឬក៏គ្មាន គឺជាបញ្ហាលំបាក ក៏ប៉ុន្តែពួកគាត់បានផ្តល់នូវបណ្តាញខ្សែបណ្តោយ ដែលអាចបង្កើននូវជំនឿទុកចិត្តពីប្រជាពលរដ្ឋ និងលទ្ធភាពនៅក្នុងការធ្វើការងារជាមួយគ្នា និងពង្រីកនូវលទ្ធភាពអាចទំនាក់ទំនងជាមួយស្ថាប័នថ្នាក់ផ្សេងទៀតបាន ។ ជាទ្រឹស្តី ពួកគាត់បានផ្តល់នូវឱកាសរបៀបជាស្ថាប័នសំរាប់អ្នកក្រីក្រ រួមទាំង (ជាពិសេស) ស្ត្រី ដើម្បីចូលរួមក្នុងបណ្តាញដែលធ្លាប់តែត្រូវបានគេមិនរាប់បញ្ចូលកន្លងមក ។ ពួកគេអាចផ្តល់នូវវេទិការមួយ ដើម្បីពិភាក្សាលើអទិភាពនានារបស់ភូមិ និងចូលរួមយ៉ាងសកម្មនៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍ភូមិ ឃុំរបស់ពួកគេ ។

## ៤. ប្រជាពលរដ្ឋ និងដីធ្លី : ភាពគ្មានដីធ្លី និងដីដែលមានសក្តានុពលសំរាប់ធ្វើការបែងចែក

### ៤.១. វិសាលភាពនៃភាពគ្មានដីធ្លី

ភាពគ្មានដីធ្លី នៅក្នុងរបាយការណ៍ស្តីពីការប្រមូលព័ត៌មានអំពីភាពគ្មានដីធ្លី និងការអភិវឌ្ឍ (LADIT) ឆ្នាំ២០០៤ បានបង្ហាញអោយឃើញថា ក្នុងចំណោមសំណាកគំរូចំនួន ២២.១៩៣គ្រួសារ នៅក្នុង៨ខេត្ត នៃតំបន់កសិ-បរិស្ថានទាំង៤ ក្នុងប្រទេសកម្ពុជា គឺមាន១១,៩ភាគរយ ដែលចំនួននេះស្ថិតនៅចន្លោះពីកំរិតខ្ពស់ ២៥,៤ភាគរយ នៃចំនួនគ្រួសារ នៅក្នុងខេត្តបាត់ដំបងដែលស្ថិតនៅក្នុងតំបន់កសិ-បរិស្ថានទន្លេសាប និងកំរិតទាប ៤,៤ភាគរយ នៅក្នុងខេត្តព្រះវិហារ ដែលស្ថិតនៅក្នុងតំបន់កសិ-បរិស្ថានខ្ពង់រាប ។ ដូចគ្នានេះដែរ ភាពគ្មានដីធ្លីនៃគ្រួសារដែលស្ត្រីជាមេគ្រួសារ នៅក្នុងចំណោមចំនួនសំណាកគំរូនេះ គឺមានចំនួន១៨,៩ភាគរយ ដែលចំនួននេះស្ថិតនៅចន្លោះពីកំរិតខ្ពស់ ៤២,២ភាគរយ ក៏ស្ថិតនៅក្នុងខេត្តបាត់ដំបង ចុះមកត្រឹម៧,៩ភាគរយនៅក្នុងខេត្តកំពត នៅក្នុងតំបន់កសិ-បរិស្ថានឆ្នេរសមុទ្រ ។ ការប្រៀបធៀបជាមួយនឹងតួលេខនៃភាពគ្មានដីធ្លី ពីការអង្កេតសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ១៩៩៩ (SES 99) មានភ្ជាប់ជាមួយនៅក្នុងសេចក្តីបន្ថែមទី១ តារាងទី១ ទោះជាវិធីសាស្ត្រនៃការជ្រើសរើសសំណាកគំរូនេះមានបញ្ហាខ្លះៗក៏ដោយ ។ ទោះជាយ៉ាងណាក៏ដោយ ក៏មានភាពដូចគ្នាជាទូទៅមួយរវាងតួលេខទាំងពីរនេះដែរ គឺតួលេខប៉ាន់ស្មាននៃអ្នកដែលគ្មានដីធ្លី មានចំនួនខ្ពស់ជាងតួលេខនៅក្នុងការអង្កេតលើការវិភាគផលប៉ះពាល់ភាពក្រីក្រ និងសង្គម (PSIA) ។

ការសិក្សាស្តីពីការប្រមូលព័ត៌មានអំពីភាពគ្មានដីធ្លី និងការអភិវឌ្ឍ (LADIT) ដែលផ្តល់មូលនិធិគាំទ្រដោយអុកស្វាម បានសន្និដ្ឋានថា រឿងរ៉ាវទាក់ទងទៅនឹងករណីឧបទ្ទវហេតុដែលនាំអោយគ្មានដីធ្លី នៅក្នុងភូមិជាក់លាក់ មិនងាយស្រួលនឹងធ្វើការរាប់ចំនួនបានឡើយ ឬសូម្បីតែចំនួនគ្រួសារដែលចាកចេញពីភូមិដោយសារពួកគេគ្មានដីធ្លីតាំងពីដំបូងមក ឬពួកគេក្លាយជាគ្មានដីធ្លី ក៏មានការលំបាកនៅក្នុងការកំណត់ចំនួនដែរ ហើយគ្រួសារដែលនៅសល់នៅក្នុងតំបន់ទាំងនោះ សុទ្ធសឹងតែជាអ្នកដែលគ្មានដីធ្លីដូចគ្នាដែរ ។ ការសិក្សានេះ ក៏បានលើកឡើងដែរថា វាមានការលំបាកណាស់ក្នុងការនិយាយជាទូទៅ ក៏ប៉ុន្តែបានលើកឡើងថា ប្រសិនបើ មានករណីឧបទ្ទវហេតុនៃភាពគ្មានដីធ្លីខ្ពស់ នៅក្នុងភូមិមួយចំនួន ដូចជា នៅក្នុងខេត្តបាត់ដំបង ឬខេត្តកោះកុង គេអាចកំណត់តំបន់ ដែលគ្រួសារក្រីក្រ ឬងាយទទួលរងគ្រោះ អាចរស់នៅបានដោយពុំចាំបាច់មានទ្រព្យសម្បត្តិជាដីធ្លីទេ ។ ទាំងនៅក្នុងខេត្តបាត់ដំបង និងកោះកុង គឺជាខេត្តដែលមានទីតាំងស្ថិតនៅក្នុងតំបន់កសិ-បរិស្ថាន ដែល សហគមន៍មូលដ្ឋានអាចមានលទ្ធភាពប្រើប្រាស់ទឹក និងព្រៃឈើធម្មជាតិបាន និងជាកន្លែងដែលតំរូវការពលកម្មប្រចាំថ្ងៃសំរាប់វិស័យកសិកម្ម មានកំរិតខ្ពស់ ទាំងនៅក្នុង និងក្រៅ ។

ភាពខុសគ្នារវាងខេត្តផ្សេងៗគ្នា នៅក្នុងតំបន់កសិ-បរិស្ថានតែមួយ បញ្ជាក់ពីវិសាលភាពដែលតំបន់ទាំងនេះមិនមានលក្ខណៈរួមដូចគ្នាជាទូទៅឡើយ ។ ជាឧទាហរណ៍ នៅខេត្តបាត់ដំបង (ករណីឧបទ្ទវហេតុ មានអត្រាជារួម២៥,៤៤ភាគរយ ហើយចំពោះគ្រួសារដែលស្ត្រីជាមេគ្រួសារ មានអត្រា៣៦,៦២ភាគរយ) ឧបទ្ទវហេតុខ្ពស់បំផុតនៃភាពគ្មានដីធ្លី គឺនៅក្នុងភូមិបាក់ព្រា ដែលមានចំនួន៨១,៥៧ភាគរយនៃគ្រួសារទាំងអស់ និងគ្រួសារដែល

ស្ត្រីជាមេគ្រួសារទាំងអស់ គឺគ្មានដីធ្លី បើប្រៀបធៀបទៅនឹងភូមិតាញៀន ដែលចំនួននេះមានត្រឹមតែ២,៨៨ភាគរយនៃចំនួនគ្រួសារសរុបនៅក្នុងភូមិ ហើយគ្រួសារដែលស្ត្រីជាមេគ្រួសារដែលមានតែ៦.២៥ភាគរយប៉ុណ្ណោះដែលគ្មានដី ។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងតំបន់កសិ-បរិស្ថានដូចគ្នា សំណាកគំរូនៅក្នុងភូមិពីរ នៅខេត្តឧត្តរមានជ័យ (ជាទូទៅចំនួនករណីឧបទ្ទវហេតុមានចំនួន៥.០៩ភាគរយ ហើយចំពោះគ្រួសារដែលស្ត្រីជាមេគ្រួសារមានចំនួន១២.៩៨ភាគរយ) មិនមានគ្រួសារដែលគ្មានដីធ្លីទេ ហើយចំនួនករណីឧបទ្ទវហេតុនៃគ្រួសារដែលគ្មានដីធ្លីមានចំនួនខ្ពស់ជាងគេបំផុតនៅក្នុងភូមិប្រាសាទមាន ១២,២៤ភាគរយ បើប្រៀបធៀបទៅនឹងចំនួនគ្រួសារដែលស្ត្រីជាមេគ្រួសារដែលគ្មានដីធ្លីមានរហូតដល់ទៅ ៣៦,៧១ភាគរយ ។ ភាពខុសគ្នា១ផ្សេងទៀត ដែលមាននៅក្នុងតំបន់កសិ-បរិស្ថានដូចគ្នា មានបង្ហាញជូននៅក្នុងសេចក្តីបន្ថែមទី១ តារាងទី៣ ។

## ៤.១.១. កម្មសិទ្ធិលើដីលំនៅដ្ឋាន

កម្មសិទ្ធិលើដីលំនៅដ្ឋាន មានសារៈសំខាន់ណាស់ចំពោះកម្មវិធីសម្បទានដីសង្គមកិច្ច (SLCP) ដោយសារតែវាបានជួយកាត់បន្ថយនូវភាពងាយទទួលរងគ្រោះថ្នាក់ដល់អ្នកក្រីក្រ ព្រមទាំងធ្វើអោយពួកគេគ្មានបំណងនឹងធ្វើការផ្លាស់ប្តូរទីលំនៅដូចគ្រួសារដែលគ្មានដីលំនៅដ្ឋានឡើយ ។ គ្រួសារដែលមិនមានដីធ្លីចំនួន ២.៦៤១គ្រួសារ ក្នុងចំណោមចំនួនសំណាកគំរូ ៨៤៤ (ស្មើនឹង៣២ភាគរយ) សុទ្ធតែមានកម្មសិទ្ធិដីលំនៅដ្ឋាន ហើយគ្រួសារដែលនៅសល់ផ្សេងទៀតចំនួន១.៧៩៣គ្រួសារ (ស្មើនឹង៦៨ភាគរយ) មិនមានដីលំនៅដ្ឋានឡើយ ។ មានឃុំចំនួន៤ នៅក្នុងសំណាកគំរូ ដែលការកាន់កាប់ដីលំនៅដ្ឋាន មិនអាចមានលទ្ធភាពធ្វើទៅបានឡើយ សំរាប់អ្នកភូមិភាគច្រើន ដោយសារតែតំបន់នានានៅក្នុងភូមិរបស់ពួកគេមានទីតាំងស្ថិតនៅក្នុងបឹងទន្លេសាប ឬក៏ក្នុងសមុទ្រ ។ នៅក្នុងករណីនេះមានគ្រួសារចំនួន៧១៤គ្រួសារ មិនមានដីលំនៅដ្ឋានទេ[១៣] ។ ប្រសិនបើចំនួននេះត្រូវបានដកចេញក៏ចំនួនគ្រួសារដែល គ្មានដីនៅតែមានចំនួននៅសល់ ៥៦ភាគរយដែរ នៅក្នុងចំណោមចំនួនសំណាកគំរូដែលមិនមានដីលំនៅដ្ឋាន ។

គ្រួសារដែលគ្មានដីលំនៅដ្ឋាន គឺសុទ្ធតែជាគ្រួសារដែលងាយទទួលរងនូវគ្រោះថ្នាក់ កាន់តែក្រីក្រ និងកាន់តែមានបំណងចង់ធ្វើដំណើរផ្លាស់ប្តូរទីកន្លែង ជាងគ្រួសារដែលមានកម្មសិទ្ធិដីលំនៅដ្ឋាន ។

## ៤.១.២. មូលហេតុដែលបណ្តាលអោយមានភាពគ្មានដីធ្លី

ជាង១ភាគ៣នៃចំនួនសំណាកគ្រួសារដែលបានសំភាសន៍ បានអះអាងថា មូលហេតុដែលធ្វើអោយពួកគេគ្មានដីធ្លី គឺដោយសារតែពួកគេទើបតែរៀបអាពាហ៍ពិពាហ៍ថ្មីថ្មោង ។ ១ភាគ៣នៃចំនួនសំណាកគ្រួសារផ្សេងទៀត

[១៣] ទាំងនេះមាន២០៥០៦ឃុំព្រៃចាស់ (៣៥៦គ្រួសារ) ៩០៣០២ ឃុំកោះកាពិ (១៧៦ គ្រួសារ) ៩០៤០៣ ឃុំស្ទឹងវែង (១១៦ គ្រួសារ) និង៧០៧១១ ឃុំព្រែកត្នោត (៦៦ គ្រួសារ) ។

ក៏បានពោលអះអាងថា ពួកគេគ្មានដីធ្លី គឺដោយសារតែពួកគេផ្លាស់ប្តូរភូមិ ។ ការសិក្សាបានបង្ហាញថា និន្នាការដែលមានការកើនឡើងនូវមធ្យមភាគនៃប្រជាពលរដ្ឋទៅតំបន់ជនបទធ្វើចំណាកស្រុក គឺដើម្បីស្វែងរកឱកាសថ្មីៗ ដោយសារតែពួកគេមិនមានលទ្ធភាពអាចរស់នៅបាន នៅក្នុងភូមិកំណើតរបស់ពួកគេ ។ ជាងនេះទៅទៀត ការសិក្សា ក៏បានសន្និដ្ឋានផងដែរថា អ្នកភូមិដែលគេបានធ្វើការសំភាសន៍ បានចាត់ទុកខ្លួនពួកគេផ្ទាល់ ឬមួយក៏អ្នកផ្សេងទៀតថា គេគឺជាអ្នកដែលមិនដែលមានដីកម្មសិទ្ធិទាល់តែសោះនៅក្នុងភូមិ ដែលគេកំពុងរស់នៅបច្ចុប្បន្ន ចំនួននេះមិនបានរាប់បញ្ចូលទាំងចំនួនគ្រួសារដែលមានកម្មសិទ្ធិដីធ្លីស្របច្បាប់ នៅក្នុងភូមិដទៃទៀត ក៏ប៉ុន្តែពួកគេបានបាត់បង់ ឬក៏បានលក់វាបាត់ទៅហើយនៅទីនោះ ។ មូលហេតុផ្សេងទៀតនៃការគ្មានដីធ្លី រួមបញ្ចូលទាំងគ្រួសារដែលរស់នៅ ក្នុងភូមិបណ្តែតទឹក (ដូចជាភូមិនេសាទនៅខេត្តបាត់ដំបង និងភូមិតំបន់ឆ្នេរនៅខេត្តកំពត និងកោះកុង) ។ ការរស់នៅនៅលើទូក គឺជាមូលហេតុមួយផ្សេងទៀតចំពោះការគ្មានដីធ្លី ។ ចំនួនតួលេខនៃអ្នកធ្វើមាតុភូមិនិវត្តន៍ អ្នកដែលផ្លាស់ទីនៅក្នុងប្រទេស និងកងទ័ពរំសាយ ត្រូវបានចាត់ចូលទៅក្នុងជំពូកអ្នកគ្មានដីធ្លីមួយក្រុមតូចផ្សេងមួយទៀត ។ តារាងលំអិតបញ្ជាក់ពីមូលហេតុទាំងនេះមានបង្ហាញ នៅក្នុងសេចក្តីបន្ថែមទី១ តារាងទី១ និងទី៤ ។

### ៤.១.៣. មូលហេតុដែលនាំអោយបាត់បង់ដីធ្លី

មូលហេតុដ៏ច្រើនលើសលុបទាក់ទងទៅនឹងការបាត់បង់ដីធ្លី គឺការមានជំងឺឈឺស្កាត់ : ៦០ភាគរយនៃចំនួនគ្រួសារដែលបានសំភាសន៍ បានបញ្ជាក់ថា នេះគឺជាមូលលហេតុដែលធ្វើអោយពួកគេបានបាត់បង់ដីធ្លី ។ គ្រួសារចំនួន ១១ភាគរយផ្សេងទៀតបានបញ្ជាក់ថា ពួកគេបាត់បង់ដធ្លី គឺដោយសារតែពួកគេខ្វះខាតស្បៀងអាហារ ៨ភាគរយដោយសារតែជំពាក់បំណុលគេ ៦ភាគរយដោយសារតែភាពក្រីក្រ ៣ភាគរយដោយសារតែការលែងលះប្តីប្រពន្ធ ២ភាគរយដោយសារតែការផ្ទេរដីធ្លីទៅអោយកូនចៅញាតិសន្តាន និង១ភាគរយទៀតដោយសារតែបរាជ័យ នៅក្នុងការធ្វើជំនួញ ។

## ៤.២. ភាពក្រខ្សត់ដីធ្លី

ការសិក្សាបានធ្វើការកំណត់ភាពក្រខ្សត់ដីជាទូទៅថា ជាគ្រួសារដែលមានដីទំហំតិចជាង១ភាគ៦ហិកតាក្នុងសមាជិកគ្រួសារម្នាក់ បើទោះបីជាការសិក្សានេះ បានធ្វើការពិចារណាទៅលើគុណភាពនៃដីកសិកម្ម ព្រមទាំងស្ថានភាពជាក់ស្តែងរបស់គ្រួសារទាំងនេះផងក៏ដោយ ។ ការសិក្សាបានរកឃើញថា គ្រួសារចំនួន ៣,៨ភាគរយ ត្រូវបានចាត់ចូលជាគ្រួសារដែលមានដីតិចតួច ហើយគ្រួសារដែលមានស្ត្រីជាមេគ្រួសារចំនួន៦,៧ភាគរយ ក៏ត្រូវបានចាត់ចូលទៅក្នុងជំពូកនេះដូចគ្នា ។ ទោះបីជាយ៉ាងណាក៏ដោយ ឧបទ្ទវហេតុដែលខ្ពស់ជាងគេបំផុតនៃចំនួនគ្រួសារដែលមានដីតិចតួចមាននៅតំបន់ខ្ពង់រាបនៃខេត្តព្រះវិហារ ហើយដែលគ្រួសារនៅក្នុងជំពូកនេះមានចំនួន១១,៦ភាគរយឯគ្រួសារដែលមានស្ត្រីជាមេគ្រួសារចំនួន១៩,៨ភាគរយក៏ត្រូវបានចាត់ចូលទៅក្នុងជំពូកនេះដូចគ្នា ។ ខេត្តបាត់ដំបងត្រូវបានរកឃើញថាជាខេត្តដែលមានចំនួនគ្រួសារដែលមានដីតិចតួចមានចំនួនតិចបំផុត ដែលចំនួននេះមានតែ ០,៨ភាគរយ ហើយគ្រួសារដែលមានស្ត្រីជាមេគ្រួសារចំនួន១,៣ភាគរយ ក៏ត្រូវបានចាត់ចូលនៅក្នុងជំពូកនេះដូចគ្នា ។

តារាងលំអិតបញ្ជាក់ពីមូលហេតុទាំងនេះមានបង្ហាញជូននៅក្នុងសេចក្តីបន្ថែមទី១ តារាងទី៦ ។

### ៤.២.១. មូលហេតុដែលនាំអោយមានភាពខ្វះខាតដីធ្លី

ប្រហែលជាង២៥ភាគរយនៃប្រជាពលរដ្ឋដែលបានធ្វើការសំភាសន៍ បានបញ្ជាក់ថា មូលហេតុដែលធ្វើអោយពួកគេគ្មានដី គឺដោយសារតែនៅចំណុចចាប់ផ្តើម ពួកគេពុំមានដីគ្រប់គ្រាន់រួចទៅហើយ ។ គ្រួសារប្រហែលជាតិចជាង ១៥ភាគរយបានបញ្ជាក់ថា ពួកគេបានផ្តល់ដីធ្លីដែលគេមានអោយទៅកូនចៅរបស់ពួកគេអស់ហើយ ហើយប្រហែលជា១៣ភាគរយផ្សេងទៀតបានបញ្ជាក់ថា ការរៀបអាពាហ៍ពិពាហ៍ថ្មីថ្មោង គឺជាមូលហេតុដែលនាំអោយពួកគេគ្មានដី ។ មូលហេតុផ្សេងៗទៀតរួមមាន ការមានជំងឺឈឺស្កាត់មានប្រហែលជាង១១ភាគរយ ការផ្លាស់ប្តូរភូមិជាង១០ភាគរយ ការទទួលបានដីមិនគ្រប់គ្រាន់ពីឪពុកម្តាយមាន៨ភាគរយ ភាពក្រីក្រមាន៤ភាគរយ ករណីមានកូនច្រើន៣ភាគរយ និងមានដីតិចតួចក្រោម៣ភាគរយ ហើយមូលហេតុចំបងមួយផ្សេងទៀត គឺបណ្តាលមកពីការជាប់ជំពាក់បំណុលគេមានចំនួន២ភាគរយ ។ មូលហេតុដទៃៗទៀតរួមមាន ការកាត់រំសាយកងទ័ព ការផ្លាស់ទីក្នុងប្រទេស ឬមាតុភូមិនិវត្តន៍ពីជំរុំភៀសខ្លួននៅតាមព្រំដែន ការខ្វះខាតសត្វកំលាំងអូសទាញ ការបរាជ័យនៅក្នុងការប្រកបរបរចិញ្ចឹមសត្វ ការទិញដីលំនៅដ្ឋាន ការដែលមិនមានសិទ្ធិនៅក្នុងប្រើប្រាស់ធនធានជលផល និងព្រៃឈើ ការប្រកាសដកហូតយកដីវិញ និងវិបត្តិក្នុងការជីវភាពរស់នៅដែលពាក់ព័ន្ធនឹងការស្លាប់នៃសមាជិកគ្រួសារ និងគ្រោះធម្មជាតិ ។

ការផ្លាស់ប្តូរទៅកាន់ភាពក្រខ្សត់ដីធ្លី គឺបណ្តាលមកពីនិន្នាការជាទូទៅដូចៗគ្នាទៅតាមពេលវេលា ទោះបីជាចំនួនអ្នកគ្មានដីធ្លីចេះតែកើនឡើងក៏ដោយ ក៏ចំនួននេះមិនមានលក្ខណៈធ្ងន់ធ្ងរដែរ បើប្រៀបធៀបនឹងតួលេខនៅក្នុងទិន្នន័យមូលដ្ឋាន ដែលមាន៣,២៤ភាគរយ នៅក្នុងឆ្នាំ១៩៩៨ ទៅ៣,៨០ភាគរយនៅឆ្នាំ២០០៤ (តាមការប៉ាន់ស្មានមានចំនួន៤,១១ភាគរយនៅឆ្នាំ២០០១) ក៏ប៉ុន្តែនៅឆ្នាំ២០០៦ ឧបទ្ទវហេតុនៃភាពក្រខ្សត់ដីធ្លី ត្រូវបានប៉ាន់ស្មានថា មានចំនួនរហូតដល់ទៅ៨,០៦ភាគរយ[១៤] ។

## ៤.៣. សក្តានុពលដីសំរាប់សម្បទានសង្គមកិច្ច

តាមការសិក្សារបស់វិទ្យាស្ថានកសិ-អាជីវកម្មកម្ពុជា (ABiC) បានបង្ហាញអោយឃើញថា មានអ្នកភូមិចំនួនតែ៣៣.៣ភាគរយប៉ុណ្ណោះ ដែលបានរាយការណ៍ថាពួកគេមានដីនៅសល់ទំនេរ ដែលដីទាំងនោះរួមមានដីតំបន់ព្រៃឈើរិចរិល និងដីកសិកម្មដែលមិនមានការប្រើប្រាស់ និងចំនួន៥៣,៣ភាគរយផ្សេងទៀត ត្រូវបានរាយ

---

[១៤] អ្នកចូលរួមនៅក្នុងក្រុមគោលដៅសំរាប់ការពិភាក្សា នៅក្នុងភូមិនីមួយៗ ត្រូវបានសួរអោយរំលឹកឡើងវិញពីចំនួនប្រជាពលរដ្ឋ (ជាចំនួនគ្រួសារ) និងចំនួនគ្រួសារដែលគ្មានដី នាឆ្នាំ១៩៦៩ (មុនពេលរដ្ឋប្រហារ និងសង្គ្រាម) និងនៅក្នុងឆ្នាំ១៩៨៤ (បន្ទាប់ពីការចាប់ផ្តើមធ្វើការ ដាំដុះជាថ្មីឡើងវិញ និងបន្ទាប់ពីមានការបែងចែកដីនៅក្នុងប្រព័ន្ធសមូហភាព) ។ ពួកគេក៏បានស្នើសុំអោយធ្វើការប្រមើលមើលពីចំនួនប្រជា ពលរដ្ឋដែលនឹងគ្មានដីធ្លីក្នុងរយៈពេល២ឆ្នាំខាងមុខ : ការពិភាក្សានេះធ្វើឡើងដោយផ្អែកទៅលើការញែកដាច់ចេញពីគ្នា នូវការប្រមើល មើលទៅលើបំលាស់ប្តូរ លើចំនួនគ្រួសារនៅក្នុងភូមិ (ការផ្លាស់ប្តូរលំនៅដ្ឋានដោយសារតែការរៀបអាពាហ៍ពិពាហ៍ និងក្រោយពេលស្លាប់) គ្រួសារដែលបច្ចុប្បន្នមានកម្មសិទ្ធិដី ក្លាយទៅជាគ្មានដី និងគ្រួសារដែលមិនមានដីក្លាយទៅជាមាន ។

ការណ៍មកថា ជាតំបន់ព្រៃឈើដែលមាននៅក្នុងសហគមន៍របស់ពួកគេ (សូមមើលតារាងទី៩ និងទី១០ នៃសេចក្តីបន្ថែមទី២) ។ ទំហំនៃដីទំនេរ និងដីព្រៃ មានទំហំខុសៗគ្នាពីភូមិមួយទៅភូមិមួយ ។ នៅតាមតំបន់មេគង្គ មិនមានភូមិណាមួយត្រូវបានគេរាយការណ៍ថា មានដី ឬមានដីព្រៃនៅសល់ទំនេរទៀតឡើយ នៅក្នុងភូមិរបស់ពួកគេ ។ ដីមួយភាគធំត្រូវបានរាយការណ៍ថា មាននៅសល់នៅតំបន់ភូមិភាគល្បសាន្ត និងតំបន់ឆ្នេរសមុទ្រ ។ ទំហំដីមិនបានប្រើប្រាស់ ក្នុងមួយភូមិៗនៅភាគល្បសាន្ត មានទំហំធំជាង១.៣០០ហិកតា ហើយនៅតាមតំបន់ឆ្នេរសមុទ្រមានជាង ៤៦០ហិកតា ។ ដីព្រៃឈើមួយភាគធំក៏ត្រូវបានគេរកឃើញថា មាននៅក្នុងតំបន់ទាំងពីរខាងលើនេះដែរ ដែលមានទំហំជាង១.៣០០ហិកតា នៅតំបន់ភាគល្បសាន្ត និង៤.៥០០ហិកតានៅតំបន់ឆ្នេរសមុទ្រ ។ ភាគច្រើននៃក្រុមគោលដៅសំរាប់ការពិភាក្សា (FGD) បានចាត់ទុកដីព្រៃឈើដែលនៅសល់ថា ជាដីដែលពួកគាត់អាចប្រើប្រាស់បានសំរាប់កសិកម្ម ជាពិសេស នៅតាមតំបន់បឹងទន្លេសាប នៅពេលដែលអ្នកភូមិនិយាយពីដីមិនទាន់ប្រើប្រាស់ គឺសំដៅទៅលើដីព្រៃលិចទឹក ដែលមានទំហំជាង១.២៩០ហិកតា ហើយដែលក្នុងនោះមានតែចំនួនតែ ៥៦ហិកតា នៃដីដែលមិនទាន់មានការប្រើប្រាស់ប៉ុណ្ណោះ ដែលជាដីព្រៃដែលអាចមាននៅទីនោះ (សូមមើលតារាងទី៩ និង១០ នៃសេចក្តីបន្ថែមទី២) ។ ក៏ប៉ុន្តែ ការកែប្រែផ្លាស់ប្តូរដីទាំងនេះ គួរតែត្រូវបានពិនិត្យពិចារណាដោយប្រុងប្រយ័ត្ន ដោយហេតុថា វាមានការលំបាកណាស់នៅក្នុងការផ្លាស់ប្តូរដីទាំងនោះ អោយទៅជាដីកសិកម្មដោយគ្រាន់តែធ្វើការកាប់ឆ្ការដីព្រៃ ជាពិសេសទាក់ទងទៅនឹងល្បឿននៃការដុះលូតលាស់យ៉ាងយឺតនៃប្រភេទដើមឈើនានា ដែលមានដើមកំណើតនៅទីនោះពីធម្មជាតិ ។

ទោះបីជា ដីនៅតំបន់ទាំងនេះត្រូវបានរាយការណ៍មកថា មាននៅសល់នៅក្នុងបណ្តាភូមិមួយចំនួនក៏ដោយ ក៏នៅតែមិនទាន់មានការឯកភាពជាទូទៅនៅឡើយទេថា តើដីទាំងនោះអាចធ្វើការផ្លាស់ប្តូរកែប្រែជាដីដាំដុះបានដែរឬយ៉ាងណាឡើយ ។ ជាងមួយភាគបួននៃក្រុមគោលដៅសំរាប់ការពិភាក្សា (៣៦,៧ភាគរយ) ប៉ុន្តែក្នុងការអង្កេតតាមគ្រួសារ មានចំនួនតិចជាង (៦,៦ភាគរយ) ដែលមិនឯកភាពទៅលើការផ្លាស់ប្តូរកែប្រែដីដែលនៅទំនេររបស់ភូមិពួកគេឡើយ ។ ទោះជាយ៉ាងណាក៏ដោយ ក៏ជាងមួយភាគបីនៃក្រុមគោលដៅសំរាប់ការពិភាក្សា (៣៦,៧ភាគរយ) ហើយការអង្កេតតាមគ្រួសារមានចំនួនតិចជាង (២៩,៤ភាគរយ) បានឯកភាពថា ដីទំនេរទាំងនេះអាចធ្វើការកែប្រែផ្លាស់ប្តូរបាន សំរាប់បំរើដល់គោលបំណងនេះ ។

ជាង១៣ភាគរយនៃក្រុមគោលដៅសំរាប់ការពិភាក្សា (FGD) គិតថា ការផ្លាស់ប្តូរកែប្រែដីភូមិទំនេរសំរាប់ការធ្វើកម្មវិធីសម្បទានដីសង្គមកិច្ច (SCLP) នឹងនាំអោយមានផលប៉ះពាល់ជាអវិជ្ជមានទៅលើជីវភាពរស់នៅ បរិស្ថាន និងទីតាំងដែលមានតំលៃជាបិតិកភ័ណ្ឌ និងជាវប្បធម៌ ។ និយាយដោយសាមញ្ញ នៅក្រោមល័ក្ខខ័ណ្ឌជាក់លាក់មួយចំនួន ដីនៅសល់ទំនេរមិនអាចប្រើប្រាស់បានឡើយ ដោយសារតែវាជាដីដែលគ្មានជីជាតិ និង/ឬ ជាដីមានថ្ម ។ ជាងនេះទៅទៀត មានឧទាហរណ៍ជាច្រើនដែលដីនៅទំនេរមិនអាចផ្លាស់ប្តូរកែប្រែទៅបាន ដោយសារតែផ្នែកមួយចំនួននៃដីទាំងនោះ មានការប្រកាសកាន់កាប់ជាមុនរួចទៅហើយ ។ ដីទាំងនេះ ត្រូវបានព័ទ្ធយកខុសច្បាប់ ហើយនៅតំបន់ជាច្រើន គឺជាដីដែលទុកចោលនៅទំនេរមិនមានការប្រើប្រាស់ ។

ការសិក្សាលើការវិភាគផលប៉ះពាល់ភាពក្រីក្រ និងសង្គម (PSIA) របស់អង្គការអុកស្វាម បានពិនិត្យទៅលើលទ្ធភាពដីដែលអាចមាននៅក្នុងភូមិប្រាំពីរផ្សេងៗគ្នា ដែលគ្របដណ្តប់លើតំបន់កសិ-បរិស្ថាន៣ ក្នុងចំណោមតំបន់ទាំង៤ នៅក្នុងប្រទេសកម្ពុជា ។ ព័ត៌មានលំអិតស្តីពីលទ្ធភាពដីដែលអាចមាននៅក្នុងភូមិនីមួយៗ មានបង្ហាញជូននៅក្នុងសេចក្តីបន្ថែមទី២ តារាងទី១០ ។ យើងអាចធ្វើការកត់សំគាល់បានថា ឧទាហរណ៍ទាំងនេះបង្ហាញពីភាពខុសគ្នារវាងជីវភាពរស់នៅនៃអ្នកដែលគ្មានដីធ្លី និងគ្រួសារដែលខ្វះដីធ្លី នៅក្នុងតំបន់កសិ-បរិស្ថានដូចគ្នា យុទ្ធសាស្ត្រទប់ទល់នឹងជីវភាពរស់នៅរបស់គ្រួសារទាំងនេះ ព្រមទាំងលទ្ធភាពដីដែលអាចមាន ឬដីទំនេរ ។

លទ្ធផលប្រហាក់ប្រហែលគ្នាអំពីសក្តានុពលដីធ្លីនៅទំនេរ ត្រូវបានរកឃើញនៅក្នុងការសិក្សាវាយតំលៃដែលធ្វើឡើង ដោយក្រុមការងារសម្បទានដីសង្គមកិច្ចនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។ លទ្ធផលទាំងអស់ ត្រូវបានកត់ត្រានៅក្នុងតារាងទី១១ សេចក្តីបន្ថែមទី២ ។ ការសិក្សារបស់ពួកគេ បានបង្ហាញអោយដឹងជាសាធារណៈ នូវឧបសគ្គដ៏ធំធេងក្នុងការកំណត់ដីសមស្របសំរាប់ធ្វើការបែងចែក ។ ជាទូទៅតំបន់ដីដែលបានកំណត់ដោយអាជ្ញាធរមូលដ្ឋានថា ជាដីទំនេរ ហើយអាចធ្វើការបែងចែកបាន ជារឿយៗមិនមានលក្ខណៈសមស្របសំរាប់កសិកម្មឡើយ ។ ដីព្រៃឈើ តំបន់ព្រៃរិចរិល តំបន់លិចទឹក ភាគច្រើនគឺជាដីដែលត្រូវបានពិចារណាថាជាដីទំនេរ ។ ការសិក្សាក៏បានបញ្ជាក់ថា ដីទាំងនោះមានម្ចាស់កាន់កាប់ស្ទើរតែទាំងស្រុងរួចទៅហើយ ជាពិសេសនៅលើតំបន់ដីដែលមានជីជាតិ ទាំងស្របច្បាប់ និងមិនស្របច្បាប់ ។ ដរាបណាមិនមានការប្តេជ្ញាចិត្តខាងផ្នែកនយោបាយអោយបានយ៉ាងខ្លាំងក្លា ព្រមទាំងរៀបចំបែបបទនៅក្នុងការកំណត់នូវតំបន់ដែលមានការកាន់កាប់មិនស្របច្បាប់នោះទេ អាជ្ញាធរមូលដ្ឋាននៅតែមិនអាចមានសមត្ថភាព និងលទ្ធភាពកំណត់តំបន់ទាំងនោះបានឡើយ ។

## ៤.៤. ភាពខុសៗគ្នានៅក្នុងជីវភាពរស់នៅនៃអ្នកដែលខ្វះដីធ្លី និងគ្មានដីធ្លី

ការសិក្សារបស់អង្គការអុកស្វាម ក៏បានប្រើប្រាស់វិធីសាស្ត្រវិភាគនិរន្តរភាពជីវភាពរស់នៅ ដើម្បីវិភាគភាពខុសគ្នាសំខាន់ៗរវាងចំណូល/សកម្មភាពជីវភាពរស់នៅរបស់អ្នកដែលខ្វះដីធ្លី និងអ្នកដែលគ្មានដីធ្លី ដែលមានការទាក់ទងយ៉ាងខ្លាំងទៅនឹងការយល់ដឹង ពីសក្តានុពលផលប៉ះពាល់លើជីវភាពរស់នៅនៃលទ្ធភាពអាចទទួលបាននូវសម្បទានដីសង្គមកិច្ច ។ ភាពខុសៗគ្នាក្នុងចំណោមភាពខុសគ្នាខាងលើដែលគួរអោយកត់សំគាល់ រួមមាន :

១). នៅពេលដែលទាំងគ្រួសារដែលគ្មានដីធ្លី និងគ្រួសារដែលខ្វះខាតដីធ្លី ពឹងផ្អែកជាសំខាន់ទៅលើការលក់កំលាំងពលកម្មប្រចាំថ្ងៃរបស់ពួកគេ គ្រួសារដែលខ្វះខាតដីធ្លី ហាក់បីដូចជាចំណាយកំលាំងពលកម្មប្រចាំថ្ងៃរបស់ពួកគេទៅលើសកម្មភាពកសិកម្ម ជាប្រភពចំណូលសំខាន់របស់ពួកគេ (ប្រហែល ៥០ភាគរយ ទល់នឹង៣០ភាគរយ) ហើយដែលក្នុងពេលជាមួយគ្នានេះដែរ គ្រួសារដែលគ្មានដីធ្លី ហាក់បីដូចជាចំណាយកំលាំងពលកម្មប្រចាំថ្ងៃរបស់ពួកគេច្រើន ទៅលើការងារក្រៅពីកសិកម្ម ជាប្រភពចំណូលសំខាន់ (ប្រហែល៣០ភាគរយ ទល់នឹង១០ភាគរយ) ។

២). គ្រួសារដែលគ្មានដីធ្លីហាក់បីដូចជាប្រកបរបរនេសាទច្រើន សំរាប់ជាប្រភពចំណូលសំខាន់របស់ពួកគេ (ប្រហែល២៤ភាគរយ ទល់នឹង១១ភាគរយ) ។ ប្រការនេះអាចពន្យល់បានពីការពិតដែលភូមិធំៗមួយចំនួន នៅក្នុងសំណាកគំរូដែលបានធ្វើការសិក្សា គឺជាភូមិនេសាទ ហើយប្រជាពលរដ្ឋភាគច្រើនគ្មានដីធ្លីទេ មានគ្រួសារតិចតួចណាស់ ឬស្ទើរតែគ្មានតែម្តងដែលខ្វះដីធ្លីនោះ ។

៣). គ្រួសារដែលខ្វះដីធ្លី មានជីវភាពរស់នៅពឹងផ្អែកទៅលើផលិតផលព្រៃឈើ សំរាប់ជាប្រភពចំណូល/គាំទ្រជីវភាពរស់នៅសំខាន់ទីពីរ (១៥,៥ភាគរយ ទល់នឹង៤ភាគរយ)។ ជាថ្មីម្តងទៀត របាយស្ថានភាពភូមិសាស្ត្រនៃប្រជាពលរដ្ឋដែលខ្វះដីធ្លី ពន្យល់ពីភាពខុសគ្នានេះ ។ នៅតំបន់ព្រៃឈើ មិនមានប្រជាពលរដ្ឋច្រើនទេដែលខ្វះដីធ្លី ជាពិសេសនៅក្នុងសំណាកភូមិ ក្នុងខេត្តព្រះវិហារ ។ ការបកស្រាយចំពោះករណីនេះ គឺប្រហែលជាថា ដីទំនេរ មិនមែនជាបញ្ហាឡើយសំរាប់តំបន់ព្រៃឈើដែលនៅដាច់ស្រយាល ។ វាមានការងាយស្រួលណាស់សំរាប់ប្រជាពលរដ្ឋនៅក្នុងការទទួលបានដីមួយចំនួនដោយធ្វើការកាប់ឆ្ការព្រៃ ក៏ប៉ុន្តែភាពស្ថិតនៅដាច់ស្រយាល ជំងឺ និងកង្វះខាតថវិកាគឺជាការលំបាកក្នុងការធ្វើអោយដីនៅតំបន់នោះ ក្លាយជាដីដែលមានលក្ខណៈពេញលេញគ្រប់គ្រាន់សំរាប់គ្រួសារទាំងនោះ ជាជាងកាន់តែធ្វើអោយពួកគេរិតតែក្រីក្រ និងងាយទទួលរងគ្រោះ ។

ការសិក្សាក៏បានធ្វើសេចក្តីសន្និដ្ឋានថា គ្រួសារដែលគ្មានដី ត្រូវការចាំបាច់មិនត្រឹមតែដីប៉ុណ្ណោះទេ ក៏ប៉ុន្តែនិរន្តរភាពជីវភាពរស់នៅផងដែរ ។ ការសិក្សានាពេលបច្ចុប្បន្ននេះ បានចង្អុលបង្ហាញថា គ្រួសារដែលគ្មានដី និងគ្រួសារខ្វះដីធ្លី មានសកម្មភាពជីវភាពរស់នៅមួយចំនួន ដែលនៅក្នុងនោះមានការធ្វើពលកម្មទាំង នៅក្នុង និងក្រៅវិស័យកសិកម្ម សកម្មភាពពឹងផ្អែកលើព្រៃឈើ និងជលផល ដែលសុទ្ធសឹងតែមានសារៈសំខាន់ទាំងអស់ ។ ការរកឃើញនេះបានបញ្ជាក់ទៅលើអ្វីដែលកំពុងត្រូវបានយល់ដឹងយ៉ាងទូលំទូលាយ គឺថាវាមានសារៈសំខាន់បំផុតក្នុងការមើលទៅលើដីថាគ្រាន់តែជាសមាសធាតុមួយនៅក្នុងជីវភាពរស់នៅរបស់គ្រួសារតែប៉ុណ្ណោះ ។

វាកម្រមានណាស់ដែលដីមួយដុំនៅក្នុងប្រទេសកម្ពុជា អាចផ្តល់ដោយខ្លួនឯងបាននូវសុវត្ថិភាពជីវភាពរស់នៅដល់គ្រួសារ ។ ជាទូទៅនៅទូទាំងប្រទេសកម្ពុជា មួរស៊ិត (១៩៩៨) បានរកឃើញថា ចំណូលពីការដាំដុះ តាមការពិតមិនមែនជាកត្តាសំខាន់ ក្នុងចំណោមប្រភពចំណូលផ្សេងៗទៀត នៅក្នុងតំបន់ជនបទនៃប្រទេសកម្ពុជាទេ ។ ទាំងអស់នេះបានបង្ហាញបន្ថែមទៀតនៅក្នុងការវិភាគពីជីវភាពរស់នៅនាពេលថ្មីៗនេះ នៅតាមបណ្តាភូមិដែលបានជ្រើសរើសមួយចំនួននៅក្នុងតំបន់កសិ-បរិស្ថានទាំងបួន (ចាន់ សុផល និងអាចារីយ៉ា ២០០២:៥១-៧) ។ ទាំងនេះគឺជាការរំពឹងទុក ដោយសារតែល័ក្ខខ័ណ្ឌអាកាសធាតុ និងធារាសាស្ត្រមិនអាចទស្សទាយបាន គុណភាពដីជាទូទៅមិនមានលក្ខណៈល្អ ហើយភាគច្រើនដីកសិកម្ម ឬមួយជាដីវាលទំនាបលិចទឹក ឬរាំងស្ងួត ។ ដោយហេតុដូច្នេះហើយជារៀងរាល់ឆ្នាំ មួយភាគធំនៃប្រជាពលរដ្ឋ គឺជាជនរងគ្រោះពីគ្រោះធម្មជាតិ ។ ការដាំដុះតាមបែបប្រពលវប្បកម្មក៏តែងតែនាំមកជាមួយនូវហានិភ័យផងដែរ (ជាឧទាហរណ៍) ការធ្វើស្រូវវស្សា ដែលតែងតែយាយីដោយសត្វកណ្តុរ

និងសត្វល្អិតចង្រៃ ។ ជាទូទៅ តំបន់ជនបទក្រីក្រនៅប្រទេសកម្ពុជា គ្រាន់តែអាចមានលទ្ធភាពគ្រប់គ្រាន់សំរាប់ការគាំទ្រដល់ការរស់នៅ នៅក្នុងភូមិរបស់ពួកគាត់ ដោយសារតែមធ្យោបាយជាច្រើននៃការប្រកបរបរចិញ្ចឹមជីវភាពរបស់ពួកគេ (ការវិភាគពីជីវភាពរស់នៅដ៏ស្មុគស្មាញមួយ អាចពិនិត្យមើលទៅលើបណ្តាញខ្សែទទឹង និងខ្សែបណ្តោយ ឬមួយក៏អវត្តមាននូវសមាសភាគសំខាន់នៃមូលធនសង្គម) ។

ទាំងនេះមិនមានន័យថា គ្រួសារទាំងឡាយ អាចមានសុវត្ថិភាពគ្រប់គ្រាន់នោះឡើយ នៅពេលដែលពួកគេគ្រាន់តែទទួលបាននូវសម្បទានដីសង្គមកិច្ច វាមានសារៈសំខាន់ជាទីបំផុត ប្រសិនបើពួកគេអាចមានលទ្ធភាពអាចទទួលបាននូវការគាំទ្រលើប្រភពជីវភាពរស់នៅច្រើនយ៉ាង ។

ផលវិបាកចំពោះកម្មវិធីសម្បទានដីសង្គមកិច្ច គឺនៅពេលធ្វើការសិក្សាពីលទ្ធភាពនៃទីកន្លែងដែលមានសក្តានុពលសំរាប់សម្បទានដីសង្គមកិច្ច វាមានសារៈសំខាន់ណាស់ដែលការវិភាគពីសក្តានុពលជីវភាពរស់នៅ សំរាប់អ្នកទទួលផលពីកម្មវិធីទាំងអស់ ត្រូវបានធ្វើការពិចារណាផងដែរ ។ ប្រការនេះត្រូវរួមបញ្ចូលផងដែរ នូវលទ្ធភាពក្នុងការប្រើប្រាស់ធនធានធម្មជាតិ ឬក៏ឱកាសសំរាប់ការមានការងារធ្វើ ឬក៏ឱកាសទាំងពីររួមគ្នា ដើម្បីអោយគ្រួសារទាំងនោះ អាចមានរបរចិញ្ចឹមជីវិតរស់នៅច្រើនយ៉ាង ហើយដែលកត្តានេះអាចទប់ទល់ នៅក្នុងឆ្នាំដែលមានគ្រោះដាយថាហេតុមិនអាចទស្សទាយបាន បានកើតមានឡើង ដូចជានៅពេលដែលផលដំណាំមានការខូចខាត ឬទទួលផលបានតិច ។

ការសិក្សាដែលអង្គការអុកស្វាមបានធ្វើការស្រាវជ្រាវនៅមូលដ្ឋាន នៅក្នុងការចាត់ចំណាត់ថ្នាក់ភូមិ ទៅតាមផលិតកម្មនៃដី លទ្ធភាពដែលអាចមាននៃធនធានធម្មជាតិ និងឱកាសសំរាប់ការមានការងារធ្វើ អាចប្រើប្រាស់ជាចំណុចចាប់ផ្តើមបាន សំរាប់ការរៀបចំនូវវិធីសាស្រ្តសាមញ្ញមួយ នៅក្នុងការវាយតំលៃពីភាពសមស្របនៃទីកន្លែងសំរាប់សម្បទានដីសង្គមកិច្ច ។ ការយល់ជ្រួតជ្រាបពីវិធីសាស្រ្ត ត្រូវតែជាការយល់ដឹងពីឱកាស និងឧបសគ្គនានាសំរាប់និរន្តរភាពជីវភាពរស់នៅ ដែលនឹងមានភាពខុសគ្នាយ៉ាងធំធេង ពីកន្លែងមួយទៅកន្លែងមួយផ្សេងទៀត ហើយដោយហេតុដូច្នេះ សម្បទានដីសង្គមកិច្ច នឹងតំរូវអោយមានការរៀបចំផែនការយ៉ាងប្រុងប្រយ័ត្ន ទៅតាមករណីជាក់ស្តែងនីមួយៗ ។ ប្រសិនបើផែនការសម្បទានដីសង្គមកិច្ចទាំងឡាយដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា នោះមានន័យថា ផែនការទាំងនោះមិនបានគិតគូរពិចារណាពីស្ថានភាពនៅមូលដ្ឋានអោយបានគ្រប់គ្រាន់ឡើយ ។

## ៤.៥. បញ្ហាទាក់ទងទៅនឹងការគ្មានដីធ្លី ដែលជាលក្ខណៈវិនិច្ឆ័យចំបង

ការសិក្សារបស់អង្គការអុកស្វាម ក៏បានធ្វើសេចក្តីសន្និដ្ឋានផងដែរថា ការកំណត់ថា ភាពគ្មានដីធ្លី ដែលត្រូវតែប្រើជាលក្ខណៈវិនិច្ឆ័យចំបង សំរាប់ទទួលបានសម្បទានដីសង្គមកិច្ច គឺនៅចោទជាបញ្ហានៅឡើយ ។ ទាំងការប្រមូលព័តិមានអំពីភាពគ្មានដីធ្លី និងការអភិវឌ្ឍ (LADIT) ក៏ដូចជាការវាយតំលៃជីវភាពរស់នៅជនបទដោយរហ័សដែលអង្គការអុកស្វាមបានធ្វើឡើង នៅក្នុងការតាមដាននូវលទ្ធភាពរបស់វា ស្របទៅតាមអង្គការអុកស្វាម ដើម្បី

ទាញចេញនូវសេចក្តីសន្និដ្ឋានជាទូទៅមួយ អំពីទំនាក់ទំនងនៃភាពចំរុងចំរើន/ភាពក្រីក្រនៃគ្រួសារមានដីធ្លីបន្តិចបន្តួច ប្រៀបធៀបជាមួយគ្រួសារដែលគ្មានដីធ្លី ។

តាមទស្សនៈនៃការស្រាវជ្រាវដែលធ្វើឡើងដោយអង្គការអុកស្វាម វាមានការងាយស្រួលច្រើនជាង ក្នុងការកំណត់រកនូវភាពគ្មានដី ហើយបន្ទាប់មកធ្វើការកំណត់ និងផ្ទៀងផ្ទាត់រកអ្នកដែលគ្មានដី ។ ម៉្យាងវិញទៀត ភាពខ្វះដីធ្លី មានទស្សនៈទានពិបាកស្មុគស្មាញជាងនៅក្នុងការកំណត់រកវា ។ ដីដែលថា ជា "ការគ្រប់គ្រាន់" គឺនៅពេលដែលមានភ្លៀងធ្លាក់គ្រប់គ្រាន់ និងគ្រួសារមានសុខភាពល្អ ហើយដីដដែលនេះ "នឹងមិនគ្រប់គ្រាន់" ប្រសិនបើមិនមានភ្លៀងធ្លាក់គ្រប់គ្រាន់ ឬប្រសិនបើនៅក្នុងគ្រួសារមានអ្នកណាម្នាក់ឈឺ ។ ជាងនេះទៅទៀត នៅពេលដែលធ្វើការផ្ទៀងផ្ទាត់ថាតើគ្រួសារណាខ្លះដែលខ្វះដី វាមានការលំបាកណាស់នៅក្នុងការបកស្រាយពន្យល់ នូវអ្វីដែលប្រជាពលរដ្ឋចង់មានន័យ ថាតើនៅពេលណាដែលពួកគេឯកភាព ឬមិនឯកភាពថា គ្រួសារណាមួយមានដីតិច ។

បើតាមការសិក្សារបស់អង្គការអុកស្វាមបានបង្ហាញថា ផលវិបាកដែលអាចកើតមានឡើងនោះ គឺភាពមិនច្បាស់លាស់នៃការខ្វះដី ដែលបញ្ហានេះនឹងធ្វើអោយអំពើពុករលួយ និងការនិយមបក្សពួកកាន់តែមានភាពងាយស្រួល ។ ប្រសិនបើមានការផ្តល់ព័ត៌មានយ៉ាងច្បាស់លាស់ថា មានតែគ្រួសារដែលគ្មានដីប៉ុណ្ណោះ ដែលអាចមានសិទ្ធិទទួលបាននូវសម្បទានដីសង្គមកិច្ច វានឹងអាចជួយធ្វើអោយមានភាពងាយស្រួលដល់ការពង្រឹងតួនាទីទទួលខុសត្រូវបានខ្លះនៅឯមូលដ្ឋាន ។ ដោយសារតែប្រជាពលរដ្ឋនៅមូលដ្ឋានមានចំនួនជាងមួយលាននាក់ ហើយសុទ្ធសឹងតែជាប្រជាពលរដ្ឋក្រីក្រ និងជាអ្នកគ្មានដីកសិកម្ម មិនទាន់មានចក្ខុវិស័យពិតប្រាកដណាមួយ ត្រូវបានពិចារណា សំរាប់ធ្វើការផ្គត់ផ្គង់តំរូវការដីដែលមានលក្ខណៈសមស្របបាននៅឡើយដល់អ្នកទាំងនោះ ។

គ្រួសារដែលបានចាត់ចូលទៅក្នុងជំពូកនៃគ្រួសារដែលគ្មានដី នឹងទទួលបាននូវសក្តានុពលសំខាន់សំរាប់ការបែងចែក និងការចាត់អាទិភាព អោយស្របទៅតាមគោលបំណងនៃកម្មវិធីសម្បទានដីសង្គមកិច្ច (ថ្នាក់ជាតិ ឬមូលដ្ឋាន) ។ ការផ្តោតការយកចិត្តទុកដាក់ទៅលើគ្រួសារដែលទើបតែរៀបការថ្មីថ្មោង ជាឧទាហរណ៍ ធ្វើការផ្តល់ឱកាសដ៏ល្អបំផុតដល់គ្រួសារទាំងនោះអោយមានការងារធ្វើគ្រប់គ្រាន់ អាចប្រើប្រាស់ធ្វើជាសក្ខីភាពដែលនឹងអាចទទួលយកបានល្អប្រសើរជាងដោយផ្នែកនយោបាយ ។ ជាការពិតប្រជាពលរដ្ឋដែលមិនមានដីលំនៅដ្ឋាន ត្រូវតែបានជ្រើសរើសជាក្រុមគោលដៅជាក់លាក់របស់កម្មវិធី ប្រសិនបើទីតាំងសំរាប់កម្មវិធីសម្បទានដីសង្គមកិច្ចត្រូវបានជ្រើសរើសនៅតំបន់ដាច់ស្រយាលពីលំនៅដ្ឋានដែលមានស្រាប់ ។ ម្យ៉ាងវិញទៀត វានឹងមានសារៈសំខាន់ណាស់នៅក្នុងការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច ប្រសិនបើភាពសំបូរបែបនៃសក្តានុពលរបស់អ្នកចូលរួមនៅក្នុងកម្មវិធី មិនត្រូវបានគេមើលរំលង ។

## ៥. ការវាយតំលៃដំបូងលើការសាកល្បងកម្មវិធីសម្បទានដីសង្គមកិច្ច

បច្ចុប្បន្នមានគំរោងសាកល្បងសម្បទានដីសង្គមកិច្ចបីបាន និងកំពុងអនុវត្ត ។ គំរោងសាកល្បងនេះស្ថិតនៅក្នុងខេត្តកំពង់ស្ពឺ បាត់ដំបង និងកំពត ។ គោលបំណងនៃការចាប់ផ្តើមគំរោងសម្បទានដីសង្គមកិច្ច នៅកន្លែងទាំងបីផ្សេងគ្នានេះ គឺដើម្បីដកស្រង់មេរៀនសូត្រនូវបទពិសោធន៍ស្តីពីការកំណត់ និងការរៀបចំស្ថាប័ន ព្រមទាំងពីបញ្ហាជាក់ស្តែង ដែលបានជួបប្រទះនៅក្នុងអំឡុងពេលអនុវត្តកម្មវិធី ។ ប្រវត្តិផ្សេងៗគ្នារបស់គំរោងសាកល្បងទាំងនេះនឹងត្រូវផ្តល់នូវព័ត៌មានជាក់លាក់ អំពី :

- ទំនាក់ទំនងរវាងសម្បទានដីសង្គមកិច្ច ទៅនឹងសម្បទានសេដ្ឋកិច្ចដែលមានស្រាប់ (ខេត្តកំពង់ស្ពឺ)
- កិច្ចសហការជាមួយនឹងកម្មវិធីអភិវឌ្ឍន៍ជនបទនៅក្នុងខេត្ត (ខេត្តកំពត)
- កិច្ចសហការ និងការសំរបសំរួលជាមួយនឹងសកម្មភាពដោះមីន ។

ការកំណត់ទីតាំងសំរាប់ធ្វើការសាកល្បង បានធ្វើឡើងនៅដើមឆ្នាំ២០០៣ ។ ទោះជាយ៉ាងណាក៏ដោយក៏ការអនុវត្តត្រូវបានពន្យារពេល ហើយនៅត្រូវការពេលវេលាច្រើនទៀត ដើម្បីបញ្ចប់ ។ មានមូលហេតុជាច្រើនអាចរកឃើញអំពីដំណើរការដែលយឺតយ៉ាវ និងមានការលំបាកនៅក្នុងការគ្រប់គ្រង ហើយតាមរយៈដំណើរការនៃការអនុវត្តកម្មវិធីនេះ វានឹងផ្តល់នូវមេរៀនដ៏មានតំលៃជាច្រើន សំរាប់ការពង្រីកការអនុវត្តសម្បទានដីសង្គមកិច្ចក្នុងទ្រង់ទ្រាយធំ ។

ការប្រមើលមើលពីគំរោងការនេះ គឺសំដៅ :

១). កំណត់ការសាកល្បងនៅមូលដ្ឋាន

២). បង្កើតឡើងនូវក្របខ័ណ្ឌស្ថាប័ន

៣). កំណត់ដីសមស្រប

៤). បង្កើតឡើងនូវទំរង់ការនានាសំរាប់ការអនុវត្ត

៥). រៀបចំព័ត៌មានសាធារណៈ និងយុទ្ធនាការបង្កើនការយល់ដឹង

៦). រៀបចំគោលការណ៍បច្ចេកទេស

៧). កំណត់នូវគ្រួសារដែលមានសិទ្ធិសមស្របទទួលបាននូវសម្បទានដីសង្គមកិច្ច

៨). រៀបចំផែនការប្រើប្រាស់ និងបែងចែកដីធ្លី

៩). ការបង្ហាញជាសាធារណៈនូវផែនការបែងចែកដី (ជ្រើសរើសអ្នកចូលរួម)

១០).ការអនុម័តផែនការ ។

ឧបសគ្គចំបងរារាំងដល់ភាពរលូននៃការអនុវត្តវិធីសាស្ត្រដ៏ស្មុគស្មាញនេះ គឺការមិនទាន់មានក្របខ័ណ្ឌច្បាប់គ្រប់គ្រាន់សំរាប់សម្បទានដីសង្គមកិច្ច ។ នៅពេលដែលអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច បានទទួលការអនុម័តដោយទីស្តីការគណៈរដ្ឋមន្ត្រីនាខែកុម្ភៈ ឆ្នាំ២០០៣ ទំរង់ការផ្សេងៗសំរាប់ការអនុវត្ត នៅត្រូវការជាចាំបាច់នូវពេល

វេលាច្រើនថែមទៀតសំរាប់ការរៀបចំ ។ ដំណើរការនៃការរៀនសូត្រពីទីកន្លែងសាកល្បង សំរាប់ការរៀបចំគោលការណ៍អនុវត្ត មានការលំបាកនឹងសំរេចបាន ដោយសារតែដំណើរការអនុវត្ត ត្រូវបានជាប់គាំងនៅដំណាក់កាលចាប់ផ្ដើម ។ អាជ្ញាធរមូលដ្ឋានមិនមានអំណាចឡើយនៅក្នុងការធ្វើសេចក្ដីសំរេចចិត្ត ជាឧទាហរណ៍ លើការបែងចែកដី ។

ការបង្កើតឡើងនូវដំណើរការសំរាប់ការរៀបចំផែនការប្រើប្រាស់ដីធ្លីដោយមានការចូលរួម អាចសំរបសំរួលដល់ការធ្វើសេចក្ដីសំរេចចិត្តលើការធ្វើផែនការរូបវន្តនៅថ្នាក់ភូមិ និងឃុំ ក៏ប៉ុន្តែដំណើរការនេះមិនបានគ្រោងរៀបចំដើម្បីធ្វើការបែងចែកដីស្របច្បាប់ទៅដល់អ្នកប្រើប្រាស់ឡើយ ។ ជាគោលការណ៍ គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង (PLUAC) គឺជាអ្នកសំរបសំរួលនៅក្នុងការធ្វើសេចក្ដីសំរេចចិត្ត ក្នុងការបែងចែកតំបន់ដីធ្លី ពីដីរដ្ឋបច្ចុប្បន្នទៅជាដីសំរាប់បំរើការប្រើប្រាស់ជាឯកជន ក្រោមកម្មវិធីសម្បទានដីសង្គមកិច្ច ។ ក្របខ័ណ្ឌច្បាប់សំរាប់ការធ្វើសេចក្ដីសំរេចចិត្តនេះ នៅមិនទាន់បានរៀបចំបញ្ចប់សព្វគ្រប់នៅឡើយ ។ ជាងនេះទៅទៀត ការប្ដេជ្ញាចិត្តផ្នែកនយោបាយពីក្រសួងពាក់ព័ន្ធផ្សេងៗ នៅក្នុងការពិភាក្សា និងការឯកភាពលើការបែងចែកដីសំរាប់គោលបំណងសង្គមកិច្ច នៅមិនទាន់បង្កើតឡើងបានល្អនៅឡើយទេ ។ ការសំរេចបាននូវការឯកភាពគ្នាជាពិសេសជាមួយនឹងតំណាងផ្នែករដ្ឋបាលព្រៃឈើ ជានិច្ចកាលតែងតែមានការលំបាក ។

មេរៀនសំខាន់ៗដែលបានរៀនសូត្រសំរាប់ពង្រីកការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចនោះ គឺក្របខ័ណ្ឌច្បាប់ត្រូវតែរៀបចំអោយហើយរួចជាស្រេច មុនពេលដំណើរការអនុវត្តអាចចាប់ផ្ដើមបាន ។ ការវាយតំលៃលំអិតលើទំរង់ការស្ថាប័នពីកន្លែងសាកល្បងទាំងបី នៅមិនទាន់អាចរៀបចំបាននៅឡើយ ។ ការងារសាកល្បងជាច្រើនទាមទារនូវការអនុវត្តចាំបាច់ ស្របពេលជាមួយគ្នានេះដែរ ត្រូវរៀបចំបែបបទច្បាប់ទំលាប់ទាំងអស់អោយបានរួចជាស្រេច ។

មេរៀនទីពីរ គឺទាក់ទងទៅនឹងគុណភាពនៃការកំណត់ដីសំរាប់ធ្វើការបែងចែក ។ បើគ្មានលក្ខណៈវិនិច្ឆ័យដីសមស្រប និងយន្តការច្បាប់សំរាប់ការរឹបអូសយកដីកសិកម្មដែលបានកាន់កាប់ខុសច្បាប់ត្រឡប់មកវិញ សំរាប់សម្បទានដីសង្គមកិច្ចនោះទេ នោះដីដែលបានលើកស្នើឡើង និងដែលអាចមាន សំរាប់ធ្វើការបែងចែក ជានិច្ចកាលនឹងមានគុណភាពទាប និង/ឬស្ថិតនៅតំបន់ដាច់ស្រយាល ។ ផ្នែកមួយនៃបញ្ហានេះ អាចមានលទ្ធភាពដោះស្រាយបានដោយធ្វើការវិនិយោគខ្ពស់នៅក្នុងតំបន់សម្បទានដីសង្គមកិច្ច ។ តែទោះជាយ៉ាងណាក៏ដោយ ដោយសារតែផលផ្ដល់ត្រឡប់មកវិញ នៅមានកំរិតបើប្រៀបធៀបទៅនឹងតំលៃនៃការវិនិយោគខ្ពស់ យើងមិនទាន់អាចធ្វើយុត្តិកម្មបាន នៅគ្រប់កន្លែងទាំងអស់នោះបាននៅឡើយ ។

## ៦. សេចក្តីសន្និដ្ឋាន និងអនុសាសន៍សំរាប់កម្មវិធីសម្បទានដីសង្គមកិច្ច

### ៦.១. បុរេតំរូវការ និងល័ក្ខខ័ណ្ឌចាំបាច់នានាសំរាប់សម្បទានដីសង្គមកិច្ច

បុរេល័ក្ខខ័ណ្ឌសំរាប់ការអនុវត្តសម្បទានដីសង្គមកិច្ចដែលមានអត្ថន័យនោះ ត្រូវមាន :

- អនុក្រឹត្យស្តីពីការកំណត់ដីរដ្ឋ និងផែនទី
- អនុក្រឹត្យស្តីពី (ការកាត់បន្ថយ) សម្បទានសេដ្ឋកិច្ច និង
- គោលការណ៍ណែនាំអនុវត្ត (ប្រកាស) និងការជំរុញការអនុវត្តច្បាប់ដីធ្លីដែលមានស្រាប់ អោយមានសុក្រឹត្យភាព (មាត្រាទី១៨) ។

បញ្ហាប្រឈមដ៏ធំបំផុតចំពោះការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចអោយបានជោគជ័យ គឺបញ្ហានៃការកំណត់ និងការផ្តល់នូវដីសមស្របគ្រប់គ្រាន់សំរាប់ធ្វើការបែងចែក ។ គុណភាព និងបរិមាណនៃដីដែលបានបែងចែក ត្រូវតែមានលក្ខណៈគ្រប់គ្រាន់ក្នុងការផ្តល់ដល់គ្រួសារនូវសុវត្ថិភាពស្បៀងអាហារយូរអង្វែង ។ បទពិសោធន៍ទទួលបានពីការសិក្សានានា និងពីការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចសាកល្បង បានបង្ហាញអោយឃើញថា ប្រសិនបើការកំណត់ដីធ្លី ត្រូវបានទុកនាទីអោយស្ថាប័នវិមជ្ឈការជាអ្នកកំណត់ ដែលជាស្ថាប័នមិនមានអាណត្តិ និងអំណាចច្បាស់លាស់ នៅក្នុងច្បាប់ភូមិបាល នឹងមានដីតិចតួចណាស់ដែលត្រូវបានកំណត់ថាជាដីទំនេរ និងអាចធ្វើការបែងចែកបាន ។ ជាងនេះទៅទៀត ភាគច្រើននៃដីទាំងនេះនឹងមិនមានលក្ខណៈសមស្របឡើយ សំរាប់កម្មវិធីសម្បទានដីសង្គមកិច្ច ពីព្រោះតែគុណភាព ឬក៏ទីតាំងដី ឬក៏កត្តាទាំងពីររួមគ្នា ។ បើគ្មានអាណត្តិ និងការបណ្តុះបណ្តាលច្បាស់លាស់នោះទេ នោះស្ថាប័ននានានៅមូលដ្ឋាន នឹងមិនអាចមានលទ្ធភាពកំណត់ និងស្នើសុំដីដែលមានលក្ខណៈសមស្របបានឡើយ ។ មិនទាន់មានផែនទី ដែលអាចជួយនៅក្នុងការកំណត់ដីឯកជនរបស់រដ្ឋ អោយបានច្បាស់លាស់ឡើយ ។ សម្បទាននានា ត្រូវបានផ្តល់អាជ្ញាប័ណ្ណជូននៅក្រោមរូបភាពខុសៗគ្នា ជួនកាលនៅក្នុងកាលៈទេសៈ និងល័ក្ខខ័ណ្ឌមិនច្បាស់លាស់ ហើយដែលមានការលំបាកនឹងទទួលបានជោគជ័យនៅឯមូលដ្ឋាន ។ កត្តាទាំងនេះ កើតមានឡើងដូចគ្នាដែរ នៅក្នុងការចាប់យកដី និងការប្រកាសកាន់កាប់លើចំណែកដីដ៏ធំផេងផ្សេងទៀត ដោយអ្នកមានអំណាច ដែលជាទូទៅជាមេបញ្ជាការកងទ័ព ឬប្រជាពលរដ្ឋដែលមានទំនាក់ទំនងជិតស្និតជាមួយនឹងមន្ត្រីរដ្ឋាភិបាល ឬមន្ត្រីគណៈបក្សនានា ។

ដើម្បីធ្វើអោយមានដីទំនេរគ្រប់គ្រាន់សំរាប់ធ្វើការបែងចែក កម្មវិធីសម្បទានដីសង្គមកិច្ច នឹងត្រូវធ្វើការរៀបចំនូវយន្តការនានា ដែលផ្តល់ផលប្រយោជន៍ចំពោះភាគីពាក់ព័ន្ធផ្សេងៗគ្នា ត្រូវបានគិតគូរពិចារណាយ៉ាងជិតដល់ ។ ស្ថិតនៅក្រោមល័ក្ខខ័ណ្ឌនយោបាយនាពេលបច្ចុប្បន្ន ដំណើរការចរចាជាមួយអ្នកកាន់កាប់ដី និងម្ចាស់សម្បទាននានា គឺជាមធ្យោបាយមួយដ៏សមស្របបំផុត ។ នៅក្នុងពេលជាមួយគ្នានេះដែរ វាជាការចាំបាច់ដែលត្រូវបន្តរៀបចំក្របខ័ណ្ឌច្បាប់ ព្រមទាំងធានាដល់ការជំរុញការអនុវត្ត និងគោរពនូវបទបញ្ជា និងបទប្បញ្ញត្តិទាំងឡាយដែលមានស្រាប់ ដែលគ្រប់គ្រងដល់ការបែងចែកដី ។

ការពិភាក្សានៅថ្នាក់ស្រុក ខណ្ឌ និងឃុំ សង្កាត់ ក៏បានគូសបញ្ជាក់ផងដែរថា គោលការណ៍ណែនាំច្បាស់លាស់ (បរិស្ថាន សង្គម សេដ្ឋកិច្ច) សំរាប់ធ្វើចំណាត់ថ្នាក់ដី រួមបញ្ចូលទាំងការធ្វើចំណាត់ថ្នាក់សម្បទានដីសាជាថ្មីឡើងវិញ គឺជាតំរូវការដ៏ចាំបាច់បំផុត ។ ប្រការនេះ ត្រូវតែប្រើប្រាស់លើសម្បទានគ្រប់ប្រភេទ ទាំងសម្បទានសេដ្ឋកិច្ច ព្រៃឈើ និងសង្គមកិច្ច ក៏ដូចជាសំរាប់ការធ្វើចំណាត់ថ្នាក់លើដីរដ្ឋជាទូទៅផងដែរ ។ គោលការណ៍ណែនាំទាំងនេះ ត្រូវតែមានការបកស្រាយអោយបានគ្រប់គ្រាន់ ដើម្បីធានានូវភាពប្រុងប្រយ័ត្ននៅក្នុងការបែងចែកដី ។ ក្នុងពេលជាមួយគ្នានេះដែរ គោលការណ៍ណែនាំទាំងនេះ ត្រូវគិតគូរពិចារណាយ៉ាងយកចិត្តទុកដាក់ផងដែរ ពីសមត្ថភាព និងតំរូវការចាំបាច់ សំរាប់ការធ្វើវិមជ្ឈការផែនការ និងការធ្វើសេចក្តីសំរេចចិត្តនានា ។

## ៦.២. ទំនាក់ទំនងរវាងសម្បទានដីសង្គមកិច្ច សម្បទានសេដ្ឋកិច្ច និងការធ្វើចំណាត់ថ្នាក់ និងការគ្រប់គ្រងដីរដ្ឋ

### ៦.២.១. ការធ្វើចំណាត់ថ្នាក់ និងការគ្រប់គ្រងដីរដ្ឋ

ប្រសិនបើគ្មានការគាំទ្រពីអនុក្រឹត្យ ដែលនឹងតម្រែតម្រង់នូវដំណើរការនៃការកំណត់ ការធ្វើចំណាត់ថ្នាក់ និងការគ្រប់គ្រងដីរដ្ឋ ត្រូវបានពិភាក្សា និងដាក់អោយប្រើប្រាស់ទេ នោះមិនមានជំហានបន្តបន្ទាប់នៃការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចក្នុងទ្រង់ទ្រាយធំ ត្រូវបានអនុវត្តឡើយ ។ នៅពេលធ្វើការសំរេចលើអនុក្រឹត្យស្តីពីការធ្វើចំណាត់ថ្នាក់ និងការគ្រប់គ្រងដីរដ្ឋ បទពិសោធន៍ពីទីកន្លែងអនុវត្តសាកល្បងនានា ត្រូវតែយកមកពិចារណាអោយបានល្អិតល្អន់ ។ ជាមួយនឹងការដឹកនាំពីក្រុមប្រឹក្សាគោលនយោបាយដីធ្លី (CLP) ទាំងកិច្ចខិតខំប្រឹងប្រែង និងការសំរបសំរួល មិនគួរត្រូវបានរំពឹងទុកថា ជាបញ្ហាចំបងនោះឡើយ ។ ការអនុម័តអនុក្រឹត្យគាំទ្រ អាចពិចារណាថាជាជំហានមួយដ៏សំខាន់ ដែលនឹងបង្ហាញពីការប្តេជ្ញាចិត្ត និងបំណងប្រាថ្នារបស់រាជរដ្ឋាភិបាលកម្ពុជា នៅក្នុងការកែលំអអភិបាលកិច្ចលើការគ្រប់គ្រងធនធានដី ។ បញ្ហាចំបងមួយក្នុងចំណោមបញ្ហាចំបងនានា ដែលចាំបាច់ត្រូវធ្វើការបញ្ជាក់អោយបានច្បាស់លាស់នោះ គឺលក្ខណៈវិនិច្ឆ័យ ដែលនឹងអនុញ្ញាតអោយធ្វើការផ្លាស់ប្តូរកែប្រែដី ដែលជាដីសាធារណៈ និងឯកជនរបស់រដ្ឋ អោយទៅជាសម្បទានដីសង្គមកិច្ច ។ នៅខណៈពេលដែលបញ្ហាស្តីពីអ្នកគ្មានដី និងភាពក្រីក្រមានសភាពធ្ងន់ធ្ងរ ហើយនៅតែជាទិដ្ឋភាពសំខាន់នោះ លក្ខណៈវិនិច្ឆ័យ និងដំណើរការបែងចែកដី ត្រូវការចាំបាច់នូវការធានាអោយមានតុល្យភាពគ្នារវាងសេដ្ឋកិច្ច សង្គម និងបរិស្ថាន ។ ប្រសិនបើគ្មានគោលការណ៍ណែនាំច្បាស់លាស់នៅថ្នាក់ជាតិនោះទេ នោះការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចនៅឯថ្នាក់មូលដ្ឋាន នឹងមិនអាចមានលទ្ធភាពប្រព្រឹត្តទៅបានឡើយ ។

### ៦.២.២. សម្បទានសេដ្ឋកិច្ច

ការរៀបចំឡើងវិញនូវប្រព័ន្ធសម្បទានសេដ្ឋកិច្ច ត្រូវតែបានទទួលនូវការពិចារណាថា ជាសមាសធាតុមួយដ៏សំខាន់បំផុត សំរាប់ការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចប្រកបដោយជោគជ័យ ។ ការជំរុញការអនុវត្តច្បាប់ដែលមានកំណត់លើសម្បទានសេដ្ឋកិច្ច និងការចាប់ផ្តើមប្រមូលពន្ធលើដីទំនេរមិនប្រើប្រាស់ ត្រូវការការលើកទឹក

ចិត្តយ៉ាងចាំបាច់ជាទីបំផុត ។ នៅក្នុងពេលបច្ចុប្បន្នដែលមានទំហំដីធំធេងនៃសម្បទានសេដ្ឋកិច្ច ទុកចោលទំនេរ ជាកត្តាមួយដែលធ្វើអោយគ្មានដីធ្លីទំនេរ សំរាប់ធ្វើការបែងចែកទៅដល់អ្នកគ្មានដីដែលត្រូវការដីចាំបាច់ ដូច្នេះ ប្រព័ន្ធដែលបានកែសំរួលរួច អាចផ្តល់ផលប្រយោជន៍ដល់ទាំងម្ចាស់សម្បទានសេដ្ឋកិច្ច និងអ្នកដែលទទួលផលប្រយោជន៍ពីកម្មវិធីសម្បទានដីសង្គមកិច្ច ។ បទពិសោធន៍ពីប្រទេសជិតខាងបានបង្ហាញអោយឃើញថា ការរៀបចំអោយមានផលប្រយោជន៍ទាំងសងខាង អាចមានលទ្ធភាពធ្វើទៅបាន ។ មុខងារសំខាន់ នៅក្នុងផ្នែកផ្គត់ផ្គង់គំរូវការលើការផ្តល់សេវាកម្ម ការកែច្នៃ និងការរកទីផ្សារសំរាប់ផលិតផលកសិកម្ម អាចជាមុខងារសំខាន់របស់ម្ចាស់សម្បទានសេដ្ឋកិច្ច ជាឧទាហរណ៍ តាមរយៈការដាំដុះដោយមានកិច្ចសន្យា ។ ការរៀបចំរបៀបនេះ ប្រហែលជាមិនចាំបាច់រៀបចំអោយមាននៅគ្រប់ទីកន្លែងទាំងអស់បន្ថែមពីលើបញ្ជីអ្នកគ្មានដីនោះទេ ។ ក៏ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏ការផ្តួចផ្តើមនានាពីផ្នែកឯកជន និងអង្គការមិនមែនរដ្ឋាភិបាលដែលមានស្រាប់ ជាឧទាហរណ៍នៅក្នុងការដាំដុះបន្លែបង្ការ និងការចិញ្ចឹមសត្វនានា បានបង្ហាញថា ចំណូល និងសក្តានុពលនៃការកាត់បន្ថយភាពក្រីក្រពីផលិតផលនានា មិនមែនត្រឹមតែស្រូវមួយមុខប៉ុណ្ណោះនោះទេ ក៏ប៉ុន្តែរួមទាំងតាមរយៈការបង្កើនទិន្នផល ការកែលំអគុណភាព ការកែច្នៃ និងការរកទីផ្សារ ដែលនៅមិនទាន់បានទាញយកមកប្រើប្រាស់អោយបានពេញលេញនៅឡើយ ។

ការលើកទឹកចិត្តយ៉ាងសកម្ម អោយមានការផ្សារភ្ជាប់ទំនាក់ទំនងរវាងម្ចាស់កាន់កាប់តូចតាច និងអ្នកវិនិយោគជុំវិញសម្បទានសេដ្ឋកិច្ចសកម្ម អាចទាញយកផលប្រយោជន៍ពីគ្នាទៅវិញទៅមកបាន និងអាចផ្តល់ផលប្រយោជន៍ទៅដល់ប្រជាពលរដ្ឋទូទៅនៅក្នុងតំបន់ ។ គំរូផ្សេងៗគ្នា រួមមានតាំងពីការដាំដុះដោយមានកិច្ចសន្យា ជាឧទាហរណ៍ អជ្ញាធរសហព័ន្ធដើម្បីអភិវឌ្ឍន៍ដីធ្លី/អាជ្ញាធរសហព័ន្ធដើម្បីបង្រួបបង្រួម និងស្តារដីធ្លីឡើងវិញនៃប្រទេសម៉ាឡេស៊ី (FELDA/FELCRA) គួរត្រូវបានលើកយកមកធ្វើការពិនិត្យពិចារណាជាបទពិសោធន៍ ។ ជាសំណើទូទៅរួមមួយ អ្នកដាក់ពាក្យសុំសម្បទានដីសេដ្ឋកិច្ច ដែលផ្ញើនូវផែនការអភិវឌ្ឍន៍ ដែលមានការពិចារណាដាក់រួមបញ្ចូលទាំងផែនការសំរាប់អភិវឌ្ឍន៍ដីដែលស្ថិតនៅជាប់នឹងតំបន់ដីសម្បទាន និងមានការគិតគូរពីការចូលរួមពីប្រជាពលរដ្ឋ នៅមូលដ្ឋាន ត្រូវតែទទួលបាននូវការផ្តល់អាទិភាពជាពិសេស ។

## ៦.២.៣. ការគ្រប់គ្រងសហគមន៍ព្រៃឈើ

ការគ្រប់គ្រងសហគមន៍ព្រៃឈើ អាចដើរតួនាទីយ៉ាងសំខាន់សំរាប់អ្នកដែលគ្មានដី និងអ្នកខ្វះខាតដី ដែលពឹងផ្អែកលើជំរើសច្រើនបែបយ៉ាងសំរាប់ការរស់នៅ និងសុខុមាលភាពរបស់ពួកគេ ។ ជាពិសេស នៅតាមតំបន់ដែលមានព្រៃក្រាស់ អ្នកភូមិដែលគ្មានដី ពឹងផ្អែកទៅលើចំណែកដ៏ធំនៃផលិតផលព្រៃឈើសំរាប់ជីវភាពរស់នៅរបស់ពួកគេ[១៥] ។ តំបន់ទាំងនោះក៏នឹងដើរតួនាទីយ៉ាងសំខាន់ផងដែរ ជាតំបន់ទ្រនាប់រវាងតំបន់កសិកម្មនៅក្នុងភូមិ

[១៥] ធានាគារអភិវឌ្ឍន៍អាស៊ីបាន និងកំពុងស្ថិតនៅក្នុងដំណើរការចាប់ផ្តើមធ្វើការសិក្សា ដើម្បីកំណត់យុទ្ធសាស្រ្តបង្កើនសុវត្ថិភាពស្បៀង និងជីវភាពរស់នៅរបស់កសិករខ្នាតតូច និងសហគមន៍រស់នៅក្នុង ឬក៏ក្បែរតំបន់ដាច់ស្រយាល នឹងដែលមិនមានលទ្ធភាពចូលទៅប្រើប្រាស់ព្រៃឈើ ។ ការសិក្សានេះក៏មានផែនការវាយតំលៃពីសក្តានុពលរបស់សហគមន៍ព្រៃឈើនៅក្នុងការកាត់បន្ថយភាពក្រីក្រ នៅក្នុងសហគមន៍តំបន់ខ្ពង់រាប និងស្វែងរកនូវទំនាក់ទំនងគ្នាទៅនឹងការធ្វើប្រតិបត្តិការពាណិជ្ជកម្មព្រៃឈើផងដែរ ។

រួមទាំងដីសំរាប់សម្បទានដីសង្គមកិច្ច និងព្រៃឈើបំរុងទុកអចិន្ត្រៃយ៍ ។ បញ្ហាប្រឈមនោះ គឺការធ្វើសុខដុមរមនីយកម្មនៃសកម្មភាពព្រៃឈើនានា ដែលកើតមានឡើងនៅក្នុងឃុំ ។ អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើបានចែងថា សហគមន៍ព្រៃឈើ គឺជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ។ រដ្ឋបាលព្រៃឈើ មានសិទ្ធិក្នុងការផ្តល់ការទទួលស្គាល់ស្របច្បាប់នៅក្នុងការកំណត់ព្រំប្រទល់សហគមន៍ព្រៃឈើនីមួយៗ ។ ជាថ្មីម្តងទៀត បែបបទនានាសំរាប់ការអនុវត្ត (ប្រកាស) ពឹងផ្អែកទៅលើនិយមន័យ និងការកំណត់ព្រំប្រទល់ដីរដ្ឋអោយបានច្បាស់លាស់ ។ អនុក្រឹត្យនាពេលបច្ចុប្បន្ននេះ ប្រហែលជាត្រូវអោយធ្វើការកែតំរូវឡើងវិញ នៅពេលរៀបចំអនុក្រឹត្យស្តីពីការធ្វើចំណាត់ថ្នាក់ និងការគ្រប់គ្រងដីរដ្ឋត្រូវបានបញ្ចប់ ។ កត្តានេះមានសារៈសំខាន់ណាស់ ទាក់ទិនទៅនឹងសក្តានុពលនៃសកម្មភាពព្រៃឈើឯកជន ឬសហគមន៍ ដែលនឹងប្រព្រឹត្តទៅនៅលើដីសាធារណៈ និងឯកជនរបស់រដ្ឋ ជាមួយនឹងការទទួលខុសត្រូវនៅក្នុងការបែងចែក និង/ឬគ្រប់គ្រង ដែលពឹងផ្អែកទៅលើក្រុមប្រឹក្សាឃុំ សង្កាត់ ។

ដូចគ្នាដែរ សក្តានុពលនៃទំនាក់ទំនងរវាងសម្បទានសេដ្ឋកិច្ច និងសង្គមកិច្ច សកម្មភាព (សហគមន៍) ព្រៃឈើនៅលើដីសំរាប់កម្មវិធីសម្បទានដីសង្គមកិច្ច និងសកម្មភាព (ពាណិជ្ជកម្ម) ព្រៃឈើអាចមានផលប្រយោជន៍ពីគ្នាទៅវិញទៅមក ។ ទោះជាយ៉ាងណាក៏ដោយ ក៏អនុក្រឹត្យនីមួយៗ ត្រូវការចាំបាច់ធ្វើការកែតំរូវអោយបានសមស្រប ដើម្បីអនុញ្ញាតអោយអ្នកដែលគ្មានដី និងអ្នកខ្វះខាតដី អាចចាប់យកបាននូវសក្តានុពលផលប្រយោជន៍ពីកម្មវិធី ដោយមានការគោរពលើគោលការណ៍នៃការពិចារណាលើនិរន្តរភាព និងបរិស្ថាន ។

## ៦.៣. ការជាប់ទាក់ទងទៅនឹងបញ្ហា ឬកម្មវិធីដីធ្លីផ្សេងៗទៀត

ការបំពេញបន្ថែមទៅលើកម្មវិធីសម្បទានដីសង្គមកិច្ច និង គំរោង ព្រមទាំងបណ្តាកម្មវិធីគ្រប់គ្រងធនធានធម្មជាតិ និងជីវភាពរស់នៅ នៅតំបន់ជនបទដោយពឹងផ្អែកលើដីផ្សេងៗទៀត ចាំបាច់ត្រូវការរៀបចំបង្កើតអោយមានឡើង ។ គ្រប់ភាគីពាក់ព័ន្ធទាំងអស់ ទាំងភាគីរាជរដ្ឋាភិបាលកម្ពុជា អង្គការមិនមែនរដ្ឋាភិបាល និង អ្នកទទួលផលដែលមានសក្តានុពលភាពទាំងអស់ សុទ្ធតែបានដឹងពីបញ្ហាប្រឈមរបស់សង្គម សេដ្ឋកិច្ច និងបរិស្ថាន នៅក្នុងការបែងចែកដី ដែលជាសំណើលើកស្នើឡើង នៅក្នុងកម្មវិធីសម្បទានដីសង្គមកិច្ច ។ មានការចាប់អារម្មណ៍ (និងតំរូវការ) នៅគ្រប់កំរិតថ្នាក់ទាំងអស់ នៅក្នុងការបង្រួបបង្រួមនូវតំរូវការផ្សេងៗគ្នា ហើយធ្វើការជាមួយគ្នាសំដៅធ្វើអោយការអភិវឌ្ឍប្រកបដោយតុល្យភាព និងនិរន្តរភាព ។ ស្ថាប័នរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងអ្នកផ្តល់ជំនួយផ្សេងៗ បានគូសបញ្ជាក់ពីចំណាប់អារម្មណ៍ នៅក្នុងការគាំទ្រដល់កម្មវិធីសម្បទានដីសង្គមកិច្ច ។ កម្មវីធីសាកល្បងសម្បទានដីសង្គមកិច្ច គឺជាកិច្ចខិតខំប្រឹងប្រែងរួមគ្នារួចមកហើយរវាងភាគីអភិវឌ្ឍន៍នានា ។ ការអនុវត្តកម្មវិធីនេះ នៅទូទាំងប្រទេស គឺជាតំរូវការចាំបាច់ ហើយភាគីគាំទ្រទាំងនោះ អាចទទួលផលប្រយោជន៍ពីកិច្ចសហការទូលាយទាំងនេះបាន ។ ដើម្បីសំរេចបាននូវការកាត់បន្ថយភាពក្រីក្រអោយបានពេញលេញ ពីប្រព័ន្ធសម្បទាននានា នៅក្នុងប្រទេសកម្ពុជា សម្បទានសេដ្ឋកិច្ច សម្បទានដីសង្គមកិច្ច សម្បទានព្រៃឈើ (ឬក៏យ៉ាងហោចណាស់សម្បទាន និង/ឬលក្ខន្តិកៈសំរាប់គំរោងសហគមន៍ព្រៃឈើ) ចាំបាច់តំរូវអោយមានការរៀបចំឡើងវិញ

និង/ឬការធ្វើសុខដុមនីយកម្មរវាងគ្នានិងគ្នា ។ ការកាត់បន្ថយភាពក្រីក្រ និងសក្តានុពលកំណើន នៅក្នុងផលិ កម្ម កសិកម្ម ការកែច្នៃ និងទីផ្សារ នឹងទទួលបានលទ្ធផលបានយ៉ាងល្អប្រសើរបំផុត ដោយធ្វើការអភិវឌ្ឍជាបន្តបន្ទាប់ នូវសម្បទានសេដ្ឋកិច្ចសកម្ម និងផ្តល់អោយអ្នកគ្មានដីនូវឱកាសនៅក្នុងការចូលរួម នៅក្នុងសកម្មភាពសេដ្ឋកិច្ច ដោយពឹងផ្អែកលើដី ។

## ៦.៤. ភាពគ្មានដី និងដីដែលអាចមាន

### ៦.៤.១. ការកំណត់អាទិភាព (តំបន់)

ទីតាំងសាកល្បងកម្មវិធីសម្បទានដីសង្គមកិច្ចទាំងបីដំបូង ត្រូវបានជ្រើសរើសនៅក្នុងតំបន់ដែលលទ្ធភាពដីទំនេរ មិនត្រូវបានរំពឹងថា ជាបញ្ហាចោទសំរាប់ការអនុវត្ត ហើយការគាំទ្រការអនុវត្តតាមរយៈអង្គការមិនមែនរដ្ឋាភិបាលនានាដែលកំពុងប្រតិបត្តិការនៅក្នុងឃុំ អាចមានលទ្ធភាពនៅទីនោះផងដែរ ។ ការសាកល្បង ត្រូវតែបើកទូលាយសំរាប់ការរៀនសូត្រពីបទពិសោធន៍នៅក្នុងតំបន់ ដែលមានធនធានធម្មជាតិ រូបវន្ត និងស្ថាប័នខុសៗគ្នា ។

នៅពេលឈានចូលទៅដល់ការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចពេញលេញ ធនធានដែលមានកំណត់ នឹងត្រូវចំណាយទៅលើអាទិភាព ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យរួមដែលបានឯកភាពគ្នា ។ នៅក្នុងពេលចាប់ផ្តើមការអនុវត្ត អាចផ្តោតជាសំខាន់ទៅលើតំបន់ដែលមានអត្រាអ្នកគ្មានដីខ្ពស់ និងលទ្ធភាពក្នុងការរកចំណូលប្រចាំថ្ងៃមានកំរិត ។ ដោយសារតែការប្រកួតប្រជែងសំរាប់ដី មានលក្ខណៈស្រួចស្រាវ ការគាំទ្រដល់អ្នកគ្មានដី គឺជាតំរូវការចាំបាច់នៅទីនោះ ។ ជំរើសមួយផ្សេងទៀត អាចជាការបន្តការបែងចែកនៅក្នុងកំរិតទូលំទូលាយនៅក្នុងតំបន់ដែលលទ្ធភាពនៃដីដែលអាចរកបាន មិនមែនជាបញ្ហាចោទធ្ងន់ធ្ងរ ហើយដែលប្រការនេះអាចបើកទូលាយដល់ការកែលំអបទពិសោធន៍នានា ជាមួយនឹងទិដ្ឋភាពស្ថាប័ននៃការអនុវត្តកម្មវិធីអោយកាន់តែប្រសើរឡើង ។ ជំរើសទីបីអាចជាការជ្រើសរើសតំបន់ដែលមានគំរោង/អ្នកផ្តល់ជំនួយនានា កំពុងតែធ្វើការនៅទីនោះ នៅក្នុងការពង្រឹងការផ្តល់សេវាកម្ម និងហេដ្ឋារចនាសម្ព័ន្ធនៅថ្នាក់មូលដ្ឋាន ។ តំលៃសំរាប់ការអនុវត្ត (សំរាប់រាជរដ្ឋាភិបាលកម្ពុជា) អាចមានកំរិតទាបនៅក្នុងតំបន់ភូមិសាស្ត្រនេះ ។ ទោះបីជាយុទ្ធសាស្ត្រណាមួយក៏ដោយ យុទ្ធសាស្ត្រទោល ឬក៏រួមគ្នា ដែលត្រូវបានយកមកប្រើប្រាស់ អោយតែមានការឯកភាព និងទទួលយកបានដោយគ្រប់ភាគីទាំងអស់ វានឹងជាកត្តាដ៏មានសារៈសំខាន់ជាទីបំផុត ។

### ៦.៤.២. ការតាំងទីលំនៅឡើងវិញ

លទ្ធផលពីការងារអង្កេតបានបង្ហាញថា អ្នកទទួលដីដែលមានសក្តានុពលភាព នឹងមិនមានបញ្ហាជំទាស់ឡើយ នៅក្នុងការធ្វើដំណើរទៅឆ្ងាយបន្តិច នៅក្នុងរង្វង់តំបន់សហគមន៍ ប្រសិនបើសក្តានុពលដីដែលពួកគេទទួលបាន ត្រូវបានធានារ៉ាប់រង ។ ការធ្វើដំណើរផ្លាស់ប្តូរនៅក្នុងប្រទេសរបស់ប្រជាពលរដ្ឋ នៅក្នុងការស្វែងរកដីសំរាប់ធ្វើការដាំដុះ កំពុងតែកើតមានឡើងរួចមកហើយ ។ នៅក្នុងពេលជាមួយគ្នានេះដែរ ប្រជាពលរដ្ឋមូលដ្ឋាននៅក្នុងតំបន់ នៅ

កន្លែងដែលដីមិនមានការខ្វះខាតសំរាប់ការផ្គត់ផ្គង់ នឹងមិនមានបញ្ហាចោទឡើយ នៅក្នុងការផ្តល់ជូនដល់អ្នកចំណូលថ្មី នូវឱកាសសំរាប់ការធ្វើសមាហរណកម្មទៅក្នុងសហគមន៍របស់ពួកគេ ។ ទោះបីជាភាពប្រាកដប្រជាមិនទាន់អាចធ្វើការអះអាងបានក៏ដោយ នៅក្នុងការលើទឹកចិត្តដល់ការតាំងទីលំនៅឡើងវិញ នៅក្នុងក្របខ័ណ្ឌនៃកម្មវិធីសម្បទានដីសង្គមកិច្ចក៏ដោយ ក៏ការផ្លាស់ប្តូរទីតាំងរបស់គ្រួសារទាំងឡាយ ផ្តល់នូវឱកាសសំរាប់ការពង្រីកកម្មវិធីសម្បទានដីសង្គមកិច្ចនៅទូទាំងប្រទេស ។

## ៦.៤.៣. សម្បទានដីសង្គមកិច្ច និងកម្មសិទ្ធិដីធ្លីរបស់ប្រជាពលរដ្ឋជនជាតិដើមភាគតិច

ការអង្កេតនេះមិនបានរួមបញ្ចូលការអង្កេតលើសហគមន៍ជនជាតិដើមភាគតិចណាមួយឡើយ ដូចគ្នាដែរចំពោះទីកន្លែងសាកល្បងកម្មវិធីសម្បទានដីសង្គមកិច្ច ដែលត្រូវតែដោះស្រាយនូវសក្តានុពលទំនាស់នានាដែលអាចកើតមានឡើងនៅតាមបណ្តាភូមិទាំងនេះ ។ ការប្រាស្រ័យទាក់ទងជាមួយនឹងសហគមន៍ដែលមានការចាប់អារម្មណ៍លើកម្មវិធីនេះ នឹងការរៀបចំគំរោងការសាកល្បងដោយប្រុងប្រយ័ត្ន អាចផ្តល់នូវព័ត៌មានចាំបាច់ ដើម្បីអនុញ្ញាតអោយសហគមន៍ទាំងនោះ ទទួលបានផលប្រយោជន៍ពីការផ្លាស់ប្តូរនូវការធ្វើចំណាត់ថ្នាក់ដី និងពីសក្តានុពលនៃកម្មវិធីបែងចែកដី ។

## ៦.៥. ការផ្តល់ការគាំទ្រសេវាកម្ម និងហេដ្ឋារចនាសម្ព័ន្ធ

បញ្ជីអាទិភាពសេវាកម្ម ដែលត្រូវការផ្តល់ចាំបាច់ទៅដល់សហគមន៍ ដើម្បីអោយពួកគាត់អាចទទួលបាននូវផលប្រយោជន៍ពីកម្មវិធីសម្បទានដីសង្គមកិច្ច មានលក្ខណៈខុសគ្នាទាំងស្រុងទៅនឹងកម្មវិធីដែលផ្តោតការយកចិត្តទុកដាក់លើផលិតកម្មកសិកម្ម ។ តំរូវការចាំបាច់នៃសេវាកម្ម និងហេដ្ឋារចនាសម្ព័ន្ធ នឹងត្រូវធ្វើការដោះស្រាយបញ្ហាចំបងពីរ : (១).អ្នកទទួលផលត្រូវតែមានលទ្ធភាពអាចប្រើប្រាស់ដីរបស់ខ្លួនដើម្បីបង្កើនផលិតផលអោយបានល្អប្រសើរបំផុត និង (២).តំរូវការចាំបាច់នៅក្នុងការដោះស្រាយមូលហេតុដែលធ្វើអោយមានវិបត្តិលក់ដីធ្លី ។

ការកែលំអដ៏ធំធេង នៅក្នុងផលិតកម្មកសិកម្ម អាចមានការសង្ឃឹមបានពីដំបូន្មានដ៏សមស្រប លើការអនុវត្តបច្ចេកទេសដាំដុះ ។ សេវាកម្មផ្សព្វផ្សាយកសិកម្ម ជាមួយនឹងការផ្តល់ការណែនាំជាក់លាក់ចំពោះកសិករខ្នាតតូចនៅក្នុងពេលអនាគតដ៏ខ្លីខាងមុខ នឹងមានផលប៉ះពាល់ល្អប្រសើរជាង ជាងការផ្គត់ផ្គង់នូវតំរូវការកសិកម្មទំនើបនានា (ឥណទាន) ។ ដូចដែលបានគូសបញ្ជាក់ដោយ Auffret (២០០៣) វត្តមានរបស់អ្នកផ្សព្វផ្សាយកសិកម្ម ឬមួយក៏អ្នកទីផ្សារអចិន្ត្រៃយ៍នៅក្នុងភូមិ បានជួយដល់ការបង្កើនចំណូលគ្រួសារយ៉ាងច្រើន ។ លទ្ធផលពីការស្រាវជ្រាវក៏បានលើកស្នើឡើងអោយមានផលប៉ះពាល់ខ្លាំងលើការកាត់បន្ថយភាពក្រីក្រនៅជនបទផងដែរ ហើយគោលនយោបាយនានាត្រូវតែផ្តោតជាសំខាន់ទៅលើបទអន្តរាគមន៍ផ្សេងៗ ដែលបង្កើននូវលទ្ធភាពនៃការផ្គត់ផ្គង់ច្រើនយ៉ាងដោយមានការប្រកួតប្រជែងតំលៃ បង្កលក្ខណៈអោយមានការប្រកួតប្រជែងតំលៃសំរាប់ការលក់ដូរនូវផលិតផល និងការកែលំអផលិតកម្ម ។ កង្វះខាតនៃលទ្ធភាពនៅក្នុងការទូទាត់ បានធ្វើអោយគ្រួសារមិនមានលទ្ធភាពទទួលបាននូវការផ្គត់ផ្គង់សំខាន់ៗ និងរារាំងគ្រួសារពីការបែងចែកនូវទិន្នផល នៅក្នុងលក្ខណៈមួយដែលមានផលចំណេញ

អតិប្បរមាជាប្រចាំ ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏លទ្ធផលពីការពិភាក្សាជាមួយក្រុមគោលដៅសំរាប់ការពិភាក្សា បានបង្ហាញថា ការទទួលយកឥណទានពីអ្នកផ្តល់ផ្លូវការ និងមិនផ្លូវការ ជារឿយៗ គឺជាមូលហេតុនៃការធ្លាក់ចូលទៅក្នុងអន្ទាក់នៃការជំពាក់បំណុលគេ ហើយជាបន្តបន្ទាប់នាំអោយឈានទៅដល់ការបាត់បង់ដីធ្លី ។ ប្រការនេះអាចបកស្រាយបានថា ជាសូចនាករសំរាប់ការចាត់អាទិភាព និងចង្វាក់នៃការផ្តល់សេវាកម្ម ។

អន្តរាគមន៍សំខាន់ៗ គឺជាការផ្តល់នូវសេវាកម្មសុខភាពដែលអាចមានលទ្ធភាពទទួលយកបាន និងទុកចិត្តបាន នៅក្នុងសហគមន៍ដែលទទួលបានប្រយោជន៍ពីកម្មវិធី ។ ការចំណាយទៅលើការព្យាបាលជំងឺនានា ត្រូវបានបញ្ជាក់ម្តងហើយម្តងទៀតថា ជាមូលហេតុចំបង ដែលធ្វើអោយគ្រួសារទាំងឡាយបាត់បង់នូវទ្រព្យសម្បត្តិរបស់ពួកគេ ។ មណ្ឌលសុខភាព និងការថែទាំសុខភាព បានលើកឡើងនៅក្នុងរបាយការណ៍នៃការអង្កេតតាមគ្រួសារ និងការពិភាក្សាជាមួយក្រុមគោលដៅសំរាប់ការពិភាក្សា បានបញ្ជាក់ថា ជាសេវាកម្មអាទិភាពរួមផ្សំជាមួយនឹងកម្មវិធីសម្បទានដីសង្គមកិច្ច ។

ប្រភេទមួយផ្សេងទៀតនៃសេវាកម្មគាំទ្រសង្គម ប្រហែលជាតំរូវអោយដោះស្រាយបញ្ហាជំពាក់បំណុលគេដែលកើតមានឡើងរួចមកហើយ ព្រមទាំងការតស៊ូដើម្បីការរស់នៅប្រចាំថ្ងៃរបស់គ្រួសារអ្នកដែលគ្មានដី ។ ទោះបីជាការផ្តល់ជាថវិកា និងកំលាំងពលកម្ម ព្រមទាំងសម្ភារនានា អាចជួយដោះស្រាយបញ្ហាបានតិចតួចក៏ដោយ ក៏ប៉ុន្តែសំរាប់អ្នកដែលមានជីវភាពក្រីក្របំផុត វាគឺជាវិនិយោគមួយដ៏មានទំហំធំធេង ដែលអាចចំណាយក្នុងការទិញសម្ភារចាំបាច់ផ្សេងៗបាន ហើយដែលអាចបង្កលទ្ធភាពអោយអ្នកដែលទទួលបានដីពីកម្មវិធី អាចបំពេញនូវកង្វះខាតបាន នៅរដូវប្រមូលផល ។ ទោះបីជាយ៉ាងដូចនេះក្តី សម្ពាធលើការលក់ដីនៅតែបន្តកើតមាន ។ អាចរំពឹងទុកបានថា បទបញ្ជាទាំងឡាយដែលមានស្រាប់ ដែលបញ្ជាក់ពីការហាមឃាត់ដល់គ្រួសារទាំងឡាយណាដែលទទួលបានដីពីកម្មវិធីសម្បទានដីសង្គមកិច្ច មិនអោយលក់ដីនៅក្នុងរយៈពេលប្រាំឆ្នាំដំបូង នឹងអាចមិនត្រូវបានគោរពតាមរយៈការឯកភាពព្រមព្រៀងក្រៅផ្លូវការ ។

## ៦.៦. បញ្ហាស្ថាប័ន និងការអនុវត្ត

តំរូវការចាំបាច់នានាចំពោះការផ្គត់ផ្គង់ច្បាប់បន្ថែម ការរៀបចំផែនការវិមជ្ឈការ និងរចនាសម្ព័ន្ធអនុវត្ត ព្រមទាំងការសំរបសំរួល និងកិច្ចសហប្រតិបត្តិការចាំបាច់នានា រវាងក្រសួងពាក់ព័ន្ធ និងភ្នាក់ងាររបស់រដ្ឋាភិបាល នឹងធ្វើអោយកម្មវិធីសម្បទានដីសង្គមកិច្ច ដើរតួនាទីយ៉ាងសំខាន់នៅក្នុងការផ្តល់អោយដល់រាជរដ្ឋាភិបាលកម្ពុជានូវការប្តេជ្ញាចិត្តចំពោះអភិបាលកិច្ចល្អ ។ ការគាំទ្រទាំងឡាយចំពោះការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច ត្រូវតែពឹងផ្អែកទៅលើការរីកចំរើននៃអភិបាលកិច្ច ដែលជាប់ទាក់ទងដោយផ្ទាល់ទៅនឹងជោគជ័យនៃការបែកចែកដីធ្លីសមស្រប និងស្មើភាពគ្នា ។ នៅក្នុងអត្ថន័យនេះ កម្មវិធីសម្បទានដីសង្គមកិច្ច នឹងចាត់ចូលទៅក្នុងជំពូកគំរោងបំលាស់ប្តូរស្ថាប័ន/អភិបាលកិច្ចល្អ ព្រមទាំងជំពូកគំរោងអភិវឌ្ឍន៍ជនបទ ។

### ៦.៦.១. ថ្នាក់ជាតិ

ការសំរបសំរួល និងកិច្ចសហការនៅគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ហាក់បីដូចជា មានដំណើររលូន ។ គណៈកម្មាធិការនេះ ត្រូវតែដាក់សម្ពាធទៅអង្គភាពវិមជ្ឈការថ្នាក់ក្រោមរបស់ខ្លួន អោយជំនះអោយបាននូវរាល់ការមិនទុកចិត្តគ្នា និងធានានូវកិច្ចសហការរវាងគ្នានិងគ្នា ។ វាក៏មានសារៈសំខាន់ផងដែរ នៅក្នុងការរៀបចំធ្វើយ៉ាងណាអោយមានការយល់ដឹងច្បាស់លាស់ ទៅលើអ្វីដែលជាតំរូវការចាំបាច់ អោយមានការគាំទ្របច្ចេកទេសដោយថ្នាក់លើ ។ ដោយសារតែនៅកំរិតថ្នាក់រដ្ឋបាលខ្ពស់ជាង តែងតែមិនអោយតំលៃទៅលើសក្តានុពលនៃអង្គភាពវិមជ្ឈការរបស់ខ្លួន វាគឺជាគ្រោះថ្នាក់ជាទីបំផុត ចំពោះការមិនអើពើពីតំរូវការចាំបាច់នៅក្នុងការវិនិយោគលើការកសាងសមត្ថភាព ។

### ៦.៦.២. ថ្នាក់ខេត្ត ក្រុង

គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុងដែលទើបបង្កើតឡើងថ្មី ត្រូវតែធ្វើការយ៉ាងជិតស្និទ្ធជាមួយនឹងគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត ក្រុង ។ ទោះបីជាមានសមាជិកភាពត្រួតស៊ីគ្នាច្រើន ការសំរបសំរួលរវាងកម្មវិធីសម្បទានដីសង្គមកិច្ច និងកម្មវិធីអភិវឌ្ឍន៍នានា គួរតែមិនមានជាបញ្ហាចោទទេ ។ ទោះជាយ៉ាងណាក៏ដោយ ក៏នៅមានតំរូវការយុទ្ធនាការផ្សព្វផ្សាយព័ត៌មាន ការបណ្តុះបណ្តាល និងការកសាងសមត្ថភាពជាពិសេសការដោះស្រាយលើចំណុចខ្សោយរបស់អង្គភាពគាំទ្របច្ចេកទេសនៅថ្នាក់ខេត្ត ក្រុង (និងនៅថ្នាក់វិមជ្ឈការក្រោមៗទៀត) ។

### ៦.៦.៣. ថ្នាក់ស្រុក ខណ្ឌ

ការសំរបសំរួល និងការសហការនៅថ្នាក់ស្រុក ខណ្ឌ រវាងភ្នាក់ងាររដ្ឋាភិបាលផ្សេងៗ ហាក់បីដូចជានៅមានភាពទន់ខ្សោយនៅឡើយ នៅក្នុងជួររចនាសម្ព័ន្ធវិមជ្ឈការ ។ ធនធានដែលមាន និង/ឬបញ្ហានៃការបែងចែកអាចជាឧបសគ្គចំបងសំរាប់ការងារនៅមូលដ្ឋាន ដែលជាតំរូវការចាំបាច់ចំពោះក្រុមការងារថ្នាក់ស្រុក ខណ្ឌ ។ ថ្នាក់ស្រុក ខណ្ឌ ប្រហែលជាថ្នាក់ដែលមានសមត្ថភាព និងធនធានដែលអាចមានខ្សត់ខ្សោយបំផុត បើប្រៀបធៀបទៅនឹងតួនាទីរំពឹងទុកនៅក្នុងកម្មវិធី ។ ការណែនាំលើអាទិភាព និងការបែងចែកធនធាន រួមជាមួយនឹងការកសាងសមត្ថភាព គឺជាតំរូវការចាំបាច់មិនអាចខានបាន ។

### ៦.៦.៤. ថ្នាក់ឃុំ សង្កាត់ និងភូមិ

អ្នកភូមិនៅមិនទាន់មានការជឿជាក់ពេញលេញ ទៅលើក្រុមប្រឹក្សាឃុំ សង្កាត់ដែលខ្លួនបានជ្រើសតាំងនៅឡើយ ។ អ្នកភូមិភាគច្រើនចង់ឃើញស្ថាប័នឯករាជ្យមួយ ដែលដើរតួនាទីជាអ្នកសំរបសំរួលជ្រើសរើសក្រុមអ្នកទទួលផល និងក្រុមអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច ។ អ្នកភូមិ ហាក់បីដូចជាមិនមានទស្សនៈចង្អៀតចង្អល់នៅក្នុងការអនុញ្ញាតអោយប្រជាពលរដ្ឋ ដែលមិនមានសញ្ជាតិជាជនជាតិខ្មែរ ចូលរួមនៅក្នុងកម្មវិធីសម្បទានដី

សង្គមកិច្ចឡើយ ។ ក៏ប៉ុន្តែទោះបីជាមានការយល់ដឹងយ៉ាងនេះក៏ដោយ ក៏ពួកគេចង់ឃើញពីតំរូវការរបស់ពួកគេត្រូវបានឆ្លើយតបមុន ។ កម្មវិធីនេះ អាចជួបប្រទះបញ្ហាខ្លះ ពីការប្រឆាំងតវ៉ានៅថ្នាក់មូលដ្ឋាន នៅពេលដែលមានការចូលរួមពីប្រជាពលរដ្ឋ ដែលមិនមានសញ្ជាតិជាជនជាតិខ្មែរ រស់នៅតាមតំបន់ជាប់ព្រំដែន ។

## ៦.៦.៥. ទិដ្ឋភាពបច្ចេកទេស

មានទិដ្ឋភាពបច្ចេកទេសមួយចំនួន នៅក្នុងកម្មវិធីសម្បទានដីសង្គមកិច្ច ដែលតំរូវអោយមានការពិចារណា និង/ឬធ្វើការកែតំរូវយ៉ាងប្រុងប្រយ័ត្ន ។ ទិដ្ឋភាពចំបងមួយ គឺ និរន្តរភាពនៃដីដែលបានបែងចែកសំរាប់ផលិតកម្មកសិកម្ម ចាំបាច់ត្រូវធានាអោយបាន ។ ការពិចារណាលើបញ្ហាបរិស្ថាន ត្រូវការពិនិត្យទៅលើការកែប្រែផ្លាស់ប្តូរតំបន់ដីព្រៃរិចរិលអោយទៅជាដីដាំដំណាំបាន ។ គោលការណ៍នៃការដាក់ពាក្យសុំ និងការជ្រើសរើសអ្នកទទួលផលត្រូវពិចារណាទៅលើល័ក្ខខ័ណ្ឌ/ទំនៀមទំលាប់ប្រពៃណីនៅមូលដ្ឋាន ។ ការផ្តួចផ្តើមគំរោងសម្បទានដីសង្គមកិច្ចនានាអាចត្រូវការពេលវេលាច្រើនជាងការរំពឹងទុក ។ ការរៀបចំផែនការសម្បទានដីសង្គមកិច្ច និងការបណ្តុះបណ្តាលលើការអនុវត្ត ត្រូវតែធ្វើការពង្រីកបន្ថែម ។ អង្គការមិនមែនរដ្ឋាភិបាល នឹងដើរតួនាទីយ៉ាងសំខាន់ នៅក្នុងការអនុវត្តនៅថ្នាក់ឃុំ សង្កាត់ ហើយដោយហេតុដូចនេះ ពួកគេត្រូវតែជាភ្នាក់ងារដ៏សំខាន់បំផុតនៅក្នុងការបណ្តុះបណ្តាលទាក់ទងទៅនឹងសម្បទានដីសង្គមកិច្ច ។

## ៦.៦.៦. តួនាទីរបស់រដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល

ការអង្កេតបានបង្ហាញថា ការចូលរួមរបស់អង្គការមិនមែនរដ្ឋាភិបាលនៅក្នុងការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច នឹងទទួលបាននូវការអោយតំលៃនៅគ្រប់លំដាប់ថ្នាក់ ។ ជាពិសេស នៅថ្នាក់ឃុំ សង្កាត់ និងភូមិ មានការពង្រីកតួនាទីដែលមានសក្តានុពលសំរាប់អង្គការមិនមែនរដ្ឋាភិបាល ។ ដូច្នេះ គំរោងសម្បទានដីសង្គមកិច្ចត្រូវតែដាក់បញ្ចូលការរៀបចំផែនការប្រើប្រាស់ដីធ្លីដោយមានការចូលរួមនៅថ្នាក់មូលដ្ឋាន ការពង្រីកការចូលរួមរបស់អង្គការមិនមែនរដ្ឋាភិបាលនៅក្នុងការរៀបចំផែនការនៅថ្នាក់មូលដ្ឋាន គឺជាប្រការដ៏មានលក្ខណៈសមស្របបំផុត ។ ការធ្វើបែបនេះ គឺស្របទៅនឹងតំរូវការរបស់អ្នកភូមិ ដែលត្រូវការការជួយគាំទ្រពីអ្នកខាងក្រៅ (តាមដាន) ក្នុងដំណើរការរៀបចំផែនការ និងការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច ។ នៅពេលដែលការសំរេចចិត្តរបស់អជ្ញាធរមូលដ្ឋាន នឹងត្រូវស្ថិតនៅជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ពួកគាត់បានបញ្ជាក់ពីតំរូវការចាំបាច់ អោយមានការគាំទ្រលើទិដ្ឋភាពបច្ចេកទេសនៃកម្មវិធី ។ ស្របពេលជាមួយគ្នានេះដែរ អ្នកភូមិក៏បានបញ្ជាក់ពីតំរូវការអោយមានការគាំទ្រ និងតាមដានស្ថាប័ននៅក្រៅរចនាសម្ព័ន្ធនូវការរបស់រដ្ឋាភិបាលផងដែរ ដើម្បីធានានូវការអនុវត្តកម្មវិធី ដែលគ្មានភាពលំអៀង និងស្មើភាពគ្នា ។

អង្គការមិនមែនរដ្ឋាភិបាលដែលជឿទុកចិត្ត និងមានសមត្ថភាព អាចដើរតួនាទីយ៉ាងសំខាន់នៅក្នុងកម្មវិធីសម្បទានដីសង្គមកិច្ចក្នុងវិសាលភាពធំ ដែលអាចមានសមត្ថភាពច្រើនជាងស្ថាប័នរដ្ឋាភិបាល ។ នៅពេល

ពួកគេអាចរក្សាបាននូវមុខងារសំរបសំរួល និងតាមដានរបស់ពួកគេបាន ការអនុវត្តនៅថ្នាក់ភូមិ ត្រូវតែផ្ទេរទៅអោយអង្គការមិនមែនរដ្ឋាភិបាល ដែលជាអ្នកសំរបសំរួលយ៉ាងជិតស្និទ្ធជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ។

### ៦.៦.៧. ការចូលរួម និងការសំរបសំរួលរបស់អ្នកផ្តល់ជំនួយ

នាពេលបច្ចុប្បន្ននេះ អ្នកផ្តល់ជំនួយមួយចំនួនអនុវត្តគំរោងសម្បទានដីសង្គមកិច្ចដោយខ្លួនគេផ្ទាល់ ។ ការបែងចែកដីដែលបានដោះមីនរួច ដីដែលបានទិញដោយមូលនិធិអ្នកផ្តល់ជំនួយ/គំរោង ។ល។ បាន និងកំពុងអនុវត្តនៅក្នុងឃុំមួយចំនួននៅទូទាំងប្រទេស ។ ម្យ៉ាងវិញទៀត ការអនុវត្តបែបនេះបានបង្កអោយមានបញ្ហា ដោយសារតែការរៀបចំផ្លូវច្បាប់ ជានិច្ចការមិនមានភាពច្បាស់លាស់ ហើយម្យ៉ាងវិញទៀត វាក៏បានបង្ហាញយ៉ាងច្បាស់ពីចំណាប់អារម្មណ៍របស់អ្នកផ្តល់ជំនួយក្នុងការគាំទ្រដល់ការបែងចែកដីធ្លី ។ មេរៀនសូត្រពីបទពិសោធន៍នានានៃគំនិតផ្តួចផ្តើមទាំងនេះ និងការទាក់ទាញអ្នកផ្តល់ជំនួយដែលមានការចាប់អារម្មណ៍ទាំងអស់រួមគ្នានៅក្នុងគន្លងតែមួយ នឹងជាផ្នែកមួយនៃមុខងារសំរបសំរួលរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (ឬស្ថាប័នសមស្របផ្សេងៗទៀត) ។

ការចូលរួមរបស់អ្នកផ្តល់ជំនួយនៅក្នុងការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច អាចប្រព្រឹត្តទៅបាន តាមមធ្យោបាយពីរ ដែលអាចកើតមានឡើងក្នុងពេលជាមួយគ្នា ហើយអាចបំពេញបន្ថែមអោយគ្នាទៅវិញទៅមក ។ គំរោងសម្បទានដីសង្គមកិច្ច អាចផ្សារភ្ជាប់ទៅនឹងសកម្មភាពនានារបស់ម្ចាស់ជំនួយដែលមានស្រាប់ នៅក្នុងភូមិជាឧទាហរណ៍ នៅកន្លែងដែលមានសេវាកម្មសំខាន់ៗ និងហេដ្ឋារចនាសម្ព័ន្ធត្រូវបានផ្តល់ទៅអោយឃុំ គំរោងសម្បទានដីសង្គមកិច្ច អាចប្រើប្រាស់នូវផលប្រយោជន៍ទាំងនោះបាន ។ ជំរើសមួយផ្សេងទៀត គឺការជួយគាំទ្រផ្នែកហិរញ្ញវត្ថុដល់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (ឬស្ថាប័នសមស្របផ្សេងទៀត) ដែលតាមរយៈនេះ សកម្មភាពនានាត្រូវបានផ្តល់មូលនិធិ និងសំរបសំរួល ។

## ៦.៧. តំរូវការស្រាវជ្រាវបន្ថែម

មានតំរូវការព័ត៌មានបន្ថែមអំពីលទ្ធភាព និងកត្តាកំណត់នានានៃជីវភាពរស់នៅដែលពឹងផ្អែកលើកសិកម្មនៅក្នុងសហគមន៍ទទួលផល ។ កម្មវិធីសម្បទានដីសង្គមកិច្ច នឹងពង្រីកមូលដ្ឋានសំរាប់ការរកប្រាក់ចំណូល និងសុវត្ថិភាពស្បៀងដោយពឹងផ្អែកលើដី ។ ទិន្នន័យបានបង្ហាញថា ទិន្នផលមានកំរិតទាបបំផុតនៅក្នុងប្រព័ន្ធដាំដុះនានាដែលមានស្រាប់ ។ សក្តានុពលរបស់វានៅមិនទាន់មានការទាញយកមកប្រើប្រាស់នៅឡើយ ។ ការសិក្សាបន្ថែមត្រូវការធ្វើឡើងជាចាំបាច់ដើម្បីពិនិត្យលើជំរើសលទ្ធភាពដែលមានលក្ខណៈប្រសើរជាង និងការផ្តល់អំណាចទៅដល់អ្នកភូមិ នៅក្នុងការប្រើប្រាស់អោយកាន់តែប្រសើរឡើងនូវធនធានដីរបស់ពួកគេ ។

កម្មវិធីកសាងសមត្ថភាព ដើម្បីរៀនសូត្រពីការអនុវត្ត ការអនុម័ត និងការកែច្នៃយកមកប្រើប្រាស់នូវវិធីសាស្ត្រដែលទទួលបានជោគជ័យ សំដៅធ្វើការកែលំអអោយកាន់តែប្រសើរឡើងនូវការដាំដុះ ត្រូវតែរៀបចំ

បង្កើតអោយមានឡើងជាចាំបាច់ ។ គោលដៅគ្របដណ្តប់របស់កម្មវិធី ត្រូវតែរួមបញ្ចូលទាំងការពិចារណាលើការដាំដុះសំរាប់តែគ្រប់គ្រាន់ក្នុងគ្រួសារ គំរូសំរាប់ការផ្សារភ្ជាប់គ្នារវាងកសិដ្ឋានខ្នាតតូចទៅនឹងទីផ្សារ និងអ្វីៗគ្រប់យ៉ាងទាំងអស់ផ្សេងទៀតដែលមានការពាក់ព័ន្ធ ។ នៅក្នុងពេលជាមួយគ្នានេះដែរ កម្មវិធីទាំងនេះចាំបាច់ត្រូវតែមានការវិភាគលើប្រសិទ្ធភាពតំលៃ ដែលត្រូវតែប្រើប្រាស់ជាគំរូវការគោលការណ៍គន្លឹះ នៅទូទាំងប្រទេស ។

សេវាកម្មគួបផ្សំសំខាន់សំរាប់សម្បទានដីសង្គមកិច្ច ដែលត្រូវការចាំបាច់នៅក្នុងសហគមន៍ទទួលផល គឺការអាចមានលទ្ធភាពទទួលបាននូវសេវាកម្មថែទាំសុខភាព ។ ការស្រាវជ្រាវក៏ត្រូវការចាំបាច់ផងដែរ នៅក្នុងការវាយតំលៃទៅលើបទពិសោធន៍នានាទាក់ទងទៅនឹងការផ្តល់សេវាកម្មថែទាំសុខភាព ការកំណត់នូវលទ្ធភាពយន្តការផ្គត់ផ្គង់ ប្រសិទ្ធភាពតំលៃ ដោយមានចូលរួមពីមូលដ្ឋាន ។

ជាទូទៅដើម្បីធ្វើការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចអោយបានពេញលេញ វានឹងមានតំលៃខ្ពស់ណាស់ ។ ដោយហេតុដូចនេះហើយ វានឹងមានសារៈសំខាន់ជាទីបំផុតនៅក្នុងការអង្កេតមើលលើលទ្ធភាពនានានៃការ ចូលរួមយ៉ាងខ្លាំងក្លាពីសំណាក់មូលដ្ឋាន នៅក្នុងគ្រប់ទិដ្ឋភាពទាំងអស់នៃកម្មវិធី ជាពិសេសនៅក្នុងការផ្តល់សេវាកម្ម និងហេដ្ឋារចនាសម្ព័ន្ធ ។ ការសិក្សាបន្ថែមត្រូវការរៀបចំអោយមានជាចាំបាច់ ដើម្បីជ្រើសរើសយកនូវបទពិសោធន៍ពីគំរោងមូលនិធិសង្គម និងគំរោងផ្តួចផ្តើមនៅថ្នាក់មូលដ្ឋានផ្សេងៗទៀត ។

## ៦.៨. សំណើនានាសំរាប់ជំហានបន្ទាប់

ការវិភាគផលប៉ះពាល់លើភាពក្រីក្រ និងសង្គម អាចវាយតំលៃបានទូលំទូលាយពីកំរិតកំពូលនៃអត្ថប្រយោជន៍ដែលនឹងទទួលបានពីកម្មវិធីបែងចែកដី ។ តួលេខលំអិតជាក់លាក់អំពីផលប្រយោជន៍នេះ អាចទទួលបានតែនៅពេលដែលមានការធ្វើសេចក្តីសំរេចចិត្តច្បាស់លាស់ ទៅលើថាតើតំបន់ជាក់លាក់ណាមួយ ត្រូវបានជ្រើសរើសសំរាប់ធ្វើការបែងចែកដី ត្រូវបានធ្វើឡើងតែប៉ុណ្ណោះ ។ វាមានសារៈសំខាន់ជាទីបំផុត នៅក្នុងការធ្វើការកំណត់ទីកន្លែងសាកល្បង អោយបានច្រើនជាងចំនួនបីកន្លែងដែលកំពុងស្ថិតនៅក្រោមដំណើរការអនុវត្ត ដែលអាចប្រើប្រាស់ ជាឧទាហរណ៍សំរាប់ (ក).ការរៀបចំក្របខ័ណ្ឌស្ថាប័នអោយបានត្រឹមត្រូវ និង (ខ).ការវិភាគលំអិតទៅលើផលប៉ះពាល់ពីកម្មវិធី ។

ការងារនៅតាមគំរោងសាកល្បងទាំងបីកន្លែង គួរត្រូវបានពិចារណា ហើយប្រសិនបើចាំបាច់គួរតែពន្យារពេលរហូតដល់ពេលដែលមានច្បាប់គ្រប់គ្រាន់ទាំងអស់ត្រូវបានរៀបចំរួចរាល់ជាស្រេច សំរាប់ការអនុវត្តអោយបានជោគជ័យ ត្រូវបានបញ្ចប់ ។ ការរំពឹងទុកពីសំណាក់ប្រជាពលរដ្ឋ ត្រូវបានកើតមានឡើងរួចទៅហើយនៅក្នុងភូមិ ដោយហេតុនេះ នៅក្នុងកាលៈទេសៈបច្ចុប្បន្ន វាមានការលំបាកណាស់ នៅក្នុងការធានាធ្វើយ៉ាងណាអោយការរំពឹងទុកនេះ អាចលេចចេញជារូបរាងបាន ។

ការបង្កើយការងារអំពីក្របខ័ណ្ឌច្បាប់សំរាប់សម្បទានដីសង្គមកិច្ច គឺមានសារៈសំខាន់ជាទីបំផុត ។ កង្វះខាតនៅក្នុងក្របខ័ណ្ឌច្បាប់ ដែលបច្ចុប្បន្ននេះរារាំងដល់ការកំណត់នូវទីកន្លែងសមស្រប សំរាប់សម្បទានដីសង្គមកិច្ច ត្រូវការចាំបាច់រៀបចំអោយមាននៅនឹងកន្លែងអោយបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន ។ មានតែនៅពេលដែលក្របខ័ណ្ឌច្បាប់ទាំងនោះត្រូវបានរៀបចំរួចជាស្រេចតែប៉ុណ្ណោះ ទើបគំរោងសាកល្បងនានាអាចមានឱកាសសំរេចបានជោគជ័យ ។ ការបន្តការងារលើការរៀបចំអនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ និងសម្បទានសេដ្ឋកិច្ច ត្រូវការអោយមានការគាំទ្រ និងពន្លឿនល្បឿនបន្ថែម ។ ទោះជាយ៉ាងណាក៏ដោយ ក៏ត្រូវធានាអោយមានគុណភាពពីលើការពន្លឿនល្បឿនដែរ ។

ពេលវេលារហូតដល់ពេលដែលមានការចាប់ផ្តើមអនុវត្តកម្មវិធីនេះនៅក្នុងទំហំធំធេង ប្រព័ន្ធត្រួតពិនិត្យ និងវាយតំលៃត្រូវរៀបចំអោយរួចជាស្រេច ។ បទពិសោធន៍ដែលទទួលបានពីកម្មវិធីពិសេសនេះសំរាប់ចែករំលែកនៅក្នុងតំបន់ គួរត្រូវបានធ្វើការចងក្រង និងរៀបចំអោយមានសំរាប់ធ្វើការផ្សព្វផ្សាយ ។ ដំណើរការ និងផលប៉ះពាល់ គួរត្រូវបានធ្វើការវិភាគ សំរាប់ជាប្រយោជន៍ដល់ការកែតំរូវកម្មវិធីបន្ត ហើយប្រសិនបើទទួលបានជោគជ័យ និងមានភាពសមស្រប គួរធ្វើការសំរបសំរួលរៀបចំកម្មវិធីសិក្ខាសាលាដើម្បីចែករំលែកបទពិសោធន៍ នៅក្នុងតំបន់ផ្សេងៗទៀតនៃភូមិភាគអាស៊ី ។

# ឯកសារយោង

Auffer, Phillip; ភាពក្រីក្រនៅតំបន់ជនបទប្រទេសកម្ពុជា : ផលប៉ះពាល់នៃការបែងចែកដី និងជំរើសគោលនយោបាយនានា (សេចក្តីព្រាងឯកសារ) វ៉ាស៊ីនតោន ខែវិច្ឆិកា ឆ្នាំ២០០៣ ។

Biddulph, Robin; ការធ្វើអោយអ្នកក្រីក្រកាន់តែអាចមើលឃើញ (តើដីទាំងអស់បាត់ទៅណា : ភាគ៤) ។ អុកស្វាមអង់គ្លេស ខែកញ្ញា ឆ្នាំ២០០២ ។

ស៊ីក បូរក្ស : ម្ចាស់កម្មសិទ្ធិដី ការលក់ដូរ និងនិន្នាការ (ការផ្តោតការយកចិត្តទុកដាក់) នៅប្រទេសកម្ពុជា : ការពិនិត្យឡើងវិញដំបូងលើទិន្នន័យដែលមានស្រាប់ និងទិន្នន័យគោលស្តីពីការអង្កេតនាពេលថ្មីៗ (សេចក្តីព្រាងឯកសារ១៦) វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវ ដើម្បីអភិវឌ្ឍន៍កម្ពុជា ខែកញ្ញា ឆ្នាំ២០០០ ។

Catalla, Rebecca, F. et al.; ការបែងចែកដីខ្នាតតូចនៅប្រទេសកម្ពុជា : មេរៀនពីករណីសិក្សាទាំងបី ខែវិច្ឆិកា ឆ្នាំ២០០១ ។

ចាន់ សុផល គីម សិដារ៉ា សាធី អាចារីយ៉ា : ដីធ្លី ជីវភាពរស់នៅនៅតំបន់ជនបទ និងសុវត្ថិភាពស្បៀងនៃប្រទេសកម្ពុជា : ទស្សនៈពីការអង្កេតពីមូលដ្ឋាន (សេចក្តីព្រាងឯកសារ២៤) វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ខែតុលា ឆ្នាំ២០០២ ។

ចាន់ សុផល សាធី អាចារីយ៉ា : បញ្ហាប្រឈមនៃជីវភាពរស់នៅនៅជនបទ : ទស្សនៈពីភូមិចំនួន៩ នៅក្នុងកម្ពុជា (សេចក្តីព្រាងឯកសារ២៥) ។ វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវ ដើម្បីអភិវឌ្ឍន៍កម្ពុជា ខែធ្នូ ឆ្នាំ២០០២ ។

ចាន់ សុផល ទេព សារ៉ាវី និងសាធី អាចារីយ៉ា : ប្លង់កម្មសិទ្ធិដីធ្លី នៅប្រទេសកម្ពុជា បច្ចុប្បន្នភាពទិន្នន័យ (សេចក្តីព្រាងឯកសារ១៩) ។ វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវ ដើម្បីអភិវឌ្ឍន៍កម្ពុជា ខែតុលា ឆ្នាំ២០០១ ។

ចាន់ សុផល ទេព សារ៉ាវី និងសាធី អាចារីយ៉ា : អន្តរកាលដីធ្លីនៅប្រទេសកម្ពុជា : ការវិភាគលើការចងក្រងឯកសារផ្ទេរកម្មសិទ្ធិ និងអន្តរកាល (សេចក្តីព្រាងឯកសារ២២) ។ វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ខែកក្កដា ឆ្នាំ២០០២ ។

Childress, Malcolm; វិស័យដីធ្លីប្រទេសកម្ពុជា ក្នុងសម័យអន្តរកាល : សំដៅឆ្ពោះទៅកាន់ការពង្រឹង និងការធ្វើប្រពលវប្បកម្មវិស័យកសិកម្ម ជលផល និងព្រៃឈើ និងការផ្តល់ការងារក្រៅពីកសិកម្ម សំរាប់អ្នកក្រីក្រ ខែតុលា ឆ្នាំ២០០៣ ។

ក្រុមប្រឹក្សាគោលនយោបាយដីធ្លី : ឯកសារគោលនយោបាយស្តីពីសម្បទានដីសង្គមកិច្ច នៅក្នុងព្រះរាជាណាចក្រកម្ពុជា ខែមីនា ឆ្នាំ២០០៣ ។

Dasgupta, Susmita, Deichmann, Uwe, Meinsner, Craig, Wheeler, David; ទំនាក់ទំនងគ្នារវាងបរិស្ថាន-ភាពក្រីក្រនៅក្នុងប្រទេសកម្ពុជា សាធារណៈរដ្ឋប្រជាមានិតឡាវ និងវៀតណាម ធនាគារពិភពលោក វ៉ាស៊ីនតោន ឆ្នាំ២០០២ ។

Groetschel, Andreas; ប្រទេសកម្ពុជា : ការវាយតំលៃពីសក្តានុពលផលប៉ះពាល់របស់សម្បទានដីសង្គមកិច្ច (ឯកសារទស្សនៈទានស្តីពីការវិភាគផលប៉ះពាល់លើភាពក្រីក្រ និងសង្គម) វ៉ាស៊ីនតោន ខែកក្កដា ឆ្នាំ២០០៣ ។

McNaughton, Andrew ឆេវ សុផាណា អ៊ីវ ភីរម្យ Hundley, Curtis : ប្រទេសកម្ពុជា កសិ-អាជីវកម្ម និងការអង្កេតលើគំរូការរៀបចំអ្នកកាន់កាប់ខ្នាតតូច ខែតុលា ឆ្នាំ២០០៣ ។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ : សេចក្តីសំរេចស្តីពីការបង្កើតតួនាទីផ្នែក និងក្រុមការងាររបស់អគ្គលេខាធិការដ្ឋាននៃសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ (ឯកសារជាភាសារអង់គ្លេស) ឆ្នាំ២០០៣ ។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ : សេចក្តីសំរេចស្តីពីការបង្កើតគណៈកម្មាធិការអនុវត្តអនុក្រឹត្យសម្បទានដីសង្គមកិច្ច (ឯកសារជាភាសារអង់គ្លេស) ឆ្នាំ២០០៣ ។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ : សេចក្តីសំរេចស្តីពីការបង្កើតបទបញ្ជាផ្ទៃក្នុងសំរាប់ការប្រតិបត្តិការរបស់ក្រុមការងារ (ឯកសារជាភាសារអង់គ្លេស) ឆ្នាំ២០០៣ ។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ : សេចក្តីសំរេចស្តីពីការប្រគល់តួនាទីបន្ថែមទៅដល់មន្ត្រីនានា ដើម្បីជួយការងារនៅក្នុងអគ្គលេខាធិការដ្ឋាននៃសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ (ឯកសារជាភាសារអង់គ្លេស) ឆ្នាំ២០០៣ ។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ : ប្រកាសស្តីពីគោលការណ៍ណែនាំ សំរាប់ការអនុវត្តអនុក្រឹត្យសម្បទានដីសង្គមកិច្ច (ឯកសារជាភាសារអង់គ្លេស) ខែវិច្ឆិកា ឆ្នាំ២០០៣ ។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ : ការតែងតាំងគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង (ឯកសារជាភាសារអង់គ្លេស) ឆ្នាំ២០០៣ ។

Oberndorf, Robert B.; ការវិភាគពីច្បាប់ និងបទបញ្ជានានា ដែលមានឥទ្ធិពលលើការចូលរួមរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ នៅក្នុងរៀបចំផែនការប្រើប្រាស់ដីធ្លីដោយមានការចូលរួម/ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន នៅក្នុងប្រទេសកម្ពុជា (សេចក្តីព្រាងឯកសារ) ខែឧសភា ឆ្នាំ២០០៣ ។

អង្គការអុកស្វាមចក្រភពអង់គ្លេស : ការរៀនសូត្រមេរៀនពីកម្មវិធីតាំងទីលំនៅឡើងវិញ នៅក្នុងប្រទេសកម្ពុជា : ការរួមចំណែកដល់ការអភិវឌ្ឍច្បាប់សម្បទានដីសង្គមកិច្ចសមស្រប មិនមានកាលបរិច្ឆេទ ។

Ramamurthy, B, ស៊ីក បូរក្ស Per Ronnas និង សុខ ហាច ប្រទេសកម្ពុជា ១៩៩៩-២០០០ : ដី ពលកម្ម និង ជីវភាពរស់នៅនៅជនបទ (សេចក្តីព្រាងឯកសារ២១) វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កម្ពុជា ខែធ្នូ ឆ្នាំ២០០៣ ។

រាជរដ្ឋាភិបាលកម្ពុជា : អនុក្រឹត្យស្តីពីសហគមន៍ព្រៃឈើ (ឯកសារផ្លូវការចុងក្រោយ ជាភាសាអង់គ្លេស) ខែកុម្ភៈ ឆ្នាំ២០០៣ ។

រាជរដ្ឋាភិបាលកម្ពុជា : អនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច (ឯកសារជាភាសាអង់គ្លេស) ខែមីនា ឆ្នាំ២០០៣ ។

រាជរដ្ឋាភិបាលកម្ពុជា : អនុក្រឹត្យស្តីពីការតែងតាំងគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ (ឯកសារជាភាសាអង់គ្លេស) ឆ្នាំ២០០៣ ។

សូ សុវណ្ណារិទ្ធ, រឿល សុភាព, អ៊ុច យុតី, ស៊ី រ័ត្នមុនី, Ballard, B. និង S. Acharya; ការវាយតំលៃសង្គមនៃដីធ្លីនៅប្រទេសកម្ពុជា : ការសិក្សានៅមូលដ្ឋាន (សេចក្តីព្រាងឯកសារ២០) វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍកម្ពុជា ខែវិច្ឆិកា ឆ្នាំ២០០១ ។

Tolentiano, VBJ; ការវាយតំលៃការអនុវត្តនៃការផ្តួចផ្តើមគោលនយោបាយជ្រើសរើស និងកំណែទំរង់មួយចំនួន នៅក្នុងប្រទេសកម្ពុជា (សេចក្តីព្រាងឯកសារដែលបានពិនិត្យកែតំរូវឡើងវិញរួច) ធនាគារអភិវឌ្ឍន៍អាស៊ី ខែកញ្ញា ឆ្នាំ២០០៣ ។

Williams, Shaun; កម្មសិទ្ធិដីធ្លី និងលទ្ធភាពក្នុងការប្រើប្រាស់នៅក្នុងប្រទេសកម្ពុជា (តើដីបាត់ទៅណាអស់ហើយ : ភាគ១) អុកស្វាមអង់គ្លេស ខែឧសភា ឆ្នាំ១៩៩៩ ។

## សេចក្តីសង្ខេប និងបទបង្ហាញនានា

គោលការណ៍ណែនាំស្តីពីដំណើរការកសាងផែនការឃុំ សង្កាត់ ។

Kirk, Michael; ដីសេដ្ឋកិច្ចរដ្ឋ នៅក្នុងប្រទេសកម្ពុជា ខែកញ្ញា ឆ្នាំ២០០៣ ។

គំរោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី : របាយការណ៍ប្រចាំឆ្នាំ ២០០២/២០០៣ ។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ គំរោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី : យុទ្ធសាស្ត្រ និងលទ្ធផលសំរេចបាន ខែធ្នូ ឆ្នាំ២០០៣ ។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ : ការអនុវត្តសាកល្បងសម្បទានដីសង្គមកិច្ច (នៅក្នុងខេត្តកំពត កំពង់ស្ពឺ និងបាត់ដំបង) (សេចក្ដីព្រាងឯកសារការរៀបចំផែនការ) ។

Oberndorf, Robert B.; ទិដ្ឋភាពទូទៅនៃការធ្វើចំណាត់ថ្នាក់ដីធ្លី និងព្រៃឈើ នៅក្រោមច្បាប់ភូមិបាល ។

## ឯកសារស្តីពីការវិភាគផលប៉ះពាល់ទៅលើភាពក្រីក្រ និងសង្គម (PSIA)

Biddulph, Robin, ការវាយតំលៃផលប៉ះពាល់លើភាពក្រីក្រ និងសង្គម នៃសម្បទានដីសង្គមកិច្ច នៅប្រទេសកម្ពុជា : ការវាយតំលៃភាពគ្មានដីធ្លី អុកស្វាមអង់គ្លេស ខែកុម្ភៈ ឆ្នាំ២០០៤ ។

វិទ្យាស្ថានកសិ-អាជីវកម្មកម្ពុជា : ការវាយតំលៃផលប៉ះពាល់ទៅលើភាពក្រីក្រ និងសង្គម នៃកម្មវិធីសម្បទានដីសង្គមកិច្ចដែលបានគ្រោង ខែមីនា ឆ្នាំ២០០៤ ។

អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ : ការវាយតំលៃសក្ដានុពលដីទំនេរ នៅក្នុងឃុំ៤០ ក្នុងខេត្តទាំង៨ (ឯកសារបង្ហាញនៅក្នុងសិក្ខាសាលាជាតិស្ដីពីលទ្ធផលនៃការវាយតំលៃផលប៉ះពាល់លើភាពក្រីក្រ និងសង្គម នាខែឧសភា ឆ្នាំ២០០៤) ខែឧសភា ឆ្នាំ២០០៤ ។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អគ្គលេខាធិការដ្ឋាននៃសម្បទានដីសង្គមកិច្ច GTZ-LMAP : គំរោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី អុកស្វាមអង់គ្លេស ព្រះរាជាណាចក្រកម្ពុជា ធនាគារពិភពលោក EASRD, សក្ដានុពលផលប៉ះពាល់ទៅលើភាពក្រីក្រ និងសង្គមនៃសំណើកម្មវិធីសម្បទានដីសង្គមកិច្ចរបស់ប្រទេសកម្ពុជា-បទបង្ហាញ និងការពិភាក្សាលើលទ្ធផល និងអនុសាសន៍ពីការវាយតំលៃផលប៉ះពាល់លើភាពក្រីក្រ និងសង្គម របាយការណ៍សិក្ខាសាលា ខែមិថុនា ឆ្នាំ២០០៤ ។

# សេចក្ដីបន្ថែម

## សេចក្តីបន្ថែមទី១ : ទិន្នន័យអំពីភាពគ្មានដី

### តារាងទី១

### ការប្រៀបធៀបទិន្នន័យវិភាគផលប៉ះពាល់ទៅលើភាពក្រីក្រ និងសង្គម ជាមួយនឹងការអង្កេតសេដ្ឋកិច្ច-សង្គមកិច្ច (SES) ឆ្នាំ១៩៩៩

| ខេត្ត | តំបន់ | គ្រួសារ | គ្រួសារគ្មានដី | %គ្រួសារគ្មានដី | %គ្រួសារគ្មានដី SES ឆ្នាំ១៩៩៩ | ចាកចេញដោយសារគ្មានដី | %ចាកចេញដោយសារគ្មានដី | សរុបគ្រួសារដែលស្ត្រីជាមេគ្រួសារ | គ្រួសារដែលស្ត្រីជាមេគ្រួសារគ្មានដី | %គ្រួសារដែលស្ត្រីជាមេគ្រួសារគ្មានដី |
|---|---|---|---|---|---|---|---|---|---|---|
| ព្រៃវែង | មេគង្គ | 3.449 | 337 | **9,8** | 8,9 | 183 | 5,3 | 574 | 110 | **19,2** |
| កំពង់ចាម | | 3.120 | 235 | **7,5** | 14,2 | 85 | 2,7 | 450 | 89 | **22,1** |
| បាត់ដំបង | ទន្លេសាប | 3.561 | 906 | **25,4** | 28,8 | 220 | 6,2 | 557 | 204 | **42,2** |
| ឧត្តរមានជ័យ | | 1.395 | 71 | **5,1** | 15,8 | 26 | 1,9 | 262 | 34 | **16,9** |
| ព្រះវិហារ | ខ្ពង់រាប | 1.880 | 81 | **4,4** | 2,4 | 49 | 2,6 | 289 | 31 | **17,7** |
| ស្ទឹងត្រែង | | 2.422 | 287 | **11,9** | 5,0 | 14 | 0,6 | 291 | 48 | **21,1** |
| កំពត | ឆ្នេរសមុទ្រ | 3.691 | 165 | **4,5** | 5,3 | 78 | 2,1 | 852 | 45 | **7,9** |
| កោះកុង | | 2.675 | 559 | **20,9** | 37,9 | 840 | 31,4 | 298 | 114 | **34,5** |
| សរុប | | **22.193** | **2.641** | **11,9** | **15,8*** | **1.495** | **6,74** | **3.573** | **675** | **18,9** |

* តួលេខនេះគឺជាមធ្យមភាពទូទាំងប្រទេស តាមការអង្កេតសេដ្ឋកិច្ច-សង្គមកិច្ច ឆ្នាំ១៩៩៩ សំរាប់តំបន់ជនបទ ហើយមិនមែនសំរាប់ខេត្តទាំង៨ នៅក្នុងការវិភាគផលប៉ះពាល់ទៅលើសង្គម និងភាពក្រីក្រនោះទេ ។

### តារាងទី២ : មូលហេតុនៃការគ្មានដីធ្លី

| មូលហេតុសំខាន់ៗដែលរាយការណ៍ដោយសមាជិកគ្រួសារដែលបានសំភាសន៍ | ចំនួនគ្រួសារ | ភាគរយគ្រួសារដែលមិនធ្លាប់មានដីធ្លីសោះ |
|---|---|---|
| រៀបអាពាហ៍ពិពាហ៍ថ្មីថ្មោង | 709 | 33,54% |
| ផ្លាស់ប្តូរភូមិ | 706 | 33,40% |
| ភូមិនៅលើទឹក[១៦] | 283 | 13,39% |
| វិលត្រឡប់ពីជំរុំជនភៀសខ្លួន | 106 | 5,01% |
| រស់នៅលើទូក | 99 | 4,68% |
| វិលត្រឡប់ពីបំរើកងទ័ព | 31 | 1,47% |
| វិលត្រឡប់ពីជនផ្លាស់ទីតាំងនៅក្នុងប្រទេស (IDP) | 7 | 0,33% |
| ផ្សេងៗទៀត | 173 | 8,18% |
| **សរុប** | **2.114** | **100,00%** |

## តារាងទី៣ ៖ ការគ្មានដីធ្លីតាមភូមិ

### ខេត្តបាត់ដំបង

| លេខ កូដភូមិ | ឈ្មោះភូមិ | គ្រួសារ | គ្រួសារ គ្មានដីធ្លី | % គ្រួសារ គ្មានដីធ្លី | គ្រួសារដែល ស្ត្រីជាមេ គ្រួសារ | គ្រួសារដែលស្ត្រី ជាមេគ្រួសារ គ្មានដីធ្លី | %គ្រួសារដែល ស្ត្រីជាមេគ្រួ សារគ្មានដីធ្លី |
|---|---|---|---|---|---|---|---|
| 2010501 | រូង | 194 | 39 | 20,10 | 40 | 12 | 30,00 |
| 2010504 | ថ្កូវ | 199 | 33 | 16,58 | 31 | 12 | 38,71 |
| 2010506 | ចង្ហូរស្វាយ | 129 | 30 | 23,26 | 16 | 8 | 50,00 |
| 2010805 | តាង៉ែន | 591 | 17 | 2,88 | 80 | 5 | 6,25 |
| 2010806 | ព្រៃផ្ដៅ | 247 | 77 | 31,17 | 26 | 16 | 61,54 |
| 2010809 | ដង្កត់ធ្នង់ | 226 | 42 | 18,58 | 24 | 4 | 16,67 |
| 2040304 | ដង្កោ | 133 | 106 | 79,70 | 21 | 18 | 85,71 |
| 2040305 | រាមសេនា | 170 | 68 | 40,00 | 27 | 16 | 59,26 |
| 2040306 | ដូនអោក | 126 | 10 | 7,94 | 23 | 5 | 21,74 |
| 2050601 | ព្រៃចាស់ | 226 | 122 | 53,98 | 42 | 31 | 73,81 |
| 2050603 | អន្លង់សណ្ដាន់ | 63 | 43 | 68,25 | 15 | 6 | 40,00 |
| 2050605 | បាក់ព្រា | 255 | 208 | 81,57 | 44 | 44 | 100,00 |
| 2080501 | ព្រៃចែក | 232 | 33 | 14,22 | 44 | 7 | 15,91 |
| 2080504 | កំពង់ព្រះ | 337 | 24 | 7,12 | 49 | 8 | 16,33 |
| 2080506 | ស្រះកែវ | 433 | 54 | 12,47 | 75 | 12 | 16,00 |
| **សរុប** | | **3.561** | **906** | **25,44** | **557** | **204** | **36,62** |

**ខេត្តកំពត**

| លេខ កូដភូមិ | ឈ្មោះភូមិ | គ្រួសារ | គ្រួសារ គ្មានដីធ្លី | % គ្រួសារ គ្មានដីធ្លី | គ្រួសារដែល ស្ត្រីជាមេ គ្រួសារ | គ្រួសារដែលស្ត្រី ជាមេគ្រួសារ គ្មានដីធ្លី | %គ្រួសារដែល ស្ត្រីជាមេគ្រួ សារគ្មានដីធ្លី |
|---|---|---|---|---|---|---|---|
| 7030401 | ក្រសាំង | 457 | 5 | 1,09 | 134 | 1 | 0,75 |
| 7030402 | ឈើទាល | 555 | 12 | 2,16 | 215 | 7 | 3,26 |
| 7030404 | ក្រហូង | 239 | 10 | 4,18 | 90 | 4 | 4,44 |
| 7030901 | កោះស្លា | 150 | 4 | 2,67 | 26 | 2 | 7,69 |
| 7030905 | ស្រែលាវ | 256 | 1 | 0,39 | 19 | 0 | 0,00 |
| 7030910 | ព្រៃពាយ | 150 | 0 | 0,00 | 24 | 0 | 0,00 |
| 7050102 | អង្គរពាក់ | 183 | 3 | 1,64 | 46 | 1 | 2,17 |
| 7050104 | ត្រពាំងឫស្សី | 153 | 2 | 1,31 | 43 | 0 | 0,00 |
| 7050105 | ក្រាំងអំពៅ | 116 | 3 | 2,59 | 22 | 1 | 4,55 |
| 7060902 | តៀមកន្ទោរ | 68 | 2 | 2,94 | 27 | 2 | 7,41 |
| 7060905 | បឹងធំខាងលិច | 241 | 12 | 4,98 | 57 | 3 | 5,26 |
| 7060906 | បឹងធំខាងកើត | 241 | 10 | 4,15 | 67 | 4 | 5,97 |
| 7071102 | ព្រែកក្រែង | 256 | 10 | 3,91 | 30 | 1 | 3,33 |
| 7071103 | ព្រែកត្នោត | 276 | 21 | 7,61 | 22 | 9 | 40,91 |
| 7071104 | ចង្ហោន | 350 | 70 | 20,00 | 30 | 10 | 33,33 |
| **សរុប** | | **3.691** | **165** | **4,47** | **852** | **45** | **5,28** |

## ខេត្តកំពង់ចាម

| លេខ កូដភូមិ | ឈ្មោះភូមិ | គ្រួសារ | គ្រួសារ គ្មានដីធ្លី | % គ្រួសារ គ្មានដីធ្លី | គ្រួសារដែល ស្ត្រីជាមេ គ្រួសារ | គ្រួសារដែលស្ត្រី ជាមេគ្រួសារ គ្មានដីធ្លី | %គ្រួសារដែល ស្ត្រីជាមេគ្រួ សារគ្មានដីធ្លី |
|---|---|---|---|---|---|---|---|
| 3030301 | ផ្តៅជុំលិច | 469 | 24 | 5,12 | 48 | 14 | 29,17 |
| 3030303 | ឈើទាល | 236 | 27 | 11,44 | 38 | 8 | 21,05 |
| 3030304 | ចាំនាង | 214 | 5 | 2,34 | 34 | 2 | 5,88 |
| 3080206 | ភូមិ ៦ | 171 | 5 | 2,92 | 42 | 2 | 4,76 |
| 3080212 | ភូមិ ១២ | 117 | 13 | 11,11 | 17 | 4 | 23,53 |
| 3080213 | ភូមិ ១៣ | 323 | 31 | 9,60 | 53 | 22 | 41,51 |
| 3090301 | ភូមិ ១ | 272 | 16 | 5,88 | 40 | 1 | 2,50 |
| 3090302 | ភូមិ ២ | 204 | 15 | 7,35 | 24 | 5 | 20,83 |
| 3090306 | ភូមិ ៦ | 375 | 27 | 7,20 | 17 | 6 | 35,29 |
| 3120402 | បុស្សខ្មែរ | 61 | 12 | 19,67 | 7 | 5 | 71,43 |
| 3120404 | វាល | 59 | 16 | 27,12 | 11 | 2 | 18,18 |
| 3120413 | ទួលចំការ | 151 | 14 | 9,27 | 45 | 9 | 20,00 |
| 3131405 | សំរោង | 181 | 5 | 2,76 | 33 | 3 | 9,09 |
| 3131408 | ទ្រមុខទី ១ | 126 | 9 | 7,14 | 16 | 2 | 12,50 |
| 3131410 | ដូង | 161 | 16 | 9,94 | 25 | 4 | 16,00 |
| **សរុប** | | **3.120** | **235** | **7,53** | **450** | **89** | **19,78** |

## ខេត្តកោះកុង

| លេខកូដភូមិ | ឈ្មោះភូមិ | គ្រួសារ | គ្រួសារគ្មានដីធ្លី | % គ្រួសារគ្មានដីធ្លី | គ្រួសារដែលស្ត្រីជាមេគ្រួសារ | គ្រួសារដែលស្ត្រីជាមេគ្រួសារគ្មានដីធ្លី | %គ្រួសារដែលស្ត្រីជាមេគ្រួសារគ្មានដីធ្លី |
|---|---|---|---|---|---|---|---|
| 9030201 | ភូមិទី១ | 237 | 102 | 43,04 | 25 | 20 | 80,00 |
| 9030202 | ភូមិទី២ | 83 | 61 | 73,49 | 7 | 5 | 71,43 |
| 9030203 | កោះស្រឡៅ | 310 | 38 | 12,26 | 31 | 13 | 41,94 |
| 9040301 | ស្ទឹងវែង | 353 | 96 | 27,20 | 24 | 16 | 66,67 |
| 9040302 | ព្រែកស្វាយ | 117 | 43 | 36,75 | 9 | 9 | 100,00 |
| 9060101 | អូរជ្រៅ | 458 | 80 | 17,47 | 52 | 20 | 38,46 |
| 9060102 | បឹងព្រាវ | 262 | 14 | 5,34 | 37 | 4 | 10,81 |
| 9060103 | ជ្រោយ | 172 | 20 | 11,63 | 19 | 5 | 26,32 |
| 9060104 | ផ្លោង | 82 | 5 | 6,10 | 13 | 3 | 23,08 |
| 9060105 | សាលាម្នាង | 245 | 19 | 7,76 | 25 | 1 | 4,00 |
| 9060107 | ទឹកប៉ោង | 129 | 70 | 54,26 | 35 | 17 | 48,57 |
| 9070401 | ព្រែកស្វាយ | 44 | 0 | 0,00 | 6 | 0 | 0,00 |
| 9070402 | កោះ | 26 | 0 | 0,00 | 6 | 0 | 0,00 |
| 9070403 | គគីរជ្រៃ | 91 | 7 | 7,69 | 3 | 1 | 33,33 |
| 9070404 | ត្រពាំងឈើត្រាវ | 66 | 4 | 6,06 | 6 | 0 | 0,00 |
| **សរុប** | | **2.675** | **559** | **20,90** | **298** | **114** | **38,26** |

## ខេត្តឧត្តរមានជ័យ

| លេខ កូដភូមិ | ឈ្មោះភូមិ | គ្រួសារ | គ្រួសារ គ្មានដីធ្លី | % គ្រួសារ គ្មានដីធ្លី | គ្រួសារដែល ស្ត្រីជាមេ គ្រួសារ | គ្រួសារដែលស្ត្រី ជាមេគ្រួសារ គ្មានដីធ្លី | %គ្រួសារដែល ស្ត្រីជាមេគ្រួ សារគ្មានដីធ្លី |
|---|---|---|---|---|---|---|---|
| 22020301 | គោកខ្ពស់ | 132 | 12 | 9,09 | 20 | 5 | 25,00 |
| 22020305 | ទន្លេស | 85 | 1 | 1,18 | 7 | 1 | 14,29 |
| 22020309 | ស្រះស្រង់ | 61 | 4 | 6,56 | 6 | 2 | 33,33 |
| 22030306 | រលំវែង | 154 | 4 | 2,60 | 83 | 4 | 4,82 |
| 22040201 | បុស្បូវ | 187 | 9 | 4,81 | 39 | 4 | 10,26 |
| 22040202 | ក្រសាំង | 175 | 5 | 2,86 | 14 | 3 | 21,43 |
| 22040206 | ប្រាសាទ | 98 | 12 | 12,24 | 14 | 5 | 35,71 |
| 22222221 | សំបួរ | 30 | 2 | 6,67 | 5 | 1 | 20,00 |
| 22222222 | គោកសំរេច | 112 | 4 | 3,57 | 18 | 3 | 16,67 |
| 22222223 | ចេកក្បួ | 80 | 7 | 8,75 | 8 | 2 | 25,00 |
| 22222224 | ទួលប្រសើរ | 66 | 4 | 6,06 | 8 | 3 | 37,50 |
| 22222225 | ផ្អាវ | 36 | 0 | 0,00 | 19 | 0 | 0,00 |
| 22222226 | មានជ័យ | 26 | 1 | 3,85 | 0 | 0 | #DIV/0! |
| 22222227 | ថ្កូវ | 74 | 0 | 0,00 | 10 | 0 | 0,00 |
| 22222228 | អូរជីក | 79 | 6 | 7,59 | 11 | 1 | 9,09 |
| **សរុប** | | **1.395** | **71** | **5,09** | **262** | **34** | **12,98** |

## ខេត្តព្រះវិហារ

| លេខកូដភូមិ | ឈ្មោះភូមិ | គ្រួសារ | គ្រួសារគ្មានដីធ្លី | % គ្រួសារគ្មានដីធ្លី | គ្រួសារដែលស្ត្រីជាមេគ្រួសារ | គ្រួសារដែលស្ត្រីជាមេគ្រួសារគ្មានដីធ្លី | %គ្រួសារដែលស្ត្រីជាមេគ្រួសារគ្មានដីធ្លី |
|---|---|---|---|---|---|---|---|
| 13040501 | ឈូក | 141 | 17 | 12,06 | 32 | 9 | 28,13 |
| 13040503 | បរិបូណ៌ | 172 | 3 | 1,74 | 66 | 1 | 1,52 |
| 13040504 | ក្តាក់ | 240 | 4 | 1,67 | 36 | 1 | 2,78 |
| 13050201 | ដំណាក់ចិន | 56 | 2 | 3,57 | 6 | 1 | 16,67 |
| 13050203 | ចំបក់ផ្អែម | 71 | 6 | 8,45 | 7 | 1 | 14,29 |
| 13050204 | ត្រពាំងឫស្សី | 70 | 3 | 4,29 | 13 | 0 | 0,00 |
| 13050501 | ប៉ាលហាល | 97 | 0 | 0,00 | 8 | 0 | 0,00 |
| 13050502 | បុស្ស | 125 | 2 | 1,60 | 13 | 0 | 0,00 |
| 13050503 | ដូង | 145 | 9 | 6,21 | 6 | 2 | 33,33 |
| 13051001 | ថ្នល់កោង | 234 | 7 | 2,99 | 35 | 2 | 5,71 |
| 13051003 | គោកអំពិល | 69 | 6 | 8,70 | 2 | 2 | 100,00 |
| 13051004 | ឪឡឹក | 163 | 9 | 5,52 | 23 | 4 | 17,39 |
| 13060401 | តាបស | 212 | 7 | 3,30 | 30 | 5 | 16,67 |
| 13060404 | ត្រពាំងធ្លក | 40 | 1 | 2,50 | 3 | 0 | 0,00 |
| 13060405 | ត្រពាំងខ្ទែង | 45 | 5 | 11,11 | 9 | 3 | 33,33 |
| **សរុប** | | **1.880** | **81** | **4,31** | **289** | **31** | **10,73** |

## តារាងទី៤

## មូលហេតុសំខាន់ៗនៃការបាត់បង់ដីធ្លី

| មូលហេតុសំខាន់ៗដែលរាយការណ៍ ដោយសមាជិកគ្រួសារដែលបានសំភាសន៍ | ចំនួនគ្រួសារ | ភាគរយគ្រួសារដែល បានបាត់បង់ដីធ្លីរបស់ខ្លួន |
|---|---|---|
| ជម្ងឺ | 318 | 60% |
| ខ្វះស្បៀងអាហារ | 56 | 11% |
| ការជំពាក់បំណុលគេ | 40 | 8% |
| ភាពក្រីក្រ | 31 | 6% |
| ការលែងលះប្តីប្រពន្ធ | 14 | 3% |
| ចែកដីធ្លីអោយទៅកូនៗ | 12 | 2% |
| ការចំណាយក្នុងពិធីបុណ្យសព ឬរៀបអាពាហ៍ពិពាហ៍ | 5 | 1% |
| ការខាតបង់ក្នុងការរកស៊ី | 5 | 1% |
| ផ្សេងៗទៀត | 46 | 9% |
| **សរុប** | **527** | **101%** |

## តារាងទី៥

## ទំហំ ឬវិសាលភាពនៃការខ្វះខាតដីធ្លី

| ខេត្ត | តំបន់ | គ្រួសារ | គ្រួសារខ្វះដីធ្លី | %គ្រួសារខ្វះដីធ្លី | ចាកចោលភូមិដោយសារខ្វះដីធ្លី | %ចាកចោលភូមិដោយសារខ្វះដីធ្លី [១៧] | សរុបគ្រួសារដែលស្ត្រីជាមេគ្រួសារ | គ្រួសារដែលស្ត្រីជាមេគ្រួសារខ្វះដីធ្លី | %គ្រួសារដែលស្ត្រីជាមេគ្រួសារខ្វះដីធ្លី |
|---|---|---|---|---|---|---|---|---|---|
| ព្រៃវែង | មេគង្គ | 3.449 | 150 | **4,3** | 135 | 4,72 | 574 | 45 | **7,8** |
| កំពង់ចាម | | 3.120 | 128 | **4,1** | 909 | 29,51 | 450 | 36 | **8,0** |
| បាត់ដំបង | ទន្លេសាប | 3.561 | 29 | **0,8** | 27 | 1,18 | 557 | 7 | **1,3** |
| ឧត្តរមានជ័យ | | 1.395 | 62 | **4,4** | 131 | 6,95 | 262 | 32 | **12,2** |
| ព្រះវិហារ | ខ្ពង់រាប | 1.880 | 218 | **11,6** | 45 | 3,61 | 289 | 57 | **19,8** |
| ស្ទឹងត្រែង | | 2.422 | 81 | **3,3** | 21 | 1,39 | 291 | 15 | **5,2** |
| កំពត | ឆ្នេរសមុទ្រ | 3.691 | 91 | **2,5** | 51 | 1,44 | 852 | 29 | **3,4** |
| កោះកុង | | 2.675 | 76 | **3,1** | 55 | 2,46 | 298 | 20 | **6,7** |
| **សរុប** | | **22.193** | **835** | **3,8** | **1.374** | **6,19%** | **3.573** | **241** | **6,7%** |

## តារាងទី៦

## មូលហេតុនៃការខ្វះខាតដីធ្លី

| មូលហេតុដែលបានរាយការណ៍ចំពោះការខ្វះខាតដីធ្លី | ចំនួន | ភាគរយ |
|---|---|---|
| មានដីធ្លីតិចតួចតាំងពីដំបូងមក | 211 | 25,27% |
| បានចែកដីធ្លីអោយកូនៗអស់ | 124 | 14,85% |
| ការរៀបអាពាហ៍ពិពាហ៍ថ្មី | 109 | 13,05% |
| ជម្ងឺ | 94 | 11,26% |
| ផ្លាស់ប្តូរភូមិ | 87 | 10,42% |
| ទទួលបានដីធ្លីតិចតួចពីឪពុក ម្តាយ | 69 | 8,26% |
| ភាពក្រីក្រ | 33 | 3,95% |
| កូនច្រើន | 25 | 2,99% |
| ការខ្វះខាតស្បៀងអាហារ | 23 | 2,75% |
| ការជំពាក់បំណុលគេ | 16 | 1,92% |
| មូលហេតុផ្សេងៗទៀត ចំពោះការបាត់បង់ដីធ្លី | 13 | 1,56% |
| វិលត្រឡប់ពីបំរើកងទ័ព | 5 | 0,60% |
| ការលែងលះប្តីប្រពន្ធ | 5 | 0,60% |
| ការខ្វះខាតសត្វពាហនៈជាកំលាំងអូសទាញ | 4 | 0,48% |
| ជនផ្លាស់ទីតាំងនៅក្នុងប្រទេស (IDP) | 3 | 0,36% |
| បរាជ័យក្នុងការចិញ្ចឹមសត្វ ឬមិនមានសត្វសំរាប់លក់ | 3 | 0,36% |
| ជនមាតុភូមិនិវត្តន៍ | 3 | 0,36% |
| ការសាងសង់ផ្ទះ ឬទិញដីភូមិសំរាប់សាងសង់ផ្ទះ | 2 | 0,24% |
| គ្រោះធម្មជាតិ | 2 | 0,24% |
| ការដកហូតដីធ្លីតាមផ្លូវច្បាប់ | 1 | 0,12% |
| គ្មានលទ្ធភាព ឬមធ្យោបាយទៅរកធនធានព្រៃឈើ | 1 | 0,12% |
| ពិធីបុណ្យសព ឬរៀបអាពាហ៍ពិពាហ៍ | 1 | 0,12% |
| គ្មានលទ្ធភាព ឬមធ្យោបាយទៅរកត្រី | 1 | 0,12% |
| **សរុប** | **835** | **100,00%** |

## តារាងទី៧

## ការប្រៀបធៀបគ្រួសារដែលមិនធ្លាប់មានដីធ្លីសោះ

| មូលហេតុ | ២០០០ | | ២០០៤ | |
|---|---|---|---|---|
| ការរៀបអាពាហ៍ពិពាហ៍ថ្មី | 405 | 36,2% | 534 | 36,5% |
| ជនមាតុភូមិនិវត្តន៍ | 385 | 34,4% | 324 | 22,1% |
| ការផ្លាស់ប្តូរភូមិ | 286 | 25,5% | 535 | 36,5% |
| មូលហេតុផ្សេងៗទៀត ចំពោះការមិនធ្លាប់មានដីធ្លីសោះ | 20 | 1,8% | 60 | 4,1% |
| វិលត្រឡប់ពីបំរើកងទ័ព | 17 | 1,5% | 8 | 0,5% |
| ជនផ្លាស់ទីតាំងនៅក្នុងប្រទេស | 6 | 0,5% | 3 | 0,2% |
| **សរុប** | **1.119** | **99,9%** | **1.464** | **99,9%** |

## តារាងទី៨

## អ្នកមានដីធ្លី ប៉ុន្តែបានបាត់បង់ដីធ្លីនោះ

| មូលហេតុ | ២០០០ | | ២០០៤ | |
|---|---|---|---|---|
| ជម្ងឺ | 442 | 47,2% | 541 | 62,1% |
| ខ្វះស្បៀងអាហារ | 180 | 19,2% | 147 | 16,9% |
| ការដកហូតដីធ្លីតាមផ្លូវច្បាប់ | 136 | 14,5% | 39 | 5,0% |
| ការជំពាក់បំណុលគេ | 38 | 4,0% | 70 | 8,0% |
| ការខាតបង់ក្នុងការរកស៊ី ឬផ្លាស់ប្តូរមុខរបររកស៊ី | 31 | 3,3% | 4 | 0,5% |
| មូលហេតុផ្សេងៗទៀត នៃការបាត់បង់ដីធ្លី | 72 | 7,7% | 54 | 6,2% |
| បានចែកដីធ្លីអោយទៅកូនៗអស់ | 22 | 2,3% | 10 | 1,1% |
| ពិធីបុណ្យសព ឬរៀបអាពាហ៍ពិពាហ៍ | 14 | 1,4% | 6 | 0,7% |
| **សរុប** | **1.059** | **99,6%** | **871** | **101,0%** |

## សេចក្តីបន្ថែមទី២ : ការសិក្សាទាយតំលៃនៅលើសក្តានុពលដីធ្លីដែលអាចរកបាន

## តារាងទី៩

## ការប៉ាន់ស្មានដីទំនេរ និងដីព្រៃដែលមានស្រាប់

(ការអង្កេតរបស់វិទ្យាស្ថានកសិ-អាជីវកម្មកម្ពុជា)

| | មធ្យមនព្វន្ត (ហិកតា) | គំរិតលំអៀង (ហិកតា) | កំហុសគំរូ (ហិកតា) |
|---|---|---|---|
| **មេគង្គ** | | | |
| • ដីមិនប្រើប្រាស់ | 0 | 0 | 0 |
| • ដីព្រៃ | 0 | 0 | 0 |
| **ទន្លេសាប** | | | |
| • ដីមិនប្រើប្រាស់ | 56,8 | 33,2 | 14,8 |
| • ដីព្រៃ | 1.290,3 | 2.563,5 | 534,5 |
| **ឆ្នេរសមុទ្រ** | | | |
| • ដីមិនប្រើប្រាស់ | 463,9 | 446,5 | 157,8 |
| • ដីព្រៃ | 4.526,1 | 10.188,6 | 2.172,2 |
| **ខ្ពង់រាប** | | | |
| • ដីមិនប្រើប្រាស់ | 1.301,8 | 1.392,6 | 296,9 |
| • ដីព្រៃ | 1.319,7 | 1.328,9 | 304,9 |
| **សរុប** | | | |
| • ដីមិនប្រើប្រាស់ | 932,4 | 1.221,3 | 206,4 |
| • ដីព្រៃ | 2.411,3 | 6.307,3 | 788,4 |

**កំណត់សំគាល់ :**

– មធ្យមនព្វន្ត : **Mean**

– គំរិតលំអៀង : **Standard Deviation**

– កំហុសគំរូ : **Standard Error**

# តារាងទី១០
# ដីដែលអាចរកបាន នៅក្នុងភូមិដែលបានធ្វើអង្កេត
# ប្រមូលព័ត៌មានអំពីភាពគ្មានដីធ្លី និងការអភិវឌ្ឍ

| | លេខកូដភូមិ | ឈ្មោះភូមិ | ខេត្ត | គ្រួសារ | គ្មានដី | ខ្វះដី | ដីទំនេរ |
|---|---|---|---|---|---|---|---|
| ឆ្នេរសមុទ្រ ភូមិ ១ | 7071103 | ព្រែកត្នោត | កំពត | 276 | 21 | 7 | 259 |
| ឆ្នេរសមុទ្រ ភូមិ ២ | 7060905 | បឹងធំខាងលិច | កំពត | 256 | 10 | 21 | 200 |
| ខ្ពង់រាប ភូមិ ១ | 19051102 | អូរត្រែល | ស្ទឹងត្រែង | 240 | 25 | 9 | 110 |
| ខ្ពង់រាប ភូមិ ២ | 19051104 | វាលខ្សាច់ | ស្ទឹងត្រែង | 122 | 19 | 5 | 1.212 |
| មេគង្គ ភូមិ ១ | 14090705 | បឹងស្នោ | ព្រៃវែង | 166 | 12 | 11 | 6 |
| មេគង្គ ភូមិ ២ | 14090704 | ធំ | ព្រៃវែង | 132 | 20 | 19 | 0 |
| ទន្លេសាប ភូមិ ១ | 2010501 | រូង | បាត់ដំបង | 194 | 39 | 4 | 291 |
| ទន្លេសាប ភូមិ ២ | 20108?? | ដង្កត់ធ្នង់ | បាត់ដំបង | 232 | 33 | 0 | 383 |

**សេចក្តីពន្យល់លំអិត :**

**តំបន់ក្បែរ-បរិស្ថានឆ្នេរសមុទ្រ**

១. ភូមិព្រែកត្នោត

- **ទីតាំងភូមិសាស្ត្រ**

ភូមិព្រែកត្នោតស្ថិតនៅតំបន់ឆ្នេរសមុទ្រ ក្នុងខេត្តកំពត នៅចន្លោះព្រៃមាត់ឆ្នេរ និងកូនភ្នំតូចៗ ដែលគ្របដណ្តប់ទៅដោយព្រែកម្តោត ។

- **ការចិញ្ចឹមជីវិតនៃគ្រួសារគ្មានដី និងគ្រួសារមានដីតិចតួច**

យោងតាមការប្រមូលព័ត៌មានអំពីភាពគ្មានដីធ្លី និងការអភិវឌ្ឍ ២០០៤/១២០ បានអោយដឹងថា ភូមិនេះមាន ២៧៦គ្រួសារ ដែលក្នុងនោះគ្រួសារគ្មានដីធ្លីមានចំនួន ២១គ្រួសារ និងគ្រួសារមានដីធ្លីតិចតួចមានចំនួន ៧គ្រួសារ ។ បើធ្វើការប្រៀបធៀបជាមួយភូមិភាគច្រើនផ្សេងទៀត នៅក្នុងការស្រាវជ្រាវនេះ អ្នកភូមិទាំងឡាយមានឱកាសល្អ ក្នុងការទាញយកផលពីធនធានធម្មជាតិ និងការផ្គត់ផ្គង់ខ្លួនឯងផ្ទាល់ ។ ពួកគេរកបង្គារ និងខ្យងពីសមុទ្រ រកវល្លិ និងអុសពីព្រៃដែលនៅជិតៗ ហើយពួកគេអាចស៊ីឈ្នួលអ្នកដែលមានដីនៅមូលដ្ឋាន ។

- **ដីទំនេរនៅក្នុងភូមិ**

ភូមិនេះបានរាយការណ៍ថា មានដីចំនួន ២៥៩.២ហិកតា ជាដីទំនេរគ្មានការកាន់កាប់ ។ ដីនេះស្ថិតនៅជើងភ្នំខាងក្រោយភូមិ ។ គ្រួសារមួយចំនួនបានកាប់ឆ្ការព្រៃលើភាគខ្លះនៃដីនេះរួចមកហើយ ។ អ្នកភូមិទាំងឡាយបានរាយការណ៍ថា ដីនេះអាចប្រើប្រាស់សំរាប់សម្បទានដីសង្គមកិច្ចបាន ប៉ុន្តែត្រូវមានផ្លូវសំរាប់ធ្វើដំណើរអោយបានសមរម្យ និងអណ្តូងទឹកផងដែរ ។

២. ភូមិបឹងធំខាងលិច

- **ទីតាំងភូមិសាស្ត្រ**

ភូមិបឹងធំខាងលិចស្ថិតនៅតាមបណ្តោយអាងទឹក នៅក្នុងតំបន់វាលស្រែនៃខេត្តកំពត ។

- **ការចិញ្ចឹមជីវិតនៃគ្រួសារគ្មានដី និងគ្រួសារមានដីតិចតួច**

យោងតាមការប្រមូលព័ត៌មានអំពីភាពគ្មានដីធ្លី និងការអភិវឌ្ឍ ២០០៤/១២០ បានអោយដឹងថា ភូមិនេះមាន២៥៦គ្រួសារ ដែលក្នុងនោះគ្រួសារគ្មានដីធ្លីមានចំនួន ១០គ្រួសារ និងគ្រួសារមានដីធ្លីតិចតួច មានចំនួន ២១គ្រួសារ ។

- **ដីទំនេរនៅក្នុងភូមិ**

ដីទំនេរចំនួន២០០ហិកតា ដែលបានរាយការណ៍ដោយប្រធានភូមិ នៅក្នុងអំឡុងពេលស្រាវជ្រាវប្រមូលព័ត៌មានអំពីភាពគ្មានដីធ្លី និងការអភិវឌ្ឍ គឺជាផ្នែកមួយនៃអាងស្តុកទឹកដែលលិចទឹកជារៀងរាល់ឆ្នាំ ។

ស្ថានភាពផ្នែកច្បាប់របស់ដីនេះ មិនច្បាស់លាស់ទេ : ប្រធានភូមិបានគិតថា វាប្រហែលជាដីសារណៈរបស់រដ្ឋ ដែលមិនអាចប្រើប្រាស់ជាឯកជនបានឡើយ ។ ទោះបីជាយ៉ាងណាក៏ដោយ គាត់ និង ក្រុមស្រាវជ្រាវបានគិតថា អាចសាងសង់ទំនប់នៅលើដីនេះ ដើម្បីធ្វើស្រូវប្រដេញទឹកនៅលើដីនេះ និងប្រមូលផលដំណាំពីដីនេះរៀងរាល់ឆ្នាំ ។

## តំបន់ក្បែរត្រ-បរិស្ថានមេគង្គ

### ៣. ភូមិអូរត្រែល

- **ទីតាំងភូមិសាស្ត្រ**

ភូមិអូរត្រែលស្ថិតនៅតាមដងទន្លេមេគង្គ នៅក្នុងតំបន់ក្បែរត្រ-បរិស្ថានខ្ពង់រាបនៃខេត្តស្ទឹងត្រែង ។

- **ការចិញ្ចឹមជីវិតនៃគ្រួសារគ្មានដី និងគ្រួសារមានដីតិចតួច**

យោងតាមការប្រមូលព័ត៌មានអំពីភាពគ្មានដីធ្លី និងការអភិវឌ្ឍ ២០០៤/១២០ បានអោយដឹងថា ភូមិមាន២៤០គ្រួសារ ដែលក្នុងនោះគ្រួសារគ្មានដីធ្លីមានចំនួន ២៥គ្រួសារ និងគ្រួសារមានដីធ្លីតិចតួច មានចំនួន ៩គ្រួសារ ។ គ្រួសារគ្មានដីធ្លី និងគ្រួសារមានដីធ្លីតិចតួច ពឹងផ្អែកទៅលើការយកជ័រទឹកពីដើមឈើធំៗ ។ នេះគឺជាប្រភពចំណូលសំខាន់របស់ពួកគេនៅរដូវប្រាំង ។ នៅរដូវវស្សាវិញ ចំណូលរបស់ពួកគេ គឺដើរស៊ីឈ្នួលធ្វើស្រែចំការអោយគេ ។ គ្រួសារទាំងមូលនិយមធ្វើដំណើរទាំងអស់គ្នា ទៅរកជ័រទឹក និងទៅធ្វើការងារតាមវាលស្រែចំការ ។ ដោយសារការបំផ្លាញព្រៃឈើ បច្ចុប្បន្ននេះ គ្រួសារមួយ ត្រូវចំណាយពេល២ ឬ៣ថ្ងៃ ដើម្បីប្រមូលជ័រទឹកក្នុងបរិមាណមួយ ដែលបរិមាណជ័រទឹកនេះពីមុនពួកគេចំណាយពេលតែមួយព្រឹកប៉ុណ្ណោះ ។ ជាទូទៅភូមិនេះមិនអាចទៅមកតាមរយៈរថយន្តបានទេ ទោះបីជាមានរថយន្តដឹកទំនិញមួយគ្រឿងបានទៅដល់ទីនោះ ដើម្បីប្រមូលទិញជ័រទឹកក៏ដោយ ។ អ្នកភូមិទាំងឡាយបានរកត្រីនៅតាមទន្លេមេគង្គ ទាំងសំរាប់ការហូបចុក និងទាំងសំរាប់យកលក់ដូរនៅទីផ្សារផងដែរ ។ គ្រួសារគ្មានដីធ្លី និងគ្រួសារមានដីធ្លីតិចតួចសុទ្ធតែអាចមានលទ្ធភាពដាំបន្លែមួយចំនួននៅតាមមាត់ច្រាំងទន្លេនៅរដូវប្រាំងបានផងដែរ ។ គ្រួសារនីមួយៗ ទទួលបានដីមួយក្បាលជាកន្លែងដែលពួកគេទៅងូតទឹក និងបោកគក់សំលៀកបំពាក់ ។ កន្លែងនេះហើយដែលពួកគេអាចមានលទ្ធភាពដាំបន្លែនានា ។ ទាំងគ្រួសារដែលមានទីលំនៅដ្ឋានយូរមកហើយ និងគ្រួសារដែលទើបនឹងមករស់នៅថ្មី សុទ្ធតែមានឱកាសដូចគ្នា ក្នុងការទទួលបានដីចំណែកនេះ ។

- **ដីទំនេរនៅក្នុងភូមិ**

ប្រធានភូមិនេះបានរាយការណ៍ថា ដីរបស់ភូមិមានទំនេរដែលគ្មានការកាន់កាប់ចំនួន ១១០ហិកតា ។ បើទោះបីជាយ៉ាងដូច្នេះក៏ដោយ នេះគឺជាដីព្រៃ ដែលរួមបញ្ចូលទាំងដីព្រៃចាស់មួយចំនួន ដូច្នេះ មិនអាចសន្មត់ថា ជាដីទំនេរ សំរាប់សម្បទានដីសង្គមកិច្ចបានទេ ។

## ៤. ភូមិវាលខ្សាច់

- **ទីតាំងភូមិសាស្ត្រ**

ភូមិវាលខ្សាច់នេះស្ថិតនៅលើកោះចំនួនបី និងនៅលើមាត់ច្រាំងម្ខាងទៀតនៃទន្លេមេគង្គ ត្រើយម្ខាងទល់មុខភូមិអូរត្រែល ។

- **ការចិញ្ចឹមជីវិតនៃគ្រួសារគ្មានដី និងគ្រួសារមានដីតិចតួច**

យោងតាមការប្រមូលព័ត៌មានអំពីភាពគ្មានដីធ្លី និងការអភិវឌ្ឍ ២០០៤/១២០ បានអោយដឹងថា ភូមិនេះមាន ១២២គ្រួសារ ដែលក្នុងនោះ គ្រួសារគ្មានដីធ្លីមានចំនួន ១៩គ្រួសារ និងគ្រួសារមានដីធ្លីតិចតួចមានចំនួន ៥គ្រួសារ ។ ប្រហាក់ប្រហែលនឹងភូមិអូរត្រែលដែរ គ្រួសារគ្មានដីធ្លី និងគ្រួសារមានដីធ្លីតិចតួចទាំងនេះ ពឹងផ្អែកយ៉ាងខ្លាំងទៅលើការរកជ័រទឹក និងរកត្រីក្នុងទន្លេមេគង្គ ។ ដោយសារតែភាពលំបាក និងការចំណាយប្រាក់ច្រើនទៅលើការឆ្លងទន្លេមេគង្គនេះ ពួកគេទិញ និងលក់របស់របរទាំងឡាយក្នុងតំលៃថោកៗ នៅទីផ្សារក្នុងមូលដ្ឋាន ដែលជួយដល់ការចិញ្ចឹមជីវិតបន្ថែមលើអ្វីដែលពួកគេអាចប្រមូល និងដាំដុះបាន ។ ប្រជាពលរដ្ឋនៅទីនេះ បានបង្ហាញអោយឃើញនូវភាពក្រីក្រយ៉ាងខ្លាំង ដែលភាពក្រីក្រនេះបានបង្ហាញឡើងតាមរយៈការខ្វះខាតនៃការស្លៀកពាក់ និងសម្ភារប្រើប្រាស់ក្នុងផ្ទះបាយ ។

- **ដីទំនេរនៅក្នុងភូមិ**

ប្រធានភូមិបានរាយការណ៍ថា នៅក្នុងភូមិមានដីទំនេរចំនួន ១.២១២ហិកតា ។ ដូចគ្នានេះដែរ ដីនេះគឺភាគច្រើនជាដីព្រៃ ។ បើតាមអ្នកស្រាវជ្រាវបានអោយដឹងថា ភូមិនេះ គួរត្រូវបានចាត់ទុកថាជាកន្លែងគួរអោយភ័យខ្លាច និងក្រីក្របំផុត (ដោយសារតែភាពដាច់ស្រយាល និងជម្ងឺគ្រុនចាញ់) សំរាប់គ្រួសារភាគច្រើនដែលពិចារណាថានឹងរស់នៅទីនេះ ដូច្នេះហើយពួកគេមិនគិតថា ដីនេះអាចសមស្រមសំរាប់សម្បទានដីសង្គមកិច្ចឡើយ ។

# តំបន់កេ្សត្រ-បរិស្ថានវាលទំនាប់លិចទឹកមេគង្គ

## ៥. ភូមិបឹងស្នោ

- **ទីតាំងភូមិសាស្ត្រ**

ភូមិបឹងស្នោស្ថិតនៅផ្នែកខាងក្រោមនៃវាលទំនាបលិចទឹកមេគង្គ នៅក្នុងខេត្តព្រៃវែង ដែលលិចទឹកទាំងស្រុងនៅរដូវវស្សា មានន័យថា ក្នុងរដូវនេះប្រជាពលរដ្ឋធ្វើដំណើរពីផ្ទះមួយ ទៅផ្ទះមួយតាមរយៈទូក ។ ភូមិនេះស្ថិតនៅយ៉ាងឆ្ងាយណាស់ពីតំបន់ព្រៃឈើ ពួកគេមិនបាន ប្រើប្រាស់អុសសំរាប់ចំអិនអាហារទេ ពួកគេចូលចិត្តប្រើលាមកគោ ក្របីក្រៀមជាជំនួស ក្នុងការចំអិនអាហារ ។

- **ការចិញ្ចឹមជីវិតនៃគ្រួសារគ្មានដី និងគ្រួសារមានដីតិចតួច**

  យោងតាមការប្រមូលព័ត៌មានអំពីភាពគ្មានដីធ្លី និងការអភិវឌ្ឍ ២០០៤/១២០ បានអោយដឹងថា ភូមិនេះមាន ១៦៦គ្រួសារ ដែលក្នុងនោះគ្រួសារគ្មានដីធ្លីមានចំនួន ១២គ្រួសារ និងគ្រួសារមានដីធ្លីតិចតួចមានចំនួន ១១គ្រួសារ ។ ពួកគេស៊ីឈ្នួលគេ ជាពិសេស នៅរដូវដកស្ទូង និងច្រូតកាត់ ។ បុរសៗតែងតែស៊ីឈ្នួលលីសែង នៅកំពង់ចម្លងអ្នកលឿង ។ នារីៗដើររកវល្លិ និងត្បាញធ្វើជាកន្ត្រកយកទៅលក់ ។

- **ដីទំនេរនៅក្នុងភូមិ**

  យោងតាមការប្រមូលព័ត៌មានអំពីភាពគ្មានដីធ្លី និងការអភិវឌ្ឍ ២០០៤/១២០ បានអោយដឹងថា ភូមិនេះមានដីទំនេរចំនួន ៦ហិកតា ។ ទោះបីជាយ៉ាងដូច្នេះក៏ដោយ នេះគឺជាដីដែលអ្នកភូមិបានកាន់កាប់រួចមកហើយ ប៉ុន្តែដីនេះខ្សោះជីជាតិខ្លាំងណាស់ដែលពួកគេមិនបានប្រើប្រាស់ឡើយ ។

## ៦. ភូមិធំ

- **ទីតាំងភូមិសាស្ត្រ**

  ភូមិធំស្ថិតនៅក្នុងឃុំជាមួយភូមិស្មោដែរ ប៉ុន្តែស្ថិតនៅជិតនឹងផ្លូវធំជាង ហើយមានព្រែកមួយ នៅក្នុងភូមិនេះ ។ ជាលទ្ធផល ជាធម្មតាអ្នកភូមិអាចដាំដំណាំទាំងរដូវប្រាំង និងរដូវវស្សានៅលើដីរបស់ខ្លួន ។

- **ការចិញ្ចឹមជីវិតនៃគ្រួសារគ្មានដី និងគ្រួសារមានដីតិចតួច**

  យោងតាមការប្រមូលព័ត៌មានអំពីភាពគ្មានដីធ្លី និងការអភិវឌ្ឍ ២០០៤/១២០ បានអោយដឹងថា ភូមិនេះមាន ១៣២គ្រួសារ ដែលក្នុងនោះគ្រួសារគ្មានដីធ្លីមានចំនួន ២០គ្រួសារ និងគ្រួសារមានដីធ្លីតិចតួចមានចំនួន ១៩គ្រួសារ ។ មានការងារស៊ីឈ្នួលផ្នែកកសិកម្មជាច្រើន ដោយសារការប្រមូលផលស្រូវ ២ដងក្នុងមួយឆ្នាំ ។ ក្រៅពីរដូវធ្វើស្រែ បុរសៗទៅភ្នំពេញដើម្បីរកការងារធ្វើនៅទីនោះ ដោយចាកចោលទុកប្រពន្ធ និងកូននៅក្នុងភូមិ ។ មិនមានប្រពៃណីរកវល្លិ និងធ្វើកន្ត្រកនៅក្នុងភូមិនេះទេ ។

- **ដីទំនេរនៅក្នុងភូមិ**

  គេបានរាយការណ៍ថា មិនមានដីទំនេរដែលអាចរកបាននៅក្នុងភូមិនេះទេ (១៤ភូមិ ក្នុងចំណោម ១៥ភូមិដែលបានសំភាសន៍ នៅក្នុងខេត្តព្រៃវែង បានរាយការណ៍ថា មិនមានដីទំនេរទេ) ។

## តំបន់ភ្នំក្រវាញ-បរិស្ថានទន្លេសាប

### ៧. ភូមិរូង

- **ទីតាំងភូមិសាស្ត្រ**

ភូមិរូងស្ថិតនៅក្នុងតំបន់មួយ ជិតជីជើងភ្នំតូចៗជាច្រើន ដែលមានទាំងដីស្រែ និងដីចំការ នៅក្នុងខេត្តបាត់ដំបង ។

- **ការចិញ្ចឹមជីវិតនៃគ្រួសារគ្មានដី និងគ្រួសារមានដីតិចតួច**

យោងតាមការប្រមូលព័ត៌មានអំពីភាពគ្មានដីធ្លី និងការអភិវឌ្ឍ ២០០៤/១២០ បានអោយដឹងថា ភូមិនេះមាន ១៩៤គ្រួសារ ដែលក្នុងនោះគ្រួសារគ្មានដីធ្លីមានចំនួន ៣៩គ្រួសារ និងគ្រួសារមានដីធ្លីតិចតួចមានចំនួន ៤គ្រួសារ ។ គ្រួសារគ្មានដីធ្លី និងគ្រួសារមានដីធ្លីតិចតួច ប្រកបរបរចិញ្ចឹមជីវិតរបស់ពួកគេ ដោយស៊ីឈ្នួលធ្វើស្រែ និងចំការ (ជាពិសេសចំការក្រូច) ។ មិនមានការធ្វើដំណើរចាកចេញពីភូមិច្រើន ដើម្បីស្វែងរកចំណូលនោះទេ ។

- **ដីទំនេរនៅក្នុងភូមិ**

យោងតាមការប្រមូលព័ត៌មានអំពីភាពគ្មានដីធ្លី និងការអភិវឌ្ឍ ២០០៤/១២០ បានអោយដឹងថា ភូមិនេះមានដីទំនេរចំនួន ២៩១ហិកតា ។ យោងតាមការចុះសំភាសន៍របស់ក្រុមស្រាវជ្រាវ ដីនេះមួយចំនួនមានសក្តានុពលប្រើប្រាស់សំរាប់ដីលំនៅដ្ឋាន និងដីចំការ ។ នឹងអាចមានតំរូវការផ្លូវ អណ្តូងទឹក និងការងាររៀបចំដីមួយចំនួន ដើម្បីកាប់ឆ្ការព្រៃគម្ពាត និងយកថ្មចេញពីផ្ទៃដីនេះ ។ ដីនេះមួយចំនួន អាចមានលទ្ធភាពផងដែរ ដែលត្រូវចាត់ចូលជាប្រភេទដីព្រៃ ។

### ៨. ភូមិដង្កត់ធ្មង់

- **ទីតាំងភូមិសាស្ត្រ**

ភូមិដង្កត់ធ្មង់ស្ថិតនៅឆ្ងាយដាច់ស្រយាលមែនទែនពីទីរួមខេត្ត (ប្រហែលជា៧០គីឡូម៉ែត្រឆ្ងាយជាងភូមិរូង) ដែលស្ថិតនៅតាមជើងភ្នំ ហើយដីកសិកម្មភាគច្រើននៅក្នុងតំបន់នេះ គឺជាដីចំការ ។

- **ការចិញ្ចឹមជីវិតនៃគ្រួសារគ្មានដី និងគ្រួសារមានដីតិចតួច**

យោងតាមការប្រមូលព័ត៌មានអំពីភាពគ្មានដីធ្លី និងការអភិវឌ្ឍ ២០០៤/១២០ បានអោយដឹងថា ភូមិនេះមាន២៣២គ្រួសារ ដែលក្នុងនោះគ្រួសារគ្មានដីធ្លីមានចំនួន ៣៣គ្រួសារ និងមិនមានគ្រួសារដែលមានដីធ្លីតិចតួចទេ ។ ភាពសម្បូរនៃម្ចាស់ដីដែលទំហំដីធំៗ នៅក្នុងតំបន់នេះ មានន័យថាមានភាពអំណោយផលល្អសំរាប់ការងារស៊ីឈ្នួលធ្វើកសិកម្ម ។ ការស្ថិតនៅជិតព្រំដែនថៃ មានន័យថាគ្រួសារជាច្រើនរកការងារនៅទីនោះ ។ នៅរដូវប្រាំង ពួកគេដើរបេះបន្លែបង្ការផ្សេងៗ នៅក្នុងព្រៃផងដែរ ។

- **ដីទំនេរនៅក្នុងភូមិ**

យោងតាមការប្រមូលព័តិមានអំពីភាពគ្មានដីធ្លី និងការអភិវឌ្ឍ ២០០៤/១២០ បានអោយដឹងថាភូមិនេះមានដីទំនេរចំនួន ៣៨៣ហិកតា ។ ដីនេះរួមមាន ដីមានគុណភាពល្អ ដីមួយចំនួនកំពុងតែដាំដុះដោយនាយទាហាន និងអ្នកធំដទៃទៀត ។ ពីមុនអ្នកភូមិទាំងឡាយបានបោះព្រំដី និងកាប់ឆ្ការដីនេះ ប៉ុន្តែក្រោយមកនាយទាហាន និងអ្នកមានអំណាចដទៃទៀតបានដេញពួកគាត់ចេញពីដីនេះ ។ បន្ទាប់មកមានលេចឮថា នាយទាហាន និងអ្នកធំ បានទាមទារសុំដីនេះជាកម្មសិទ្ធិឯកជន ដោយពួកគេនិយាយថា វាជាដីរបស់រដ្ឋទេ ។ ក្រៅពីដីដែលមានគុណភាពនេះ ក្នុងចំណោមដី៣៨៣ហិកតាក៏មានដីកូនភ្នំតូចៗ ដែលជាដីមានគុណភាពអន់ ហើយមិនអាចប្រើប្រាស់សំរាប់កសិកម្មបានឡើយ ។

## តារាងទី១១ ៖ ដីធ្លីដែលអាចរកបានសំរាប់សម្បទានដីសង្គមកិច្ច នៅក្នុងខេត្តដែលធ្វើសិក្សានាំង៨

(ការសិក្សាវាយតំលៃរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់)

| លេខកូដ | ខេត្ត | ស្រុក | ឃុំ | ដីដែលអាចរកបាន តាមឃុំ (ហិកតា) | ប្រភេទគម្របដី | ភាពសមស្របរបស់ដី | យោបល់ |
|---|---|---|---|---|---|---|---|
| ១ | បាត់ដំបង | បាណន់ | ចែងមានជ័យ | 100 | ព្រៃរបោះ | ផលិតកម្មកសិកម្ម | ដីមានមីន លិចទឹកនៅរដូវវស្សា ។ ខ្វះទឹកនៅរដូវប្រាំង ។ |
| ២ | បាត់ដំបង | បាណន់ | តាគ្រាម | 120 | ព្រៃរបោះ | ផលិតកម្មកសិកម្ម | ដីមានមីន |
| ៣ | បាត់ដំបង | បវេល | ល្វា | 100 | ព្រៃរិចរិល | លំនៅដ្ឋាន និងធ្វើចំការ | ប្រជាពលរដ្ឋបានកាប់ឆ្ការផ្នែកមួយចំនួន ដើម្បីធ្វើចំការ |
| ៤ | បាត់ដំបង | ឯកភ្នំ | ព្រៃចាស់ | 0 | - | - | |
| ៥ | បាត់ដំបង | សង្កែ | កំពង់ព្រះ | 900 | ដីព្រៃលិចទឹក | | |
| សរុប | | | | **1.220** | | | |
| ៦ | កំពង់ចាម | ជើងព្រៃ | ផ្តៅជុំ | 10 | ដីវាល | | ដីមិនបានប្រើប្រាស់ (ដីឯកជន) |
| ៧ | កំពង់ចាម | កោះសូទិន | កោះសូទិន | 0 | - | - | |
| ៨ | កំពង់ចាម | ក្រូចឆ្មារ | កំពង់ទ្រាស | 0 | - | - | |
| ៩ | កំពង់ចាម | ពញាក្រែក | កណ្តោលជ្រំ | 0 | - | - | |
| ១០ | កំពង់ចាម | ព្រៃឈរ | តុងរ៉ុង | 5,17 | | | |
| សរុប | | | | **15,17** | | | |
| ១១ | កំពត | ឈូក | ឈូក | 10 | ព្រៃរិចរិល | លំនៅដ្ឋាន ធ្វើស្រែ និងចំការ | ខ្វះទឹកនៅរដូវប្រាំង |
| ១២ | កំពត | ឈូក | ត្រពាំងប្លាំង | 230 | ព្រៃរិចរិល និងវាលស្មៅ | លំនៅដ្ឋាន ធ្វើស្រែ និងចំការ | អាចមានច្រើនជាងនេះទៀត |

| លេខកូដ | ខេត្ត | ស្រុក | ឃុំ | ដីដែលអាចរកបានតាមឃុំ (ហិកតា) | ប្រភេទគម្របដី | ភាពសមស្របរបស់ដី | យោបល់ |
|---|---|---|---|---|---|---|---|
| ១៣ | កំពត | ដងទង់ | ដំណាក់សុក្រំ | 0 | - | - | |
| ១៤ | កំពត | កំពង់ត្រាច | កន្ទោរខាងលិច | 0 | - | - | |
| ១៥ | កំពត | កំពត | ព្រែកត្នោត | 0 | - | - | តំបន់ឧទ្យានជាតិ និងតំបន់ការពារធនធានធម្មជាតិ |
| **សរុប** | | | | **240** | | | តំបន់ការពារព្រៃកោងកាង |
| ១៦ | កោះកុង | កោះកុង | កោះកាពិ | 0 | - | - | |
| ១៧ | កោះកុង | ស្មាច់មានជ័យ | ស្ទឹងវែង | 0 | - | - | |
| ១៨ | កោះកុង | ស្រែអំបិល | បឹងព្រាវ | 0 | - | - | តំបន់ឆ្នេរសមុទ្រ |
| ១៩ | កោះកុង | ថ្មបាំង | ឫស្សីជ្រុំ | 100 | ព្រៃរិចរិល និងវាលស្រែចាស់ | ការដាំដុះក្នុងរដូវវស្សា និងលំនៅដ្ឋាន | ស្ថិតនៅក្រោមការគ្រប់គ្រងរបស់អង្គការ**អភិរក្សអន្តរជាតិ** (International Conservation) |
| ២០ | កោះកុង | ថ្មបាំង | ថ្មដូនពៅ | 0 | - | - | |
| **សរុប** | | | | **100** | | | |
| ២១ | ព្រះវិហារ | ត្បែងមានជ័យ | ភ្នំត្បែងពណិ | 405 | ព្រៃរបោះ ព្រៃរិចរិល និងដីព្រៃឫស្សី | ពិបាកធ្វើកសិកម្ម ពីព្រោះខ្វះទឹក | មាន៤កន្លែងនៅក្នុងឃុំ ។ មានទំនាស់ទាក់ទងនឹងព្រំប្រទល់ឃុំ ។ មានការកាប់ឆ្ការដីព្រៃ ។ |
| ២២ | ព្រះវិហារ | រវៀង | រស្មី | 0 | - | - | |
| ២៣ | ព្រះវិហារ | រវៀង | រីករាយ | 4.400 | ដីវាលខ្សាច់ និងដីខ្ពង់រាប | លំនៅដ្ឋាន និងធ្វើស្រែ | មាន២កន្លែងផ្សេងគ្នា ស្ថិតនៅសង្ខាងផ្លូវជាតិលេខ២ |
| ២៤ | ព្រះវិហារ | រវៀង | រំដោះ | 1.300 | ព្រៃរបោះ | ធ្វើស្រែ និងចំការ | មាន៦កន្លែងផ្សេងគ្នា នៅក្នុងឃុំ |
| ២៥ | ព្រះវិហារ | សង្គមថ្មី | ស្ដៅ | 20 | ព្រៃរបោះ និងព្រៃរិចរិល | ពិបាកធ្វើកសិកម្ម ពីព្រោះខ្វះទឹក | មាន៣កន្លែងផ្សេងគ្នា នៅក្នុងឃុំ |
| **សរុប** | | | | **6.125** | | | |

| លេខកូដ | ខេត្ត | ស្រុក | ឃុំ | ដីដែលអាចរកបានតាមឃុំ (ហិកតា) | ប្រភេទគម្របដី | ភាពសមស្របរបស់ដី | យោបល់ |
|---|---|---|---|---|---|---|---|
| ២៦ | ព្រៃវែង | កំពង់ត្របែក | កំពង់ត្របែក | 0 | - | - | ការទន្ទ្រានយកដីធ្លី |
| ២៧ | ព្រៃវែង | ពាមរ | កោះរការ | 850 | ដីព្រៃលិចទឹក | ធ្វើស្រែប្រាំង | ដីមានទំនាស់ ជាប់ព្រំដែនប្រទេសវៀតណាម |
| ២៨ | ព្រៃវែង | ព្រះស្ដេច | ល្វា | 10 | ដីព្រៃគម្ពោត | លំនៅដ្ឋាន និងធ្វើស្រែ | នៅក្នុងភូមិកំពង់ថ្នល់ និងព្រៃក្ដួច |
| ២៩ | ព្រៃវែង | ព្រៃវែង | ពពឺស | 18 | ដីស្រែ និងចំការ | ធ្វើស្រែ និងចំការ | ដីចែកអោយប្រជាពលរដ្ឋរួចហើយ ក្នុងឆ្នាំ១៩៨៧ |
| ៣០ | ព្រៃវែង | ស៊ីធរកណ្ដាល | អំពិលក្រៅ | 0 | - | - | |
| សរុប | | | | **878** | | | |
| ៣១ | ស្ទឹងត្រែង | សេសាន | ភ្លុក | 450 | ព្រៃស្បាតចាស់ | លំនៅដ្ឋាន ដំណាំឈើហូបផ្លែ ធ្វើស្រែ និងចំការ | មាននៅក្នុងភូមិ បានប៊ុង និងភ្លុក |
| ៣២ | ស្ទឹងត្រែង | សៀមប៉ាង | ថ្មកែវ | 0 | - | - | |
| ៣៣ | ស្ទឹងត្រែង | ស្ទឹងត្រែង | ស្រះឫស្សី | 360 | ដីព្រៃស្បាតចាស់ | ដំណាំឈើហូបផ្លែ ធ្វើស្រែ និងចំការ | មាន៦កន្លែងផ្សេងគ្នា នៅក្នុងឃុំ |
| ៣៤ | ស្ទឹងត្រែង | ថាឡាបរិវ៉ាត់ | ចំការលើ | 3.960 | ព្រៃស្បាតចាស់ និងព្រៃរិចរិល | លំនៅដ្ឋាន និងធ្វើចំការ | មាននៅ៣ភូមិ |
| ៣៥ | ស្ទឹងត្រែង | ថាឡាបរិវ៉ាត់ | ថាឡា | 2.800 | ព្រៃស្បាតចាស់ និងព្រៃរិចរិល | លំនៅដ្ឋាន និងធ្វើចំការ | មាននៅ៤ភូមិ |
| សរុប | | | | **7.570** | | | |
| ៣៦ | ឧត្ដរមានជ័យ | បន្ទាយអំពិល | គោកខ្ពស់ | 250 | ព្រៃពាក់កណ្ដាលស្រោងរិចរិលមាន៥០% ដីវាលទំនាប ៤០% និងដីវាលស្មៅ១០% | លំនៅដ្ឋាន ធ្វើចំការ និងព្រៃការពារ | មានបឹងមួយឈ្មោះបឹងត្រាវ ដែលនៅជុំវិញបឹងមានមីន |
| | ឧត្ដរមានជ័យ | បន្ទាយអំពិល | គោកខ្ពស់ | 61 | ព្រៃរិចរិល និងដីទំនាប (ដីមានមីន) | ធ្វើស្រែ និងចំការស្រូវ | សំរាប់គ្រួសារយោធិនរំសាយ និងប្រជាពលរដ្ឋខ្វះដី |

| លេខកូដ | ខេត្ត | ស្រុក | ឃុំ | ដីដែលអាចរកបានតាមឃុំ (ហិកតា) | ប្រភេទគម្របដី | ភាពសមស្របរបស់ដី | យោបល់ |
|---|---|---|---|---|---|---|---|
| ៣៧ | ឧត្តរមានជ័យ | ចុងកាល់ | ក្រសាំង | 136 | ព្រៃរបោះរិចរិល និង ព្រៃកំប៉ូត | ធ្វើស្រែ និងចំការស្រូវ | មានផ្លូវរទេះ |
| | ឧត្តរមានជ័យ | ចុងកាល់ | ក្រសាំង | 82,5 | ព្រៃរបោះរិចរិល និង ព្រៃកំប៉ូត | ធ្វើស្រែ និងចំការស្រូវ | មានផ្លូវរទេះ និងប្រភពទឹកល្អ |
| | ឧត្តរមានជ័យ | ចុងកាល់ | ក្រសាំង | 70 | ព្រៃរបោះរិចរិល និង ព្រៃកំប៉ូត | ធ្វើស្រែ និងចំការស្រូវ | មានផ្លូវរទេះ និងប្រភពទឹកល្អ |
| ៣៨ | ឧត្តរមានជ័យ | សំរោង | បុស្បូវ | 2 | ដីវាល | លំនៅដ្ឋាន | |
| | ឧត្តរមានជ័យ | សំរោង | បុស្បូវ | 10 | ដីវាល | សេវាកម្មសាធារណៈ | |
| ៣៩ | ឧត្តរមានជ័យ | ត្រពាំងប្រាសាទ | បាក់អន្លុង | 281 | ដីមានមីន និងដីព្រៃកំប៉ូត | លំនៅដ្ឋាន និងធ្វើស្រែ | |
| | ឧត្តរមានជ័យ | ត្រពាំងប្រាសាទ | ផ្អាវ | 800 | ព្រៃស្បាតចាស់ | លំនៅដ្ឋាន និងចំការស្រូវ | |
| សរុប | | | | **1.692,5** | | | |
| សរុបទាំងអស់ | | | | **17. 840,76** | | | |
| **ឃុំអាចរកដីបាន** | | | | **២៧ឃុំ** | | | |
| **ឃុំមិនអាចរកដីបាន** | | | | **១៤ឃុំ** | | | |

## សេចក្តីបន្ថែមទី៣ ៖ ការយល់ដឹងរបស់អ្នកភូមិ

សេចក្តីបន្ថែមនេះ រាប់បញ្ចូលនូវកំរងពាក្យដកស្រង់មួយចំនួន ដែលជាការសន្ទត់របស់អ្នកចូលរួមគ្រប់ប្រភេទ នៅក្នុងការសិក្សាវិភាគផលប៉ះពាល់ទៅលើសង្គម និងភាពក្រីក្រ ។ ការបញ្ចូលពាក្យដកស្រង់ទាំងនេះចាត់ទុកថាមានសារប្រយោជន៍ ពីព្រោះវាគឺជាសំឡេងរបស់សមាជិកទាំងអស់ ដែលគឺជាអ្នក ឬអាចជាអ្នកបានចូលរួមនៅក្នុងកម្មវិធីសម្បទានដីសង្គមកិច្ច ។ ជាធម្មតា ការសិក្សាស្រាវជ្រាវរបៀបនេះ តែងតែមានការដកស្រង់ជាច្រើនថែមទៀត ដែលអាចត្រូវបានបញ្ចូលក្នុងរបាយការណ៍ ។ ទោះជាយ៉ាងដូច្នេះក្តី អ្នកសរសេររបាយការណ៍ចាត់ទុកថា ការបកស្រាយខាងក្រោមនេះ បង្ហាញបាននូវអ្វីដែលមានក្នុងការសិក្សាវិភាគផលប៉ះពាល់ទៅលើសង្គម និងភាពក្រីក្រ ។

## សារៈសំខាន់នៃការធ្វើកសិកម្មសំរាប់ការចិញ្ចឹមជីវិតនៅជនបទ

អ្នកចូលរួមជាស្ត្រីនៃក្រុមគោលដៅសំរាប់ការពិភាក្សា ដែលរស់នៅចំការលើ ក្នុងខេត្តស្ទឹងត្រែងពន្យល់ថា ៖

*អង្ករគឺជាអាហារសំខាន់ជាងគេរបស់ពួកយើង ប៉ុន្តែពួកយើងពុំមានអង្ករគ្រប់គ្រាន់ជារៀងរាល់ឆ្នាំឡើយ ។ យើងត្រូវការដី និងសត្វពាហនៈដែលជាកំលាំងអូសទាញ ដើម្បីកាត់បន្ថយការស្រេកឃ្លានរបស់ពួកយើង និងចុងក្រោយគឺភាពក្រីក្រ ។ ប្រសិនបើគ្មានដីគ្រប់គ្រាន់ ពួកយើងប្រាកដជា គ្មានលទ្ធភាពដើម្បីដាំដុះអ្វីៗឡើយ មានន័យថា ពួកយើងនឹងស្លាប់ដោយអត់អាហារ ។*

## មូលហេតុជាច្រើនដែលនាំអោយគ្មានដីធ្លី

ក្នុងចំណោមនៃបញ្ហាឬសគល់ទាំងឡាយ ជម្ងឺមិនមែនជាបញ្ហាចំឡែកនោះទេ ដូចដែលស្ត្រីចំណាស់ជនជាតិព័រ[១៨] ម្នាក់ក្នុងក្រុមគោលដៅសំរាប់ការពិភាក្សា នៅភូមិឱឡឹក ខេត្តព្រះវិហារបានត្អូញត្អែរថា ៖

*ក្រោយសម័យ ប៉ុល ពត ក្រុមគ្រួសារខ្ញុំ មានដីមួយកន្លែងដែលពួកយើងប្រើប្រាស់ដើម្បីដាំដុះដំណាំសំរាប់គ្រួសារ ប៉ុន្តែឥឡូវនេះ ពួកយើងគ្មានដីទេ ។ ពួកយើងគ្មានដីហើយក៏ក្រខ្លាំងណាស់ដែរ ។*

*កាលពីប៉ុន្មានឆ្នាំមុន ប្តីរបស់ខ្ញុំមានជំងឺគ្រុនចាញ់ ហើយពួកយើងត្រូវបង្ខំចិត្តលក់ដីរបស់យើងមួយផ្នែកសំរាប់យកប្រាក់ទៅទិញថ្នាំសង្កូវដើម្បីយកមកព្យាបាលជំងឺ ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក្រោយមកគាត់ក៏បានស្លាប់បាត់ទៅ ។ បន្ទាប់មកកូនៗរបស់ខ្ញុំ ក៏ចាប់ផ្តើមមានជំងឺគ្រុនចាញ់ទៀត ។ ពួកយើងក៏លក់ដីទាំងអស់ដែលយើងមានសំរាប់យកលុយទៅទិញថ្នាំសង្កូវមកព្យាបាលជំងឺកូនៗ ។ ជាអកុសល កូនៗ*

[១៨] មានជនជាតិដើមភាគតិចច្រើនជាង១៧ពូជសាសន៍នៅក្នុងប្រទេសកម្ពុជា ។ ជនជាតិព័រ គឺជាជនជាតិមួយក្នុងចំណោមជនជាតិដើមភាគតិចទាំងនោះ ។ ជនជាតិនេះ ច្រើនប្រទះឃើញនៅខេត្តព្រះវិហារ ប៉ុន្តែមានមនុស្សភាគតិចណាស់ដែលបានស្គាល់ជនជាតិនេះ ។

*ក៏បានស្លាប់ទៅទៀតដែរ ហើយនៅសល់កូនតូច៧ចំនួនបួននាក់ ។ កូន៧ទាំងនេះ គឺពឹងពាក់អាស្រ័យទាំងស្រុងមកលើខ្ញុំតែម្នាក់ឯង ។ សព្វថ្ងៃនេះប្រភពចំណូលតែមួយគត់សំរាប់គ្រួសារខ្ញុំ គឺបានមកពីការក្រងស្លឹកបូលផ្ទះលក់ ។ យើងប្រាថ្នាចង់មានដី ដើម្បីពួកយើងអាចដាំដំណាំសំរាប់ទទួលទាន ដែលយ៉ាងហោចណាស់ក៏អាចធានាថា ពួកយើងមិនអត់ឃ្លានពេកនោះដែរ ។*

## លក្ខណៈវិនិច្ឆ័យសំរាប់ការទទួលបាននូវសិទ្ធិចូលរួមក្នុងកម្មវិធីសម្បទានដីសង្គមកិច្ច

លក្ខណៈវិនិច្ឆ័យទី១ ចែងថា ដើម្បីទទួលបានសិទ្ធិ អ្នកសុំដីសម្បទានសង្គមកិច្ចត្រូវតែមានសញ្ជាតិខ្មែរ និងមានសមត្ថភាពតាមផ្លូវច្បាប់ដើម្បីធ្វើជាម្ចាស់ដី ។ កសិករចំណាស់ក្នុងវ័យ៧០ឆ្នាំ រស់នៅក្នុងភូមិខ្សោកត្បូង ខេត្តព្រៃវែង មិនសប្បាយចិត្តនឹងលក្ខណៈវិនិច្ឆ័យនេះ ដោយលើកឡើងថា :

*គួរតែគ្មានការរើសអើងណាមួយឡើយ ។ គួរតែមិនមែនតែជនជាតិកម្ពុជា/ខ្មែរ តែមួយប៉ុណ្ណោះទេ ដែលមានសិទ្ធិនៅក្នុងកម្មវិធីនេះ ។ ជនជាតិដទៃទៀតគួរតែមានសិទ្ធិដែរ ដរាបណាពួកគេរស់នៅជាអចិន្ត្រៃយ៍នៅលើទឹកដីកម្ពុជា ហើយដែលពួកគេប្រហែលជាអាចទទួលបាននូវសញ្ជាតិស្របច្បាប់ ។ យើងមិនត្រូវទុកអោយពួកគាត់រស់នៅដោយគ្មានកម្មសិទ្ធិដីធ្លីនោះទេ ប្រសិនបើពួកគេក៏ជាអ្នកក្រដែរនោះ ។*

ប្រជាកសិករម្នាក់ទៀត ស្ថិតក្នុងវ័យ៤០ឆ្នាំ រស់នៅភូមិសំបូរ ខេត្តឧត្តរមានជ័យ បានគាំទ្រការយល់ឃើញរបៀបនេះដែរ ដោយលើកឡើងថា :

*អ្នកណាក៏ដោយអោយតែគ្មានដី គួរតែមានសិទ្ធិទទួលបានដីសំរាប់ការចិញ្ចឹមជីវិតរបស់ពួកគាត់ ។ មិនថាពួកគាត់ជាជនជាតិអ្វីឡើយ ដរាបណាពួកគាត់រស់នៅក្នុងភូមិតែមួយជាមួយពួកយើង ។ អាជ្ញាធរអាចសំរេចលើទំហំដីសំរាប់លំនៅដ្ឋាន ប៉ុន្តែចំពោះដីសំរាប់ធ្វើកសិកម្ម គួរតែយ៉ាងហោចណាស់ ក៏មានទំហំ ២ហិកតា ក្នុងមួយគ្រួសារដែរ ។*

ប្រជាកសិករម្នាក់ទៀត ក្នុងវ័យ៤០ឆ្នាំ រស់នៅក្នុងភូមិរពៀក ខេត្តកំពត បានបន្លឺនូវទស្សនៈយល់ឃើញទាំងនេះសារជាថ្មី ។ បុរសនេះ បាននិយាយយ៉ាងល្អិតល្អន់ថា :

*វាមិនយុត្តិធម៌ឡើយដែលថាមានតែជនជាតិកម្ពុជា/ខ្មែរ មានសិទ្ធិនៅក្នុងកម្មវិធីនេះ ។ សួរថាតើជនជាតិដទៃទៀតមិនមែនជាមនុស្សទេឬ? ពោលគឺពួកគេក៏មានសិទ្ធិរស់រានដែរ ។ ដរាបណាពួកគេជាមនុស្ស ហើយមានកំលាំងពលកម្មសំរាប់កាប់គាស់ភ្ជួររាស់ដី ពួកគេគួរមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍នេះដែរ ។*

លក្ខណៈវិនិច្ឆ័យទី២ចែងថា ដើម្បីមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍នេះ ត្រូវតែជាមេគ្រួសារមេគ្រួសារ ដែលមានសមាជិកពីរនាក់ ឬច្រើននាក់ដែលជាបលសាច់សាលោហិតជាមួយគ្នា ឬមានចំណងអាពាហ៍ពិពាហ៍ និងរស់នៅជាមួយគ្នាក្នុងលំនៅឋានតែមួយ ។ លក្ខណៈវិនិច្ឆ័យនេះ ហាក់ដូចជារើសអើងប្រឆាំងនឹងគ្រួសារដែលមាន

សមាជិកតែម្នាក់ឯង ហើយដែលអាចជាគ្រួសារក្រីក្របំផុត ប៉ុន្តែបានធ្វើការងារយ៉ាងខ្លាំងក្លា ។ មនុស្សវ័យចំណាស់ក្នុងក្រុមគោលដៅសំរាប់ការពិភាក្សា រស់នៅក្នុងស្រុកស្រែអំបិល ខេត្តកោះកុង មិនយល់ព្រមនឹងលក្ខណៈវិនិច្ឆ័យនេះ ដោយលើកឡើងថា :

*គឺជាការដែលមិនអាចទទួលយកបានឡើយ ។ តើអ្នកយល់ឃើញយ៉ាងណាដែរ? តើអ្នកយល់ឃើញថាមនុស្សចាស់ដូចរូបខ្ញុំនេះ មិនត្រូវការទទួលទានដើម្បីរស់ទេឬ? តើអ្នកយល់ថាមនុស្សចាស់លេបថ្ម ដើម្បីរស់រានបាន ក៏ព្រោះតែពួកគាត់មើលទៅដូចជាថ្មមែនទេ? ខ្ញុំមានអាយុ៧០ឆ្នាំជាងហើយ ប៉ុន្តែខ្ញុំនៅតែត្រូវការទទួលទានដើម្បីរស់នៅ ហើយដើម្បីអោយមានកំលាំងពលំគ្រប់គ្រាន់ ក្នុងការធ្វើស្រែចំការ ។ សព្វថ្ងៃនេះ ខ្ញុំពឹងពាក់អាស្រ័យទាំងស្រុងទៅតែលើការងារប្រចាំថ្ងៃ ។ គោលនយោបាយនេះ គឺមានលក្ខណៈរើសអើងជាទីបំផុត ប្រឆាំងនឹងមនុស្សចាស់ជរា ដែលជាគ្រួសារឯកោម្នាក់ឯងដូចរូបខ្ញុំ ។*

កសិករក្មេងក្នុងវ័យ២០ឆ្នាំម្នាក់រស់នៅក្នុងស្រុកសំរោង ខេត្តឧត្តរមានជ័យ បានបញ្ចេញនូវការព្រួយបារម្ភចំពោះលក្ខណៈវិនិច្ឆ័យនេះថា :

*ខ្ញុំគឺជាកូនកំព្រា ។ ឪពុកម្តាយខ្ញុំស្លាប់ជាច្រើនឆ្នាំកន្លងមកហើយ ដោយសារភាពក្រីក្រ និងដោយសារជំងឺ ។ គាត់គ្មានបានបន្សល់ទុកនូវកេរ្តិ៍អ្វីបន្តិចបន្តួចណាដល់រូបខ្ញុំទេ ។ ខ្ញុំរស់នៅតាមយថាកម្មរបស់ខ្ញុំ ។ ដូចដែលលោកអ្នកឃើញស្រាប់ហើយ ប្រអប់ដៃរបស់ខ្ញុំម្ខាងមិនអាចប្រើបាន ប៉ុន្តែខ្ញុំគឺជាកម្មករស៊ីឈ្នួលម្នាក់ ។ ខ្ញុំរស់តាមបែបរកបានមួយថ្ងៃសំរាប់ទទួលទានមួយថ្ងៃ ។ ប្រសិនបើខ្ញុំគ្មានការងារធ្វើ ក្នុងថ្ងៃណាមួយ ខ្ញុំនឹងមិនមានអ្វីសំរាប់ទទួលទានឡើយ ។ ឥឡូវនេះខ្ញុំនៅមានកំលាំងខ្លាំងក្លា ហើយខ្ញុំអាចនៅរកការងារបានធ្វើខ្លះ ប៉ុន្តែមិនគ្រប់គ្រាន់ទេសំរាប់ការរស់នៅ ។ នៅពេលខ្ញុំចាស់ទៅ តើអនាគតរបស់ខ្ញុំ នឹងទៅជាយ៉ាងណា ប្រសិនបើខ្ញុំគ្មានដីនោះ? តើខ្ញុំនឹងនៅតែមានលទ្ធភាពលក់កំលាំងជារៀងរហូត លុះដល់ថ្ងៃខ្ញុំស្លាប់បានដែរឬយ៉ាងណា ?*

ស្ត្រីចំណាស់ម្នាក់ក្នុងក្រុមគោលដៅសំរាប់ការពិភាក្សា រស់នៅក្នុងស្រុកសង្គមថ្មី ខេត្តព្រះវិហារ បានត្អូញត្អែរចំពោះចំណាត់ការ ដ៏អយុត្តិធម៌នៃលក្ខណៈវិនិច្ឆ័យនេះថា :

*ខ្ញុំមានតែម្នាក់ឯង ក្រីក្រគ្មានដី ហើយថែមទាំងចាស់ទៀត ។ កាលពីខ្ញុំនៅក្មេងជាងនេះ ខ្ញុំអាចប្រកបរបរលក់កំលាំងសំរាប់ការរស់នៅ ។ ឥឡូវនេះ ខ្ញុំចាស់ណាស់ទៅហើយ មិនអាចធ្វើការងារដោយប្រើកំលាំងបានទៀតទេ ។ ប្រសិនបើខ្ញុំគ្មានសិទ្ធិទទួលបានដីនឹងគេទេ ខ្ញុំនឹងគ្មានអ្វី១ទាំងអស់សំរាប់រស់តទៅទៀត ដូចដែលលោកអ្នកឃើញស្រាប់ហើយ ។ ជួនកាលខ្ញុំអត់ឃ្លានខ្លាំងណាស់ ។ ខ្ញុំសូមអរគុណចំពោះអ្នកភូមិផងជាមួយខ្ញុំ ដែលជួនកាលគេបានចែករំលែកឱ្យខ្ញុំនូវអ្វីដែលគេមាន ។ រាជរដ្ឋាភិបាលគួរតែចែកដីដល់គ្រួសារណាដែលមានតែម្នាក់ឯងផង មិនថាអ្នកនោះចាស់ឬក្មេងឡើយ ។ ព្រោះថាថ្វីត្បិតយើងមិន*

*មានកំលាំងពលកម្មគ្រប់គ្រាន់ក៏ដោយ ក៏យើងអាចដាំដុះដាលក្ខណៈទបវ៉ាស់ដៃលើដីរបស់យើងបានដែរ ។ តើមានអ្វីខ្លះជាការឧបត្ថម្ភ របស់រាជរដ្ឋាភិបាលដល់គ្រួសារដែលមានសមាជិកតែម្នាក់ឯង ហើយជាស្ត្រីចំណាស់ដូចរូបខ្ញុំនេះ? គេគ្មានកម្មវិធីសំរាប់ជួយមនុស្សចាស់ជរាទេ ។ គេមិនបានយកចិត្តទុកដាក់ចំពោះពួកយើងឡើយ ។ ហើយប្រហែលជាពួកគេសប្បាយចិត្តណាស់ នៅពេលដែលឃើញយើងសុំទានគេ នៅតាមផ្លូវថ្នល់ក្នុងទីប្រជុំជននោះ ។*

ការសន្មត់ថា លក្ខណៈវិនិច្ឆ័យខាងបញ្ហាហិរញ្ញវត្ថុនោះ នឹងផ្អែកតាមកំរិតនៃភាពក្រីក្រ ។ អ្នកចូលរួមក្នុងក្រុមគោលដៅសំរាប់ការពិភាក្សា និងអ្នកដែលគេសំភាសទីភាគច្រើន បានយល់ព្រមចំពោះរឿងនេះ ហើយក៏មានការស្នើសុំមួយចំនួនផងដែរ ។ អ្នកចូលរួមទាំងឡាយនៅក្នុងភូមិព្រែកល្បៀប ខេត្តកោះកុង បានស្នើសុំថា :

*ថ្វីត្បិតតែប្រជាពលរដ្ឋខ្លះមិនក្រផ្នែកហិរញ្ញវត្ថុក៏ដោយ ក៏ពួកគេគួរទទួលបានដីដែរ ព្រោះថាពួកគេមិនចាំបាច់ចំណាយប្រាក់ដែលជាចំណូលយកទៅទិញដី ។ នៅពេលដែលពួកគេប្រើប្រាស់ចំណូលដើម្បីជាថ្នូរទទួលបានដី ពួកគេនឹងមិនមានប្រាក់ចំណូលគ្រប់គ្រាន់សំរាប់ការចំណាយក្នុងការរស់នៅឡើយ ។ ពួកគេត្រូវការដីសំរាប់ជាមធ្យោបាយសុវត្ថិភាព ។ នៅពេលពួកគេគ្មានការងារធ្វើ ពួកគេអាចប្រើប្រាស់ដីធ្លីនោះបាន ។ សេដ្ឋកិច្ចរបស់ប្រទេស យើងមិនទៀងទាត់ឡើយ ហើយការងារផ្សេងពីស្រែចំការ មិនមានពេលណាដែលធានាសុវត្ថិភាពទេ ។*

លក្ខណៈវិនិច្ឆ័យទី៤ ដែលបានចែងនៅក្នុងអនុក្រឹត្យថា អ្នកសុំដីសម្បទានសង្គមកិច្ច ត្រូវតែមិនមែនជាកម្មសិទ្ធិករ ឬភោគីនៃដីផ្សេងទៀតដែលមានទំហំស្មើ ឬធំជាងទំហំដីដែលបានប្រគល់ឱ្យនៅក្នុងកម្មវិធីសម្បទានដីសង្គមកិច្ចឡើយ ។ មានមនុស្ស មួយចំនួនតូចដែលមិនសប្បាយចិត្តចំពោះរឿងនេះ ។ កសិកររស់នៅក្នុងស្រុកសំរោង ខេត្តឧត្តរមានជ័យ បានសំដែងអោយដឹងនូវទស្សនៈយល់ឃើញរបស់នាងថា :

*តាមពិតទៅ ដីទំហំត្រឹម២ហិកតា សំរាប់គ្រួសារខ្លះពុំគ្រប់គ្រាន់ឡើយ ។ ថ្វីត្បិតតែពួកគេមានកម្មសិទ្ធិដីច្រើនប៉ុណ្ណឹង ក៏គេនៅត្រូវការដីច្រើនជាងនេះទៅទៀត ។ ពីព្រោះអ្នកខ្លះមានកូនច្រើន ហើយពួកគេត្រូវការដីដើម្បីទុកចែកកូនចៅជំនាន់ក្រោយ ។ ដីគឺវានៅស្ថិតស្ថេរ ប៉ុន្តែមនុស្សចេះតែមានចំនួនច្រើនឡើង ។*

លក្ខណៈវិនិច្ឆ័យទី៥ តំរូវអោយអ្នកសុំដីសម្បទានសង្គមកិច្ច ត្រៀមខ្លួនជាស្រេច មានឆន្ទៈ និងមានលទ្ធភាពចូលរួមក្នុងកម្មវិធីសម្បទានដីសង្គមកិច្ច ។ លក្ខណៈវិនិច្ឆ័យនេះ ត្រូវបានគាំទ្រយ៉ាងពេញទំហឹង ។ គ្មាននរណាម្នាក់ជំទាស់ឡើយ ។ អ្នកចូលរួមក្នុងក្រុមគោលដៅសំរាបការពិភាក្សា រស់នៅក្នុងឃុំតាក្រាម ខេត្តបាត់ដំបង បានធ្វើការកត់សំគាល់ថា :

*យើងគួរតែកុំរើសអើងប្រឆាំងនឹងគ្រួសារដែលមានសមាជិកតែម្នាក់ឯង ។ ដរាបណាគេមានការប្រុងប្រៀបរួចជាស្រេច និងមានឆន្ទៈរួមជាមួយនឹងលទ្ធភាពចូលរួមនៅក្នុងកម្មវិធី គាត់គួរត្រូវមានសិទ្ធិទទួល*

*បានទូវអត្ថប្រយោជន៍នេះ ។ ប្រសិនបើគេមិនអនុញ្ញាតអោយគាត់ចូលរួម គាត់ហាក់មានអារម្មណ៍ថា សង្គមបានបោះបង់ពួកគាត់ចោល ហើយពួកគាត់អាចធ្វើអ្វីម្យ៉ាងខុស ។*

## ការបំពេញនូវលក្ខខណ្ឌនានាដើម្បីទទួលបានសិទ្ធិ

អ្នកទាំងឡាយដែលជំទាស់ប្រឆាំងនឹងល័ក្ខខ័ណ្ឌទាំងនោះ បានផ្តល់នូវហេតុផលរបស់ពួកគេ ។ អ្នកចូលរួមនៅក្នុងក្រុមគោលដៅសំរាប់ការពិភាក្សា ក្នុងភូមិចំការ ខេត្តឧត្តរមានជ័យ បានមានប្រតិកម្មប្រឆាំងជំទាស់នឹងល័ក្ខខ័ណ្ឌទី១ ថា :

*រាជរដ្ឋាភិបាលកម្ពុជា ពុំគួរកំណត់នូវល័ក្ខខ័ណ្ឌយ៉ាងដូច្នោះទេ ។ ប្រជាពលរដ្ឋក្រីក្រ នឹងមិនមានធនធានដែលសូម្បីតែសំរាប់សង់ខ្ទម (ដូចទ្រុងមាន់) បានមួយផង ក្នុងរយៈពេលបីខែ ។ ប្រជាពលរដ្ឋក្រីក្រដែលរស់នៅក្នុងភូមិរបស់យើង មិនមានជំរកអោយបានត្រឹមត្រូវសំរាប់ជ្រក ហើយពួកគាត់បានរស់នៅទីនេះតាំងពីច្រើនឆ្នាំមកហើយ ។ ហេតុដូច្នេះហើយ សួរថាតើពួកគាត់អាចសង់លំនៅដ្ឋានបាន ដោយរបៀបណា ក្នុងរយៈពេលតែបីខែ នៅលើដីដែលគេនឹងផ្តល់អោយនោះ ? ។*

អ្នកចូលរួមពិភាក្សាក្នុងក្រុមគោលដៅសំរាប់ការពិភាក្សា ក្នុងភូមិព្រៃពាយ ឃុំត្រពាំងភ្លាយ ខេត្តកំពតដែលជាជនពិការ ទាំងអស់គ្នា បានមានប្រតិកម្មប្រឆាំងនឹងល័ក្ខខ័ណ្ឌទី២ ថា :

*យើងរស់នៅតាមរបៀបមានមួយពេលស៊ីមួយពេល ។ ប្រសិនបើគេអោយដីយើង ហើយតំរូវអោយយើងដាំដុះលើដីនោះក្នុងរយៈពេល១២ខែ គឺពិតជាពិបាកណាស់សំរាប់ពួកយើង ។ នៅពេលពួកយើងនឹងធ្វើការរៀបចំដីដែលបានផ្តល់អោយយើងតាមរយៈកម្មវិធី ពួកយើងនឹងមិនអាចមានអ្វសំរាប់ទទួលទាន និងចិញ្ចឹមគ្រួសាររបស់យើងឡើយ ។ ពួកយើងលក់កំលាំងពលកម្មរបស់ពួកយើង សំរាប់ជីវិតប្រចាំថ្ងៃ ។ រាជរដ្ឋាភិបាល គួរបន្ធូរបន្ថយល័ក្ខខ័ណ្ឌនេះបន្តិច ប្រសិនបើចង់ជួយអ្នកក្រីក្រដូចពួកយើងនេះ ។*

ល័ក្ខខ័ណ្ឌចែងថា អ្នកទទួលដីនឹងមានលទ្ធភាពធ្វើលិខិតកាន់កាប់ដីធ្លីរយៈពេលប្រាំឆ្នាំ ក្រោយបំពេញល័ក្ខខ័ណ្ឌនៃកម្មវិធីសម្បទានដីសង្គមកិច្ចរួច ។ សមាជិកក្នុងក្រុមគោលដៅសំរាប់ការពិភាក្សា និងគ្រួសារផ្តល់ព័ត៌មានមួយចំនួន មានការព្រួយបារម្ភអំពីល័ក្ខខ័ណ្ឌនេះ ។ អ្នកចូលរួមក្នុងក្រុមគោលដៅសំរាប់ការពិភាក្សា ក្នុងភូមិលើ ខេត្តស្ទឹងត្រែង ដែលភាគច្រើនជាជនជាតិខ្មែរ-លាវ បានសំដែងនូវការមិនយល់ព្រមថា :

*រយៈពេល៥ឆ្នាំ ដើម្បីទទួលបាននូវសិទ្ធិកាន់កាប់ដីបន្ទាប់ពីកម្មវិធីចាប់ផ្តើម គឺជារយៈពេលយូរខ្លាំងណាស់ ។ យើងត្រូវការសុវត្ថិភាព និងការធានាដើម្បីទប់ទល់នឹងអ្នកដណ្តើមយកដី ។ មានតែកម្មសិទ្ធិដីធ្លីទេ ដែលប្រហែលជាអាចធានានូវរឿងទាំងនោះបាន ។ ភូមិរបស់យើងខ្ញុំដាច់ស្រយាល និងស្ថិតនៅស្ទើរតែកណ្តាលទ្រូងព្រៃទៀតផង ។ យើងមានទំលាប់ធ្វើកសិកម្មពនេចរជាច្រើនជំនាន់មកហើយ ។ យើងត្រឡប់ទៅ*

*កាន់ដីចំការចាស់ក្នុងរវាង៥ ទៅ ៧ឆ្នាំ ដោយអាស្រ័យទៅនឹងការដុះដាលព្រៃឡើងវិញ ។ ឥឡូវនេះ នៅពេលដែលយើងត្រឡប់ទៅកាន់ចំការចាស់វិញ មានអ្នកដទៃទៀត គេកាន់កាប់ដីរបស់ភូមិយើងអស់ទៅហើយ ។ នៅពេលដែលលោកអ្នកចូលទៅក្នុងភូមិ លោកអ្នកអាចសង្កេតឃើញថា អ្នកដទៃមកពីខាងក្រៅ ដែលសុទ្ធសឹងជានាយទាហាន អ្នកមាន និងអ្នកមានអំណាច ធ្វើរបងហ៊ុំព័ទ្ធយកដីពួកយើងអស់រលីង ។ ពួកយើងចង់បានដីទាំងនេះមកវិញ ។ យើងបានប្រាប់ពួកនោះថា វា គឺជាដីសំរាប់ធ្វើកសិកម្មពនេចររបស់ពួកយើង ប៉ុន្តែពួកគេបានសួរមកវិញថា ឯណាភស្តុតាង? តើអ្នកឯងមានលិខិតកាន់កាប់ដីធ្លីដែលបញ្ជាក់ថា អ្នកឯងជាម្ចាស់កម្មសិទ្ធិដីដែរឬទេ? យើងមិនអាចទាមទារយកដីនោះមកវិញបានទេ ។ ហេតុដូច្នេះហើយទើបពួកយើងស្ទើរតែទាំងអស់គ្នាមិនមានដីធ្លី ។ យើងមានត្រឹមតែដីទំហំតូចមួយចំរៀកដែលមិនអាចទ្រទ្រង់គ្រួសារយើងបាន ។ ហើយពួកយើងលែងហ៊ានផ្លាស់ទីទៅកាន់ទីកន្លែងផ្សេងទៀតដើម្បីធ្វើកសិកម្មពនេចរ ដែលជាទំលាប់របស់ពួកយើងទៀតហើយ ។*

ជនជាតិចាមដែលជាអ្នកចូលរួមក្នុងក្រុមគោលដៅសំរាប់ការពិភាក្សា ក្នុងភូមិដប់បីលើ ខេត្តកំពង់ចាម មានហេតុផលប្រហាក់ប្រហែលគ្នានេះដែរ ។ ពួកគេបានពន្យល់ថា :

*យើងស្នើរាជរដ្ឋាភិបាលគួរអនុញ្ញាតអោយយើងមានកម្មសិទ្ធិដីធ្លីត្រឹមតែ៣ឆ្នាំ ក្រោយបំពេញល័ក្ខខ័ណ្ឌនៃកម្មវិធី ។ ពីព្រោះយើងអាចនឹងប្រាកដថា គ្មាននរណាម្នាក់អាចនឹងមកយកដីពីយើងបាន ។ យើងបានឮតាមវិទ្យុថា មានអ្នកទន្ទ្រានដណ្តើមយកដីជាច្រើនពាសពេញប្រទេស ហើយអ្នកដែលបាត់បង់ដី ជានិច្ចកាលគឺជាអ្នកក្រដែលគ្មានប័ណ្ណកម្មសិទ្ធិដីធ្លី ហើយអ្នកដែលឈ្នះគឺជាទាហាន អ្នកមាន និងអ្នកមានអំណាច ។*

ចំពោះល័ក្ខខ័ណ្ឌទី៤ ប្រជាពលរដ្ឋភាគច្រើនចង់បានការធានាថា ទាយាទរបស់ពួកគេ មិនថាចាស់ ឬក្មេងឡើយ គួរមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ពីដី ។ ក្នុងភូមិឈើទាល ខេត្តកំពត ប្រជាពលរដ្ឋនៃក្រុមគោលដៅសំរាប់ការពិភាក្សា បានលើកឡើងថា :

*ជាការល្អដែលរាជរដ្ឋាភិបាល នឹងអាចអនុញ្ញាតអោយទាយាទទទួលយកដី នៅពេលបុព្វការីជនស្លាប់ទៅ ។ ប៉ុន្តែពួកយើងចង់អោយប្រាកដថា មិនថាទាយាទនោះមានវ័យចំណាស់ណាទេ គឺគាត់គួរមានសិទ្ធិ នឹងទទួលបាននូវសិទ្ធិទាំងនេះ ។ យើងស្នើរាជរដ្ឋាភិបាល គួរធ្វើការរៀបចំអោយបានសមស្រប ដើម្បីធានាថាដីគឺពិតជាបានប្រគល់អោយ ឬមួយផ្តល់នូវការការពារចំពោះទាយាទដែលមានវ័យក្មេង បើមិនដូច្នោះទេអាចមាននរណាម្នាក់ យកដីនោះដោយប្រើអំណាច ។ រាជរដ្ឋាភិបាល អាចគួរគិតពិចារណាអំពីការបង្កើតគណៈកម្មការធានាសុវត្ថិភាពដីភូមិ ដែលសមាសភាពរួមមានអ្នកចាស់ទុំក្នុងភូមិ តាអាចារ្យ និងមេភូមិ ដើម្បីធានាសុវត្ថិភាពដីធ្លីអោយត្រឹមត្រូវ សំរាប់ទាយាទស្របច្បាប់ មុននឹងគាត់អាចចាត់ចែងដីធ្លីទាំងនោះដោយខ្លួនឯងបាន (ជារូបវន្តបុគ្គល) ។*

មានប្រជាពលរដ្ឋមួយចំនួនដែលបានសំភាសន៏ក៏រិតគ្រួសារ និងនៅក្នុងក្រុមគោលដៅសំរាប់ការពិភាក្សា ជំទាស់ចំពោះល័ក្ខខ័ណ្ឌទី៥ ។ អ្នកចូលរួមនៅក្នុងក្រុមគោលដៅសំរាប់ការពិភាក្សា នៅស្រះឫស្សី ខេត្តស្ទឹងត្រែង បានសំដែងអោយឃើញនូវការព្រួយបារម្ភរបស់ពួកគាត់អំពីរឿងនេះថា :

*ប្រសិនបើគេមិនអនុញ្ញាតអោយយើងជួល ឬប្រើប្រាស់ដីដែលគេអោយ ធ្វើជារបស់បញ្ចាំបានទេ យើងអាចប្រឈមមុខនឹងភាពលំបាក នៅពេលណាដែលយើងពិតជាត្រូវការលុយដើម្បីដោះស្រាយបញ្ហាអាសន្ន ជាពិសេសនៅពេលយើងឈឺ ឬគ្រុនចាញ់ ។ យើងត្រូវការលុយដើម្បីទូទាត់ថ្លៃព្យាបាល ដែលជានិច្ចកាលយើងគ្មានលុយដែលសូម្បីតែមួយរៀលផង ។ ប្រសិនបើយើងអាចប្រើប្រាស់ដីធ្វើជារបស់បញ្ចាំបាន យើងអាចទទួលបានលុយខ្លះដើម្បីព្យាបាលជំងឺ បើមិនដូច្នោះទេ យើងនឹងមានបញ្ហាធ្ងន់ធ្ងរ ឬមួយលុះត្រារាជរដ្ឋាភិបាលមានសេវាថែរក្សាសុខភាពល្អៗសំរាប់ពួកយើង ។*

អ្នកចូលរួមក្នុងក្រុមគោលដៅសំរាប់ការពិភាក្សា ក្នុងភូមិព្រែកត្នោត ខេត្តកំពត បានគាំទ្រការយល់ឃើញរបៀបនេះ ។ អ្នកចូលរួមក្នុងក្រុមគោលដៅសំរាប់ការពិភាក្សាពិសេសនេះ ដែលជាចាម និងខ្មែរ បានយល់ព្រមថា :

*ល័ក្ខខ័ណ្ឌទី៥ គួរត្រូវបានបន្ធូរបន្ថយ ។ រាជរដ្ឋាភិបាលគួរធ្វើការលើកលែងចំពោះករណីបញ្ចាំ ឬមួយលក់ដីដែលបានផ្តល់អោយ ។ ការបញ្ចាំ ឬលក់ដីមួយផ្នែកណាមួយនោះ គួរត្រូវអនុញ្ញាត ប្រសិនបើ អ្នកដែលបានទទួលដីនោះពិតជាត្រូវការលុយសំរាប់ដោះស្រាយបញ្ហាអាសន្នមែននោះ ឧទាហរណ៍ ចំពោះជំងឺធ្ងន់ធ្ងរ សួរថាតើត្រូវទុកអោយគាត់ស្លាប់ឬយ៉ាងណា ។*

ទោះជាយ៉ាងណាក៏ដោយ អ្នកដែលគាំទ្រល័ក្ខខ័ណ្ឌនេះក៏បានស្នើថា រយៈពេលដែលអនុញ្ញាតសំរាប់ជួល លក់ ឬដោះដូរ គួរពន្យារអោយបានយូរជាងនេះបន្តិច ។ អ្នកចូលរួមក្នុងក្រុមគោលដៅសំរាប់ការពិភាក្សា ដែលរស់នៅ ក្នុងអតីតតំបន់គ្រប់គ្រងដោយខ្មែរក្រហម ក្នុងត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ បានជំទាស់ថា :

*ប្រសិនបើអ្នកទទួលបានដី ប្រាកដជាត្រូវការដី ហើយមានបំណងចង់រស់នៅក្នុងភូមិជាមួយនឹងពួកយើង គាត់នឹងមិនលក់ដីដែលគេបានអោយទៅគាត់ឡើយ ។ ដូច្នេះហើយ គេគួរតែមិនអនុញ្ញាតអោយគាត់ជួល លក់ ឬដោះដូរអ្វីទាំងអស់ ។ ប័ណ្ណកម្មសិទ្ធិដីធ្លី គួរតែអោយក្រោយរយៈពេល៥ឆ្នាំ ប៉ុន្តែលុះត្រាតែក្រោយរយៈពេល១០ឆ្នាំ ទើបអនុញ្ញាតអោយជួល លក់ ឬដោះដូរដីបាន ។ បើមិនដូច្នោះទេ នៅពេលដែលគាត់លក់ដីនោះទៅ គាត់នឹងក្លាយជាអ្នកដែលគ្មានដីម្តងទៀត ហើយក៏ចាកចេញពីភូមិ ហើយប្រហែលជាអាចនឹងព្យាយាមទៅរកដីទីណាផ្សេងទៀតផង ។*

**ដីដែលនៅទំនេរ**

អ្នកចូលរួមក្នុងក្រុមគោលដៅសំរាប់ការពិភាក្សា ក្នុងភូមិព្រែកត្នោត ខេត្តកំពត បានពន្យល់ថា ហេតុអ្វីបានជាដីទំនេរនៅក្នុងភូមិរបស់គាត់ មិនអាចបង្កបង្កើនផលបាន ។

*ដីធ្លីដែលគ្មានគេប្រើប្រាស់មាននៅក្នុងភូមិរបស់យើង ប៉ុន្តែគេមិនអាចបង្កបង្កើនផលលើដីនោះបានទេ ។ ដីទាំងនោះគ្មានជីជាតិទេ ។ វាគឺជាដីដែលសំបូរថ្ម ។ ទោះជាយ៉ាងណាក៏ដោយ គេអាចប្រើប្រាស់ជាវាលស្មៅសំរាប់សត្វពាហនៈរបស់យើង ។ វាមិនមែនជាដីល្អសំរាប់ដាំដំណាំទេ ។ ប្រសិនបើ យើងធ្វើការដាំដុះ យើងនឹងបាត់ បង់វាលស្មៅ ។ លើសនេះទៅទៀត យើងក៏ចង់អភិវឌ្ឍដីនេះអោយទៅជាដីព្រៃសហគមន៍ ទោះបីជា គេបានកាប់បំផ្លាញព្រៃឈើអស់ខ្លះៗហើយក៏ដោយ ។*

អ្នកចូលរួមក្នុងក្រុមគោលដៅសំរាប់ការពិភាក្សា ក្នុងភូមិរុន ខេត្តស្ទឹងត្រែង មានហេតុផលប្រហាក់ប្រហែលគ្នានេះដែរថា :

*ដីប្រមាណជាង៥០ហិកតា នៅក្នុងភូមិរបស់យើង គ្មាននរណាប្រើប្រាស់វាឡើយ ។ គេអាចផ្ទេរទៅអោយកម្មវិធីសម្បទានដីសង្គមកិច្ច ប៉ុន្តែអាចនឹងមានផលប៉ះពាល់ជាអវិជ្ជមានទៅលើការចិញ្ចឹមជីវិតជីវិតរបស់អ្នកភូមិយើង ។ ជាក់ស្តែងនៅពេលដែលគេដាំដុះ យើងមិនអាចយកជ័រទឹកបានទៀតឡើយ ។ ក្រៅអំពីការដាំដុះដំណាំ យើងពឹងអាស្រ័យលើការប្រមូលជ័រទឹក ។*

អ្នកចូលរួមជាស្ត្រីម្នាក់នៅក្នុងក្រុមគោលដៅសំរាប់ការពិភាក្សា ក្នុងភូមិឈើទាល ខេត្តកំពត បានត្អូញត្អែរថា :

*ដីទំនេរមាននៅក្នុងភូមិរបស់យើង ។ វាជាដីភូមិចាស់ និងដីស្រែរបស់យើង ។ ប៉ុន្តែទាហានបានដេញពួកយើងអោយចាកចេញ ។ យើងមិនអាចប្រើប្រាស់ដីនោះបានទៀតទេ ។ ពួកគេបោះបង្គោលព្រំដីដូច្នេះហើយ យើងមិនអាចយកដីនោះមកវិញបានទេ ។ តើអ្នកណាអាចជួយពួកយើងបាន? ប្រសិនបើដីនោះគេអាចប្រគល់អោយមកពួកយើងវិញបាន យើងមិនចាំបាច់ធ្វើការផ្លាស់ទីទៅណាឡើយ ។*

ខាងក្រោមនេះ គឺជាពាក្យដកស្រង់ចេញពីក្រុមគោលដៅសំរាប់ការពិភាក្សា ក្នុងភូមិញ៉ាងស៊ុម ខេត្តស្ទឹងត្រែង បានឯកភាពថា ដីទំនេរក្នុងភូមិរបស់គាត់ អាចចែកអោយអ្នកតាំងទីលំនៅថ្មី ឬអ្នកមកពីចំងាយបាន ប៉ុន្តែអ្នកភូមិរបស់គាត់ដែលគ្មានដី ត្រូវតែចែកអោយមុនគេ ។

*ដីទំនេរនៅក្នុងភូមិរបស់យើង អាចត្រូវបានធ្វើការបែងចែកជូន ក្រោមកម្មវិធីសម្បទានដីសង្គមកិច្ច ។ ក៏ប៉ុន្តែយើងស្នើថា រាជរដ្ឋាភិបាលចែកដីជូនអ្នកដែលគ្មានដី និងគ្រួសារដែលខ្វះដីដែលរស់នៅក្នុងភូមិយើង មុននឹងអោយដីនេះទៅអ្នកដែលមកតាំងទីលំនៅថ្មីនៅទីនេះ ។ ពេលណាគ្រប់គ្នាដែលរស់នៅទីនេះមានដី*

*គ្រប់គ្រាន់ហើយ ដីដែលនៅសេសសល់បន្ទាប់ពីការបែងចែក អាចផ្តល់ជូនជនកម្ពុជាណាក៏ដោយដែលមកពីគ្រប់ទិសទីក្នុងប្រទេសកម្ពុជាបាន ។*

ស្ត្រីចំណាស់ស្ថិតក្នុងវ័យ៥០ឆ្នាំម្នាក់ក្នុងគ្រួសារដែលគ្មានដី នៅក្នុងក្រុមគោលដៅសំរាប់ការពិភាក្សា ក្នុងភូមិឈើទាល ខេត្តកំពត មិនយល់ស្របយ៉ាងខ្លាំងក្លា ជាមួយនឹងដៃគូការងាររបស់គាត់ចំពោះបញ្ហាតាំងទីលំនៅសាជាថ្មី ។ គាត់បានអះអាងថា :

*ពួកយើងគ្មានដីក៏ដោយសារតែទាហាន ។ ពួកគេបង្ខំអោយយើងចាកចេញពីដីរបស់យើង ។ សូម្បីតែគ្រួសាររបស់ខ្ញុំគ្មានដី និងក្រីក្រក៏ដោយចុះ ខ្ញុំមិនយល់ព្រមដែលថា យើងគួរផ្លាស់ទីលំនៅចេញ ។ យើងនឹងស្នាក់នៅទីនេះ ក្នុងភូមិនេះ ពីព្រោះវាជាភូមិកំណើតរបស់យើង ។ សាច់ញាតិមិត្តភ័ក្រទាំងអស់ និងអ្នកដែលខ្ញុំស្គាល់ទាំងអស់រស់នៅទីនេះ។ ការផ្លាស់ប្តូរទៅកាន់ទីដទៃ មានន័យថា យើងត្រូវតែសំរបសំរួលខ្លួនយើងទៅនឹងស្ថានភាព និងល័ក្ខខ័ណ្ឌថ្មី ។ ឧទាហរណ៍រួមមាន ធាតុអាកាស សហគមន៍ថ្មី បញ្ហាថ្មីជាដើម ។ យើងបន្តលក់កំលាំងពលកម្មនៅទីនេះ សំរាប់ការរស់នៅពីមួយថ្ងៃទៅមួយថ្ងៃ ។ ប្រសិនបើរាជរដ្ឋាភិបាលពិតជាមានសន្ទានចិត្តមែននោះ គួរយកដីពីទាហាន ហើយអោយដីនោះមកពួកយើងវិញ ឬមួយរាជរដ្ឋាភិបាលគួរមានកម្មវិធីប្រសើរជាងនេះ សំរាប់អ្នកក្រីក្រដោយផ្តល់ជាការងាររកចំណូល ។*

ប្រជាពលរដ្ឋរស់នៅកន្លែងដទៃ មានហេតុផលផ្សេងៗទៀតដែរ ដែលលើកទឹកចិត្តពួកគាត់មិនអោយផ្លាស់ប្តូរទីលំនៅ ។ ទោះជាយ៉ាងណាក៏ដោយ ពួកគាត់មិនបានប្រឆាំងយ៉ាងដាច់អហង្ការថា មិនផ្លាស់ប្តូរទីលំនៅនោះទេ ។ អ្នកចូលរួមក្នុងក្រុមគោលដៅសំរាប់ការពិភាក្សា ស្រុកថ្មបាំង ខេត្តកោះកុង បានអះអាងថា :

*យើងគ្មានដី ក៏ប៉ុន្តែពួកយើងមិនចង់ផ្លាស់ចេញពីភូមិរបស់យើងដែរ ព្រោះថាយើងមានទម្លាប់ពឹងពាក់អាស្រ័យទៅលើព្រៃ ។ យើងរស់នៅដោយការប្រមូលយកជ័រទឹក ក្រវាញ បន្លែព្រៃ វល្លិ ផ្តៅ ឃ្មុំ និងផ្លែឈើដទៃទៀត ។ ទោះបីយ៉ាងដូច្នេះក៏ដោយ ថ្មីៗនេះ ជីវភាពរស់នៅរបស់ពួកយើង មានការធ្លាក់ចុះដោយសារតែសកម្មភាពចិញ្ចឹមជីវិតរបស់ពួកយើងទាំងនេះត្រូវបានហាមឃាត់ ដោយអង្គការអភិរក្ស ។*

*មានដីព្រៃរិចរិលដែលគ្មានការប្រើប្រាស់ ។ ដីព្រៃរិចរិលនេះធ្លាប់ប្រើប្រាស់សំរាប់ធ្វើកសិកម្មពនេចរ ក្នុងទសវត្សឆ្នាំ៦០ ប៉ុន្តែគេមិនអនុញ្ញាតអោយយើងប្រើប្រាស់ដីទាំងនេះទៀតឡើយ ។ សូមមេត្តាមើលចុះ ដែលសូម្បីតែដីដែលស្ថិតនៅពីក្រោយផ្ទះរបស់យើង នៅខាងក្រោយចំការ គេមិនអនុញ្ញាតអោយយើងធ្វើការដាំដុះដែរ ។ ពួកអភិរក្សទាំងនេះប្រាប់យើងថា គេមិនអនុញ្ញាតអោយដាំដុះដំណាំអ្វីនៅលើដីនេះពីព្រោះវាមិនល្អចំពោះបរិស្ថានទេ ។ ពួកគេនិយាយថា ពួកយើងបំផ្លាញបរិស្ថាន និងជីវចំរុះផ្សេងៗ ។*

*យើងមិនដែលកាប់ឈើធំៗ ហើយដុតបំផ្លាញវា ដើម្បីយកដីសំរាប់ធ្វើស្រែចំការទេ ។ ដូនតារបស់យើងណែនាំយើងមិនអោយធ្វើយ៉ាងដូច្នោះឡើយ ។ ដូនតាយើងនិយាយថា អំណាចនៃអារក្សថែរក្សាព្រៃ តែងតែរស់នៅលើដីដែលមានដើមឈើធំៗ ។ ដូច្នេះបើយើងហ៊ានប៉ះពាល់ដីនោះ យើងនឹងមានបញ្ហាធ្ងន់ធ្ងរ ។ យើងកាប់ឆ្ការតែដីព្រៃកម្លោតដែលមានឈើខ្លះៗ ហើយដាំដុះដំណាំនៅលើដីនោះ ។ យើងតែងតែវិលត្រឡប់ទៅកាន់ដីដែលយើងធ្លាប់ធ្វើកសិកម្មពនេចរជារៀងរាល់ជាង៥ឆ្នាំម្តង នៅពេលដែលដើមឈើដុះធំល្មមដែលបញ្ជាក់អោយដឹងថា ដីមានជីជាតិឡើងវិញហើយ ។ ហើយទំហំដីជាទូទៅ មានផ្ទៃតូចជាងមួយហិកតាក្នុងមួយគ្រួសារ ។ ប្រសិនបើយើងពិតជាត្រូវការកាប់ដើមឈើធំៗ តួយ៉ាង ដូចជាដើមក្រវ៉ាញ យើងត្រូវរៀបចំពិធីបន់ស្រន់តាមប្រពៃណី ហើយសុំការអនុញ្ញាតពីអារក្សថែរក្សាព្រៃ ។ តែទោះជាយ៉ាងណាក៏ដោយ យើងកម្រកាប់ដើមឈើធំៗណាស់ ។*

*ឥឡូវអ្នកអភិរក្សព្រៃទាំងនេះ មិនយល់ដឹងអោយបានច្រើនអំពីទំនៀមទំលាប់របស់យើង តែផ្ទុយទៅវិញបានបន្ទោសពួកយើងចំពោះការបំផ្លាញព្រៃឈើ បរិស្ថាន និងជីវចំរុះ ។ យើងប្រហែលត្រូវគេជិះជាន់សង្កត់សង្កិនហើយ ។ សូមលោកអ្នកក្រឡេកមើលចុះ ប្រសិនបើរាជរដ្ឋាភិបាលប្រាកដជាយកចិត្តទុកដាក់ចំពោះអ្នកក្រីក្រ យើងស្នើអោយរាជរដ្ឋាភិបាលកុំប្រគល់សិទ្ធិអំណាចទាំងស្រុង ទៅអោយពួកអ្នកអភិរក្សច្រមុះវែងទាំងអស់នេះ ប៉ុន្តែអោយយើងខ្ញុំធ្វើការជាមួយពួកនេះ ដើម្បីកំណត់អោយបានច្បាស់លាស់នូវព្រំប្រទល់តំបន់អភិរក្ស ហើយបន្ធូរបន្ថយច្បាប់ខ្លះៗ ដើម្បីអាចអោយយើងបន្តសកម្មភាពប្រកបរបរចិញ្ចឹមជីវិតរបស់យើងតទៅទៀត ។ កាលពីប៉ុន្មានឆ្នាំមុន នៅពេលដែលសម្បទានិកព្រៃឈើគ្រប់គ្រងព្រៃ យើងនៅមានលទ្ធភាពបន្តសកម្មភាពប្រកបរបរចិញ្ចឹមជីវិតយើងជាធម្មតា ។ អ្នកថ្មីទាំងនេះ យកចិត្តទុកដាក់ច្រើនតែទៅលើរឿងបរិស្ថាន ជាជាងរឿងសិទ្ធិរស់រានមានជីវិតក្នុងភាពជាមនុស្ស ។*

## សមត្ថភាពរបស់បុគ្គលិកគាំទ្របច្ចេកទេសថ្នាក់ខេត្ត ក្រុង

នៅពេលដែលគណៈកម្មការប្រើប្រាស់ និងបែងចែកដីធ្លីខេត្ត (PLUAC) ក្រុងភាគច្រើន រាយការណ៍អោយដឹងថា ពួកគេមានលទ្ធភាពច្រើនសំរាប់ធ្វើការងារ ដែលដាក់អោយធ្វើដោយអគ្គលេខាធិការដ្ឋានសម្បទានដីសង្គមកិច្ច (SSLC) ក៏នៅមានចំនួនជាងពាក់កណ្តាលនៃក្រុមនេះ សំដែងអោយឃើញនូវក្តីកង្វល់លើសមត្ថភាពនៃបុគ្គលិកអង្គភាពគាំទ្របច្ចេកទេសរបស់ពួកគេក្នុងការជួយគាំទ្រពួកគេ ។ មានចំនួនតែពាក់កណ្តាលនៃក្រុមនេះជឿជាក់ថា បុគ្គលិកអង្គភាពគាំទ្របច្ចេកទេសរបស់ពួកគេ អាចមានលទ្ធភាពផ្តល់ជូននូវការគាំទ្របច្ចេកទេស ក្នុងទិដ្ឋភាពការងារទាំងអស់ ។ ឧទាហរណ៍ នៅខេត្តស្ទឹងត្រែង សមាជិកគណៈកម្មការប្រើប្រាស់និងបែងចែកដីធ្លីខេត្តមានវត្តមាននៅក្នុងអង្គប្រជុំជាមួយនឹងក្រុមចុះមូលដ្ឋាន បានពន្យល់ថា :

*បុគ្គលិកអង្គភាពគាំទ្របច្ចេកទេសរបស់យើង អាចធ្វើការងារបច្ចេកទេសបាន ប៉ុន្តែពួកគេត្រូវការវគ្គបណ្តុះបណ្តាលខ្លះៗថែមទៀត ។ បញ្ហារបស់ពួកគេ គឺបញ្ហាការងារអភិវឌ្ឍន៍ ។ ពួកគេមានការពិបាកក្នុងការ*

*ធានាថា ហេដ្ឋារចនាសម្ព័ន្ធដែលពាក់ព័ន្ធគ្នា សេវាកម្ម និងសម្ភារៈ ត្រូវបានធ្វើសមាហរណកម្ម នៅក្នុងផែនការ និងក្នុងការត្រួតពិនិត្យការងារអភិវឌ្ឍន៍ ។ ពួកគេនឹងត្រូវការវគ្គបណ្តុះបណ្តាលជាច្រើន ក្នុងទិដ្ឋភាពអស់ទាំងនេះ ។*

នៅខេត្តឧត្តរមានជ័យ សមាជិកគណៈកម្មការប្រើប្រាស់ និងបែងចែកដីធ្លីខេត្ត មានការព្រួយបារម្ភជាពិសេស លើទិដ្ឋភាពបច្ចេកទេសទាក់ទងនឹងដី សំរាប់បុគ្គលិកអង្គភាពគាំទ្របច្ចេកទេស ។

*ខេត្តរបស់យើង គឺជាខេត្តថ្មីជាមួយនឹងសមត្ថភាពបុគ្គលិកនៅមានកំណត់ ។ ការពិបាកសំរាប់បុគ្គលិកអង្គភាពគាំទ្របច្ចេកទេសរបស់ពួកយើង រួមមានការកំណត់ និងជ្រើសរើសអ្នកទទួលផល ការត្រួតពិនិត្យកម្មវិធី និងអ្នកទទួលផល សនិទានកម្មដីឡូត៍/ក្បាលដីឡូត៍ និងចំនួនអ្នកទទួលផល និងការធានាថាការធ្វើសមាហរណកម្មហេដ្ឋារចនាសម្ព័ន្ធដែលពាក់ព័ន្ធគ្នា សេវាកម្ម និងសម្ភារៈនៅក្នុងផែនការ ។ ពួកគេនឹងត្រូវការវគ្គបណ្តុះបណ្តាលលើទិដ្ឋភាពនិងគោលការណ៍ណែនាំទាំងឡាយ ។ ធនធានថវិកា នឹងក្លាយជាឧបស័គ្គឱ្យដែរ ។*

សមាជិកគណៈកម្មការប្រើប្រាស់ និងបែងចែកដីធ្លីខេត្ត នៅខេត្តកំពង់ចាម បានពន្យល់ថា :

*ថវិកា និងសម្ភារៈដែលគាំទ្រពីថ្នាក់ជាតិ នឹងមិនគ្រប់គ្រាន់ឡើយ ។ វគ្គបណ្តុះបណ្តាលបច្ចេកទេស នៅតែត្រូវការ ។ ឧទាហរណ៍ ការកំណត់ដីធ្លី ការធ្វើចំណាត់ថ្នាក់ដីធ្លី ការជ្រើសរើសអ្នកទទួលផល ...។ល។ ប៉ុន្តែរឿងសំខាន់គឺទាក់ទងនឹងច្បាប់ អនុក្រឹត្យ និងប្រកាស ត្រូវតែធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងការគាំទ្រគោលការណ៍ណែនាំ និងនីតិវិធីទាំងឡាយត្រូវតែមានសំរាប់អោយយើងអនុវត្ត បើមិនដូច្នោះទេ ច្បាប់ និងអនុក្រឹត្យ នៅតែគ្មានប្រយោជន៍ដដែល ។*

## សមត្ថភាពនៃក្រុមការងារស្រុក ខណ្ឌ

ចំនួនសមាជិកជាស្ត្រីនៅក្នុងក្រុមការងារស្រុក ខណ្ឌនៅមានកំរិត ។ ជាមធ្យមគឺមានតែស្ត្រីម្នាក់គត់ ជាសមាជិកនៅក្នុងក្រុមការងារស្រុក ខណ្ឌនីមួយៗ ។ ប្រហាក់ប្រហែលគ្នានេះដែរ សមាជិកភាពស្ត្រីមានចំនួនតិចនៅក្នុងគណៈកម្មការប្រើប្រាស់ និងបែងចែកដីធ្លីខេត្ត ក្រុង ។ នៅខេត្តស្ទឹងត្រែង គណៈកម្មការប្រើប្រាស់ និងបែងចែកដីធ្លីខេត្ត បានផ្តល់ហេតុផលដែលបណ្តាលអោយមានសមាជិកភាពស្ត្រីទាបនៅក្នុងក្រុមការងារស្រុកថា :

*នៅក្នុងខេត្តរបស់យើង ជាមធ្យមមានសមាជិកចំនួនប្រាំពីរនាក់ នៅក្នុងក្រុមការងារស្រុក ដែលទទួលការតែងតាំងសំរាប់កម្មវិធីសម្បទានដីសង្គមកិច្ច ។ កម្រមានស្ត្រីនៅក្នុងក្រុមណាស់ ។ នៅក្នុងក្រុមការងារស្រុកទាំង៥របស់យើង គឺមានតែមួយក្រុមទេដែលមានស្ត្រីជាសមាជិកម្នាក់ ។ នៅក្នុងខេត្តរបស់យើង មានការពិបាកណាស់សំរាប់ពួកយើង ដើម្បីទទួលបានមាជិកភាពរបស់ស្ត្រី ។ ជាការពិត គឺមានស្ត្រីតិចតួចណាស់ដែលមានការសិក្សា ដើម្បីជាសមាជិកនៃក្រុមការងារស្រុក ។*

មានចំនួនប្រហែលមួយភាគប្រាំនៃក្រុមការងារស្រុក ខណ្ឌ ចង់ទទួលបានការគាំទ្រពីថ្នាក់ខេត្ត ក្រុង និងថ្នាក់ជាតិ ។ ក្រុមការងារស្រុក ក្នុងខេត្តស្ទឹងត្រែង បានសំដែងអោយឃើញនូវតំរូវការលើការគាំទ្រថា :

*ដូចដែលពួកយើងបាននិយាយពីមុនមកហើយ ពួកយើងអាចធ្វើការដូចដែលបានដាក់ជូនដោយអគ្គលេខាធិការដ្ឋានសម្បទានដីសង្គមកិច្ច ដោយសារតែ យើងបានធ្វើការងារប្រហាក់ប្រហែលនឹងការងារនេះ នៅក្នុងស្រុករបស់យើងពីមុនមកហើយ ប៉ុន្តែគ្រាន់តែមានលក្ខណៈតូចតាច និងយូរ១ម្តងប៉ុណ្ណោះ ។ ឥឡូវនេះមានក្របខ័ណ្ឌច្បាប់ដែលយើងត្រូវតែអនុវត្តតាម ។ ដើម្បីយល់ដឹង និងអនុវត្តក្របខ័ណ្ឌច្បាប់ទាំងនេះបានវាមិនមែន ជាការងារស្រួលឡើយ ។ ដូច្នេះយើងត្រូវការការគាំទ្រពីថ្នាក់ទាំងពីរ គឺថ្នាក់ជាតិ និងថ្នាក់ខេត្ត ។ វគ្គបណ្តុះបណ្តាលបច្ចេកទេសសំរាប់សមាជិកក្រុមការងារស្រុករបស់ពួកយើង គឺជាអាទិភាព ។ ពួកគេត្រូវតែមានលទ្ធភាពដើម្បីផ្ទេរចំណេះដឹងតាមរយៈវគ្គបណ្តុះបណ្តាលទៅអោយក្រុមប្រឹក្សាឃុំ ។ ការផ្សព្វផ្សាយក្របខ័ណ្ឌចច្បាប់ និងព័ត៌មានអំពីកម្មវិធីទៅដល់សាធារណជន គឺជាការចាំបាច់ជាទីបំផុតទីពីរ ។ ជាចុងក្រោយ នៅក្នុងអំឡុងពេលនៃការអនុវត្តកម្មវិធី យើងនឹងត្រូវការការគាំទ្រពីអ្នកបច្ចេកទេសនៃគណៈកម្មការប្រើប្រាស់ និងបែងចែកដីធ្លីខេត្ត ។*

នៅស្រុកស្រែអំបិល ខេត្តកោះកុង ក្រុមការងារស្រុក បានសំដែងអោយឃើញប្រហាក់ប្រហែលគ្នា ប៉ុន្តែមានភាពជាក់លាក់ជាងអំពីការគាំទ្រ :

*មុននឹងមានការអនុវត្តកម្មវិធីជាក់ស្តែង វគ្គបណ្តុះបណ្តាលអំពីការកំណត់ដីធ្លី ការធ្វើចំណាត់ថ្នាក់ដីធ្លី និងការរៀបចំផែនការប្រើប្រាស់ដី (ឧទាហរណ៍ គណៈកម្មការប្រើប្រាស់ និងបែងចែកដីខេត្ត) ការកំណត់ និងការជ្រើសរើសអ្នកទទួលផលសំខាន់ និងក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធ (ដោយរាប់បញ្ចូលទាំងច្បាប់ភូមិបាល) ត្រូវតែបណ្តុះបណ្តាលទៅដល់បណ្តាសមាជិកនៃក្រុមការងារស្រុក ។ យ៉ាងហោចណាស់អ្នកបច្ចេកទេសម្នាក់ត្រូវបានចាត់អោយមកធ្វើការជាមួយពួកយើងសំរាប់ភូមិមួយ ជាការដកពិសោធន៏ ដើម្បីអោយយើងអាចទទួលបាននូវបទពិសោធន៏អនុវត្តជាក់ស្តែងនៅមូលដ្ឋាន ។ លើសនេះទៅទៀតអនុញ្ញាតអោយមានសម្ភារៈការិយាល័យ សំរាប់អោយយើងអនុវត្តកម្មវិធី យើងនឹងត្រូវការមធ្យោបាយធ្វើដំណើរ និងថវិកា ។*

ក្រុមការងារស្រុកសង្គមថ្មី ខេត្តព្រះវិហារ ដែលលទ្ធភាពទៅដល់ទីកន្លែងនោះ គឺជាបញ្ហាសំខាន់ បានស្នើសុំការគាំទ្រតែមួយគត់ :

*នៅមានដីទំនេរច្រើនណាស់នៅទីនេះ ។ ឥឡូវនេះរាជរដ្ឋាភិបាលមានកម្មវិធីសម្បទានដីសង្គមកិច្ច ។ អ្វីដែលយើងត្រូវការនោះ គឺវគ្គបណ្តុះបណ្តាលបច្ចេកទេសអំពីការរៀបចំដែនដី និងរដ្ឋបាលដីធ្លី អនុក្រឹត្យលេខ១៩* (អនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច) *និងសេចក្តីណែនាំ និងនីតិវិធីសំរាប់អនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច ។ ទោះជាយ៉ាងណាក៏ដោយ លោកអ្នកគួរកត់សំគាល់ថា ប្រហាក់ប្រហែលនឹងស្ថាប័នផ្សេង*

*ទៀតរបស់រាជរដ្ឋាភិបាលដែរ ស្រុករបស់យើងមិនមានធនធានថវិកាគ្រប់គ្រាន់ សំរាប់ប្រតិបត្តិការការងារពួកយើងខ្លួនឯងឡើយ ។*

## សមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់

កិច្ចការ ការទទួលខុសត្រូវ និងតួនាទីដែលពួកគេបានធ្វើ បានសង្ខេបដោយការពិនិត្យវាយតំលៃជនបទដោយមានការចូលរួម (PRA) ជាមួយនឹងក្រុមប្រឹក្សាឃុំបាក់អន្លង់[១៩] ខេត្តឧត្តរមានជ័យ :

*ក្រុមប្រឹក្សាឃុំរបស់យើងអនុវត្តតួនាទី និងការងារ ជាអាទិ៍រួមមាន ១).ប្រមូលនិងរាយការណ៍អំពីស្ថិតិប្រជាពលរដ្ឋ/មនុស្សសាស្ត្រនិងផលិតផល ។ ២).រក្សាទិន្នន័យកំណើត (អត្រានុកូលដ្ឋានកំណើត អាពាហ៍ពិពាហ៍ និងស្លាប់) ។ ៣).រៀបចំចងក្រងផែនការអភិវឌ្ឍន៍និងវិនិយោគឃុំ ។ ៤).ផ្តល់ការណែនាំអំពីប្រធានបទកសិកម្មនិងវិស័យពាក់ព័ន្ធផ្សេងៗ ។ ៥).ដោះស្រាយជាមួយមូលដ្ឋាននូវជំលោះតូចតាច និងពង្រឹងច្បាប់នៅមូលដ្ឋាន ។*

អ្នកចូលរួមនៅក្នុងក្រុមគោលដៅសំរាប់ការពិភាក្សា ក្នុងភូមិថ្នល់គង ខេត្តព្រះវិហារ បានបរិយាយយ៉ាងល្អិតល្អន់អំពីចំណេះដឹងការងាររបស់ក្រុមប្រឹក្សាឃុំថា :

*យើងពិតជាមិនបានយល់ច្រើន នូវអ្វីដែលក្រុមប្រឹក្សាឃុំបានធ្វើឡើយ ។ តាមអ្វីដែលយើងដឹង ពួកគេបានធ្វើកិច្ចការមួយចំនួនតូច ។ ពួកគេធ្វើការយ៉ាងជិតស្និទ្ធិជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាលនានា ដើម្បីទទួលបានការគាំទ្រ ក្នុងការជីកអណ្តូង សាងសង់សាលារៀន និងផ្លូវនៅមូលដ្ឋាន ។*

នៅថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង អ្នកភូមិនៅក្នុងក្រុមគោលដៅសំរាប់ការពិភាក្សា ហាក់ដូចជាមានការយល់ឃើញដូចគ្នាដែរ អំពីការងារដែលក្រុមប្រឹក្សាឃុំបានធ្វើ ចំពោះអ្វីដែលក្រុមប្រឹក្សាឃុំ បានរាយការណ៍ខាងលើថា :

*យើងមិនបានដឹងថាតើក្រុមប្រឹក្សាឃុំ បានធ្វើអ្វីឡើយក្រោយពីពួកគាត់ ត្រូវបានជ្រើសរើសតាមការបោះឆ្នោតរួចមក ។ ពួកគាត់បានប្រមូលស្ថិតិប្រជាពលរដ្ឋ និងឯកសារដីធ្លីដែលបានប្រើប្រាស់ និងកាន់កាប់ដោយអ្នកភូមិ ។ ហើយពួកគាត់ក៏បានប្រាប់យើងថា ឈប់កាប់ដើមឈើនៅក្នុងតំបន់នេះ តទៅទៀតដោយហេតុថាតំបន់នេះ នឹងត្រូវផ្ទេរធ្វើជាតំបន់ការពារ ។*

ទោះជាយ៉ាងណាក៏ដោយ ពួកគាត់ស្នើថា ក្រុមប្រឹក្សាឃុំ គួរទទួលបាននូវការគាំទ្របច្ចេកទេស សម្ភារៈ និងថវិកាគ្រប់គ្រាន់ ។ ក្រុមគោលដៅសំរាប់ការពិភាក្សា ក្នុងភូមិកោះស្លា ខេត្តកំពត បានស្នើថា :

*ថ្វីត្បិតតែក្រុមប្រឹក្សាឃុំអាចធ្វើការងារបានមួយចំនួនមែន ពួកគាត់នឹងមិនអាចមានលទ្ធភាពធ្វើការងារទាំងនោះដោយមធ្យោបាយសព្វយ៉ាងដោយខ្លួនឯងបានទេ ពោលគឺពួកគាត់ត្រូវការការគាំទ្រ ។ ការគាំទ្រ*

---

[១៩] បាក់អន្លង់ គឺជាអតីតតំបន់គ្រប់គ្រងដោយពួកខ្មែរក្រហមក្បាលរឹងក្នុងស្រុកត្រពាំងប្រាសាទ ។

*ទាំងនោះអាចរាប់បញ្ចូលរួមមាន វគ្គបណ្តុះបណ្តាលបច្ចេកទេស និងទិដ្ឋភាពច្បាប់ ថវិកា និងធនធានមនុស្សជាច្រើនទៀត ។ ឥឡូវនេះ ក្រុមប្រឹក្សាឃុំ ស្មើរតែដេកស្លក ថ្វីត្បិតតែពួកគាត់ធ្វើការងារបន្តិចបន្តួចដូចជាដោះស្រាយវិវាទនៅមូលដ្ឋាន និងរៀបចំផែនការអភិវឌ្ឍន៍ ។ មូលហេតុសាមញ្ញ ដោយសារមិនមានមនុស្សគ្រប់ចំនួន ។*

អ្នកចូលរួមក្នុងក្រុមគោលដៅសំរាប់ការពិភាក្សា ក្នុងភូមិចែងមានជ័យ ខេត្តបាត់ដំបង ហាក់យល់ព្រមនឹងយោបល់នេះ ជាពិសេសអំពីបញ្ហាសមត្ថភាពបច្ចេកទេសរបស់ក្រុមប្រឹក្សាឃុំ ។ ពួកគាត់បានផ្តល់ជាអនុសាសន៍ថា :

*ក្រុមប្រឹក្សាឃុំ មិនធ្វើការងារបានដោយខ្លួនឯងទេ ។ យើងផ្តល់អនុសាសន៍ថា ពួកគាត់ជាបឋម គួរត្រូវទទួលបាននូវវគ្គបណ្តុះបណ្តាលបច្ចេកទេសល្អៗសិន ហើយនៅក្នុងអំឡុងពេលអនុវត្តន៍ អ្នកបច្ចេកទេសដែលប្រហែលជាមកពីបណ្តាអង្គការមិនមែនរដ្ឋាភិបាល គួរត្រូវបានចាត់តាំងអោយធ្វើការយ៉ាងជិតស្និទ្ធជាមួយពួកគាត់ ដើម្បីផ្តល់ការគាំទ្រផ្នែកបច្ចេកទេស ។*

អ្នកចូលរួមនៅក្នុងក្រុមគោលដៅសំរាប់ការពិភាក្សាក្នុងភូមិប៉ាល់ហាល់ ខេត្តព្រះវិហារ បានចូលរួមការយល់ឃើញអំពីបញ្ហានេះថា :

*ថ្វីបើយើងគិតថា ក្រុមប្រឹក្សាឃុំ អាចធ្វើការងារទាំងអស់ដែលទាក់ទងនឹងកម្មវិធីសម្បទានដីសង្គមកិច្ចបាន យើងត្រូវនិយាយថា ក្រុមប្រឹក្សាឃុំគួរទទួលបាននូវមធ្យោបាយធ្វើដំណើរ សម្ភារៈ បច្ចេកទេស និងថវិកាគ្រប់គ្រាន់ ។ ប៉ុន្តែអ្វីដែលពួកគាត់ត្រូវការជាទីបំផុតនោះ គឺវគ្គបណ្តុះបណ្តាលបច្ចេកទេស ជាឧទាហរណ៍អំពីផែនការប្រើប្រាស់ដីធ្លី និងការធ្វើចំណាត់ថ្នាក់ដីធ្លី ។*

ព័ត៌មានមួយស្តីពីក្រុមប្រឹក្សាឃុំ ដែលទទួលបានមកពីការងារនៃការពិនិត្យវាយតំលៃជនបទដោយមានការចូលរួម (PRA) ដែលធ្វើការជាមួយពួកគាត់ ត្រូវបានដកស្រង់ដូចខាងក្រោម :

*ជាការពិតដោយគ្មានការសង្ស័យដែលថា ពួកយើងនឹងអាចធ្វើការងារបានខ្លះៗ ដូចដែលមានចែងនៅក្នុងអនុក្រឹត្យ ។ ដើម្បីធ្វើការងារអោយបានល្អ នៅក្នុងកម្មវិធីសម្បទានដីសង្គមកិច្ច យើងនឹងត្រូវការការជួយឧបត្ថម្ភបីសំខាន់ គឺ : ១).ផ្តល់វគ្គបណ្តុះបណ្តាលបច្ចេកទេសអោយបានសមស្រប លើការងារចំណាត់ថ្នាក់ដីធ្លី និងការគ្រប់គ្រងការអនុវត្តកម្មវិធី ២).ចាត់តាំងអ្នកបច្ចេកទេសខាងការគ្រប់គ្រង និងរដ្ឋបាលដើម្បីផ្តល់ការគាំទ្រដល់យើងជាប្រចាំ ៣).គាំទ្រផ្នែកថវិកាដល់ពួកយើង ។*

អ្នកចូលរួមក្នុងការពិនិត្យវាយតំលៃជនបទដោយមានការចូលរួម (PRA) នៅក្នុងក្រុមការងារស្រុកឈូក ខេត្តកំពត បានគាំទ្រការយល់ឃើញនេះថា :

*ក្រុមប្រឹក្សាឃុំនឹងត្រូវការអ្នកបច្ចេកទេស ដើម្បីផ្តល់ការគាំទ្រជាប្រចាំ ដើម្បីអោយពួកគាត់អាចធ្វើការ*

*ងារបាន ។ ជាងនេះទៀត ពួកគាត់នឹងត្រូវតែទទួលបាននូវវគ្គបណ្តុះបណ្តាលផ្នែកច្បាប់ និងបច្ចេកទេសផងដែរ ។ តាមពិតទៅ ពួកគាត់នឹងគ្មានលទ្ធភាពអនុវត្តកម្មវិធី ដោយគ្មានថវិកា សម្ភារៈ បច្ចេកទេស និងមធ្យោបាយធ្វើដំណើរបានឡើយ ។*

ក្នុងភូមិបានប៉ុង ខេត្តស្ទឹងត្រែង អ្នកចូលរួមនៅក្នុងក្រុមគោលដៅសំរាប់ការពិភាក្សា បានអះអាងថា ក្រុមប្រឹក្សាឃុំ មិនអាចធ្វើការដោយគ្មានការគាំទ្រសមស្របបានឡើយ ។

*ក្រុមប្រឹក្សាឃុំ នឹងមិនមានសមត្ថភាពធ្វើការ និងអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចបានទេ ។ ពួកគាត់អាចធ្វើការងារទាំងនេះបាន លុះត្រាណាពួកគាត់បានទទួលការគាំទ្របច្ចេកទេសគ្រប់គ្រាន់ ពីការិយាល័យកម្មសិទ្ធិ និងគ្រប់គ្រងដីធ្លីថ្នាក់ខេត្ត និងស្រុក និងអង្គការមិនមែនរដ្ឋាភិបាល ។*

ក្រុមប្រឹក្សាឃុំរកវាយ ខេត្តព្រះវិហារ ក៏បានទទួលស្គាល់ ដោយឥតលាក់លាមចំពោះសមត្ថភាពមានកំរិតរបស់ពួកគាត់ ក្នុងការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច ហើយអំពាវនាវរកការគាំទ្រថា :

*ដោយស្មោះត្រង់ទៅ ក្រុមប្រឹក្សាឃុំរបស់យើង នឹងគ្មានលទ្ធភាពដើម្បីអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចបានទេ ព្រោះថាយើងគ្មានមនុស្សគ្រប់គ្រាន់ ហើយជាពិសេស យើងគ្មានជំនាញបច្ចេកទេស ហើយការសិក្សា និងចំណេះដឹងរបស់យើងក៏មានកំរិតទៀត ។ លើសនេះទៅទៀត យើងគ្មានបទពិសោធន៍កន្លងមកដែលពាក់ព័ន្ធនឹងកម្មវិធី ។ ដើម្បីអោយយើងអាចអនុវត្តកម្មវិធីបាន យើងនឹងត្រូវការរាល់ការគាំទ្របច្ចេកទេសដែលនឹងបានផ្តល់អោយដោយក្រុមការងារស្រុក ហើយយើងនឹងត្រូវការមនុស្សម្នាក់ ដែលមានចំណេះដឹងអំពីកម្មវិធី ដើម្បីជួយយើងជាប្រចាំ ។*

## ការចូលរួមនៃក្រុមដទៃទៀត

ការពិភាក្សាបានរៀបចំឡើង ដោយមានអ្នកចូលរួមនៅក្នុងក្រុមគោលដៅសំរាប់ការពិភាក្សា និងអ្នកដែលយើងសំភាសន៍ដែលជាមេគ្រួសារ ដើម្បីស្វែងយល់អំពីហេតុផលដែលស្ថិតនៅពីក្រោយការគិតរបស់ពួកគេ អំពីការចូលរួមរបស់ក្រុមក្រៅប្រព័ន្ធនៅក្នុងកម្មវិធីសម្បទានដីសង្គមកិច្ច និងសកម្មភាពនៃកម្មវិធីសម្បទានដីសង្គមកិច្ច ។ អ្នកភូមិឡាកាយ ខេត្តស្ទឹងត្រែង ពន្យល់ហេតុផលរបស់ពួកគេ ក្នុងការស្នើសុំអោយមានការចូលរួមរបស់ក្រុម និងមនុស្សដូចដែលបានរៀបរាប់ ខាងលើថា :

*ត្រូវតែអោយមានចាស់ទុំក្នុងភូមិចូលរួម ។ យើងគោរពពួកគាត់និងជឿជាក់លើពួកគាត់ ។ ពួកគាត់អាចជួយកំណត់សិទ្ធិរបស់អ្នកទទួលផល និងធ្វើជាសាក្សីក្នុងដំណើរការនិងការអនុវត្តកម្មវិធី ។ មន្ត្រីរាជរដ្ឋាភិបាល ជាពិសេសមកពីក្រសួងយុត្តិធម៌ គួរចូលរួមនៅក្នុងកម្មវិធីដើម្បីធានាយុត្តិធម៌និងសមធម៌ផងដែរ ។*

អ្នកចូលរួមនៅក្នុងក្រុមគោលដៅសំរាប់ការពិភាក្សានៅរលំវែង ខេត្តឧត្តរមានជ័យ អោយដឹងពីមូលហេតុ ដែលពួកគេស្នើសុំថា ការចាប់ឆ្នោត គួរត្រូវយកមកប្រើដើម្បីធានាសមធម៌ និងការដែលអាចទទួលយកបាន ។

*មានបញ្ហាពុករលួយជាច្រើន ក្នុងន័យបក្សពួកនិយម និងការយកលុយ ។ ជាឧទាហរណ៍ ប្រជាពលរដ្ឋ ដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយនឹងមន្ត្រីដែលទទួលខុសត្រូវការងារបែងចែកដី អាចនឹងទទួលបានដី ដែលល្អ ឬមួយនៅពេលខ្វះដី ពួកគេអាចក្លាយជាអ្នកមានអាទិភាពបាន ។ ដើម្បីជៀសវាងបញ្ហានេះ ជាដំបូងគេត្រូវធ្វើការកំណត់នូវដីដែលមាន និងបង់លេខឬទុកអោយគ្មានលេខ (ទទេ) គួរត្រូវកំណត់ទៅ អោយដីឡូត៍ដែលកំពុងមានស្រាប់ ឬដែលគ្មានសំរាប់បែងចែក ។ ពេលនោះអ្នកដែលគ្មានដី ជាឧទាហរណ៍ អ្នកដែលអាចជាអ្នកទទួលផលពីកម្មវិធី គួរហៅអោយមកចាប់ឆ្នោតដោយចៃដន្យ ។*

ប្រជាពលរដ្ឋនៅផ្អាវ ខេត្តឧត្តរមានជ័យ បានដាក់ការជឿទុកចិត្តទៅលើអង្គការមិនមែនរដ្ឋាភិបាល ។ ពួកគាត់ជឿថា អង្គការមិនមែនរដ្ឋាភិបាលអាចធានានូវតម្លាភាព និងការដែលអាចទទួលយកបាននៃកម្មវិធី ។ ពួកគាត់ បានពន្យល់ថា :

*នៅពេលភ្នាក់ងាររាជរដ្ឋាភិបាលនឹងអនុវត្តកម្មវិធី យើងខ្ញុំគិតថាអង្គការមិនមែនរដ្ឋាភិបាលគួរចូលរួម ។ អង្គការមិនមែនរដ្ឋាភិបាលអាចធ្វើជាអ្នកសង្កេតការណ៍ ដែលនឹងពិនិត្យលើភាពស្មោះត្រង់ និងគណនេយ្យ ភាពមន្ត្រីរាជរដ្ឋាភិបាលដែលទទួលខុសត្រូវកម្មវិធី ។*

ប្រជាពលរដ្ឋនៅស្រែពស់ ខេត្តស្ទឹងត្រែង គ្មានអ្វីជំទាស់ទៅនឹងសំណើនេះទេ ។ ពួកគាត់ពន្យល់មូលហេតុ ដែលគាត់ចង់អោយអង្គការមិនមែនរដ្ឋាភិបាលចូលរួមក្នុងកម្មវិធី និងអ្វីដែលអង្គការមិនមែនរដ្ឋាភិបាលអាចធ្វើបាន។

*យើងស្នើថា អង្គការមិនមែនរដ្ឋាភិបាល គួរចូលរួមធ្វើជាអ្នកសង្កេតការណ៍ ដើម្បីធានាថា កម្មវិធីមានយុត្តិធម៌ និងគ្មានភាពលំអៀង ពីព្រោះពួកនេះមិនមានចំណេញផលប្រយោជន៍អ្វីណាមួយឡើយ ប៉ុន្តែពួកគេយកចិត្ត ទុកដាក់តែមនុស្សតែប៉ុណ្ណោះ ។ ពួកគេគួរចូលរួម ជាពិសេសក្នុងពេលកំណត់ដី ការជ្រើសរើសអ្នកទទួលផល និងដំណាក់កាលបែងចែក ។*

## **ការផ្សព្វផ្សាយអំពីសកម្មភាពនៃកម្មវិធីរបស់គណៈកម្មការប្រើប្រាស់ និងបែងចែកដីធ្លីខេត្ត ក្រុង**

ការចែកចាយព័ត៌មាន និងក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធនឹងកម្មវិធីជាមួយសាធារណជន ត្រូវបានចាត់ទុកថា ជាការចាំបាច់សំរាប់សហគមន៍មួយចំនួន ដើម្បីធានាតម្លាភាពនៃកម្មវិធី ។ សហគមន៍ទាំងនេះប្រាថ្នាថា ការប្រកាសជាសាធារណៈអំពីកម្មវិធី មុនការអនុវត្តកម្មវិធីជាក់ស្តែង គួរត្រូវបានធ្វើឡើង ដើម្បីអោយប្រជាពលរដ្ឋអាចយល់ដឹងអំពីកម្មវិធីបានល្អ ហើយអាចមកពិភាក្សាអំពីកម្មវិធី ។ ប្រជាពលរដ្ឋក្នុងភូមិបុស្ស ខេត្តព្រះវិហារ បានបន្លឺការយល់ឃើញរបស់គាត់អំពីរឿងនេះថា :

*រាជរដ្ឋាភិបាលមានគោលនយោបាយ និងក្របខ័ណ្ឌច្បាប់សំរាប់កម្មវិធី ។ ដើម្បីធានាតម្លាភាព រាជរដ្ឋាភិបាលគួរធ្វើសេចក្តីប្រកាសជាសាធារណៈអំពីកម្មវិធីនេះ ។ គេត្រូវតែប្រាប់ប្រជាពលរដ្ឋអោយដឹង នូវអ្វីដែលកំពុងកើតមានឡើង ។ នៅពេលដែលបានប្រាប់ពួកគាត់ ពួកគាត់អាចដឹងអំពីកម្មវិធីនេះ ហើយអាចពិភាក្សាអំពីបញ្ហាដែលអាចកើតមានឡើង ។*

ប្រជាពលរដ្ឋភូមិសំបូរ ខេត្តឧត្តរមានជ័យ បានផ្តល់ការយល់ឃើញស្រដៀងគ្នាថា :

*រាជរដ្ឋាភិបាលមានក្របខ័ណ្ឌច្បាប់ ដែលបញ្ជាក់យ៉ាងច្បាស់លាស់អំពីលក្ខណៈវិនិច្ឆ័យ សំរាប់បេក្ខជនទទួលបាននូវសិទ្ធិសំរាប់កម្មវិធី ។ ក្របខ័ណ្ឌច្បាប់នេះ ត្រូវតែធ្វើការផ្សព្វផ្សាយអោយបានទូលំទូលាយ និងចែកចាយក្នុងចំណោមប្រជាពលរដ្ឋ ដើម្បីអាចអោយគាត់ដឹងច្បាស់លាស់អំពីកម្មវិធី ។ នៅពេលដែលគេប្រាប់គាត់ ពួកគាត់អាចដឹងថាតើលក្ខណៈវិនិច្ឆ័យមានភាពយុត្តិធម៌ ឬមិនយុត្តិធម៌ ។ ហើយបន្ទាប់មកនៅពេលពួកគាត់ដឹងច្បាស់លាស់អំពីលក្ខណៈវិនិច្ឆ័យ ពួកគាត់អាចវិនិច្ឆ័យថាតើការអនុវត្តកម្មវិធី មានភាពយុត្តិធម៌ ឬមិនយុត្តិធម៌ ក្នុងដំណាក់កាលនៃការអនុវត្តកម្មវិធី ។*

## ការមិនអាចជៀសវាងបាននៃវិវាទដីធ្លី

សមាជិកក្រុមការងារស្រុក នៅស្រុកបវេល ខេត្តបាត់ដំបង បានថ្លែងអោយដឹងថា :

*នៅក្នុងខេត្តបាត់ដំបង មានរឿងវិវាទដីធ្លីច្រើនណាស់ ។ ចំពោះកម្មវិធីសម្បទានដីសង្គមកិច្ច វិវាទអាចនឹងកើតមានឡើង ។ ប៉ុន្តែរឿងដែលសំខាន់នោះ គឺត្រូវជៀសវាង ឬកាត់បន្ថយវិវាទទាំងនេះ ។ មានការពិបាកខ្លាំងណាស់ក្នុងការដោះស្រាយវិវាទទាំងនេះ នៅពេលដែលវាកើតឡើង ។ គឺធ្វើអោយយើងឈឺក្បាលយ៉ាងខ្លាំង ហើយវាមានតំលៃថ្លៃខ្លាំងណាស់ ។ វិធានការដើម្បីកាត់បន្ថយវិវាទទាំងនេះ គឺធ្វើការផ្សព្វផ្សាយក្របខ័ណ្ឌច្បាប់ដែលពាក់ព័ន្ធអោយបានទូលំទូលាយ ហើយផ្តល់វគ្គបណ្តុះបណ្តាលដល់អ្នកធ្វើការដែលពាក់ព័ន្ធអំពីច្បាប់ ជាពិសេសប្រជាពលរដ្ឋមូលដ្ឋាន ។ ពន្យល់ពួកគាត់ អំពីគោលនយោបាយចែកចាយដីធ្លីអោយបានច្បាស់លាស់ និងលក្ខណៈវិនិច្ឆ័យសំរាប់បេក្ខភាពដែលទទួលបាននូវសិទ្ធិ ។ (សមាជិកក្រុមការងារស្រុកបវេល ខេត្តបាត់ដំបង បញ្ជាក់អោយដឹងអំពីការយល់ឃើញរបស់គាត់) ។*

នៅអំឡុងពេលសិក្សាវាយតំលៃជនបទដោយមានការចូលរួម (PRA) នៅឃុំបាក់អន្លង់[២០] ខេត្តឧត្តរមានជ័យ ក្រុមប្រឹក្សាឃុំ បានបញ្ជាក់អោយឃើញនូវកង្វល់របស់គាត់អំពីប្រភេទនៃវិវាទ ។

*មានដីទំនេរនៅក្នុងតំបន់របស់ពួកយើង ។ ប៉ុន្តែដូចដែលអស់លោកឃើញតាមផ្លូវស្រាប់ហើយថា ដីទំនេរត្រូវបានគេកាប់គាស់ និងព័ទ្ធរបងអស់ ។ អ្នកទន្រ្ទានចាប់យកដីជាច្រើន បានប្រកាសកាន់កាប់ដីដោយ*

---

[២០] ឃុំបាក់អន្លង់ គឺជាអតីតមូលដ្ឋានដែលគ្រប់គ្រងដោយពួកខ្មែរក្រហមក្បាលរឹង ។

*ខុសច្បាប់ ហើយយើងគិតថា ពួកគេកំពុងបង្កើតពាក្យចាមអារាមអំពីរឿងនេះ ។ ប៉ុន្តែសួរថាតើយើងអាចធ្វើអ្វីបានខ្លះចំពោះរឿងនេះ? ដូច្នេះយើងឧបមាថា យើងរឹបអូសយកដីទាំងនោះសំរាប់កម្មវិធីសម្បទានដីសង្គមកិច្ច ពួកជនឱកាសនិយមទាំងនេះនឹងប្រឆាំង ហើយរឿងនេះនឹងកើតឡើងដោយគ្មានការសង្ស័យឡើយ ពេលនោះនឹងមានវិវាទយ៉ាងធំកើតមានឡើង ។*

សមាជិកគណៈកម្មការប្រើប្រាស់និងបែងចែកដីធ្លីខេត្តកំពត ក៏មានកង្វល់របស់ពួកគាត់អំពីវិវាទដែរ ប៉ុន្តែមានភាពខុសប្លែកពីខាងលើ ។

*គណៈកម្មការប្រើប្រាស់និងបែងចែកដីធ្លីខេត្ត នឹងត្រូវប្រើប្រាស់ដើម្បីកំណត់ និងចាត់ចំណាត់ថ្នាក់ដីដែលនៅទំនេរក្នុងព្រំដែនដីឯកជន និងដីសាធារណៈរបស់រដ្ឋ ។ ថ្វីត្បិតតែយើងអាចកំណត់ដីទំនេរក្នុងព្រំដែនដីឯកជនរបស់រដ្ឋ យើងប្រហែលជាមិនអាចផ្លាស់ប្តូរដីនោះអោយទៅជាដីសំរាប់កម្មវិធីបានដែរ ដោយហេតុថានឹងអាចមានវិវាទលើការប្រើប្រាស់ដីទាំងនោះ ។ វាអាចជាដីព្រៃឈើ ដែលអាចមានផលប៉ះពាល់ជាអវិជ្ជមានទៅលើបរិស្ថាន ហើយប្រហែលជាភ្នាក់ងារពាក់ព័ន្ធមិនអាចប្រគល់អោយនោះទេ ។*

នៅភូមិបឹងព្រាវ ខេត្តកោះកុង អ្នកចូលរួមក្នុងក្រុមគោលដៅសំរាប់ការពិភាក្សា រក្សាជំហរថា នឹងមានវិវាទតូចតាចប៉ុណ្ណោះ កើតមានឡើងក្នុងពេលដំណើរការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច ។

*បញ្ហា ឬវិវាទតូចតាចនឹងកើតមានឡើង ព្រោះថាប្រជាពលរដ្ឋអាចមានភាពច្រណែនគ្នាទៅវិញទៅមក ។ ជាឧទាហរណ៍ ដីនឹងមិនមានទំនេរសំរាប់ប្រជាពលរដ្ឋគ្រប់គ្នាទេ ។ នេះមានន័យថា នឹងមានប្រជាពលរដ្ឋដែលនឹងអាចទទួលបានដី ក៏ដូចជាប្រជាពលរដ្ឋដែលនឹងមិនអាចទទួលបានដី ។ ក្នុងករណីទាំងនេះនឹងមានជំលោះកើតមានឡើងនៅក្នុងចំណោមពួកគាត់ ។ វិវាទទាំងនោះ អាចសំរបសំរួលនិងដោះស្រាយបានដោយក្រុមប្រឹក្សាឃុំ ។*

អ្នកចូលរួមក្នុងភូមិអូរជីក ខេត្តឧត្តរមានជ័យ ប្រមើលឃើញថា វិវាទធ្ងន់ធ្ងរអាចនឹងកើតមានឡើងក្នុងចំណោមអ្នកដែលបានទទួលផលពីកម្មវិធី ។

*បញ្ហាធ្ងន់ធ្ងរអាចនឹងកើតមានឡើង រវាងអ្នកទទួលផលដែលនឹងទទួលបានដីឡូតិ៍ជាប់ៗគ្នា ។ យើងគិតថានឹងមានជំលោះរំលោភកើតមានឡើង ។ ជាឧទាហរណ៍ នៅពេលប្រគល់ដី អ្នកទទួលដីអាចមិនមានធនធានដើម្បីកំណត់ ឬធ្វើរបងឬធ្វើទំនប់ទឹកជុំវិញដីបានទេ ។ ពេលនោះនឹងមានការអះអាងខុសលើបញ្ហាព្រំដីទៅវិញទៅមក ដែលនឹងនាំអោយមានការប្រវ៉ាយប្រតប់គ្នាក្នុងចំណោមពួកគាត់ ។*

អ្នកចូលរួមក្នុងក្រុមគោលដៅសំរាប់ការពិភាក្សា ក្នុងភូមិអូរទ្រាល ខេត្តស្ទឹងត្រែង ជឿថា នឹងគ្មានវិវាទណាមួយ ហើយវិវាទនោះ អាចជៀសវាងបាន ។ ពួកគាត់បានពន្យល់ថា :

*នឹងគ្មានវិវាទណាមួយនៅក្នុងកម្មវិធីឡើយ ពីព្រោះយើងអាចជៀសវាងបាន ។ ដើម្បីជៀសវាងវិវាទ យើងគួររៀបចំដំណើរការ និងការអនុវត្តកម្មវិធីតាមរបៀបមានការចូលរួមច្រើន និងតម្លាភាព ។ យើងត្រូវតែអោយភាគីពាក់ព័ន្ធទាំងអស់ចូលរួម ធ្វើសាក្សី និងសង្កេតការ ហើយយើងចាំបាច់ត្រូវធ្វើឱ្យប្រាកដថា ដីដែលអោយទៅបេក្ខជនដែលទទួលបាននូវសិទ្ធិ ធ្វើការកំណត់ និងសំគាល់អោយបានច្បាស់លាស់ ។*

ប្រជាពលរដ្ឋនៅបាក់អន្លង់ ខេត្តឧត្តរមានជ័យ បានពន្យល់អំពីជំលោះកើតមានឡើងក្នុងកម្មវិធីសម្បទានដីសង្គមកិច្ច ដែលក្រុមប្រឹក្សាឃុំអាចដោះស្រាយបានយ៉ាងណានោះ ។

*ដូចដែលយើងបានជំរាបជូនថ្មីៗនេះថា ក្រុមប្រឹក្សាឃុំអាចដោះស្រាយជំលោះតូចតាចនៅក្នុងឃុំបាន ។ ក្នុងករណីកម្មវិធីសម្បទានដីសង្គមកិច្ច យើងក៏អាចដោះស្រាយវិវាទដែលមានលក្ខណៈតូចតាចបានដែរ ។ វិវាទអាចគ្រាន់ជាវិវាទក្នុងចំណោមអ្នកទទួលផល ហេតុដូច្នេះហើយ យើងអាចសំរបសំរួល និងដោះស្រាយវិវាទនោះបាន ក៏ប៉ុន្តែមិនមែនជាវិវាទធំៗដែលជាប់ពាក់ព័ន្ធជាមួយនឹងអ្នកមានអំណាចឡើយ ។*

ក្រុមប្រឹក្សាឃុំរីករាយ ខេត្តព្រះវិហារ ក៏បានធានាអះអាងថា ពួកគាត់អាចគ្រាន់តែសំរបសំរួល នៅក្នុង ឬដោះស្រាយវិវាទតូចតាចដែលពាក់ព័ន្ធនឹងកម្មវិធីប៉ុណ្ណោះ ។

*យើងអាចសំរបសំរួល និងផ្សះផ្សាក្នុងចំណោមភាគីជំលោះ យើងមិនអាចធ្វើអ្វីអោយលើសនេះបានទេ ។*

សមាជិកក្រុមការងារស្រុក នៅខេត្តកោះកុង មានទស្សនៈយល់ឃើញប្រហាក់ប្រហែលគ្នា អំពីលទ្ធភាពរបស់ក្រុមប្រឹក្សាឃុំ ដើម្បីដោះស្រាយវិវាទកើតមានឡើងក្នុងកម្មវិធី ។

*នឹងមានវិវាទតូចតាចកើតឡើងម្តងម្កាលតែប៉ុណ្ណោះ ដែលក្រុមប្រឹក្សាឃុំ និងអាជ្ញាធរពាក់ព័ន្ធថ្នាក់ស្រុក អាចដោះស្រាយបាន ។ វិវាទទាំងនេះ នឹងមិនត្រូវការយន្តការស្មុគស្មាញ ដើម្បីដោះស្រាយទេ ។ ការសំរបសំរួល និងផ្សះផ្សាក្នុងចំណោមភាគីជំលោះ គឺជាវិធីសាស្ត្រដែលអាចអនុវត្តបាននៅក្នុងរឿងនេះ ។*

នៅឃុំកំពង់ព្រះ ខេត្តបាត់ដំបង នៅក្នុងអំឡុងពេលនៃដំណើរការពិនិត្យវាយតំលៃជនបទដោយមានការចូលរួម (PRA) សមាជិកក្រុមប្រឹក្សាឃុំ បានឯកភាពចំពោះរឿងនេះ ប៉ុន្តែបន្ថែមថា :

*យើងមិនត្រូវវាយតំលៃទាបចំពោះទំហំនៃជំលោះឡើយ ។ ដូចដែលក្រុមប្រឹក្សាឃុំលើកឡើងថា យើងអាចដោះស្រាយបានតែជំលោះតូចតាចដែលយើងបានធ្វើកន្លងមកទេ ។ ប៉ុន្តែនៅពេលដែលជំលោះកើតមានឡើងពាក់ព័ន្ធនឹងអ្នកមានអំណាច និងជនឱកាសនិយម យើងត្រូវតែនិយាយថា ជំលោះទាំងនោះគួរត្រូវបានបញ្ជូន ឬដោះស្រាយដោយយន្តការវិវាទដីដែលកំពុងមានស្រាប់នៅថ្នាក់ស្រុក និងថ្នាក់ខេត្ត ។ ប្រភេទនៃជំលោះទាំងនេះ គឺហួសពីសមត្ថកិច្ច និងសមត្ថភាពរបស់យើង ។*

ទោះជាយ៉ាងណាក៏ដោយ នៅពេលមានវិវាទកើតមានឡើង ជាឧទាហរណ៍ មនុស្សដែលមានឋានៈខ្ពង់ខ្ពស់ ឬជាទាហាន យន្តការថ្នាក់ខេត្តនឹងគ្មានសារៈសំខាន់អ្វីឡើយ ។ សមាជិកគណៈកម្មការប្រើប្រាស់និងបែងចែកដីធ្លីខេត្តនៅខេត្តឧត្តរមានជ័យ បានពណ៌នាអំពីបទពិសោធន៍ពាក់ព័ន្ធរបស់ពួកគាត់ថា :

*យើងមានការព្រួយបារម្ភតែរឿងទាហានដែលអាចមកអះអាងយកដី ដែលយើងចែកទៅអោយប្រជាពលរដ្ឋ ដូចដែលអ្វីកើតមានឡើងកន្លងមក ។ ដីប្រគល់អោយសហគមន៍ ពេលនោះទាហានបានមកកាន់កាប់ និងដេញប្រជាពលរដ្ឋស៊ីវិលអោយចេញពីដីរបស់ពួកគាត់ ដោយអះអាងថា ជាកម្មសិទ្ធិរបស់ទាហានទាំងនោះ ។ ហើយពួកគេនៅបន្តអះអាងយកដីព្រៃជាច្រើនទៀត ។ យើងមិនអាចដោះស្រាយស្ថានភាពរបៀបនេះបានទេ លុះត្រាតែមានអន្តរាគមន៍ពីរាជរដ្ឋាភិបាល ឬក្រសួងការពារជាតិ ។*

## សេវាគាំទ្រ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ

មនុស្សចំណាស់ម្នាក់ក្នុងវ័យ៧០ឆ្នាំ ដែលបានចូលរួមនៅក្នុងក្រុមគោលដៅសំរាប់ការពិភាក្សា នៅភូមិតាបាស់ ខេត្តព្រះវិហារ បានរំលឹកនូវបទពិសោធន៍របស់គាត់អំពីភាពក្រីក្រ និងជីវភាពរស់នៅអាស្រ័យលើដីធ្លី និងបានពន្យល់ពីហេតុផលនៃការតភ្ជាប់រវាងផ្លូវ និងផ្សារមានសារៈសំខាន់យ៉ាងដូច្នេះ :

*ខ្ញុំបានឆ្លងកាត់ភាពពិបាកនៅក្នុងជីវិត ។ ខ្ញុំបានរស់នៅតាំងពីរបបបារាំង ។ ដីតែមួយមុខមិនអាចជួយកាត់បន្ថយភាពក្រីក្របានទេ ។ តាមពិតអ្នកត្រូវការដីសំរាប់ការប្រកបរបរចិញ្ចឹមជីវិតអាស្រ័យទៅលើដី និងការបង្កបង្កើតផលកសិកម្ម ។*

*នៅក្នុងភូមិរបស់យើង ភាពក្រីក្រគ្របដណ្តប់ទៅលើទាំងគ្រួសារដែលមានដី និងគ្រួសារដែលគ្មានដី ។ ដីខ្លះនៅក្នុងភូមិរបស់យើងធ្វើបានផលច្រើនណាស់ ។ អ្នកភូមិយើងខ្លះធ្វើស្រូវ និងដាំដំណាំសំរាប់លក់ដូរផ្សេងៗ ដូចជា សណ្តែកសៀង ល្ង សណ្តែកបាយ និងពោត ។ យើងអាចដាំដំណាំទាំងនេះបានផលយ៉ាងច្រើន ប៉ុន្តែយើងមិនអាចលក់ផលិតផលទាំងនេះបាន ពីព្រោះយើងគ្មានទំនាក់ទំនងទៅនឹងទីផ្សារ ហើយផ្លូវថ្នល់ស្ទើរតែមិនអាចប្រើប្រាស់បាន ។*

*នៅពេលដែលលោកអ្នកមិនអាចមានលទ្ធភាពទៅដល់ទីផ្សារ ហើយផ្លូវមានសភាពមិនល្អ ប្រហែលជាលោកអ្នកអាចលក់ផលិតផលនោះបាន ប៉ុន្តែក្នុងតំលៃមួយទាបបំផុត ។ ជាឧទាហរណ៍ យើងអាចលក់ផលិតផលនៅឯមាត់របងទ្វារចំការបានក្នុងតំលៃ ១.០០០រៀល ក្នុងមួយគីឡូក្រាម ប៉ុន្តែនៅពេលដែលផ្លូវពិបាក អ្នកទិញអាចទិញយកបានក្នុងតំលៃតែ ១០០រៀល ក្នុងមួយគីឡូក្រាម ពីព្រោះពួកគេអះអាងថាពួកគេត្រូវការទូទាត់សំរាប់ថ្លៃដឹកជញ្ជូនយ៉ាងច្រើន សាំង សុវត្ថិភាពបុគ្គលិកនៅតាមផ្លូវ ...។ល។ ពេលនោះហើយដែលពួកយើងនៅតែក្រ ពីព្រោះផលិតផលមានតំលៃថោកខ្លាំងណាស់ ដែលយើងស្ទើរតែមិនអាចទូទាត់រួចជាមួយនឹងថ្លៃផលិតផង ។*

*ឥឡូវនេះ លោកអ្នកអាចមើលឃើញស្ថានភាពប្រើប្រាស់ផ្លូវថ្នល់នៅក្នុងតំបន់របស់ពួកយើង ។ ផ្លូវប្រទាក់គ្នាខ្វែងខ្វាត់ក្នុងព្រៃ ហើយរលាក់ ឆ្លងកាត់ជ្រោះតូចៗ ។ នៅរដូវប្រាំងវាមិនជាបញ្ហាអ្វីទេ ។ នៅរដូវវស្សាផ្លូវទាំងនេះមិនអាចប្រើប្រាស់បានឡើយ ។ អាក្រក់ជាងនេះទៅទៀតនោះ គឺមានមីនច្រើនណាស់ ។ មានចំការមីនចំនួនប្រាំបួននៅតាមបណ្តោយផ្លូវ ។ នៅរដូវវស្សា ពេលដែលផ្លូវទន់ និងមានភក់ មីនផ្ទុះឡើងជាញឹកញាប់ ហើយបំផ្លាញឡាន និងអាយុជីវិតរបស់អ្នកធ្វើដំណើរ និងឈ្មួញកណ្តាល ។*

*កម្មវិធីសិលាបានផ្តត់ផ្គង់ថវិកាសាងសង់សាលារៀនមួយខ្នង អស់រយៈពេលជិតមួយឆ្នាំមកហើយ ។ ការសាងសង់សាលារៀនមិនទាន់ទាំងចាប់ផ្តើមផង ហើយអ្នកម៉ៅការសំណង់បានបោះបង់ចោល និងសុំលប់កិច្ចសន្យាចោល ។ ត្រូវការរយៈពេលជាច្រើនខែ ដើម្បីដឹកសម្ភារៈសំណង់ ដូចជា ស៊ីម៉ង់ ដែក ឥដ្ឋ ...។ល។ មកដល់ទីនេះ ។ ក្នុងពេលដែលកំពុងរង់ចាំសម្ភារៈមកដល់ ជាងសំណង់ជាច្រើននាក់ត្រូវស្នាក់នៅទីនេះ ដោយចំណាយលុយរបស់ពួកផ្ទាល់ដោយគ្មានការទូទាត់ប្រាក់កម្រៃ ។ ជាងសំណង់ទាំងអស់នោះអស់លុយ ហើយពួកគេមិនត្រូវការកិច្ចសន្យាអ្វីទៀតឡើយ ។ ហេតុដូច្នេះហើយ សួរថាតើនរណាចង់មកទីនេះ ដើម្បីធ្វើជំនួញនោះ?*

ប្រជាពលរដ្ឋនៅកោះរការក្រៅ ខេត្តព្រៃវែង បាននិយាយថា លុយគឺជាតំរូវការចាំបាច់ ពីព្រោះកសិករ ត្រូវការលុយសំរាប់ការបង្កបង្កើនផលរបស់គាត់ ។ ពួកគាត់ពន្យល់អំពីរឿងនេះតាមរយៈនៃបទពិសោធន៏របស់គាត់ថា :

*ពេលដែលលោកអ្នកមានដី លោកអ្នកនៅត្រូវការធនធាននិងលុយ ពីព្រោះវាសំខាន់ណាស់សំរាប់ការបង្កបង្កើនផល និងការរស់នៅប្រចាំថ្ងៃ ។ នៅក្នុងភូមិរបស់យើង កសិករដែលមានដីគ្រប់គ្រាន់ គឺក្រដូចគ្នានឹងអ្នកដែលគ្មានដី ពីព្រោះពួកគេនៅជំពាក់បំណុលគេ ។ ពួកគាត់ខ្ចីបុលគេដើម្បីយកមកបង្កបង្កើនផល និងសំរាប់ការចាយវាយក្នុងពេលមានអាសន្ន ។ ពួកគាត់ត្រូវការលុយ ដើម្បីទិញគ្រាប់ពូជកសិកម្ម និងសាំងសំរាប់បូមទឹកដាក់ដំណាំ និងស្រូវ ។*

*ឥឡូវនេះគេឈប់ខ្ចីលុយពីពួកចងការប្រាក់ ឬពីអ្នកផ្តល់សេវាចងការប្រាក់នៅមូលដ្ឋានទៀតហើយ ព្រោះអត្រាការប្រាក់ខ្ពស់ពេក ។ ពួកគេបានខ្ចីពីជនជាតិវៀតណាម និងរដ្ឋាភិបាលវៀតណាម ។ ពួកគេមិនយកការប្រាក់អ្វីទាំងអស់ ។ កសិកររបស់យើងត្រូវធ្វើរឿងតែម្យ៉ាង គឺលក់ផលិតផលទៅអោយអ្នកដែលគេអោយខ្ចីប្រាក់នោះ ។ ប្រសិនបើបានផលទាប ពួកគេមិនដែលសុំអោយសងវិញទេ ។ ផ្ទុយទៅវិញ គេបានអោយខ្ចីថែមទៀតសំរាប់បង្កបង្កើនផលលើកក្រោយទៀត ។*

*ការអោយអ្នកភូមិយើងខ្ចី អាចយកពីឈ្មួញមូលដ្ឋានមានអត្រាការប្រាក់ប្រហែល៥០ភាគរយ ឬច្រើនជាងនេះទៅទៀតក្នុងមួយឆ្នាំ ។ យើងស្នើថា ឥណទានគួរតែមានបញ្ចូលនៅក្នុងកម្មវិធីសម្បទានដីសង្គមកិច្ច*

*ដើម្បីអោយកសិករអាចខ្ចីសំរាប់ទុនកសិកម្ម ហើយឥណទានទាំងនោះ គួរមានអត្រាការប្រាក់ទាប ត្រឹម ១០ភាគរយក្នុងមួយឆ្នាំ ។*

ប្រជាពលរដ្ឋក្នុងក្រុមគោលដៅសំរាប់ការពិភាក្សា ក្នុងស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ស្នើសុំថា ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មសង្គមកិច្ចគួរត្រូវបានភ្ជាប់ជាមួយនឹងកម្មវិធី ។ ពួកគាត់បានបង្ហាញនូវគំនិតគាត់ថា :

*ការចែកដី នឹងមិនមានលទ្ធភាពជួយសំរាលប្រជាពលរដ្ឋពីភាពក្រីក្របានឡើយ ។ សូមក្រឡេកមើលចុះក្រោយពីការចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជា មេបញ្ជាការរបស់យើងអនុញ្ញាតអោយកាន់កាប់ដីទំហំមួយហិកតាក្នុងមួយគ្រួសារ ក្នុងករណីខ្លះ ប្រជាពលរដ្ឋបានយក១.៥ហិកតា សំរាប់មនុស្សម្នាក់ ។ ប៉ុន្តែពួកយើងនៅតែក្រ ថ្វីត្បិតយើងអាចមានដីទំហំពី១-១.៥ហិកតា សំរាប់មនុស្សម្នាក់ក៏ដោយ ។ តើមកពីហេតុអ្វី?*

*ក្រុមគ្រួសារខ្លះ ត្រូវការលក់ ឬបញ្ចាំដីរបស់គាត់ដើម្បីយកលុយ សំរាប់ប្រើប្រាស់ក្នុងការថែទាំសុខភាព ។ ដីអាចរក្សាទុកបាន ប៉ុន្តែអ្នកជំងឺអាចស្លាប់បានដែរ ។ គ្រួសារជាច្រើនមិនអាចមានលទ្ធភាពលោះយកដីមកវិញបានឡើយ ។ ហេតុដូច្នេះហើយ ពួកយើងស្នើរថា ដំណើរការសេវាសុខភាព គួរត្រូវបានបញ្ចូលនៅក្នុងកម្មវិធី តែមិនមែនសំរាប់តែរយៈពេលពីរ ឬបីឆ្នាំប៉ុណ្ណោះទេ គឺសំរាប់រយៈពេលជារៀងរហូត ។*

អ្នកចូលរួមក្នុងក្រុមគោលដៅសំរាប់ការពិភាក្សា ក្នុងភូមិព្រៃផ្តៅ ខេត្តបាត់ដំបង បានគាំទ្រទស្សនៈយល់ឃើញរបៀបនេះ ។ ពួកគាត់បានប្រាប់អំពីបទពិសោធន៏គាត់អោយដឹងថា :

*នៅពេលគេចែកដីអោយមកអ្នកភូមិរបស់យើងវិញ នៅក្រោយទសវត្សឆ្នាំ១៩៨០ គ្រួសារនីមួយៗ ទទួលបាននូវទំហំដីធំៗ ពីព្រោះដីកាលណោះគេបោះបង់ចោលនៅទីនេះ ព្រោះតែសន្តិសុខមិនល្អ ។ គ្រួសារនីមួយៗ ទទួលបានដីពីរវាង១០ ទៅ ១៥ហិកតា ។ ប៉ុន្តែឥឡូវនេះ យើងក្រ ហើយគ្មានដីថែមទៀតផង ។ ឈ្មួញរកស៊ីជាជនជាតិចិន រស់នៅក្រុងបាត់ដំបងកាន់កាប់ដីយើងទាំងអស់ ។ តើលោកអ្នកដឹងទេថា មកពីហេតុអ្វី?*

*បញ្ហាធំតែមួយគត់ដែលពួកយើងជួបប្រទះ គឺបញ្ហាជំងឺ ។ នៅពេលដែលយើងឈឺ ហើយគ្មានសេវាសុខភាពសំរាប់អ្នកក្រដូចពួកយើង ។ អ្វីដែលយើងជាច្រើននាក់បានធ្វើ គឺលក់ដី ឬបញ្ចាំដីដើម្បីយកលុយទៅទិញថ្នាំព្យាបាល និងសេវាពេទ្យ ។ បំណុលចេះតែកើនឡើង ហើយទីបំផុត ក៏អោយដីទៅឈ្មួញចិនដែលអោយខ្ចីលុយ ឬមួយក៏លក់វាក្នុងតំលៃយ៉ោងថោក ។ គេធ្វើអោយពួកយើង ស្ថិតក្នុងសភាពទ័លច្រក ។ ហេតុដូច្នេះ យើងគិតថា ដីតែមួយមុខ នឹងមិនអាចជួយយើងអោយផុតពីភាពក្រីក្របានឡើយ លើកលែងតែមានអ្វីបន្ថែមលើសនេះទៀតដូចជា សេវាសុខភាព ។*

នៅភូមិឪឡឹក ខេត្តព្រះវិហារ ដែលជីវិតរស់នៅរបស់ជនជាតិព័រ ដែលជាជនជាតិដើមភាគតិច និងជាអ្នកចូលរួមក្នុងក្រុមគោលដៅសំរាប់ការពិភាក្សា មានគំនិតស្រដៀងគ្នា ប៉ុន្តែបានបន្ថែមនូវចំណុចផ្សេងមួយទៀតចំពោះគំរូការសេវាសុខភាពសាធារណៈថា :

*ផ្តល់ដីជូនប្រជាពលរដ្ឋគឺជាការល្អណាស់ ។ ប៉ុន្តែដីនៅថេរ នៅពេលដែលមនុស្សកើតជារៀងរាល់ថ្ងៃ ។ អ្នកភូមិយើងជាច្រើនចាប់ផ្តើមរស់នៅរួមគ្នាតាំងពីក្មេង ។ អ្នកខ្លះបានរៀបការនៅក្មេងអាយុត្រឹម១២ឆ្នាំ ។ យើងមិនដែលរៀបចំអាពាហ៍ពិពាហ៍ដែលមានតំលៃថ្លៃទេ ពីព្រោះយើងគ្មានរបស់របរអ្វីដែលមានតំលៃឡើយ ។ មនុស្សគ្រាន់តែស្រឡាញ់គ្នា ហើយក៏រស់នៅក្នុងជំរកតែមួយជាមួយគ្នា ។ អ្វីដែលយើងធ្វើឥឡូវនេះគឺគ្រាន់តែថ្វាយដង្វាយតូចតាចទៅដល់អារក្សដែលថែរក្សាភូមិ និងព្រៃ ដូចជាស្រា និងមាន់តែប៉ុណ្ណោះ ។ នៅអាយុប្រមាណ១៤ឆ្នាំ ម្នាក់ៗមានកូនពីរនាក់ ។ គ្រួសាររបស់យើងមានសមាជិកច្រើន ។ យើងចង់អោយមានកូនតិច ប៉ុន្តែយើងមិនដឹងថាតើត្រូវធ្វើយ៉ាងដូចម្តេចទេ ។ នៅពេលមានកម្មវិធីចែកដីបញ្ហានេះគួរត្រូវបានពិចារណាផងដែរ ។*

នៅក្នុងអំឡុងពេលពិភាក្សាក្នុងក្រុមគោលដៅសំរាប់ការពិភាក្សា នៅភូមិមានជ័យ ខេត្តឧត្តរមានជ័យ អ្នកចូលរួមដែលជាអតីតសមាជិកខ្មែរក្រហម និយាយថា សេវាកម្មអប់រំ និងសាសនា គួរស្ថិតនៅក្នុងកញ្ចប់នៃកម្មវិធីចែកដីធ្លី ។ ពួកគាត់ ផ្តល់ហេតុផលចំពោះតម្រូវការហេដ្ឋារចនាសម្ព័ន្ធ និងសេវាអប់រំ និងសាសនា យ៉ាងដូច្នេះ :

*ឥឡូវនេះ ក្មេងៗមានការលំបាកណាស់ក្នុងការទៅសាលារៀន ពីព្រោះសាលារៀនមាននៅតែឯទីរួមស្រុកត្រពាំងប្រាសាទ ។ ថ្វីត្បិតតែលោកអ្នកមានដី លោកអ្នកនឹងមិនប្រាកដថា ភាពក្រីក្រត្រូវធ្លាក់ចុះឡើយ ។ យើងគិតថា មានការអប់រំជាមួយនឹងព្រះពុទ្ធសាសនានៅក្នុងកម្មវិធី អាចជាការល្អ និងអាចជួយកាត់បន្ថយវិវាទនៅក្នុងសង្គម ដែលទីបំផុតជួយសំរាលភាពក្រីក្រតាមរបៀបយូរអង្វែង ។*

*នៅពេលលោកអ្នកមានការសិក្សាអប់រំល្អ លោកអ្នកទំនងជានឹងអាចដោះស្រាយវិវាទ ដោយប្រើប្រាស់សតិបញ្ញារបស់លោកអ្នក ជាជាងពឹងផ្អែកតែទៅលើអាវុធដើម្បីដោះស្រាយវិវាទ ដូចដែលយើងទាំងអស់គ្នាធ្លាប់ឆ្លងកាត់កន្លងមក ។ ជាមួយគ្នានេះផងដែរ ការសិក្សាអប់រំ អាចអោយយើងទទួលបាននូវព័ត៌មានស្តីពីការអភិវឌ្ឍជីវភាពរស់នៅរបស់ពួកយើង និងបច្ចេកវិទ្យាកសិកម្មថ្មីៗ ។ ការសិក្សាអប់រំត្រូវមកព្រមគ្នាជាមួយនឹងវិស័យព្រះពុទ្ធសាសនា ពីព្រោះព្រះពុទ្ធជាអង្គម្ចាស់ ប្រៀនប្រដៅយើងទាំងអស់គ្នា អោយរស់នៅក្នុងភាពសុខដុមរមនាជាមួយនឹងគ្នា រស់នៅក្នុងសុខសន្តិភាពជាមួយនឹងអ្វីៗគ្រប់យ៉ាងដែលមាននៅក្នុងសហគមន៍មនុស្សជាតិ និងទីរហោស្ថាន ។ យើងត្រូវការសេវា និងមណ្ឌលសាសនា ពីព្រោះនៅក្នុងទំនៀមទំលាប់ប្រពៃណីរបស់យើងវាមានសារៈសំខាន់ខ្លាំងណាស់ ។ យើងត្រូវការព្រះសង្ឃ និងតាអាចារ្យ ដើម្បីប្រារព្ធពិធីសែនព្រេនតាមប្រពៃណី និងវប្បធម៌ សំរាប់ពិធីមង្គលការ ពិធីបុណ្យសព ប្រារព្ធពិធីបុណ្យចូលឆ្នាំថ្មី បុណ្យភ្ជុំបិណ្ឌ និងពិធីបុណ្យផ្សេងៗទៀត ។*

ក្រុមប្រឹក្សាឃុំបាក់អន្លង់ ខេត្តឧត្តរមានជ័យ ដែលបានចូលរួមនៅក្នុងសិក្សាវាយតំលៃជនបទដោយមានការចូលរួម (PRA) របស់ឃុំ បានការពារសំណើរបស់ពួកគាត់សំរាប់កញ្ចប់ឧបត្ថម្ភដែលពាក់ព័ន្ធថា :

*ក្រោយពីអោយដីទៅអ្នកទទួល ទាមទារអោយធ្វើការសាងសង់ផ្ទះ នៅលើដីដែលជាដីលំនៅដ្ឋានរបស់ពួកគាត់ ហើយធ្វើស្រែចំការនៅលើដីកសិកម្មរបស់ពួកគាត់ ។ សួរថាតើគាត់អាចធ្វើស្រែចំការបានយ៉ាងដូចម្តេចកើត ព្រោះពួកគាត់ដែលជាអ្នកក្រគ្មានដី គ្មានម្ហូបអាហារបំរុងទុក គ្មានលុយសំរាប់ទិញសម្ភារៈសំណង់ ហើយពួកគាត់គ្មានឧបករណ៍ធ្វើស្រែចំការ និងគ្មានសត្វពាហនៈសំរាប់ភ្ជួររាស់ផងនោះ? ពួកគាត់ភាគច្រើនធ្វើការងាររកបានកំរៃមួយថ្ងៃសំរាប់ចាយវាយតែមួយថ្ងៃប៉ុណ្ណោះ ។ តើពួកគាត់អាចធ្វើអ្វីបានខ្លះ?*

*នៅក្នុងដំណាក់ការដំបូង ប្រហែលការជួយឧបត្ថម្ភស្បៀងអាហារខ្លះៗ ជំរកបណ្តោះអាសន្ន ឧបករណ៍ធ្វើស្រែចំការ និងសត្វពាហនៈសំរាប់សំរាប់ភ្ជួររាស់ស្រែចំការ ត្រូវតែផ្តល់ជូនពួកគាត់ ។*

ក្រុមប្រឹក្សាឃុំកន្ទោរខាងលិច ខេត្តកំពត បានបញ្ចេញទស្សនៈយល់ឃើញប្រហាក់ប្រហែលគ្នានេះដែរ ប៉ុន្តែស្នើសុំអោយមានការរៀបចំរចនាសម្ព័ន្ធរដ្ឋបាលអោយបានល្អដែលអាចដំណើរការបាននៅក្នុងភូមិថ្មីៗទាំងនោះ ។

*ការបំរុងទុកនូវម្ហូបអាហារ គឺជាការសំខាន់បំផុត ហើយរាជរដ្ឋាភិបាលគួរផ្តល់ជូនអ្នកទទួលផលពីកម្មវិធីក្នុងរយៈពេលយ៉ាងហោចណាស់៦ខែដំបូង ពីព្រោះអ្នកក្រគ្មានដី ជាទូទៅក្រគ្មានអ្វីទាំងអស់ ។ ជំរកបណ្តោះអាសន្ន និងឧបករណ៍ធ្វើស្រែចំការ និងសត្វពាហនៈសំរាប់ភ្ជួររាស់ស្រែចំការ គួរតែផ្តល់ជូនពួកគាត់ផងដែរ ដើម្បីអោយពួកគាត់អាចមានដំបូលសំរាប់ជ្រកកោន និងមានមធ្យោបាយធ្វើការបង្កបង្កើនផលជាបន្តបន្ទាប់ ។ ក៏ប៉ុន្តែអ្វីដែលសំខាន់បំផុតនោះ គឺរចនាសម្ព័ន្ធរដ្ឋបាលមួយដែលល្អ គួរត្រូវបង្កើតអោយមានឡើង ដើម្បីធានានូវសន្តិសុខ និងការអភិវឌ្ឍដែលប្រកបដោយចីរភាព ។*

សមាជិកក្រុមការងារស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ ដែលបានចូលរួមនៅក្នុងការសិក្សាវាយតំលៃជនបទដោយមានការចូលរួម (PRA) បានពន្យល់អំពីរបៀបដែលកម្មវិធីសម្បទានដីសង្គមកិច្ច អាចរួមចំណែកជួយសំរាលភាពក្រីក្រថា :

*កម្មវិធីសម្បទានដីសង្គមកិច្ច នឹងអាចរួមចំណែកជួយសំរាលភាពក្រីក្របាន ពីព្រោះប្រជាពលរដ្ឋរបស់យើងដែលគ្មានដី នឹងអាចមានលទ្ធភាពមានដីសំរាប់ធ្វើផ្ទះ និងសំរាប់ការបង្កបង្កើនផលិតផលកសិកម្ម ។ ពួកគាត់នឹងអាចធ្វើការងារដោយខ្លួនឯងលើដីស្រែរបស់ពួកគាត់ ដើម្បីធ្វើស្រូវសំរាប់គ្រួសារ និងអាចដាំបន្លែបង្ការខ្លះៗសំរាប់លក់ ។ ពេលនោះហើយដែលពួកគាត់ នឹងអាចរកចំណូលបាន ដែលយ៉ាងហោចណាស់បានជារៀងរាល់ឆ្នាំដែរសំរាប់គ្រួសាររបស់គាត់ ហើយពួកគាត់មិនចាំបាច់លួចឆ្លងកាត់ព្រំដែន ដើម្បីទៅរកការងារធ្វើនៅប្រទេសថៃនោះទេ ។*

អ្នកចូលរួមនៅក្នុងក្រុមគោលដៅសំរាប់ការពិភាក្សា នៅភូមិត្រពាំងខ្ទេង ខេត្តព្រះវិហារ បានពន្យល់មូលហេតុដែលពួកគាត់ គិតថា កម្មវិធីសម្បទានដីសង្គមកិច្ច នឹងអាចជួលកាត់បន្ថយភាពក្រីក្រថា :

*យើងបានស្នើថា ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មសង្គមកិច្ច និងការគាំទ្របបមខ្លះមួយចំនួន គួរធ្វើឡើងព្រមគ្នាជាមួយនឹងកម្មវិធីសម្បទានដីសង្គមកិច្ច ។ ប្រសិនបើតំរូវការរបស់យើង ត្រូវបានគេពិចារណា និងឆ្លើយតបនោះ យើងនឹងប្រាកដថា កម្មវិធីពិតជានឹងជួយកាត់បន្ថយភាពក្រីក្រមែន ។ ឧទាហរណ៍ នៅពេលយើងមានដី យើងអាចធ្វើស្រូវសំរាប់ផ្គត់ផ្គង់គ្រួសារ ហើយស្រូវដែលនៅសល់ យើងអាចលក់នៅទីផ្សារ នៅពេលមានផ្លូវ និងផ្សារនៅទីនោះ ។ ហើយយើងនឹងធានាថា យើងនឹងថែរក្សាហេដ្ឋារចនាសម្ព័ន្ធអោយបានល្អ ដើម្បីអាចអោយយើងទទួលបាននូវផលប្រយោជន៍ ជានិច្ចនិរន្ត ។ ដូនតារបស់ពួកយើងបានបង្រៀនអោយយើងចេះនិយាយថា "នៅពេលយើងជ្រកក្រោមដើមឈើណាមួយ យើងត្រូវតែការពារ និងថែរក្សាដើមឈើនោះអោយបានល្អ ដើម្បីទុកប្រើប្រាស់នៅពេលក្រោយទៀត" ។ នៅពេលយើងថែរក្សាហេដ្ឋារចនាសម្ព័ន្ធទាំងនេះ យើងត្រូវការធ្វើអោយបានខ្លាំងក្លាថែមទៀត ដើម្បីបង្កើតអោយបានច្រើន ដើម្បីអាចអោយយើងទាញយកផលប្រយោជន៍បានជាអតិបរមាពីវា និងដើម្បីធ្វើអោយការរស់នៅរបស់យើងមានភាពប្រសើរឡើង ។*

ប្រជាពលរដ្ឋនៅភូមិស្វាយ ខេត្តកោះកុង បានផ្តល់យោបល់អំពីហេតុផលដែលពួកគាត់ជឿទៅលើកម្មវិធីថា នឹងអាចជួយរួមចំណែកសំរាលភាពក្រីក្រ ជាមួយនឹងទិដ្ឋភាពផ្សេងគ្នាមួយទៀត :

*កម្មវិធីនឹងជួយកាត់បន្ថយភាពក្រីក្រ ប្រសិនបើហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មសង្គមកិច្ច ដូចជា មណ្ឌលសុខភាព និងសេវាកម្មសុខភាព ត្រូវបានផ្តល់ជូន ។ លោកអ្នកមានដី ប៉ុន្តែលោកអ្នកមិនអាចបង្កបង្កើតអ្វីបានឡើយ ប្រសិនបើលោកអ្នកឈឺ ។ រឹងរឹតតែអាក្រក់ជាទីបំផុត ប្រសិនបើសេវាកម្មសុខភាព និងមណ្ឌលសុខភាពនៅឆ្ងាយ ។ គ្រាន់តែសោហ៊ុយធ្វើដំណើរ យើងត្រូវចំណាយអស់ស្រូវមួយបាវ ទំងន់៥០គីឡូក្រាមទៅហើយ ។ យើងជឿជាក់ថា ប្រសិនបើកម្មវិធីភ្ជាប់ជាមួយនូវសេវាកម្មទាំងនេះ គេអាចសន្សំលុយបានយ៉ាងច្រើន ហើយភាពក្រីក្រនឹងត្រូវកាត់បន្ថយ ។*

អ្នកចូលរួមក្នុងក្រុមគោលដៅសំរាប់ការពិភាក្សា ក្នុងភូមិកោះសំរេច ខេត្តឧត្តរមានជ័យ បានត្អូញត្អែរអំពីស្ថានភាព និងភាពខ្វះខាតសាលារៀនសំរាប់ក្មេងៗថា :

*មានសាលារៀនបណ្តោះអាសន្នមួយខ្នង នៅក្នុងតំបន់របស់ពួកយើង ។ គ្រូបង្រៀន៧នាក់ បង្រៀន នៅទីនោះ ។ សាលារៀនមានទីតាំងឆ្ងាយជាង១គីឡូម៉ែត្រពីភូមិកុល ស្ថិតនៅក្នុងបរិវេណវត្ត ។ សាលារៀនមានចំនួន៧បន្ទប់រៀន ។ បន្ទប់រៀននៅក្នុងសាលាមានស្ថានភាពខ្យល់ខ្សោយ ទ្រុឌទ្រោម ដំបូលប្រក់ស្លឹក ។ បន្ទប់រៀនមួយទៀតនៅពីក្រោមវត្តលោកសង្ឃ ហើយមួយទៀតនៅក្រោមដើមស្វាយ ។*

អ្នកចូលរួមក្នុងក្រុមគោលដៅសំរាប់ការពិភាក្សា ក្នុងភូមិថ្នល់ជ័យ ខេត្តព្រៃវែង មិនសប្បាយចិត្តចំពោះការខ្វះខាតសាលារៀន សំរាប់ក្មេងៗផងដែរ ។

*តាមតែយើងដឹង គឺមានសាលារៀនតែមួយខ្នងដែលមានបន្ទប់រៀនចំនួន៥ នៅក្នុងតំបន់របស់យើង ។ សាលារៀន មិនដែលមានគ្រប់គ្រាន់សំរាប់ក្មេងៗរបស់ពួកយើងឡើយ ។ គេនៅត្រូវការអោយមានបន្ទប់រៀន និងគ្រូៗច្រើនថែមទៀត ។*

នៅក្នុងអំឡុងពេលនៃដំណើរការសិក្សាវាយតំលៃជនបទដោយមានការចូលរួម (PRA) ក្រុមប្រឹក្សាឃុំត្បែងពី ខេត្តព្រះវិហារ បានប្រាប់ក្រុមការងារអំពីសេវាកម្មសុខភាពនៅក្នុងតំបន់ពួកគាត់ថា :

*មណ្ឌលសុខភាពស្រុក ស្ថិតនៅក្នុងឃុំនេះ ។ មានបុគ្គលិក៥នាក់បំរើការនៅទីនោះ ។ ប៉ុន្តែសម្ភារៈបរិក្ខារពេទ្យ និងសេវាកម្ម ជានិច្ចកាលមានការខ្វះខាត ។*

អ្នកចូលរួមនៅក្នុងកិច្ចប្រជុំនៃក្រុមគោលដៅសំរាប់ការពិភាក្សា ក្នុងភូមិទឹកពង ខេត្តកោះកុង បានពោលអះអាងថា :

*មានមន្ទីរពេទ្យបង្អែកមួយនៅក្នុងតំបន់នេះ ។ យើងគិតថា មានបុគ្គលិកបំរើសេវាកម្មសុខភាពគ្រប់គ្រាន់នៅមន្ទីរពេទ្យនេះ ។ ក៏ប៉ុន្តែជារឿយៗ នៅពេលយើងទៅមន្ទីរពេទ្យដើម្បីទទួលសេវាសុខភាព គ្មានបុគ្គលិកណាម្នាក់នៅទីនោះទាល់តែសោះ ដោយសារតែពួកគាត់ទទួលបាននូវការទូទាត់មិនគ្រប់គ្រាន់ សំរាប់ទ្រទ្រង់ជីវភាពរស់នៅ ហេតុដូច្នោះហើយ ទើបពួកគាត់ត្រូវចេញទៅប្រកបមុខរបរខាងក្រៅផ្សេងទៀត ។ សម្ភារៈបរិក្ខារពេទ្យក៏មានការខ្វះខាតផងដែរ ។ មន្ទីរពេទ្យអាចព្យាបាលបានតែជំងឺធម្មតា រីឯជំងឺធ្ងន់ធ្ងរ និងការវះកាត់ យើងត្រូវបញ្ជូនទៅមន្ទីរពេទ្យនៅភ្នំពេញ ដែលការចាយវាយសំរាប់ការធ្វើដំណើរ និងព្យាលបាលថែរក្សាមានតំលៃថ្លៃជាទីបំផុត ។*

អ្នកចូលរួមនៅក្នុងក្រុមគោលដៅសំរាប់ការពិភាក្សា១ ក្នុងភូមិបឹងព្រាវ ខេត្តកោះកុងដដែល បានយល់ស្របទៅនឹងទស្សនៈយល់ឃើញដែលបានសំដែងអោយដឹងខាងលើ ហើយបន្ថែមទៀតថា :

*យើងពិតជាត្រូវការវេជ្ជបណ្ឌិត និងបុគ្គលិកជំនាញផ្នែកថែរក្សាសុខភាព មកធ្វើការនៅមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក ។ សម្ភារៈបរិក្ខារពេទ្យ និងថ្នាំពេទ្យ ដែលជានិច្ចកាលការផ្គត់ផ្គង់មានភាពខ្វះខាត ។ រីតតែពិបាកមែនទែននោះ គឺឥរិយាបទរបស់បុគ្គលិកពេទ្យតែម្តង ។ ពួកគេតែងតែប្រើពាក្យអាក្រក់ និងបំពារបំពានជាមួយយើងដូចយើងជាមនុស្សឆ្កួត ។*

សហគមន៏ជាច្រើនជួបការលំបាកលើការផ្គត់ផ្គង់ទឹកនៅរដូវប្រាំង ។ អ្នកចូលរួមនៅក្នុងសហគមន៏ចាមក្នុងភូមិ១៣ ខេត្តកំពង់ចាម បានពន្យល់អំពីលទ្ធភាពទទួលការផ្គត់ផ្គង់ទឹករបស់សហគមន៏គាត់ថា :

*នៅភូមិរបស់យើង ពួកយើងគ្មានអណ្តូងសូម្បីតែមួយក៏គ្មានផង ។ ប៉ុន្តែពួកយើងសំណាងណាស់ ព្រោះថាយើងរស់នៅជិតទន្លេមេគង្គ ។ ទន្លេមេគង្គ គឺជាប្រភពផ្គត់ផ្គង់ទឹកដំបូងរបស់យើងសំរាប់អ្វីៗសព្វយ៉ាងទាំងអស់ ។ យើងយកទឹកដោយផ្ទាល់ពីទីនោះ ។*

នៅក្នុងអំឡុងពេលពិភាក្សា នៅក្នុងការសិក្សាវាយតំលៃជនបទដោយមានការចូលរួម (PRA) ជាមួយនឹងក្រុមប្រឹក្សាឃុំភ្លុក ខេត្តស្ទឹងត្រែង អ្នកចូលរួមក៏បានត្អូញត្អែរអំពីភាពខ្វះខាតទឹកប្រើប្រាស់ផងដែរថា :

*នៅក្នុងឃុំរបស់យើង មិនមានទន្លេ និងបឹងទេ ។ គ្មានប្រភពទឹកធម្មជាតិទាល់តែសោះ ។ គេបានជីកអណ្តូងស្នប់ចំនួន៨ ដែលផ្តល់ដោយអង្គការ **ភី.អេហ្វ.ឌី** ដែលជាអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិមួយ ។ ការផ្តល់អណ្តូងភ្ជាប់ជាមួយនឹងកម្មវិធីសិទ្ធិកុមារ ។ អណ្តូងទាំង៨នេះ មិនមានលទ្ធភាពអាចផ្គត់ផ្គង់ទឹកគ្រប់គ្រាន់សំរាប់ប្រជាពលរដ្ឋក្នុងឃុំយើងទាំងមូលបានឡើយ ។ យើងបានស្នើសុំអោយមានអណ្តូងចំនួន៤ទៀត ប៉ុន្តែនៅមិនទាន់បានទទួលចំលើយនៅឡើយទេ ។ ប្រជាពលរដ្ឋក្នុងឃុំរបស់យើង មានការពិបាកជាច្រើនពាក់ព័ន្ធនឹងបញ្ហាខ្វះខាតទឹកប្រើប្រាស់នេះ ។*

ក្រុមប្រឹក្សាឃុំស្តៅ ខេត្តព្រះវិហារ បានពន្យល់អំពីស្ថានភាពផ្លូវថ្នល់ និងភាពដែលអាចទៅដល់ទីផ្សារថា :

*គ្មានផ្សារណាមួយដែលស្ថិតនៅក្បែរឃុំនេះទេ ។ ភូមិទាំងឡាយចំណុះអោយឃុំនេះ មានចំងាយពី៦-១៨គីឡូម៉ែត្រពីទីរួមស្រុក ។ មានតែផ្សារតូចមួយប៉ុណ្ណោះនៅឯទីរួមស្រុក ហើយយើងអាចទៅដល់ដោយជិះម៉ូតូឌុប ក្នុងតំលៃ១0.000រៀល ក្នុងការធ្វើដំណើរមួយលើក ។ ប្រជាពលរដ្ឋក៏ទៅផ្សារភ្នំត្បែងដែរ ។ ចំងាយជិតបំផុតប្រវែង៦គីឡូម៉ែត្រពីសាលាឃុំ ទៅកាន់ផ្សារភ្នំត្បែង ។ ហើយដូចដែលលោកអ្នក បានឃើញហើយថា ផ្លូវនៅក្នុងតំបន់រស់នៅរបស់ពួកយើង គឺមានស្ថានភាពអាក្រក់ជាទីបំផុត ។*

អ្នកចូលរួមក្នុងក្រុមគោលដៅសំរាប់ការពិភាក្សា ក្នុងភូមិចំការលើ ខេត្តស្ទឹងត្រែង បានពន្យល់អំពីស្ថានភាពផ្លូវ នៅក្នុងតំបន់រស់នៅរបស់ពួកគាត់ថា :

*ផ្លូវពិបាកខ្លាំងណាស់នៅទីនេះ ។ ផ្លូវភូមិមានប្រហែលតែ៥0ភាគរយតែប៉ុណ្ណោះ ដែលអាចធ្វើដំណើរតាមម៉ូតូបាននៅរដូវវស្សា ។ រីឯផ្លូវទៅកាន់ស្រុក រឹតតែពិបាកជាងនេះ ទាំងនៅរដូវវស្សា និរដូវប្រាំ ។ ផ្លូវខូចដែលហួសពីអាចជួសជុលបានទៅហើយ ។ នៅរដូវវស្សា ផ្លូវលិចទឹក ។ ចំងាយពីភូមិទៅកាន់ស្រុកមានប្រវែងតែ២៧គីឡូម៉ែត្រប៉ុណ្ណោះ ប៉ុន្តែយើងអាចទៅដល់ទីនោះដោយថ្មើរជើង ឬមួយដោយប្រើកង់*

*ឬម៉ូតូ ។ ជារឿយៗអ្នកភូមិត្រូវធ្វើដំណើរដោយថ្មើរជើងទៅកាន់ទីរួមស្រុក ប្រសិនបើពួកគាត់ត្រូវការទៅទីនោះ ដោយសារតែតំលៃម៉ូតូឌុបថ្លៃពេក គឺ ៤០.០០០រៀល ក្នុងការធ្វើដំណើរមួយលើក ។*

នៅព្រែកចាស់ អ្នកចូលរួមបានប្រាប់ក្រុមការងារថា ពួកគាត់អាចទៅដល់ទីរួមស្រុក និងទីរួមខេត្តបានតែតាមទូក ដែលជាមធ្យោបាយស្រួលជាងគេ ។

*មធ្យោបាយធ្វើដំណើររបស់ពួកយើងនៅទីនេះ គឺទូក ។ មធ្យោបាយនេះអាចប្រើប្រាស់បានពេញមួយឆ្នាំ ។ យើងត្រូវតែជិះទូកពីទីនេះទៅកាន់ទីរួមស្រុក និងខេត្ត ហើយម៉ូតូមានតែនៅទីនោះប៉ុណ្ណោះ ។ ចំងាយពីទីនេះទៅកាន់ទីរួមស្រុកប្រហែល៤៣គីឡូម៉ែត្រ ប៉ុន្តែតំលៃទូក គឺ១០.០០០រៀល ក្នុងការធ្វើដំណើរមួយលើក ។*

សមាជិកក្រុមការងារស្រុកកំពង់ត្របែក ខេត្តព្រៃវែង បានជជែកអំពីសេវាឥណទាន នៅតំបន់រស់នៅរបស់គាត់ថា:

*ភ្នាក់ងារឥណទានជាច្រើន ធ្វើការនៅក្នុងស្រុករបស់យើង ។ ទាំងនេះរាប់បញ្ចូលទាំងអ្នកចងការប្រាក់ចិន អេស៊ីលីដា ប្រាសាក់ និងហ្ប្រេដ ។ អ្នកចងការប្រាក់ចិនយកអត្រាការប្រាក់១០% ក្នុង១ខែ នៅពេលដែល អេស៊ីលីដា ប្រាសាក់ និងហ្ប្រេដ យកអត្រាការប្រាក់៤% ក្នុង១ខែ ។ ថ្វីត្បិតតែមានភ្នាក់ងារឥណទានជាច្រើន ប៉ុន្តែវិសាលភាពគ្របដណ្តប់ គឺនៅមានកំរិត និងមិនទាន់ទូលាយទូលាយនៅឡើយ (ជាឧទាហរណ៍ អ្នកខ្ចីមានច្រើនជាង៥០ភាគរយ) ។ម្យ៉ាងវិញទៀត ដើម្បីទទួលឥណទានបានពីប្រាសាក់ អេស៊ីលីដា ហ្ប្រេដ អ្នកភូមិត្រូវមានរបស់បញ្ចាំ/របស់ធានា ដូចជា ប្លង់ដី ដែលជាការពិបាកខ្លាំងណាស់សំរាប់ពួកគាត់ ។*

អ្នកចូលរួមនៅក្នុងក្រុមពិភាក្សានៅភូមិព្រៃចាស់ ខេត្តបាត់ដំបង បានត្អូញត្អែរអំពីលទ្ធភាពមានកំរិតនៃសេវាកម្មឥណទាននៅក្នុងតំបន់រស់នៅរបស់គាត់ថា :

*មានតែឥណទានក្រៅផ្លូវការ ដែលផ្តល់ដោយគ្រួសារអ្នកមានប៉ុណ្ណោះ នៅក្នុងតំបន់រស់នៅរបស់ពួកយើងខ្ញុំ ហើយគេរើសមុខអ្នកខ្ចីខ្លាំងណាស់ ។ អ្នកមានឥណទាន អោយឥណទានទៅតែអ្នកខ្ចីណាដែលគេស្គាល់ច្បាស់ ឬអ្នកដែលគេមានទំនាក់ទំនងល្អប៉ុណ្ណោះ ។ ប៉ុន្តែទោះជាយ៉ាងដូច្នេះក៏ដោយ គេយកអត្រាការប្រាក់រហូតដល់ ១៥% ក្នុងមួយខែ ។*

នៅភូមិស្ទឹងវែង ខេត្តកោះកុង អ្នកចូលរួមនៅក្នុងក្រុមគោលដៅសំរាប់ការពិភាក្សា បានត្អូញត្អែរថាអត្រាការប្រាក់ ដែលយកដោយប្រភពឥណទានផ្លូវការ និងក្រៅផ្លូវការ មានតំលៃថ្លៃ ហើយស្នើអោយបញ្ចុះកំរិតអត្រាការប្រាក់បន្តិច ។

*មានទាំងឥណទានផ្លូវការ និងក្រៅផ្លូវការនៅក្នុងភូមិរបស់ពួកយើងខ្ញុំ ។ ប៉ុន្តែអត្រាការប្រាក់ថ្លៃ ។ ប្រភពឥណទានផ្លូវការយកតំលៃ៤% ក្នុង១ខែ នៅពេលដែលប្រភពក្រៅផ្លូវការយក៣-៥% ។ ប្រភពផ្លូវការ*

*ត្រូវការរបស់បញ្ចាំ ក្នុងទ្រង់ទ្រាយជាប្លង់ដីដែលយើងពុំមាន ។ ចំណែកឯប្រភពក្រៅផ្លូវការ យើងទូទាត់តែ ៣% នៃអត្រាការប្រាក់ ប្រសិនបើយើងមានអ្វីធានា ឧទាហរណ៍ដូចជាមាស ។ រាជរដ្ឋាភិបាល គួរពិចារណា ផ្តល់ឥណទានកម្ចីទៅប្រជាពលរដ្ឋ សំរាប់សកម្មភាពរកស៊ីចិញ្ចឹមជីវិតរបស់ពួកគាត់ ក្នុងកំរិតអត្រាការ ប្រាក់ទាប ។ យើងគិតថា អត្រាការប្រាក់១% ក្នុង១ខែ នឹងអាចជួយយើងបានច្រើនខ្លាំងណាស់ ។*

ក្នុងនាមជាក្រុមប្រឹក្សាឃុំកោះសូទិន ខេត្តកំពង់ចាម បានលើកឡើងថា :

*គណៈកម្មការវត្ត និងព្រះសង្ឃ ចលនាប្រជាពលរដ្ឋ និងរកថវិកាសំរាប់ការកសាងផ្លូវថ្នល់នៅក្នុងមូលដ្ឋាន និងជួសជុល និងថែរក្សាសាលារៀនទាំងឡាយ ។ ពួកគេរកថវិកាសំរាប់បុណ្យប្រពៃណីផងដែរ ។*

របាយការណ៍ត្រូវបានការសាទរដោយក្រុមការងារស្រុកនៅកន្លែងដទៃៗទៀត ។ ក្រុមប្រឹក្សាឃុំអំពិលក្រៅ ខេត្តព្រៃវែង បានបញ្ជាក់បន្ថែមអំពីតួនាទីប្រហាក់ប្រហែលគ្នារបស់ព្រះសង្ឃ និងអាចារ្យវត្ត នៅក្នុងស្រុករបស់ ពួកគាត់ថា :

*ព្រះសង្ឃ និងឧបាសកបាសិការ បានដើរតួនាទីយ៉ាងល្អ ។ ពួកគាត់ជួយកសាងសាលារៀននៅក្នុង បរិវេណជីវត្ត និងភូមិ និងបណ្តាញផ្លូវថ្នល់ឃុំ ។ តាមពិតពួកគាត់ក៏សាងសង់វត្តផងដែរ ។*

ក្រុមប្រឹក្សាឃុំឈូក ខេត្តកំពត បានបញ្ចេញអោយឃើញនូវរបាយការណ៍ប្រហាក់ប្រហែលគ្នានេះថា :

*ព្រះសង្ឃក្រៅពីបង្រៀនធម៌ព្រះពុទ្ធ បានរកថវិកាសំរាប់ការកសាងសាលារៀន និងអណ្តូងសំរាប់ការ ផ្គត់ផ្គង់ទឹក ។*

នៅឃុំថ្មដៅពៅ ក្រុមប្រឹក្សាឃុំ និយាយថា :

*ព្រះសង្ឃ និងតាអាចារ្យ រកថវិកាដើម្បីសង់វត្ត ។ ពួកគាត់ក៏បានជួយបង្រៀនដល់កូនចៅរបស់យើង ផងដែរ ដោយសារយើងគ្មានសាលារៀន និងគ្រូបង្រៀនគ្រប់គ្រាន់ ។*

ក្រុមប្រឹក្សាឃុំផ្អាវ ខេត្តឧត្តរមានជ័យ បានអោយតំលៃផ្សេងគ្នាអំពីតួនាទីរបស់ព្រះសង្ឃ និងអាចារ្យវត្តថា :

*ព្រះសង្ឃរកថវិកាដើម្បីសាងសង់វត្ត និងផ្សព្វផ្សាយការប្រៀនប្រដៅរបស់ព្រះពុទ្ធ ។ ព្រះសង្ឃផ្តល់ជូន នូវការប្រៀនប្រដៅរបស់ព្រះពុទ្ធដល់ប្រជាពលរដ្ឋមូលដ្ឋាន និងអប់រំពួកគាត់អំពីការមិនរំលោភបំពារ បំពាន ដើម្បីអោយសហគមន៍របស់យើងអាចជឿនលឿន ហើយអំពើឧក្រិដ្ឋកម្ម និងការរំលោភបំពារ បំពានអាចលប់បំបាត់បាន ។*

អ្នកចូលរួមក្នុងក្រុមគោលដៅសំរាប់ការពិភាក្សា នៅភូមិផ្តៅជុំលិច ខេត្តកំពង់ចាម បានបន្ថែមយោបល់របស់ពួកគាត់ថា :

*ក្រៅពីបានបូជាជូនព្រះពុទ្ធសាសនា ព្រះសង្ឃ និងអាចារ្យចូលរួមចំណែកកសាង និងថែរក្សាបណ្តាញផ្លូវនៅមូលដ្ឋាន សាលារៀន និងសាលាសំណាក់ ។*

អ្នកចូលរួមក្នុងក្រុមគោលដៅសំរាប់ការពិភាក្សា នៅភូមិទី៦ ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម បានផ្តល់ការពន្យល់ដោយសង្ខេប អំពីតួនាទីនៃសាសនាឥស្លាម នៅក្នុងភូមិរបស់គាត់ថា :

*សាសានឥស្លាមនៅក្នុងភូមិរបស់យើង គ្មានធ្វើអ្វីឡើយ ។ អ្នកដើរតាមសាសនា គ្រាន់តែផ្សព្វផ្សាយសាសនារបស់ពួកគាត់ និងបង្រៀនក្មេងរបស់គាត់អំពីសាសនា និងជំនឿរបស់គាត់តែប៉ុណ្ណោះ ។*

នៅភូមិ១៣ ស្រុកកោះសូទិន ប្រជាពលរដ្ឋបានប្រាប់អោយដឹងអំពីតួនាទីរបស់អ្នកដើរតាមសាសនាឥស្លាមនៅភូមិរបស់គាត់ថា :

*មេដឹកនាំសាសនាឥស្លាមនៅក្នុងសហគមន៍របស់យើង បង្រៀនពួកយើងអំពីសាសនា ប៉ុន្តែក៏ធ្វើការងារដទៃទៀតដែរ ។ គាត់ជួយដោះស្រាយវិវាទគ្រួសារ ហើយសំរេច និងធ្វើជាសាក្សីអំពីកេរ្តិ៍មរតកគ្រួសារទៅអោយទាយាទដែលនៅរស់ ។ ពួកគាត់ក៏រកថវិកា ដើម្បីទៅជួយប្រជាពលរដ្ឋឥស្លាមក្រីក្រនៅក្នុងភូមិ មនុស្សចាស់ជរា និងក្មេងកំព្រាឪពុកម្តាយផងដែរ ។*

សំរាប់ឃុំដែលមានព្រះវិហារគ្រីស្តសាសនា បានពន្យល់អំពីតួនាទីរបស់អ្នកកាន់សាសនាគ្រិស្ត នៅក្នុងភូមិរបស់គាត់ថា :

*តាមដែលយើងដឹង អ្នកកាន់សាសនាគ្រិស្តនៅក្នុងឃុំរបស់យើង គ្រាន់តែធ្វើការងារផ្សព្វផ្សាយសាររបស់ព្រះយេស៊ូគ្រិស្ត ហើយបង្រៀនសាសនិកជនរបស់ពួកគេអំពីជំនឿរបស់ព្រះយេស៊ូគ្រិស្តតែប៉ុណ្ណោះ ។*

ក្រុមការងារស្រុកសង្កែ ខេត្តបាត់ដំបង បានការពន្យល់ដូចគ្នាអំពីអ្វីដែលសាសនិកជនគ្រិស្តធ្វើ នៅក្នុងស្រុករបស់ពួកគាត់ថា :

*មានព្រះវិហារគ្រិស្តសាសនាចំនួន៣ នៅក្នុងស្រុករបស់ពួកយើង ។ ពួកគេធ្វើការដើម្បីជួយកុមារកំព្រាឪពុក ម្តាយ ប៉ុន្តែក្នុងគោលបំណងសាសនាតែប៉ុណ្ណោះ ។ ពួកគេបញ្ច្រាបជំនឿគ្រិស្តសាសនា ក្នុងចំណោមសមាជិកសហគមន៍ និងអ្នកដែលជឿតាម ។*

អ្នកចូលរួមនៅភូមិព្រៃតូច ខេត្តព្រៃវែង បានពន្យល់នូវអ្វីដែលអង្គការមិនមែនរដ្ឋាភិបាលបានធ្វើ នៅក្នុងភូមិរបស់ពួកគាត់ថា :

*មានអង្គការចំនួន៣ ធ្វើការនៅក្នុងភូមិរបស់យើង ។ ពួកគេធ្វើការទៅតាមអត្ថប្រយោជន៍ខុសគ្នា ។ អង្គការអេគីប (AQIP) ធ្វើការអភិវឌ្ឍ និងកែលំអផលិតកម្មស្រូវ ។ អង្គការអុកស្វាម (Oxfam) ផ្តល់អណ្តូង និងសង់សាលារៀន ។ អង្គការផាដេក (PADEK) ជួយបង្កើតសមាគមឥណទាន ដែលអោយកម្ចីទៅប្រជាពលរដ្ឋមូលដ្ឋាន ក្នុងកំរិតអត្រាការប្រាក់ទាប ។*

នៅភូមិក្តាក ខេត្តព្រះវិហារ អង្គការមិនមែនរដ្ឋាភិបាលធ្វើការលើវិស័យដទៃទៀត ដូចដែលអ្នកចូលរួមនៅក្នុងក្រុមគោលដៅសំរាប់ការពិភាក្សា បានរៀបរាប់ថា :

*មានអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន ដែលកំពុងធ្វើការនៅក្នុងភូមិរបស់យើង នៅក្នុង២-៣ឆ្នាំចុងក្រោយនេះ ។ បុគ្គលិក៨នាក់ ធ្វើការនៅ អេ.អេ.អេជ (AAH) ។ គេបង្កើតធនាគារគោសំរាប់ប្រជាពលរដ្ឋមូលដ្ឋាន ហើយផ្តល់អណ្តូង២ ។ អង្គការម៉ែក (MAG) បានដោះមីននៅក្នុងតំបន់នេះ ហើយដំណើរការកម្មវិធី "ការដោះដូរអាវុធ/គ្រឿងផ្ទុះជាមួយនឹងកម្មវិធីស្បៀងអាហារ" ។ កម្មវិធីមានបំណង ដើម្បីកាត់បន្ថយអាវុធ ។ អង្គការរ៉ាត់ (RAT) បានជួយសកម្មភាពមត្តេយ្យសាលា ហើយក៏បានបង្កើតធនាគារគោដែរ ។ អង្គការ អេជ.យូ (HU) មានបុគ្គលិក៤នាក់ ដែលធ្វើការដើម្បីប្រមូលព័ត៌មានសុខភាពពីអ្នកភូមិ ហើយបង្រៀនពួកគាត់អំពីការអនុវត្តថែទាំសុខភាពល្អ និងអនាម័យ ។*

អ្នកចូលរួមនៅក្នុងក្រុមគោលដៅសំរាប់ការពិភាក្សា ក្នុងភូមិបានប៉ុង ខេត្តស្ទឹងត្រែង បានអោយតំលៃផ្សេងគ្នាអំពីការងារ និងតួនាទីរបស់អង្គការមិនមែនរដ្ឋាភិបាល នៅក្នុងភូមិរបស់គាត់ថា :

*ប្រហែលជាមានអង្គការមិនមែនរដ្ឋាភិបាលចំនួន៣ ធ្វើសកម្មភាពនៅក្នុងភូមិរបស់ពួកយើង ។ អង្គការស៊ីប៉ា (CEPA) ធ្វើការដើម្បីការពារ និងលើកកំពស់ការយល់ដឹងអំពីបរិស្ថានធម្មជាតិ ។ អង្គការស៊ី.អេ.អេ (CAA) ធ្វើការដើម្បីការពារមច្ឆាជាតិ និងធនធានទន្លេ និងលើកកំពស់យល់ដឹងអំពីការការពារធនធានមច្ឆាជាតិ ។ អង្គការអាត់ហុក (ADHOC) ផ្តល់វគ្គបណ្តុះបណ្តាលអំពីសិទ្ធិមនុស្ស ការមិនរំលោភបំពារបំពាន និងប្រជាធិបតេយ្យ ដល់អ្នកភូមិមេភូមិ និងក្រុមប្រឹក្សាឃុំ ។*

ក្រុមប្រឹក្សាឃុំកណ្តោលជ្រុំ ខេត្តកំពង់ចាម បានកត់សំគាល់ការងាររបស់អង្គការមិនមែនរដ្ឋាភិបាលធ្វើការនៅក្នុងឃុំរបស់ពួកគាត់ថា :

*អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនធ្វើការនៅក្នុងឃុំរបស់យើង ។ យើងចាំឈ្មោះរបស់អង្គការទាំងនោះមិនបានច្បាស់ទេ ។ អង្គការភាគច្រើន មានគំរោងដើម្បីលើកកំពស់ការយល់ដឹងរបស់សហគមន៍អំពីជំងឺ*

*អេដ.អាយ.វី អេតស៍ ការពន្យារកំណើត ហើយផ្តល់ការចាក់ថ្នាំបង្ការដល់ក្មេងៗ ។ អង្គការកម្មវិធីស្បៀងអាហារពិភពលោកនៃអង្គការសហប្រជាជាតិ ផ្តល់ស្បៀងអាហារទៅសាលារៀន ដើម្បីធ្វើអោយប្រសើរឡើងនូវអាហារូបត្ថម្ភរបស់កុមារសិស្សសាលា ហើយផ្តល់ស្បៀងពលកម្មសំរាប់ការកសាងផ្លូវជនបទ ។*

ក្រុមប្រឹក្សាឃុំល្វា ខេត្តបាត់ដំបង បានបង្ហាញចំណេះដឹងអំពីអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការនៅក្នុងមូលដ្ឋានរបស់គាត់ថា :

*មានអង្គការមិនមែនរដ្ឋាភិបាលចំនួនពីរធ្វើការនៅក្នុងឃុំរបស់យើងខ្ញុំ ។ អង្គការទាំងពីរនោះ ធ្វើការងារលើវិស័យឥណទានខ្នាតតូច ។ អង្គការការីតាស់ (CARITAS) ទាក់ទងនឹងគំរោងឥណទានដែលអោយកម្ចីទៅប្រជាពលរដ្ឋនៅក្នុងសហគមន៍ ក្នុងកំរិតអត្រាការប្រាក់ទាប នៅពេលដែលអង្គការឃែរ (CARE) ជួយសហគមន៍មូលដ្ឋានរៀបចំសមាគមសន្សំប្រាក់ ។ សមាគមសន្សំប្រាក់សហគមន៍ ក៏បានអោយកម្ចីនៅក្នុងអត្រាការប្រាក់ទាបផងដែរ ។ ក្រៅពីនេះ មានកម្មវិធីសិលារបស់រាជរដ្ឋាភិបាល ដែលបានចូលរួមនៅក្នុងគំរោងវិមជ្ឈការ និងអភិវឌ្ឍន៍ថ្នាក់សហគមន៍ ។*

ក្រុមប្រឹក្សាឃុំតាគ្រាម ខេត្តបាត់ដំបង នៅក្នុងអំឡុងពេលសិក្សាវាយតំលៃជនបទដោយមានការចូលរួម (PRA) បានអះអាងថា មានអង្គការមិនមែនរដ្ឋាភិបាលចំនួន៩ ធ្វើការយ៉ាងសកម្មនៅក្នុងឃុំរបស់ពួកគាត់ ។ ពួកគាត់បានពន្យល់ថា :

*មានអង្គការមិនមែនរដ្ឋាភិបាលចំនួន៩ កំពុងធ្វើការនៅក្នុងឃុំនេះ ។ អង្គការមួយចំនួន រៀបចំ និងដំណើរការការងារឥណទាន ធនាគារស្រូវ និងធនាគារសត្វពាហនៈ ។ អង្គការខ្លះផ្តល់ការអប់រំថែរក្សាសុខភាព និងកិច្ចឧបត្ថម្ភដល់ជនពិការ ។ អង្គការដទៃផ្សេងទៀតចូលរួមនៅក្នុងការស្តារប្រព័ន្ធធារាសាស្រ្តខ្នាតតូច និងមធ្យម និង ផ្តល់ការបណ្តុះបណ្តាល និងផ្សព្វផ្សាយកសិកម្ម ដល់សហគមន៍ ដើម្បីកែលំអផលិតកម្មកសិកម្មរបស់ពួកគេ ។ អង្គការមិនមែនរដ្ឋាភិបាលផ្នែកសិទ្ធិមនុស្ស ផ្តល់វគ្គបណ្តុះបណ្តាលអំពី និងលើកកំពស់ការយល់ដឹងក្នុងចំណោមសមាជិកសហគមន៍ អំពីការមិនរំលោភបំពារបំពាន សិទ្ធិមនុស្ស និងប្រជាធិបតេយ្យ ។*

នៅឃុំកោះកាពិ ខេត្តកោះកុង ក្រុមប្រឹក្សាឃុំ បានផ្តល់ព័តិមានផ្ទាល់ខ្លួនរបស់ពួកគាត់អំពីការងាររបស់អង្គការមិនមែនរដ្ឋាភិបាល និងគំរោងរបស់ម្ចាស់ជំនួយថា :

*អង្គការដានីដា (DANIDA) មានគំរោងអភិវឌ្ឍន៍តំបន់ឆ្នេរសមុទ្រនៅទីនេះ ។ គំរោងគាំទ្រការដាំព្រៃកោងកាងឡើងវិញ បង្កើតការការពារនិងគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍ និងផ្តល់វគ្គបណ្តុះបណ្តាលសំរាប់ការបង្កើតភ្នាក់ងារចិញ្ចឹមសត្វភូមិ ។ អង្គការមិនមែនរដ្ឋាភិបាលមួយ ធ្វើការក្នុងវិស័យ*

*សុខាភិបាល ។ អង្គការនេះផ្តល់វគ្គបណ្តុះបណ្តាលអំពីការពន្យារកំណើត និងបណ្តុះបណ្តាលដល់អ្នក ឬភ្នាក់ងារបញ្ជូនព័ត៌មានចំនួន១៦ ដើម្បីធ្វើការងារជាមួយសហគមន៍ ។*

ចំពោះអ្នកចូលរួមនៅភូមិព្រែកស្វាយ ខេត្តកោះកុង និយាយថា អង្គការមិនមែនរដ្ឋាភិបាល ហាក់ដូចជាមិនធ្វើការ សំរាប់បំរើផលប្រយោជន៍ពួកគាត់ឡើយ ។ ផ្ទុយទៅវិញ អង្គការមិនមែនរដ្ឋាភិបាល ហាក់ដូចជាទុកពួកគាត់ចោល ដោយគ្មានឱកាសសំរាប់ជីវភាពរស់នៅ ។ អ្នកភូមិទាំងនេះ មិនចូលចិត្តនូវអ្វីដែលអង្គការមិនមែនរដ្ឋាភិបាល បានធ្វើនៅក្នុងភូមិរបស់ពួកគាត់ :

*ហេតុអ្វីបានជារាជរដ្ឋាភិបាលកម្ពុជាមិនមកជួយពួកយើង? យើងឃើញមានតែ ស៊ី.អាយ (ជាអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិមួយ) ចូលមក និងធ្វើឆ្កួតៗលើពួកយើង ។ បុគ្គលិកអង្គការស៊ី.អាយ មិនអនុញ្ញាតអោយយើងធ្វើសកម្មភាពរកស៊ីចិញ្ចឹមជីវិត ដូចជាប្រមូលជ័រទឹក ក្រវាញ វល្លិ៍មាស ដូចដែលយើងធ្លាប់ធ្វើកន្លងមក ។ ទាំងនេះគឺជាទំលាប់រកស៊ីចិញ្ចឹមជីវិតរបស់សហគមន៍ពួកយើង ដែលបានធ្វើកន្លងមកដោយដូនតារបស់យើង ។*

អ្នកចូលរួមនៅក្នុងក្រុមគោលដៅសំរាប់ការពិភាក្សា ក្នុងភូមិវាលខ្សាច់ ខេត្តស្ទឹងត្រែង បានពណ៌នាអំពីការងារ និងតួនាទីរបស់ក្រុមកសិករដែលកំពុងមាននៅក្នុងភូមិរបស់គាត់ថា :

*មានក្រុមអ្នកនេសាទនៅក្នុងភូមិរបស់យើង អនុវត្តដោយសមាជិក៧នាក់ ។ អ្នកទាំងនេះ ត្រួតពិនិត្យការធ្វើការនេសាទ ដើម្បីធានាថា គ្មាននរណាម្នាក់ប្រើប្រាស់សម្ភារៈនេសាទខុសច្បាប់ឡើយ ។ ពួកគេផ្សព្វផ្សាយ និងចែកចាយព័ត៌មានអំពីការធ្វើការនេសាទ រៀបចំការជួបជុំជាមួយនឹងអ្នកភូមិ និងលើកកំពស់ការយល់ដឹងអំពីការប្រើប្រាស់សម្ភារៈនេសាទសមស្រប និងការការពារធនធានជលផល ។*

អ្នកចូលរួមក្នុងក្រុមគោលដៅសំរាប់ការពិភាក្សា ក្នុងភូមិចាងហ៊ុន ខេត្តកំពត បានរាយការណ៍ថា មានក្រុមសហគមន៍នៅក្នុងភូមិរបស់ពួកគាត់ ។ ពួកគាត់ពណ៌នាការងាររបស់ក្រុមនោះថា :

*ក្រុមអភិរក្សធនធានធម្មជាតិសហគមន៍មួយត្រូវបានរៀបចំឡើង ។ ក្រុមធ្វើការងារជាទូទៅ ដើម្បីថែរក្សា និងការពារព្រៃកោងកាងដែលជាជំរករស់នៅរបស់សត្វទឹក ។ យើងជឿជាក់ថា នៅពេលដែលព្រៃកោងកាង បានថែរក្សា និងការពារបានល្អ ជលផលនិងផលនេសាទ នឹងកើនឡើងផងដែរ ។*

នៅភូមិខ្មែរឥស្លាម ខេត្តកំពង់ចាម ប្រជាពលរដ្ឋបានពណ៌នាការងារ និងតួនាទីរបស់សមាគមមូលដ្ឋានថា ធ្វើការ ដើម្បីថែរក្សាអត្តសញ្ញាណ និងជំនឿរបស់ពួកគេ និងដើម្បីជួយសមាជិកក្រីក្រ ។

*យើងបានបង្កើតសមាគមខ្មែរ-ឥស្លាមមួយនៅទីនេះ ។ អ្វីដែលសមាគមយើងធ្វើ គឺដើម្បីធានាថា សមាជិកសហគមខ្មែរ-ឥស្លាម មានសុខុមាលភាពល្អ និងរួចផុតពីភាពក្រីក្រ ។ យើងក៏រកថវិកាសំរាប់សាងសង់ និងថែរក្សាសាលារៀនខ្មែរ-ឥស្លាម សំរាប់ការសិក្សាអប់រំ និងការប្រៀនប្រដៅរបស់សាសនាឥស្លាម ។*

អ្នកចូលរួមនៅក្នុងក្រុមគោលដៅសំរាប់ការពិភាក្សា ក្នុងភូមិអន្លង់សណ្តាន់ ខេត្តបាត់ដំបង បានពណ៌នាការងាររបស់ក្រុមកសិករមូលដ្ឋានរបស់ពួកគាត់ ដែលទំនងជាធ្វើការសំរាប់ការអភិវឌ្ឍន៏មូលដ្ឋានថា :

*យើងមានសមាគមអ្នកភូមិនៅក្នុងភូមិរបស់យើង ។ ការងារភាគច្រើនដែលសមាគមធ្វើ គឺកៀងគរធនធានមូលដ្ឋានសំរាប់ការសាងសង់ និងថែរក្សាស្ពាន និងផ្លូវលំ និងសាលាឆទានសំរាប់អ្នកធ្វើដំណើរ ។*

យើងនឹងដកស្រងអត្ថបទ ពីការពិភាក្សាជាមួយនឹងអ្នកចូលរួមនៅក្នុងក្រុមគោលដៅសំរាប់ការពិភាក្សា ដែលមកពីមជ្ឈដ្ឋានផ្សេងៗ ។ អ្នកចូលរួមក្នុងក្រុមគោលដៅសំរាប់ការពិភាក្សា នៅភូមិឈើទាល ខេត្តកំពង់ចាម បានប្រាប់អំពីការងាររបស់គណៈកម្មការអភិវឌ្ឍន៏ភូមិថា :

*គណៈកម្មការអភិវឌ្ឍន៏ភូមិ កៀងគរកំលាំងពលកម្មមូលដ្ឋាន និងវិភាគទាជាលុយសំរាប់ថែទាំបណ្តាញផ្លូវថ្នល់ភូមិ និងសាលារៀន ។*

នៅភូមិទួលស្វាយព្រៃ អ្នកចូលរួមក្នុងក្រុមគោលដៅសំរាប់ការពិភាក្សា បានប្រាប់អំពីការងារខុសគ្នាដែលធ្វើដោយគណៈកម្មការអភិវឌ្ឍន៏ភូមិរបស់ពួគគាត់ថា :

*គណៈកម្មការអភិវឌ្ឍន៏ភូមិរបស់យើង បានរៀបចំគំរោងឥណទានខ្លះៗ ដែលទាក់ទងនឹងលុយ និងសត្វពាហនៈ ។ ពួកគេគ្រប់គ្រងលុយ និងគំរោងឥណទានដែលយកអត្រាការប្រាក់ទាបពីអ្នកខ្ចីនៅក្នុងមូលដ្ឋាន ហើយពួកគេគ្រប់គ្រង និងថែរក្សាធនាគារគោក្របី ។*

យោងតាមអ្នកចូលរួមក្នុងក្រុមគោលដៅសំរាប់ការពិភាក្សា នៅភូមិគ្រាំងអំពិល ខេត្តកំពត បានលើកឡើងថា :

*"គណៈកម្មការអភិវឌ្ឍន៏ភូមិរបស់គាត់ ធ្វើការងារយ៉ាងជិតស្និតជាមួយនឹងកម្មវិធីសិលារបស់រាជរដ្ឋាភិបាល ។ សមាជិកគណៈកម្មការអភិវឌ្ឍន៏ភូមិ ត្រួតពិនិត្យ និងមើលខុសត្រូវការសាងសង់ស្ពាននៅក្នុងមូលដ្ឋាន និងហេដ្ឋារចនាសម្ព័ន្ធដ៏ដៃទៀត ដែលផ្តល់ឥណទានដោយកម្មវិធីសិលា"* ។

អ្នកភូមិអូរជ្រៅ ខេត្តកោះកុង ដែលបានចូលរួមក្នុងក្រុមគោលដៅសំរាប់ការពិភាក្សា បានពន្យល់យ៉ាងក្បោះក្បាយអំពីការងាររបស់គណៈកម្មការអភិវឌ្ឍន៍ភូមិថា :

*គណៈកម្មការអភិវឌ្ឍន៍ភូមិ រៀបចំបង្កើតផែនការអភិវឌ្ឍន៍មូលដ្ឋានជាមួយអ្នកភូមិ ។ នៅក្នុងផែនការតំរូវការជាអាទិភាពរបស់អ្នកភូមិ ត្រូវបានកំណត់ ។ អាទិភាពទាំងនេះ រួមមាន អណ្តូងស្នប់ប្រើដោយដៃ ផ្លូវលំ គំរោងឥណទាន ធនាគារគោ និងប៉ុស្តិ៍សុខភាព និងសេវាកម្មថែទាំសុខភាព ។*

នៅភូមិដំណាក់ចិន ខេត្តព្រះវិហារ អ្នកចូលរួមនៅក្នុងក្រុមគោលដៅសំរាប់ការពិភាក្សា បានចង្អុលអោយឃើញការងារប្រហាក់ប្រហែលគ្នា ដែលធ្វើឡើងដោយគណៈកម្មការអភិវឌ្ឍន៍ភូមិរបស់ពួកគាត់ថា :

*គណៈកម្មការអភិវឌ្ឍន៍ភូមិត្រូវបានបង្កើតឡើង ។ គណៈកម្មការនេះមានសមាជិក៥នាក់ រាប់បញ្ចូលទាំងស្ត្រីម្នាក់ផង ។ សមាជិកគណៈកម្មការអភិវឌ្ឍន៍ភូមិ ធ្វើការជាទូទៅជាមួយកម្មវិធីសិលា ។ ពួកគាត់រៀបចំបង្កើតផែនការអភិវឌ្ឍន៍មូលដ្ឋាន ដោយអនុលោមទៅតាមតំរូវការកម្មវិធីសិលា ។*

នៅភូមិរំដេង ខេត្តស្ទឹងត្រែង ប្រជាពលរដ្ឋបានពណ៌នាការងារប្រហាក់ប្រហែលគ្នានេះដែររបស់សមាជិកគណៈកម្មការអភិវឌ្ឍន៍ភូមិរបស់ពួកគាត់ ប៉ុន្តែបន្ថែមថា ផែនការបានផ្តល់អោយទៅអង្គការមិនមែនរដ្ឋាភិបាលសំរាប់ការឧបត្ថម្ភគាំទ្រ ។

*ការងារភាគច្រើនរបស់គណៈកម្មការអភិវឌ្ឍន៍ភូមិនៅក្នុងភូមិរបស់យើង គឺរៀបចំផែនការអភិវឌ្ឍន៍មូលដ្ឋាន ដែលនឹងត្រូវដាក់ជូនអង្គការមិនមែនរដ្ឋាភិបាលសំរាប់ការគាំទ្រ ។ នៅក្នុងផែនការ អ្នកភូមិបានស្នើសុំអណ្តូងទឹក និងផ្លូវលំ ។*